ពោះពុម្ពលើកទី៣

ក្នុងល្វែងមានរស្មី

ជីវិតបុគ្គលម្នាក់ដែលជួបការ
រំខានចិត្តរឿយៗ ហើយមិន
ចេះថែរក្សាចិត្តឱ្យបានល្អទេ
ក៏អាចទទួលឥទ្ធិពលបញ្ហានោះ
ឱ្យក្លាយទៅជា ប្រែប្រួលចរិត
ឥរិយាបថបាន ដូចជាសត្វ
សុនខដែលនៅក្នុងចំណងឬ
ឃ្លីមាត់តែងតែកាចសាហាវ
ជាងសុនខដោះលែងឱ្យមាន
សេរីភាពជាធម្មតា ។

វេជ្ជបណ្ឌិត ថោង នីដាមុនី

៣.ស. ២៥៦៣

អារម្ភកថា

ចំណងជើងសៀវភៅនេះមានឈ្មោះថា **ក្នុងល្វឹងមាសរសផ្អែម** ដែលបានសរសេរឡើងសៀវភៅលើកទី ១០ ដែលក្នុងគោលបំណងតែមួយគត់គឺ **ចែកជាធម្មទាន**។

ចំណីអារម្មណ៍ គតិអបរំ ទស្សនវិជ្ជាមហាជន ដែលមានក្នុងសៀវភៅនេះ ត្រូវបានរៀបចំចងក្រឡឹង គឺដើម្បីបម្រើអារម្មណ៍របស់មិត្តអ្នកអានទាំងអស់។ ការពិត មិនមានអ្នកណាអាចជៀសរួចនោះទេ មានតែការចេះព្រមនឹងអ្វីដែលកើតឡើងចំពោះយើងប្រចាំថ្ងៃ ហើយព្យាយាមរកដោះដំណោះស្រាយវាឱ្យបានល្អ ទើបជីវិតមានសេចក្តីសុខ។

សូមអភ័យទោសចំពោះការប្រើប្រាស់គ្រាមភាសា ព្រោះជាពាក្យមហាជនសុទ្ធសាធ ដើម្បីកុំឱ្យមានសំណើចនេះឥតន័យសោះ ខ្ញុំព្រះករុណាបានបញ្ចូលសំណួរចម្លើយស្តីពីសុខភាព គ្រាន់ជាប្រយោជន៍បានឆ្លុះបញ្ចាំងពីទង្វើផ្សេងៗក្នុងការរស់នៅរបស់យើងផង។ សូមឧទ្ទិសសៀវភៅនេះជូនដល់អ្នកចូលចិត្តអាន និងចង់ដឹងពីបញ្ហាសុខភាព ក៏ដូចជាការរស់នៅប្រចាំថ្ងៃ។

ភ្នំពេញ ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកសក ព.ស ២៥៦៣

ភេទ្ធបណ្ឌិត ថោច នីជាមុនី

សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណា សូមថ្លែងអំណរគុណ និងអរគុណចំពោះឧបាសក ឧបាសិកា យ៉ាងជ្រាលជ្រៅដែលបានលះបង់ពេលវេលាដ៏មានតម្លៃ កម្លាំងកាយ កម្លាំងចិត្ត ព្រមទាំងប្រាក់កាក់មួយចំនួនចូលរួមដើម្បីបោះពុម្ពសៀវភៅនេះឡើង។

ចំពោះសៀវភៅដែលបានចងក្រងនេះដែរ បើសិនជាប្រិយមិត្តអ្នកអានទាំងអស់ឃើញមានកំហុសឆ្គង ឬចំណុចខ្វះខាត សូមមេត្តាផ្តល់ដំណឹងមកខ្ញុំព្រះករុណាតាមរយៈលេខទូរស័ព្ទខាងក្រោម ដោយសេចក្តីអនុគ្រោះផងចុះ។ ដូច្នេះនៅពេលក្រោយខ្ញុំព្រះករុណាអាចទទួលបាននូវការរៀបរៀងឲ្យកាន់តែល្អប្រសើរឡើង។

(+855) 012 782 550 (វេជ្ជបណ្ឌិត ថោង នីដាមុនី)

Facebook: Thong Nidamony

(+855) 010 335 854 (សុះ កុសល)

Facebook: Kosal Sos

Facebook Page: **សាលាធម្មសនាចំការត្របែក**

<u>រាយនាមអ្នកមានឧបការៈក្នុងធម្មទាន</u>

❖ អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធ

វេជ្ជបណ្ឌិត ថោង នីដាមុនី

សុះ កុសល

❖ កែសម្រួល នឹង រាយអត្ថបទ

សុះ កុសល

សាន សុធា

❖ ផ្នែកបច្ចេកទេសកុំព្យូទ័រ

សុះ កុសល

ចំណាក់ចំនង

Facebook Page: សាលាធម្មសភាចំការត្របែក។

ដើម្បីបានសៀវភៅ ឬចូលរួមជាបច្ច័យសម្រាប់បោះពុម្ព
សៀវភៅបន្ទាប់។

- ទីតាំង សាលាធម្មសភាចំការត្របែក ស្ថិតនៅតាមបណ្តោយ
ផ្លូវ៦០ម៉ែត្រ (ព្រែកហូរ) រាជធានីភ្នំពេញ។ទំនាក់ទំនងតាមរ
យៈ:

វេជ្ជបណ្ឌិត ថោងនីដាមុនី	012 782 550
ឧបាសក ចាន់ កុកស្រ៊ុន	016 815 308
សុះ កុសល	010 335 854

**សាលាធម្មសភាចំការត្របែក មានបង្រៀនព្រះធម៌ និង
ដោះស្រាយបញ្ហាផ្លូវចិត្ត រាល់ថ្ងៃសៅរ៍
ចាប់ពីម៉ោង ៨:00ព្រឹក រហូតដល់ម៉ោង ៤:00 ល្ងាច
(មានសមាធិ ១ម៉ោង)**

ជាំងៗ ប្រាវៗ នៃវ៉ើយ ក្នុងផ្ទះហ្នឹង អាណាមេអាណាកោយ? អញ អ្នកខំរកលុយធ្វើការត្រាក់ៗ ញើសហូរជាឈាមចិញ្ចឹមក្បាលឲ្យស៊ីរស់គ្រប់គ្នា ប៉ុណ្ណឹងហើយនៅមកចង់ខ្លាំងដាក់អញទៀតវ៉ើយ។ រឿងហ្នឹងខ្ញុំដឹងហើយលោកប្តី តែបើឯងចិញ្ចឹមឲ្យអញស៊ីរស់ដូចសត្វធាតុក៏អញមិនទ្រាំតស៊ូទៀតដែរ កូនក្មួយគាត់ឯងដេកស៊ីពេញផ្ទះ ណាថ្លៃទឹក ថ្លៃភ្លើង ម្ហូប ថ្លៃបង់សាលាកូន សព្វគ្រប់បែបយ៉ាង ចំណែកខ្លួនឯងដើរផឹកស៊ីស្រីញីអូនបង ឲ្យមីអូនស៊ីសៀងមីនាងស៊ីស៊ុប ស្រវឹងជោកពាក់កណ្តាលអាធ្រាត្របានត្បុលក្បាលចូលមុង បើតែយ៉ាងៗហ្នឹងអញទ្រាំមិនបានទេ ចង់ទៅជាស្លឹកក៏ទៅចុះ។ បើនៅតែចចេសរករឿងអញ តិចថូផ្តាឡើងក្បាលវ៉ើយ។ ហ្នឹងហើយ! អញខំស៊ីបាយរាល់ថ្ងៃគឺទុកក្បាលឱ្យឯងសំពងលេងទេតើ? ព្រោះអញអត់ដែតទេ មើលមីហ្នឹងវាមាត់រឹង កុំចាប់ប៉ា អាដេតទុកឲ្យប៉ាទះមាត់វាឲ្យចេញឈាមមើល។ កុំប៉ា! ឈប់ទៅៗ យប់ជ្រៅណាស់ហើយខ្មាស់គេ។ លែងអញខ្ចែត ទុកឲ្យអញព្រលះអាបុហ្នឹងឲ្យចាស់ដៃម្តង យប់ហ្នឹងម៉េចក៏មានអ្នកចូលពេទ្យម្នាក់ដែរនាងឯងចាំមើលណា។ ហ្ន៎កម៉ែ! ចាំបាច់ទៅដេកពេទ្យឯណា អ៊ំពេទ្យកំពុងតែដើរមកហើយតើ? លោកគ្រូពេទ្យហែងស្រែកពីចំងាយ៖ មានការអីលោក

ប្អូនផេងហ្អើយ! ឮតែផូងផាំងពេញផ្ទះហ្នឹង នេះយប់ជ្រៅហើយណា! ពូផេងតបៈ អត់មានអីទេលោកបង ខ្ញុំចង់ប្រដៅប្រពន្ធកាកិណ្ណានេះបន្តិច វាជារឿងគ្រួសារខ្ញុំទេ។ អើ! វាជារឿងគ្រួសារឯងពិតមែន ប៉ុន្តែបើមានអំពើហឹង្សាកើតឡើងនោះ អ្នកជិតខាងមានសិទ្ធិប្តឹង នឹងជួយធ្វើអន្តរាគមន៍បានណាអានាង (មានសម្លេងឆ្លើយតបមលពីម្ខាងរបង) ។ សម្លេងបុរសចាស់អំបាញ់មិញ ហាក់មានឥទ្ធិពលមកលើគ្រួសារពូផេងមីងស៊ុមជាខ្លាំង ដោយពួកគាត់ស្ងាត់បាត់មាត់រៀងៗខ្លួនចាំស្តាប់សម្លេងនោះបន្តទៀត។ លោកតាអាចារ្យសន មានវ័យប្រមាណ៧០ឆ្លាយឆ្នាំ ដើរកោងៗចូលមកក្នុងរបង ហើយលើកដៃបាំងថ្ងាសសម្លឹងមើលទៅក្នុងផ្ទះ រួចពោលថាៈ ជីវិតសត្វរបស់លោកនៅមួយថ្ងៃលំបាកជាងមួយថ្ងៃ ម្នាក់ៗប្រឹងរកប្រឹងរស់ស្ទើរតែមិនបាន ព្រោះហេតុតែជីវិតខ្លះរហូតដល់ទៅហ៊ានកាប់សម្លាប់ ឆក់ប្លន់ លួច កុហក់ ភូតភរ ឆរបោកឥតត្រាប្រណី បានចំណេញត្រឹមតែបីដងហ៊ានកុហកបងប្អូនឯង ចំណេញ៥ដងហ៊ានកុហកម៉ែឪឯង ចំណេញ១០ដងហ៊ានសម្លាប់ជីវិតមនុស្សសព្វថ្ងៃជាមនុស្សឥតមាន **ទាន សីល ភាវនា** វិញ្ញាណទាំងឡាយចាប់កំណើតឡើងសុទ្ធតែជាវិញ្ញាណចងពៀរ តាមស៊ីសងហុតឈាមគ្នាគួរ

ឲ្យខ្លាចរអា ឯពួកឯងត្រូវមកចង់អារកគ្នាទាំងយប់ព្រោះតែហេតុអីទៅហ្ន៎? ពូផេងមីងស៊ុមពេលនេះគាត់នៅសល់ភាពជាមនុស្សខ្លះដែរ ទើបត្រូវចែកផ្លូវគ្នា ពូផេងរត់ចុះទៅសំពះសួរលោកតាសន ឯមីងស៊ុមរត់ទៅយកកន្ទេលមកក្រាលនៅរានហាលមុខផ្ទះជូនភ្ញៀវ ចំណែកប្រុសដេតនិងនាងណែតប្រញាប់ទៅលើកយកថាសប៉ាន់តែនិងពែង មកដាក់ជូនភ្ញៀវពិសា។ ក្នុងហាន:ជាចាស់ព្រឹទ្ធាចារ្យប្រកបដោយគុណភាពខាងគតិបណ្ឌិត សាសនានិងទស្សន:វិជ្ជាមហាជន លោកតាសនបានបញ្ចេញវាចាពោលរំងាប់អធិករណ៍ដោយក្តីមេត្តា ករុណា ហើយអញ្ជើញញាតិជិតខាង ដែលឆ្ពើលឆោទឡោមកដល់ជាបន្តបន្ទាប់ឲ្យអង្គុយលេង។ លោកតាសនពោល: ផ្ទះលោកក្មួយផេងឯងឥឡូវមិនសូវស្ងាត់ដូចគេឯងសោះ សូម្បីតែនៅពាក់កណ្តាលអាធ្រាត្រហើយក៏ដោយ ម្តងៗអញស្មានតែភ្លើងឆេះផ្ទះសឹងរកហៅគេជួយពន្លត់រាល់លើក តើហេតុវាចេះតែយ៉ាងម៉េចហ្ន៎:? មីងស៊ុម ពោលកាត់មុន: កាលនៅអត់លុយមិនទាន់ចេះបែកគំនិតទេអ៊ំ ដល់មកមានលុយប្រឹសៗលោតែចេះដើរស៊ីធឹកអត់គិតផ្ទះសំបែងកូនប្រពន្ធ ខ្ញុំដល់កទ្រាំលែងបានទើបរកឈឿង។ ពូផេងគ្រហឹមតប: ហ្អឹស! ស្រីអីអត់មារយាទមិនចេះគោរពប្តីខាតល័ក្ខណ៍

បំបាក់អន្សា គ្មានស្គាល់ច្បាប់ស្រី ប្រពន្ធវាមិនកើត គ្មានរបៀបរៀបរយ គ្មានសណ្តាប់ធ្នាប់អញ្ចុញថប់ណាស់ បានចេះតែដើរលេងធឹកស៊ីឲ្យ បានធូរទ្រូងខ្លះ។ លោកតាសនស្មានដឹងមុនថាតែបណ្តោយឲ្យប្រកែក គ្នាយូរទៀត កំហឹងនឹងផ្ទុះសារជាថ្មី ទើបមានប្រសាសន៍បំបែកយោបល់ ៖ ហឺស! ផេងអើយ រឿងស្នេហានេះគឺដូចជាគេស៊ីអំពៅពីគល់ទៅចុងផ្អែមតែពីតំបូងស៊ីយូរទៅសាបទៅៗ ប៉ុន្តែបណ្ឌិតទាំងឡាយគេចេះផ្លាស់ប្តូរពីចិត្តដែលសាបនោះឲ្យទៅជាចិត្តមេត្តាករុណាវិញ។ តណ្ហា គឺជាធម្មជាតិនៃចិត្តដែលមិនចេះឆ្អែតម្តងណាឡើយ កាត់តែគិតកាន់តែចង់ដើម្បីឲ្យឆ្អែតគឺមានតែឈប់តែប៉ុណ្ណោះ។ បើឯងមានចិត្តអាសូរដល់ប្រពន្ធកូនជាពិសេសកិត្តិយសកូន ក៏គួរល្មមឈប់ប្រព្រឹត្តទៅទៀត ព្រោះនេះជាទោសក្នុងបច្ចុប្បន្ន និងទោសក្នុងបរលោកដែលមានកំណើតតែក្នុងនរក និងតិរច្ឆានតែប៉ុណ្ណោះ។ រាគតណ្ហាធ្វើឲ្យជីវិតបិតក្នុងក្តីស្រវឹង ព្រោះត្រូវស្រវឹងក្នុងវ័យ ស្រវឹងក្នុងភាពភ្លើតភ្លើនស្រើបស្រាល ស្រវឹងថាទៀងជាសុខ ស្រវឹងថាមានខ្លួនមានខ្លឹមសារ ស្រវឹងភ្លេចជាតិ **ជរា ព្យាធិ មរណៈ** ពេលខ្លះខ្លាចការពិតក្នុងជីវិតរស់នៅប្រចាំថ្ងៃ មិនហ៊ានប្រឈមមុខនិងសច្ចៈធម៌ ក៏ទៅពួនសំងំនៅពីក្រោយដបស្រា ហើយយកសន្លឹក

បៀរធ្វើជាផ្លិតបិទបាំងការពិត គេចដៀសពីវិបាករបស់កម្មខ្លួនឯង តើធ្វើនេះសមជាមេគ្រួសារឬទេហ្ន៎? តាមពិតអ៊ំចាស់ជិតចូលរណ្តៅទៅហើយ ពុំគួរអើមកខ្វល់នឹងរឿងក្មេងៗទេ ប៉ុន្តែសល់បទពិសោធន៍ជីវិតខ្លះក៏ចេះតែស្តីប្រដៅគេឯងអញ្ចឹងទៅ ព្រោះចង់ឲ្យគេល្អ គេសុខ។ ជីវសាស្ត្ររបស់មនុស្សប្រុសនេះណា សឹងតែជាទូទៅគឺច្រើនតែធ្លាក់ចុះកាន់តំរេកជាងមនុស្សស្រី នេះជាធម្មជាតិ។ ពិតហើយអ៊ំ! ព្រោះមនុស្សប្រុស៧២ម៉ោង ក្រោយពីស្លាប់ទៅពងស្វាសនៅតែផលិតមេជីវិតនៅឡើយទេ (ពេទ្យហេងលូកមាត់បន្ទរ) សូម្បីតែអាយុ៧០ឆ្នាំហើយ ពងស្វាសនៅតែផលិតទឹកកាមដែរ។ ស្ងាត់មួយស្របក់លោកតាសនក៏និយាយបន្តៈ មនុស្សប្រុសចូលដល់មជ្ឈឹមវ័យគេចែកជាបីក្រុមគឺ **១ក្រុមគិតថា** មុននឹងលាចាកលោកនេះទៅ ត្រូវបន្សល់សេចក្តីល្អឲ្យមនុស្សជំនាន់ក្រោយ ត្រូវធ្វើជាគំរូល្អ ជាបុព្វការីជនដ៏ឧត្តមសម្រាប់ជាតិមនុស្សបែបនេះបើបានក្លាយជាមេដឹកនាំ គឺជាសំណាងរបស់រាស្ត្រណាស់។ **ក្រុមទី២** គិតថាជីវិតតែកាលណាស្លាប់ទៅ គឺក្លាយជាផេះជាចំណីរភ្លើងចំណីជន្លេនហើយ វាគ្មានកើតទៅណាទេ ខ្មោចងាប់គឺដូចជាខ្មោចត្រីអាំងអញ្ចឹងដែរ ស្លាប់ទៅហើមប៉ោងស្អុយដូចខ្មោចឆ្កែ ខ្មោចកណ្តុរ ខ្មោចអ្នកមានក៏ដូច

ជាខ្មោចអ្នកក្រ។ ស្លាប់ទៅខានបានសប្បាយហើយ ហេតុនេះទាន់ពេលនៅរស់ត្រូវសប្បាយឲ្យអស់ចិត្តយិតឲ្យអស់ចង់ ពួយឲ្យណាណីទៅដណ្តើមការសប្បាយគ្នាទល់ថ្ងៃស្លាប់។ **ក្រុមទី៣** ជាក្រុមនិយមថា ចង់អ្នកណាគេធ្វើអីក៏មិនខ្វល់ដែរ។ ផេងហ្អើយ! តើឯងចង់ធ្វើជាបុរសប្រភេទណា? ព្រះពុទ្ធទ្រង់ទូន្មានថា **ស្វាមីត្រូវអនុគ្រោះភរិយាដោយស្ថាន៥យ៉ាងគឺ**

១- មានសេចក្តីរាប់អានដោយសំដីទន់ផ្អែម

២- ដោយការមិនបៀតបៀនមើលងាយមើលថោក

៣- ដោយមិនប្រព្រឹត្តិកន្លងចិត្តភរិយា មានសហាយស្មន់ ផិតក្បត់ជាដើម

៤- ដោយការប្រគល់ឲ្យនៅឥស្សរិយយស លើកតម្កើងសិទ្ធិសេរីភាពក្នុងសេចក្តីថ្លៃថ្នូរសមរម្យ

៥- ផ្តត់ផ្គង់គ្រឿងប្រដាប់តាក់តែងកាយ និងសំលៀកបំពាក់ឲ្យបានសមរម្យ

ឯភរិយា ត្រូវប្រតិបត្តិស្វាមីដោយស្ថាន៥យ៉ាងគឺ

១- ចាត់ចែងការងារផ្ទះសំបែងដោយផ្ចិតផ្ចង់

២- សង្គ្រោះដល់ញាតិរបស់ស្វាមី និងញាតិរបស់ខ្លួនដោយស្មោះស្ម្មើ

៣- ថែទាំទ្រព្យសម្បត្តិដែលស្វាមីរកបានមកហើយកុំឲ្យបាត់បង់

៤- មិនប្រព្រឹត្តិកន្លងចិត្តស្វាមីដោយការសហាយស្មន់និងផិតក្បត់

៥- ឆ្លាតប្រសប់ក្នុងការតាមដានអប់រំកូនព្រមទាំងមិនខ្ជិលច្រអូសក្នុងកិច្ចការគ្រប់យ៉ាង។

ហើយភរិយានេះបើតាមចរិយាមារយាទ ព្រះលោកចាត់ជា៧ពួកគឺ

១- ភរិយាប្រាកដស្មើដោយអ្នកសម្លាប់

២- ភរិយាប្រាកដស្មើដោយមាតា

៣- ភរិយាប្រាកដស្មើដោយចោរ

៤- ភរិយាប្រាកដស្មើដោយមិត្តសំឡាញ់

៥- ភរិយាប្រាកដស្មើដោយម្ចាស់ ធ្វើចៅហ្វាយប្តី

៦- ភរិយាប្រាកដស្មើដោយខ្ញុំស្រី

៧- ភរិយាប្រាកដស្មើដោយប្អូនស្រី

តើនាងស៊ុមឯងចង់ធ្វើភរិយាបែបណាមួយដែរ? ប្តីប្រពន្ធឯងមានការប្រតិបត្តិចំពោះគ្នាដូចម្តេចដែរ? តទៅនេះអំប្រាប់ពីរបៀបផ្ទាញ់ក្រោធដល់ពួកឯងម្ប៉ាងដោយ **អធិវាសនខន្តី** គឺសេចក្តីអត់ធ្មត់រំងាប់ក្តីក្រោធដែលព្រះសម្មាសម្ពុទ្ធបានបង្រៀន គឺជាខន្តីប្រកបដោយបញ្ញា មិនមែនខន្តីអត់ខាំធ្មេញក្តាប់ដៃញ៉ែរខ្លួនទទ្រើកនោះទេ ខន្តីរបៀបនេះគឺដូចជាការគំរាមឲ្យខ្លាក្រាបតែប៉ុណ្ណោះ វារងចាំតែឱកាសល្អមកដល់ កលោតសង្គ្រប់ចាប់ហែកក្រញីស៊ីតាមកំហឹងវាជាមិនខាន ខន្តីដែលព្រះពុទ្ធទ្រង់បង្រៀន គឺប្រកបដោយបញ្ញាយល់ហេតុ និងផលរបស់កំហឹងរក្សាអធ្យាស្រ័យល្អ ព្រោះឃើញសភាពមិនទៀតជាទុក្ខនិងករុណាណាស់ ព្រោះជាអ្នករួមចាស់ រួមឈឺ រួមស្លាប់ជាមួយគ្នា។ គ្នាកំពុងមានកំហឹង គឺចិត្តកំពុងតែឆេះក្តីឱបដើមចេកស្លោក ព្រោះទោសៈចុះក្នុងអត្តភាពដុតកម្លោចគ្នាកំពុងរងទុក្ខ ព្រោះមិនបានអប់រំ យើងស្តាប់ឮហើយ កុំទៅពិចារណានាំតែឈឺចាប់ចិត្តឥតប្រយោជន៍សម្លេងមានមកមួលក្តិច ឬចាក់ដោតឲ្យយើងឈឺចាប់ឯណា បើយើងទាស់នឹងសម្លេង យើងរក្សា

ចិត្តកុំឲ្យចាប់សម្លេងមកត្រិះរិះជាអារម្មណ៍មិនល្អឲ្យខ្លួនឯង ប៉ុណ្ណឹងទៅបានហើយ។ ក្មួយផេងក៏អញ្ចឹង បើឯងទាស់នឹងសម្លេងម៉េចមិនវាយសម្លេង? ពូផេងខាននិយាយយូរមកហើយក៏តបថា៖ ខ្ញុំវាយប្រភពសម្លេងហ្នឹងណាពូ សម្លេងចេញពីស្គរ បើមិនពុះបំបែកស្គរចោលឲ្យខ្ញុំពុះស្អីវិញ ដើម្បីឲ្យបាត់សម្លេងស្រកៀរត្រចៀកនោះ? គ្មានអ្នកណាថ្លង់ជាងអ្នកដែលមិនចង់ឮទេ។ អើ! សម្លេងខ្ញុំវាសុទ្ធតែស្រកៀរត្រចៀកហើយទាល់តែសម្លេងធុងបាស់ក្នុងក្លឹបបារ ចង់រហែកក្រដាស់ត្រចៀកបានលែងស្រកៀរ (មីងស៊ុមខំស្រែកត) ។ អើៗបានហើយចាំស្តាប់ទៀតសិនក្រៅពីខន្តីព្រះលោកមានវិធីទប់ក្តីក្រោធ៤យ៉ាងទៀត ល្មមនឹងជ្រើសយកមកប្រើដើម្បីថែរក្សាចិត្តបាន ព្រោះដើម្បីឲ្យជីវិតមនុស្សរស់បានក្តីសុខគ្រប់ៗគ្នាមកនេះ ម្នាក់ៗគឺសុទ្ធតែមានទស្សនៈវិជ្ជាផ្ទាល់ខ្លួនសម្រាប់រំពឹងត្រិះរិះគន់គិតពិចារណា ដោះស្រាយបញ្ហាជីវិត ព្រោះបញ្ញាដែលចេះដោះទុក្ខចេញពីចិត្តគឺជាបញ្ញាដ៏ឧត្តម ហើយបញ្ញានេះរកមិនបាននៅក្រៅព្រះពុទ្ធសាសនាឡើយ។ ខ្វះអីសញ្ញាប័ត្រផ្លូវលោក ម៉ាគរគោកតែមិនចេះដឹកនាំខ្លួនឯងឲ្យឈ្នះ **រាគៈ ទោសៈ មោហៈ**បាន។ ផ្ទះក្មួយផេងឯងតាមអញធ្លាប់ឃើញពេញម៉ាជញ្ជាំងខាងកើតផ្ទះ អញឃើញដាក់

តាំងសុទ្ធតែសញ្ញាប័ត្រក្នុង និងក្រៅប្រទេសតែមកត្រូវរស់ក្រោមតណ្ហា បញ្ចេញឫកមនុស្សអត់ធម្មសញ្ញា យារដៃចង់ទះតប់ប្រពន្ធកូននឹងគេដែរនេះ។ សញ្ញាប័ត្រមនុស្សខុសពីសញ្ញាប័ត្រព្រះ សញ្ញាប័ត្រមនុស្សដូចជាគ្រូពេទ្យខ្លះចេញមកពីសាលាវិញ បានត្រឹមម៉ាសញ្ញាប័ត្រជាឃាតករប៉ូលិសខ្លះបានត្រឹមម៉ាចេះសម្លុតគម្រាមគំហែងគេ តុលាការខ្លះរៀនបានត្រឹមសញ្ញាប័ត្រភូតកុហក បោកប្រាស់អ្នកក្រីក្រយ៉ាងនេះជាដើម។ ផ្តើមចេញពីការសិក្សារលើចិត្តអារម្មណ៍ខ្លួនឯង ព្រះលោកប្រទានសញ្ញាប័ត្រដល់បរិស័ទ ៨ពួកដែលព្យាយាមលះបាបអកុសលពីក្នុងចិត្តសន្តានឲ្យបានជាសន្តិបុគ្គល គួរដល់នូវការធ្វើអញ្ជលីកម្មយ៉ាងក្រៃលែង ពួកលោកមានវិធីផ្ចាញ់ក្រោធដល់ទៅ៤យ៉ាង៖

១- រំងាប់ក្តីក្រោធដោយមិនក្រោធតប

២- ផ្ចាញ់ក្រោធដោយសេចក្តីល្អ

៣- ផ្ចាញ់ក្រោធដោយក្តីមេត្តា ករុណា

៤- ផ្ចាញ់ក្រោធដោយការពោលពាក្យពិត និងវាចាទន់ភ្លន់។

ផែង! ហើយហេតុជាប្រធាននៃសេចក្តីវិនាសមាន៤យ៉ាង៖

១- ជាអ្នកលេងស្រី

២- ជាអ្នកសេពសុរា

៣- លេងល្បែងពាលា ល្បែងភ្នាល់ដាក់លុយកាក់

៤- សេពគប់មនុស្សអាក្រក់ជាមិត្ត។

ឯធម្មជាតិមិនចេះឆ្អែតនោះមាន ៣យ៉ាងគឺ

១- ការដេក

២- ការសេពគប់គ្រឿងញៀនស្រវឹង

៣- ការសេពកាមទាំងអស់កាន់តែសេពគឺកាន់តែញៀន ។

អាពីរខាងក្រោយនេះ ចង់ឆ្អែតគឺទាល់តែឈប់។ អើ! បើនិយាយពីហេតុនិងផលរបស់ទោសៈវិញ ព្រះពុទ្ធលោកពន្យល់គួរឲ្យជ្រះថ្លាណាស់ មើលចុះអញឲ្យតែនិយាយពីពុទ្ធដីកា អញព្រឺស្បែក ព្រឺក្បាលប៉ុនកញ្ចឹល្អឺ អស្ចារ្យនឹងព្រះបញ្ញាញាណរបស់ព្រះពុទ្ធនេះក្រៃលែងណាស់ ហេតុនាំឲ្យកើតកំហឹងព្រះលោកពន្យល់ថាមកពី **ទិដ្ឋិ មានៈ តណ្ហា និង ឧបាទាន** នេះឯង។ **ទិដ្ឋិ** គឺចចេសរឹងរូសថាខ្លួនល្អលើសគេ ខ្លួនស្មើគេ

ខ្លួនអន់ជាងគេ តណ្ហាការប្រាថ្នាមិនចេះឆ្អែត ឱ្យតែអ្នកណាហ៊ានប្រឆាំងនឹងផលប្រយោជន៍ខ្លួន ក៏ខឹងតូងឡើងឧបាទានការប្រកាន់មាំ ឱ្យតែមានធម៌ទាំងនេះហើយរមែងមានកំហឹងកើតឡើងហើយ។ មនុស្សយើងរស់ជាមួយចិត្ត តែមិនដឹងចិត្តខ្លួនឯងយ៉ាងម៉េចទេ ខ្លះមិនដឹងទល់ថ្ងៃស្លាប់ទៀតផងក៏មាន ចិត្តដែលធម្មជាតិផ្តល់ឱ្យមានល្អ មានអាក្រក់ ប៉ុន្តែឱ្យតែមានបញ្ហាមិនបានយកចិត្តល្អមកដោះស្រាយទេ ប្រើតែចិត្តអាក្រក់ឲ្យដោះស្រាយ ទើបបញ្ហារកច្រកចេញមិនរួច។ ស្មានតែប្រើចិត្តអាក្រក់នោះអាចស្វែងរកទីបញ្ចប់នៃបញ្ហាបានឬ? នេះមកតែពីមិនបានអប់រំថែទាំចិត្ត ចេះថែទាំតែកាយទោះជាក្រណាត់មួយម៉ែត្រថ្លៃ ២០០ដុល្លារ ក៏ទិញយកឱ្យកាយស្លៀកដណ្តប់ដែរ ស្បែកជើង១គូរ១០០ដុល្លារ ២០០ដុល្លារ ចិញ្ចៀនខ្សែកសព្វគ្រប់បែបយ៉ាងខំតាក់តែងឱ្យកាយ ឯចិត្តវិញចង់ខឹងក៏ខឹង ចង់មួរម៉ៅក្តៅក្រហាយយ៉ាងណាក៏ចេះតែពួយតាមទំនើង ព្រោះមិនទាន់ដល់ថ្ងៃវាកើតវិបល្លាស ចាំដល់ថ្ងៃវិកលចរិតមកដល់គឺហួសពេលអស់ហើយត្រៀមចាំតែយកកំណើតនៅនរក ប្រេត តិរច្ឆាន និងអសុរកាយឱ្យហើយទៅ មិនថាអញ្ចឹងឬលោកបងពេទ្យហែង? បាទច្បាស់មែនហើយអំ (ពេទ្យហែងបន្ត) តាមពិតជីវិតមនុស្សគឺបិតនៅ

ក្រោមឥទ្ធិពលសេដ្ឋកិច្ច នយោបាយ បាតុភូតជីវៈគីមី និងអ័រម៉ូន បរិយាកាសសង្គមគ្រួសារនិងរបបអាហារ។ ចរិតឬកពារ បុគ្គលិកលក្ខណៈ និងអំពើតាមកាយវាចាចិត្តរបស់មនុស្សសុទ្ធតែទទួលរងដោយអន្តរអំពើពីខាងក្រៅ និងខាងក្នុងទាំងអស់។ ហើយឥទ្ធិពលទាំងអស់នោះមានអំពើដោយផ្ទាល់ ឬមិនផ្ទាល់ទៅលើគួរសរសៃប្រសាទសុាំប៉ាទិច (បសាទរូបធំ) និងប៉ារ៉ាសុាំប៉ាទិច (បសាទរូបតូច) ការគិតច្រើនព្រួយចិត្ត ខ្វល់ខ្វាយ កង្វល់ តប់ប្រមល់ទល់ពុទ្ធោ ការនឹកគិតត្រិះរិះមិនល្អទៅលើកាមតណ្ហា ការចង្អៀតចង្អល់ចិត្តព្រោះក្តីកំណាញ់ច្រណែន ឬស្យា ការរំជួលចិត្តព្រោះលោកធម៌ពាល់ត្រូវ រំជួលចិត្តដោយការបានលាភបាត់លាភ បានយសបាត់យស ជួបសុខជួបទុក្ខ ស្រលាញ់ស្អប់ សរសើរនិន្ទា ការរំជួលចិត្តងាយៗយ៉ាងនេះ គឺនាំឱ្យមានការភ្ញោចទៅលើប្រព័ន្ធប្រសាទសុាំប៉ាទិច ដែលនាំឱ្យកើតមានបាតុភូតតាមផ្លូវចិត្តអារម្មណ៍ ធ្វើឱ្យដេកមិនលក់ បាយមិនបានព្រោះគិតច្រើន នាំឱ្យឆ្អែតចិត្តលែងឃ្លានបាយ កាយស៊ីបាយចិត្តស៊ីអារម្មណ៍ មួរម៉ៅឆាប់ខឹង មានការគិតតៗគ្នាជាប់មិនដាច់ (ទោះបីចាំឈប់គិតក៏ចរន្តនៃការគិតនៅតែផុសចេញមកឱ្យគិត) ឬមានការគិតដាច់រយៈកំពុងគិតៗស្រាប់តែរលត់ឈឹង

មិនដឹងថាកំពុងគិតអី ឱ្យមានការគិតរវើរាយចង់និយាយតែឯង បើគ្មានមធ្យោបាយរំងាប់ការគិតទេក៏ក្លាយជាមនុស្សវិកលចរិក រលត់ពន្លឺរស្មីជីវិតអស់មួយអត្តភាពទទេ។ បាតុភាពលើរាងកាយចំពោះគ្រាប់ភ្នែកការខឹងច្រើន នាំឱ្យរីកកូនក្រមុំភ្នែករហូតដល់ដក់ទឹកក្នុងភ្នែកឲ្យសួតមាត់សួតក ទងសួតរីកយ៉ាងគំហុកនាំឱ្យដូចជាបាត់ខ្យល់ដង្ហើមត្រដរកខ្យល់ បែកញើសស្អិតលើថ្ងាសនិងកញ្ចឹងក ត្រជាក់ចុងដៃចុងជើង ញ័រទ្រូងបេះដូងដើរញាប់ សរសៃឈាមរួម នាំឱ្យលើសសម្ពាធឈាម (អាចដាច់សរសៃឈាមក្នុងខួរក្បាល) ឱ្យជាតិស្ករលើសក្នុងឈាម (បាត់លំនឹងជាតិស្ករក្នុងជំងឺទឹកនោមផ្អែម) ឬជាតិស្ករចុះមានការប្រែប្រួលជាតិកាល់ស្យូម សូដ្យូម ប៉ូតាស្យូម នាំឱ្យទល់លាមក។ រំញោចការគិតនាំឱ្យសរសៃប្រសាទសុំប៉ាទិចដើរខ្លាំង ពេលនោះសរសៃសុំប៉ាទិចត្រូវខំបង្កើតសកម្មភាពរបស់ខ្លួនទប់ទល់នឹងសកម្មភាពសុំប៉ាទិចវិញ នាំឱ្យកើតមានបាតុភូតវិលមុខ ព្រិលភ្នែកស្រវាំង ទឹកមុខមិនល្អខ្មៅជាំរស្មីភ្នែកស្រអាប់ ឬក្រហមជាំរមាស់ខ្មៅមុខ (អេះមានស្នាមជាំ) ចេញមុនច្រើនពិបាកដកដង្ហើមព្រោះត្បៀតទងសួត (ឧស្សាហ៍ដកដង្ហើមធំ តឹងណែនចប់ក្នុងទ្រូង) បេះដូងដើរយឺតនឹងរីកសរសៃឈាមនាំឱ្យចុះសម្ពាធឈាម

ងាយវិលមុខដួល ឱ្យអាស៊ីតក្រពះចេញខ្លាំងនាំឱ្យរលាកក្រពះ រលាកពោះវៀន រាកអាចម៍ ឈឺសន្លាក់ដៃជើងចុកចាប់សាច់ដុំ តឹងណែនរោយកញ្ឆឹងក ចុករោយសាច់ដុំមុខ ធ្វើឱ្យធ្ងន់ធ្ងរដល់ជំងឺ រ៉ាំរ៉ៃព្រោះតែការគិតច្រើន ដូចជាជំងឺទឹកនោមផ្អែម ខ្សោយថ្លើម ខ្សោយបេះដូង តម្រងនោមជំងឺទាក់ទងនឹងប្រព័ន្ធប្រសាទភាពស៊ាំដូចជារមាស់តាអក កើតហឺតជំងឺប្រតិកម្មស្បែក ជំងឺសន្លាក់រ៉ាំរ៉ៃ ងាយកើតមហារីក និងជំងឺឆ្លងផ្សេងៗ ការគិតច្រើនដែលនាំឱ្យកើតកំហឹង នឹងការជាប់ជំពាក់ដោយលោភៈ ធ្វើឱ្យជំងឺខាងលើនេះកាន់តែធ្ងន់ធ្ងរទៅ។ ហេតុនេះទិដ្ឋិ មានៈ តណ្ហា ឧបាទាន សុទ្ធតែជាអកុសលវិតក្កៈ ដែលមានកាមវិតក្កៈ (ការត្រិះរិះកាមក្នុងរាគៈតណ្ហា) ព្យាបាទវិតក្កៈ (ការត្រិះរិះប៉ុនប៉ងបៀតបៀន ឬត្រិះរិះឱ្យកើតការថ្នាំងថ្នាក់ចិត្តនាំឱ្យកើតកំហឹង) ឧទ្ធច្ចកុក្កុច្ចៈ (ការគិតរាយមាយឥតសណ្តាប់ធ្នាប់ ផុតរឿងមួយចូលរឿងមួយ ពេលថ្ងៃហុយដូចផេះ ពេលយប់ឆេះដូចភ្លើង លោតទាល់តែខ្សោះអស់ដៃអស់ជើង) នឹងវិចិច្ឆាការគិតសង្ស័យមិនដាច់ស្រេច ម៉្យាងអង្គុយសង្ស័យគេឯងគ្រប់គ្នា ប្តីទៅធ្វើការសោះសង្ស័យថាគេមានស្រីផិតក្បត់ខ្លួន សង្ស័យថាគេនឹងបោះបង់ចោលខ្លួន លែងរវើរវល់យកចិត្តទុកដាក់ចំពោះខ្លួនៗនឹងក្លាយ

ជាមនុស្សអស់តម្លៃ ត្រូវក្លាយជាមនុស្សឆ្លៀតដើររើសសម្រាមតាមចិញ្ចើមថ្នល់ រហូតដល់ប្រើជីវិតទាំងមូលឱ្យរស់ក្នុងក្តីសង្ស័យរហូតដល់សង្ស័យតាំងពីខ្លួនឯងបិតក្នុងសភាពស្រពិចស្រពិល ពុំច្បាស់លាស់លែងហ៊ានសម្រេច លែងធ្វើការអ្វីកើត។ បសាទរូបធំ និងបសាទរូបតូចទាំងពួងនេះបំពេញមុខងារបានល្អ ទើបជីវិតរស់នៅប្រចាំថ្ងៃប្រព្រឹត្តទៅបានជាធម្មតា ការគិតខុសរបៀបនាំឱ្យការសម្របសម្រួលរវាងសរសៃប្រសាទទាំងពីរខូចសណ្តាប់ធ្នាប់ នាំឱ្យកើតជំងឺជាច្រើនមុខ ចាប់ផ្តើមពីមនុស្សពូកែខឹង ពូកែរករឿងច្រណែនប្រច័ណ្ឌក្លាយជាមនុស្សពូកែឈឺ គឺ «ស្តេចឈឺ» ឮគេឈឺអីឯងឈឺហ្នឹងដែរគ្មានចាញ់អ្នកណាម្នាក់ឡើយ។ ឈឺអស់មួយតួរខ្លួន ឈឺថ្លើម ក្រពះ ពោះវៀន សួត បេះដូង តម្រងនោម ស្បូន ត្រចៀក ច្រមុះ បំពង់ក ពីចុកចាប់សព្វសាច់សរសៃ ឈឺអត់ហេតុផល ឡើងខ្លាញ់ ទឹកនោមសាប ទឹកនោមប្រៃ ឈឺនោះឈឺ (ទាល់តែព្រមស្លាប់) បានជាបងស៊ុមឯងប្រឹងខឹងឱ្យមែនទែនទៅ ក្រែងលោកើតជំងឺស្លាប់បានបងផេងយកប្រពន្ធថ្មីទៅ ឯបងផេងក៏អញ្ចឹងដែរកុំចេះតែគិតពីចិត្តខ្លួនឯងមិនយល់ចិត្តអ្នកដទៃខ្លះ ប្រយ័ត្នប្រពន្ធស្លាប់ចោលអត់អ្នកណាមើលថែកូន ដាំបាយឱ្យហូប ល្មមនាំគ្នាគិតសារជាថ្មីដើម្បីក្តី

សុខដល់កូនចៅផងទៅ។ ពេទ្យហែងលើកពែងតែក្រេបបន្តិចតាសន ឆ្លៀតឱកាសនិយាយបន្ត យប់ជ្រៅបន្តិចមែនតែខ្ញុំនេះបែរជាញៀនទឹកតែ ចង់តែនិយាយ ព្រោះមិនទាន់ងងុយដេកទេ នាងស៊ុមឯងក៏អញ្ជើងទំនេ រៗទុកត្រចៀកស្តាប់ធម៌ខ្លះទៅ ឱ្យបានសេចក្តីសុខផ្លូវចិត្តនឹងគេខ្លះ។ មើលរឿងភាគកុំរកមើលតែសាច់តួ និងម៉ូតខោអាវ គ្រឿងអលង្ការ ត្រូវ ចេះពិនិត្យសិក្សាតួអង្គក្នុងរឿងខ្លះផង ព្រោះសាច់រឿងគឺស្តែងចេញពីជីវិត ពិតរបស់មនុស្សនេះឯង។ ត្រចៀកកុំពិរោះតែសម្លេងខ្លងខ្ទាំង ស្អីបទចង់ ងាប់។ ស៊ីកទៀតមោហ៍។ អញឮម្តងៗសែនខ្មាស់មច្ចុរាជដែលវាលប ចាំតែសម្លាប់ ដួលតោលៗរាល់ថ្ងៃរាល់យប់អត់ភ្លាក់អាត្មាសោះ ម្នាក់ៗ ទាំងតូចទាំងធំ សុទ្ធតែស្រវឹងនឹងជីវិតនាំគ្នាសាងតែអំពើឥតប្រយោជ ន៍។ ស៊ុមហ្អើយ! ចង្អៀងផ្ទះអ្នកណាបំភ្លឺផ្ទះអ្នកនោះ អញមិនដឹងរឿងក្នុង ផ្ទះឯងយ៉ាងណាៗឱ្យជាងខ្លួនឯងផ្ទាល់ទេ ប៉ុន្តែបុរាណតែងពោលថា ស្ត្រីជាអ្នករម្ងាស់ស៊ុប ដាក់ភ្លើងខ្លាំងវាខ្លោចឆ្ងៀមស៊ីមិនកើត ថែមទឹក ជ្រលាសាបបាត់រស់ជាតិ ស៊ុបប្តីប្រពន្ធក៏ដូចគ្នា បើយកភ្លើងទល់ភ្លើង នឹងឆេះខ្ទេចខ្ទីអស់ បើសាបពេកឬធូររលុងពេកក៏បាត់បង់តម្លៃជាប្តី ប្រពន្ធ។ ស្ត្រីជាអ្នកញាក់ខ្សែខ្លែងពេលខ្យល់បោកខ្លាំងត្រូវចេះបន្ធូរ ពេល

ស្ងាត់ខ្យល់ត្រូវចេះស្រាវខ្សែកុំទុកឱ្យខ្លែងដាច់ខ្សែ មិនងាយតាមរកយកមកវិញទេ។ ស៊ុមហ្អើយ ពួកអាមនុស្សប្រុសនេះ វាស្លាប់ក្រឡាក្រោមការថ្នាក់ថ្នមរបស់ស្រីៗទេ ឯងដឹងទេខ្មែរយើងពីដើមមានដីធំណាស់ប៉ុន្តែដោយសារតែចាញ់កលមាយាស្រី គេបោកយកដីអស់សឹងតែរកដីធ្វើម៉ុងមិនបាន។ ឯងត្រូវចេះប្រើបញ្ញាជាអាវុធដើម្បីយកឈ្នះចិត្តប្តីឱ្យបាន កុំចេះតែបន្ទោកតម្លៃខ្លួនឯងទៅធៀបជាមួយស្រីក្រៅរបងឱ្យសោះ។ ចាស៎អុំ ខ្ញុំនឹងព្យាយាមធ្វើ (មីងស៊ុមឆ្លើយទាំងអោនមុខចុះ) មិនមែនព្យាយាមទេ គឺធ្វើបើឯងព្យាយាមគឺឯងនៅចាញ់ចិត្តមានះចចេសរឹងរូសនៅឡើយទេ ស៊ុមហ្អា? កុំធ្វើជាកញ្ជះចិត្តអាក្រក់ឱ្យសោះ ចិត្តមានះចិត្តប្រកាន់អស់នេះ វាគ្រាន់តែធ្វើឲ្យជីវិតឯងរស់នៅក្នុងបន្លាតែប៉ុណ្ណោះ។ អារឿងប្រពន្ធពីរបីនេះវាមានតាំងពីមុនគ្រិស្តសករាជ មានតាំងពីមុនព្រះពុទ្ធកើតមកម្លេះ វាមិនមែនជារឿងថ្មីបំផុតសម្រាប់ឯងទេ ប៉ុន្តែសំខាន់ត្រង់ តើប្រពន្ធមួយណាដែលចេះស្គាល់ចិត្តប្តីជាងគេ គឺនាងនោះហើយបាននៅក្នុងមុងជាមួយប្តីច្រើនជាងគេ។ ប៉ុន្តែតណ្ហាវាមិនដែលចេះឆ្អែតអីវាអុំ សូម្បីតែនាងមុំកូនយាយជាន់នៅចុងភូមិខាងលិចក៏ឮសូរថាដើររកស៊ីយប់ដែរ អញ្ចឹងហើយបានជាពួកអាកញ្ជាស់ស្វាវានៅមិន

សុខគ្រប់គ្នា អញមិនមែនជាចាស់ស្ទាវទេរ៉ើយ អញចាស់ទំនើង! (ពូផេង ស្រែកកាត់មីងស៊ុមផូង)។ ឮច្បាស់ហើយនៅអ៊ំ? ពួកអាសត្វទីទុយ អាសត្វរាត្រីចរអស់នេះ រកបាត់ពន្លឺថ្ងៃមិនទាន់ទេ ភ្នែកក្រឡេកក្រឡាប់ដូចមៀមដូចគូក ស៊ីបាយលែងត្រង់មាត់ ប្រឹងលេបទឹកប្រញឹបប្រញាប់អត់ខ្លាចអួលស្លាប់ ហួចឆ្មេកឆ្ងាចរកញីឈ្មោលភ្លាម។ ឱ្យតែល្ងាចចោះនាំគ្នាពោមអ៊ូរនៅមុខផ្ទះនាងមុំនោះហើយ។ នែ៎មីង! កុំរាលភ្លើងផ្តេសផ្តាស់មើលឆេះតែគ្នាឯងទៅកុំអុជដល់ខ្ញុំ ខ្ញុំអត់បានបៀតបៀនអ្នកណាទេរ៉ើយ (មីងស៊ុមនិយាយមិនបានគិត អត់ដឹងនាងមុំកំពុងអង្គុយកាន់ចង្កៀងក្បែរពាងទឹក នាងដើរកាត់ទីនោះ លុះឃើញមនុស្សអ៊ូអរក៏ចូលមកស្តាប់ទៅ)។ អើហ៎ ចៅមុំឯងមកដែរក៏ល្អហើយម៉េចថាមិនបៀតបៀនអ្នកដទៃនេះបៀតបៀនទាំងខ្លួនឯងទៀតផង។ ការជាប់សិក្ខាបទកាមេមានទោសធ្ងន់ទាំងបច្ចុប្បន្ន និងបរលោក បច្ចុប្បន្នឆ្លងជំងឺកាមរោគខ្លួនឯង។ ធ្វើឱ្យអ្នកដ៏ទៃឈ្លោះទាស់ បែកបាក់គ្រួសារ ឬមានការចម្លងរោគតៗគ្នាទៅប្រពន្ធកូនគេ ជាតិទៅមុខនឹងកើតជាមនុស្សខ្ទើយ ហើយធ្លាក់នរកត្រូវឡើងរកាដែកមុតដាច់រយះឈឺពីតផ្សារ កើតស្លាប់ក្នុងរណ្តៅនរកជាអង្វែង។ អូហ៎! តាសនអើយទំរាំដល់វេនខ្ញុំ បន្លាររកានោះវាសឹកវារឹល

រលោងស្រិលដូចត្រប់ក្តគោអស់ទៅហើយ ថាមិនបានពេលឡើងរកា នោះវាស្រួលគួចខ្ញុំទៅវិញទេហាសហាសហា (នាងមុំស្រីមាត់អត់គម្រប សើចទន់កល្ងៀក)។ តាសនពោលទាំងមុខស្លូត ហេតុតែមិនដឹងធម៌ចៅ ហ្អើយ ដើមរកានោះកើតឡើងដោយផលកម្មរបស់ខ្លួនឯងម្នាក់ៗទេ មិន មែនកើតឡើងមួយដើមសម្រាប់មនុស្សវាល់លាននាក់ឯណា វេលាណា ឯងធ្វើចុតិបដិសន្ធិជាសត្វនរកភ្លាម ដើមរកាដែកនោះក៏កើតឡើង សម្រាប់ឯងភ្លែងដែរហើយនាយយមបាល ក៏ចាប់វាយបង្ខំឱ្យឯងវារឡើង វារចុះ លុះត្រាតែមុតសុះសាច់ក៏មិនឈប់។ អញ្ជឹងតាឯងធ្លាប់ឃើញ? (នាងមុំញាត់ឱ្យតាសន) ចំពោះចំណុចនេះពូសូមអារកាត់ចុះ (ពូពេទ្យ ហោងលើកដៃឡើងផងនិយាយផង) កម្មវិបាកជាអំពើបាបក្នុងអនាគត ជាតិ លោកតាសនគាត់គ្រាន់តែសម្តែងតាមគម្ពីរតែប៉ុណ្ណោះ ប៉ុន្តែចូរ ក្ងួយបានពិនិត្យគិតឲ្យឃើញពីកម្មទាន់ហន់ ដែលកើតពីការសន្សំបានរៀ ងៗខ្លួននៅមណ្ឌលអង្គការជនពិការ ឯងទៅមើលចុះ គ្រាន់តែអ្នកដែល រលួយស្បែកសាច់ ដោយសារទឹកអាស៊ីតម៉ាគរគោក ព្រោះតែការប្រជែង គ្នាដណ្តើមយកអសុភ ដែលគ្រាន់តែជាថង់លាមកសោះ អ្នកចម្រៀងត្រូវ គេបាញ់ស្លាប់ខ្លះ ស្លាប់មួយកំណាត់ខ្លួនរស់នៅខ្មោចមិនដូចខ្មោចមនុ

ស្បែមិនដូចមនុស្ស ត្រឹមតែជាសត្វចម្លែកដើរកាត់ភូមិផ្អើលគោក្របីឱ្យឆ្កែសង្ស័យឲ្យក្មេងភ័យលោះព្រលឹង ព្រោះតែរុំក្រណាត់មុខដូចជានិនចារជប៉ុនអញ្ចឹង នេះឯងចំអកព្រហ្មលិខិត ព្រោះតែការស្រើបស្រាលភ្លើតភ្លើននោះ។ ពូហេងឯងកុំចេះតែបន្ទោសតែម្ខាងឲ្យសោះ បើទំពក់វាមិនទៅភ្នៅក៏វាមិនមកដែរ ស្រីខ្លះគ្នាគ្មានមុខរបរស្ថានភាពគ្រួសារខ្វះខាត ម្តាយឪពុក ឬបងប្អូនត្រូវគ្នារ៉ាប់រងក្នុងបន្ទុកដូចយ៉ាងជាខ្ញុំនេះម៉ែចាស់លិតពពើម ឈឺលើសឈាមផង បាយភ្នែកផង គ្មានប្រាក់ទិញថ្នាំសង្កូវ ខ្ញុំជាស្រីអត់មុខរបរគ្មានចំណេះដឹងអីនឹងគេ តើខ្ញុំត្រូវរកស៊ីអីទៅពូ? (នាងទំលាក់សម្លេងបន្តិចព្រោះអួលដើមក) ពូដឹងទេជីវិតខ្ញុំនេះត្រូវផ្សងព្រេងយ៉ាងណា អាយុមិនទាន់គ្រប់ការត្រូវម្ចាស់ផ្ទះចាប់រំលោភដូចសត្វធាតុ រួចគេបោះលុយឱ្យត្រឹមបួនប្រាំម៉ឺន ហើយបណ្តេញចេញពីផ្ទះព្រោះខ្លាចត្រូវបែកការណ៍។ ខ្ញុំលង់មិនចេះអក្សរមិនដឹងជាត្រូវស្វែងរកយុត្តិធម៌នៅឯណាឆ្ងាយជាយសំពត់ ដែលត្រូវទាញយកមកជូតទឹកភ្នែកនោះទេពូ (និយាយដល់ត្រឹមនេះនាងមុំទប់ទឹកភ្នែកលែងបាន ប្រឹកដកដង្ហើមវែងស្រូបឱ្យពេញទ្រូងដើម្បីរៀបក្តីឈឺចាប់) ស្រីខូចក៏ជាមនុស្សខ្ញុំមានបេះដូងដូចគេឯងដែរណាពូ ដោយសារតែអាសូរម្តាយចាស់ដែលដេកថ្ងូរា

ល់ៗយប់ ខ្ញុំយកជីវិតទៅប្តូរនឹងប្រាក់ ភ្ញៀវខ្លះគេវាយធ្វើបាបខ្ញុំដូចសត្វ ធាតុ គេចាប់បង្ខំតាមអំពើចិត្ត ទាំងមិនដែលគិតសោះថា បើគេប្រព្រឹត្ត អំពើយ៉ាងនេះលើកូនចៅក្រុមគ្រួសារគាត់វិញ តើគាត់គិតយ៉ាងណា? ភ្ញៀវខ្លះអាងអំណាចគម្រាមសំឡុតស្រីៗយកទៅរំលោភបំពាន ទាំងគ្នា មិនបានលក់ខ្លួនផង។ ខ្ញុំឃើញគេបង្កើតកន្លែងបង្ហាត់បណ្តុះបណ្តាល វិជ្ជាជីវៈខ្ញុំសែនត្រេកអរ នឹងចង់តែបានថ្វាយបង្គំលោកអ្នកមានមេត្តាធម៌ នោះទេ ប៉ុន្តែមិនមានច្រើនកន្លែងឬនៅជិតភូមិយើងអាចឱ្យខ្ញុំទៅរៀន ចោលម៉ែបាន បើខ្ញុំមានចំណេះខ្ញុំនឹងផ្លាស់ប្តូរមុខរបរដែលសង្គមគេស្អប់ ខ្ពើមនេះហើយ (នាងបន្ទរដង្ហើមធំបន្តិច) ពូពេទ្យហែងដកដង្ហើមធំយូរ ដែរហើយបន្តវាចា ជីវិតគឺជាទុក្ខដូចព្រះថាមែន ការឈឺចាប់មានគ្រប់ ច្រកល្ហកលើផែនដីដ៏ធុយស្រួយនេះ ឱកូនស្រី! ពូមិនដឹងថាឯងមានការ តស៊ូក្នុងឆាកជីវិតដល់ម្លឹងសោះ អញ្ចឹងទេតើព្រះបាទជ័យវរ្ម័នទី៧ទ្រង់ មានរាជឱង្ការថា ទុក្ខសោករបស់រាស្ត្រគឺជាទុក្ខសោករបស់អញ អញ ឈឺមិនមែនជាជំងឺអញទេ តែឈឺព្រោះឃើញរាស្ត្រមានក្តីឈឺចាប់។ ឱ ព្រះបាទធម្មិករាជជាក្សត្រទ្រង់ធម៌ ព្រះកិត្តិនាមរបស់ព្រះអង្គបានចារ ឆ្លាក់ក្នុងក្រអៅបេះដូង យើងគ្រប់គ្នាតជាប់រាប់ជំនាន់ជាវៀងរហូត។

ក្សត្រដែលល្អគឺគ្រប់គ្រប់រាស្ត្រឲ្យមានសេរីភាពមានភាពសំបូរសប្បាយ មិនដូចការតំអូញរបស់ការីង៉ុយ នគរថ្កើងប្លែកសប្បាយតែភ្នែកក្នុងចិត្តរងកម្ម កាលណាទៅទើបបានគេនាំគ្នាយល់ថា បើស្វែងរកទ្រព្យយើងនឹងអស់ទ្រព្យបើយើងចំណាយទ្រព្យយើងនឹងបានទ្រព្យ គឺទ្រព្យនៅសុគតិទេវតានឹងមិនឆ្លើយតបចំពោះការឧទ្ទិសដ្ឋានដែលពោរពេញទៅដោយអំពើបាប ហើយក៏មិនប្រទានពរដល់ទុរគតដែលចេះតែអង្វរករលន់តួដោយឥតបញ្ញានោះដែរ។ ឬមួយការផ្សាយមេត្តា ផ្សាយសេចក្តីស្រលាញ់ដោយគ្មានចិត្តច្រណែនសូម្បីតែចំពោះសត្រូវរបស់យើង នោះគឺជាការបិទភ្នែកជឿទេឬ? សេចក្តីអាក្រក់របស់មនុស្សម្នាក់គឺចាត់ទុកដូចជាគេសាងសេចក្តីស្លាប់ឱ្យខ្លួនឯង ប៉ុន្តែក្នុងសម័យដែលមនុស្សទាល់ហើយក្រទៀត តើគេអាចជៀសពីធ្វើអាក្រក់បានទេ? អ្នកមានគេរក្សាសីលបានបរិសុទ្ធិ ក៏ព្រោះតែគេមានហើយមិនសូវជួបហេតុនាំឱ្យទាស់ចិត្ត ចុះអ្នកក្រដូចពួកយើងតើត្រូវបំផ្លាញគុណធម៌ចោលអស់ទៅឬ? មិនត្រូវបំផ្លាញចោលទេនាំខូចពូជ ត្រូវរស់ចាំថ្ងៃលាចាកលោកិយដោយក្តីបរិសុទ្ធិ ព្រោះលោកនេះគឺជាលោកនៃក្តីវិនាសទេ (តាសនភ្លួយមាត់កាត់ប្រសាសន៍ពេទ្យហែង)។ មែនហើយពូ អើហ៍មុំហ្អើយ! ពូមាន

បទពិសោធន៍ខ្លះ ចង់ប្រាប់ដល់នាងគ្រាន់បានថែរក្សារជីវិតឱ្យរស់នៅបានយូរ គ្រាន់បានបម្រើម្តាយចាស់ជរា (ពេទ្យហែងមិនទាន់និយាយចប់ផងនាងមុំលូកមាត់កាត់) អរគុណពូ ស៊ូរស់ក្បែរម៉ែឲ្យគាត់វាយ ស្តីជេរ ខ្ញុំមិនចង់រស់នៅជាមួយគេអ្នកដទៃទេឡើយ បើទោះជាត្រូវដកស្នូងទាំងគ្មានសំលៀកបំបាក់គ្រប់គ្រាន់ ក៏ខ្ញុំសប្បាយចិត្ត ព្រោះពេលយប់បានដេកកើយទ្រូងម៉ែ តើពូចង់អប់រំខ្ញុំពីអ្វីខ្លះទៅពូ? ពេទ្យហែងលើកដៃអង្អែលក្បាលថ្នមៗ ទាំងមានដានទឹកភ្នែករងថ្លាដក់លើត្របកភ្នែកដ៏ឃ្លេរយាររបស់គាត់ព្រោះតែក្តីករុណា ធម្មជាតិសព្វថ្ងៃវាប្រែប្រួលអស់ហើយមិនដូចពីមុនទេ ឯងមិនត្រូវទុកចិត្តអ្នកណាទាំងអស់ថា គ្មានផ្ទុកមេរោគអេដស៍ មកទល់សព្វថ្ងៃរកថ្នាំព្យាបាលអេដស៍ឱ្យចំមុខមិនទាន់ឃើញផង (ឃើញតែថ្នាំពន្យារ) ស្រាប់តែលេចចេញវីរុស អេច អាយ វី បង្ករឱ្យកើតមហារីកមាត់ស្បូនយ៉ាងសាហាវទៀត ប៉ុន្តែវាអាចការពារបានដោយសារការប្រើប្រាស់ស្រោមអនាម័យឱ្យបានទៀងទាត់។ តើពេលណាខ្លះដែលអាចនាំឱ្យឯងភ្លេចប្រើស្រោម? ពេលឯងឃើញគេក្មេងសាច់គេស្អាត កុំនឹកស្មានថារូបគេនោះគ្មានរោគឱ្យសោះ។ ពេលឯងស្រលាញ់គេពេក យកធ្វើជាសង្ឃឹមជឿថាគេស្មោះចំពោះឯងតែម្នាក់ វា

មកស្មោះជាមួយឯងបាន វាក៏មានស្មោះជាមួយអ្នកដទៃទៀតបានដូចគ្នា។ ពេលឯងឃើញគេឱ្យលុយច្រើនក៏ភ្លើតភ្លើនភ្លេចប្រើស្រោម ឬគេឱ្យលុយច្រើន ជាថ្នូរនឹងការរួមភេទដោយមិនប្រើស្រោម ដូចជានាងសាន វាប្រាប់ពូពេលភ្ញៀវបរទេសហៅវាទៅដេក វាឃើញគេដាក់ក្រដាស់១០០ដុល្លារលើភ្លៅ ក៏នឹងត្រេកអរថា ត្រូវតែប្រឹងតស៊ូទប់ទល់បើទោះជាត្រូវទទួលការឈឺចាប់ម្តេចក្តី ទីបំផុតត្រូវវាចតរូបផង ចាប់កាច់ដៃកាច់ជើងក្រឡាប់ផ្កាប់ផ្ងារគ្រប់ម៉ូតគ្រប់ម៉ាក ឈឺចាប់ខ្លាំងពេកទ្រាំលែងបានក៏លើកដៃសំពះសុំតែមួយម៉ឺនរៀលជិះម៉ូតូឌុបត្រឡប់ទៅផ្ទះវិញ ដេកបិទកៅអៀកខ្លាផងស្អំស្រោពន្លែផង អស់មួយអាទិត្យបានដើររួច កុំចេះតែចង់បានលុយគេខ្លាំងពេក។ ពេលយប់ជ្រៅពេក ភ្ញៀវគេហៅប្រយ័ត្នឯងរវល់តែងុយដេកជ្រុលពេកក៏អាចភ្លេចប្រើស្រោមបានដែរ។ ពេលឯងប្រើប្រាស់គ្រឿងញៀនស្រវឹង ថ្នាំញៀនថ្នាំសម្រើបវានាំឱ្យវង្វេងស្មារតីភ្លេចប្រើប្រាស់ស្រោមដូចយកជីវិតទៅលេងនឹងសេចក្តីស្លាប់អញ្ចឹង។ ការធឹកស្រាប៊ីយែរនេះក៏ដូចគ្នា គែអាចលួចដាក់ថ្នាំ យើងមិនដឹងលុះធឹកទៅលែងមានសតិប្រុងប្រយ័ត្ន។ ក្នុងកន្លែងរាំ បារ ក្លឹប នេះក៏អញ្ចឹងដែរ ចំហាយផ្សែងគេបាញ់ឈ្ងុយៗ គេអាចលាយថ្នាំឱ្យញៀនសប្បាយវង្វេង

រង្វាន់ លុះភ្ញៀវគេស្រវឹងគេចាប់បង្ខំអត់ឱ្យលុយក៏មាន។ គេឲ្យលុយច្រើនឱ្យឯងសេពមេថុនតាមមាត់តាមរន្ធគូថគ្រោះថ្នាក់ឆ្លងរោគណាស់ ភ្ញៀវធ្វើពុតជាមិនចេះពាក់ស្រោម ឬលួចដោះស្រោមចេញលួចក្តិចចុងស្រោមឱ្យធ្លាយបំពង់ចង់ចម្លងរោគទៅអ្នកដទៃ ព្រោះជំនឿពីបុរាណតៗមកថាបើបានចំលងរោគទៅអ្នកដទៃ នោះខ្លួនគេនឹងបានជាសះស្បើយ។ ពេលខ្លះភ្ញៀវធ្វើពុតជាខ្មាស់អៀនសុំបិទភ្លើង តែគេមិនព្រមពាក់ស្រោមក៏មាន ហើយឯងក៏រឹតតែត្រូវប្រុងប្រយ័ត្នថែមទៀតនៅពេលដែលភ្ញៀវគេហៅចេញទៅក្រៅ គេថាគេតែម្នាក់ឯងទេ ពេលទៅដល់កន្លែងគេស្រាប់តែគ្នីគ្នាគេបួនដប់នាក់ចាប់បង្ខំឯងដោយអត់ប្រើស្រោម ដែលគេហៅថា បូកឬវាបោកគ្រាប់បែក (លេងស្រីហើយរត់ចោលអត់ឱ្យលុយ) ក៏មាន។ ណ៎ាក! អាពួកម៉ាក ឬម៉ូយដែលមកញឹកញាប់អាងតែលើកមុនមិនអី លើកក្រោយមិនប្រើស្រោមនេះក៏គ្រោះថ្នាក់ណាស់ដែរ ការដែលពិនិត្យឈាមលើកទីមួយឃើញមិនអី មិនប្រាកដថាមិនមានរោគនោះទេព្រោះក្រោមឆ្លងមេរោគអេដស៍ភ្លាមមើលមិនឃើញទេ ក្នុងឈាមមានមេរោគរយៈពេលបីទៅប្រាំមួយខែឯនោះ ប៉ុន្តែការចម្លងរោគទៅអ្នកដទៃជាធម្មតា។ នេះពួកគាន់តែរៀបរាប់ត្រួសៗពីជំងឺអេដស៍តែប៉ុណ្ណោះ ចាំថ្ងៃបន្ត

ទៀតពូនឹងប្រាប់ឯងពីជំងឺមហារីកមាត់ស្បូន ដែលកំពុងតែយាយីជីវិតស្ត្រីយ៉ាងខ្លាំងខ្លានោះ។ និយាយសឹងផុតមាត់មិនទាន់ ពូពេទ្យក៏ហារមាត់ស្ទាបហ៊ាមៗ ឯអ្នកដទៃក៏នាំគ្នាឆ្លងជំងឺស្ទាបហ៊ាមៗតាមតៗគ្នា ហើយក្រោកពត់ខ្លួនប្រាណ រួចជំរាបលាគ្នាទៅកាន់លំនៅដ្ឋានរៀងៗខ្លួនទៅ ព្រោះសល់ម៉ោងតិចតួចដែរ គ្រាន់នឹងបិទភ្នែកបំភ្លេចទុក្ខពីវេលាថ្ងៃដោយអំណាចទិព្វមន្តនៃធម្មជាតិនាពេលព្រឹកព្រលឹម។

ម៉ោងជិត១២ថ្ងៃត្រង់ ថ្ងៃនេះមេឃស្រលះ ខ្យល់ធ្លាក់ត្រសៀកៗ ធ្វើមនុស្សខ្ជិលច្រអូសចង់តែដេកឱ្យលក់ដល់ណាណី លោកគ្រូពេទ្យហោងទើបតែប្រែខ្នងដល់កន្ទេល ស្រាប់តែកូនឆ្កែភឿរបស់គាត់ព្រួសរ៉ូសៗយ៉ាងសង្ហើញ គាត់ប្រែទឹកមុខក្រញ៉ូវហើយរអ៊ូតិចៗ៖ អញធុញអើញ ធុញម៉ាជីវិតពេទ្យ សឹងរកពេលដេកឱ្យលក់ស្កប់ស្កល់មិនបានវ៉ី ព្រលឹមស្រាងឡើងមិនទាន់បានអី ចូលពោះមួយម៉ាត់ផង គេមកប្រាប់ថាលោកគ្រូអាចម៍ខ្ញុំរាវ អាចម៍ខ្ញុំរឹង សំប៉ែត សព្វបែបសព្វយ៉ាង ដល់ពេលរៀបស៊ីបាយស្រាប់តែគេមកប្រាប់ថា លោកគ្រូខ្ញុំរមាស់ក្តិត អញហ្អើយអញធ្វើពេទ្យម៉្លេៗឃើញតែអាចម៍នោម កំហាក ខ្ទុះឈាម គ្មានដែលបានឃើញផ្កាកូលាប ឃើញសួនឧទ្យានស្រូបខ្យល់អាកាសបរិសុទ្ធអីនឹងគេទេ ថ្ងៃ

ណាមួយ អញច្បាស់ជាទប់ក្លាយជាពេទ្យឆ្កួតមិនខានទេមើលទៅ។ កំពុងតែរអ៊ូង៉ូវៗ ស្រាប់តែនាងមុំសើចដាក់គ្រហ៊ាញៗនៅមាត់ទ្វា ពូពេទ្យក៏សួរ៖ អើហ៎! មកមានការអីហ្អីនាងមុំ? ចាស៎ពូ ខ្ញុំចង់មកសួរពូពីព័ត៌មានរោគមហារីកស្បូននឹងណា ក្រែងលោចេះការពារបានខ្លះ (មុំតប)។ អើហ៎ ល្អហើយនាងចង់ចេះចង់ដឹង គឺជាការប្រពៃណាស់ ព្រោះស្ត្រីស្លាប់ដោយសារជំងឺនេះ ឥឡូវកើនច្រើនណាស់លើពិភពលោក ប្រទេសជឿនលឿនគេកាត់បន្ថយបានច្រើនហើយ ចំណែកស្រុកយើងគ្រាន់តែយល់ក៏មិនទាន់យល់ច្បាស់ផង អ្នកខ្លះសំបូរប្រាក់តែងតែខ្លួនសាប៊ូ ក្រែម ទឹកអប់ ប្រេងម្សៅ អត់ដឹងក្នុងផលិតផលអស់នោះ គេលាយជាតិអរម៉ូនឱ្យសក់ និង សាច់ឆាប់ស្រស់ស្អាត ហើយជាតិគីមីអស់នោះនាំឱ្យ កើតជំងឺមហារីកស្លាប់អីមិនដឹងទេ។ បើតាមរយៈអាហារវិញនាងមុំហ្អើយ ចាំតែមើលទៅ មុខជានាំគ្នាស្លាប់មួយចំហៀងខ្លួនពេញទឹក ពេញដីជាមិនខាន ម្សៅស៊ុប ឬបីចេងនេះឈ្មោះវិទ្យាសាស្ត្រគឺជាអាស៊ីតគ្លុយតាមិច ជប៉ុនរកឃើញនឹងផលិតតាំងពីមុនសង្គ្រាមលោកលើកទី២មកម្លេះ ប៉ុន្តែសព្វថ្ងៃនេះជប៉ុនផលិតមែនគឺសម្រាប់តែលក់ទេ បើគេបានជាជ្រុលហូបចូលមាត់គឺគេរត់ទៅលូកខ្វេះមាត់ឲ្យក្អួត មិន

ហ៊ានលេបចូលពោះឡើយ ឯស្រុកយើងវិញ នាងហ្អើយបើអត់ម្សៅស៊ុប នេះ គឺលែងចេះធ្វើម្ហូបអ្វីទាំងអស់ហើយ។ នៅប្រទេសបារាំងដំបូង ឡើយពួកវេជ្ជសាស្ត្រចេះតែនាំគ្នាឆ្ងល់ថា អតិថិជនដែលចេញចូលហូប អាហារក្នុងផ្សារចិនរាល់ថ្ងៃ គុយទាវរាល់ព្រឹក គុយទាវមួយចានគេបង់ ម្សៅស៊ុប១ស្លាបព្រា ២ស្លាបព្រាពងទាកូនប៉ូវឱ្យរាល់ថ្ងៃ មិនយូរប៉ុន្មាន ទេក៏លេចចេញដេកមិនលក់ ឧស្សាហ៍ឈឺក្បាលចុកចាប់ដៃជើង អស់ កម្លាំងមិនដឹងមូលហេតុ ពួកពេទ្យបារាំងបូមឈាមស្រាវជ្រាវទៅ ឃើញ តែជាតិអាស៊ីតគ្លុយតាមិចនេះកើនឡើងក្នុងឈាមជាប់ គេក៏ដាក់ឈ្មោះ សំនុំរោគសញ្ញាតំអូញនេះថា (សហសញ្ញាភោជនីយដ្ឋានចិន ឬឆាយនី សរ៉េស្តូរ៉ង់សាំងជ្រូម) លុះក្រោយមកគេក៏ចាប់តាមដានបាតុភូតរបស់ ជាតិគីមីនេះបានឃើញច្បាស់ថា វាជាប្រព័ន្ធភ្ជោចកោសិកាខួរក្បាល ជាតិម្សៅស៊ុបនេះភ្ជោចកោសិកាខួរក្បាល យូរទៅលើកូនសរសៃរឈាម ក្រហម នាំឲ្យធ្លាយឈាមហូរពេញខួរក្បាលឲ្យងាប់មួយចំហៀងខ្លួន នាងមុំអើយ ទៅថ្ងៃមុខអាយុវែងតែអ្នកមានសីលទេមើលទៅ។ ចំណែក ឯរឿងមហារីកមាត់ស្បូននេះវិញ វាជារោគដែលកើតឡើងនៅពេលដែល កោសិកាមាត់ស្បូន មានភាពមិនប្រក្រតី រីកដុះដាល់នៅលើមាត់ស្បូន

និងកស្បូន គេអាចដឹងបានដោយការត្បាយកកោសិកាមាត់ស្បូនទៅពិនិត្យនៅមន្ទីពិសោធន៍ ខ្លះហៅថា **បៀកយករំអិលកស្បូនទៅពិនិត្យ**។ មូលហេតុរបស់វា គឺបណ្តាលមកពីមេរោគប្រភេទវីរុសម្យ៉ាងឈ្មោះ **អេច អាយ វី** វីរុសនេះងាយឆ្លងតាមរយៈការរួមភេទដោយមិនប្រើប្រាស់ស្រោមអនាម័យការពារ។ វីរុសក្រុមនេះមានរាប់រយប្រភេទ ប៉ុន្តែប្រភេទទី១៦ និង ១៨ បង្ករឲ្យកើតមហារីក មាត់ស្បូន ទ្វារមាស នឹងលើប្រដាប់ភេទស្ត្រី ឯប្រភេទទី៦ និងទី១១ វាបង្ករជាជំងឺសរមាន់ដែលបារាំងហៅថា **ក្រែតដឹកុក** នោះវានឹងបង្ករឱ្យទៅជាដុំមហារីកក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមក ចំពោះបុរសវានាំឱ្យកើតមហារីកក្បាលលិង្គ។ មធ្យោបាយការពារមានពីរយ៉ាងគឺ៖

១- ត្រូវប្រើស្រោមអនាម័យការពារឱ្យបានត្រឹមត្រូវ នូវរាល់ពេលរួមភេទ

២- ចាក់ថ្នាំបង្ការវាការពារបានចំពោះវីរុស៤ប្រភេទខាងលើ តែតម្លៃថ្លៃបន្តិចចំណែកវ៉ាក់សាំង១ប្រភេទទៀតធូរថ្លៃ តែការពារបានវីរុស២ប្រភេទគឺ ប្រភេទ១៦ និង ១៨ តែប៉ុណ្ណោះ។ (រយៈពេលចាក់៦ខែ)ប៉ុន្តែត្រូវចាំថា ចំងឺមហារីកមាត់ស្បូនវាមិនមែនបណ្តាលមកពីមេរោគនេះតែ

មួយមុខប៉ុណ្ណោះទេ វានៅមានមូលហេតុផ្សេងទៀតដែរ ហេតុនេះដើម្បីទទួលបានការការពារឱ្យបានល្អជាងនេះមានតែ ទៅជួបជាមួយគ្រូពេទ្យឯកទេសខាងជំងឺស្ត្រី ដើម្បីឱ្យគេពិនិត្យមើលកោសិកាមាត់ស្បូន ឬឆ្លុះមើលកស្បូនឱ្យបានទៀងទាត់តាមការណាត់តែប៉ុណ្ណោះ។ នឹងហើយមុហ្អើយ ដើម្បីបានរស់ជាមនុស្សនេះមានតែត្រូវខំរកខំចេះខំដឹងឱ្យបានច្រើន ទើបឈរជើងលើផែនដីនេះជាប់បានយូរ ពុំនោះទេ.... (សម្លេងឆ្កែភឿព្រួសកាត់ម្តងទៀត) អូហ៍! ជំរាបសួរអ៊ំសនហ្អើយ ទើបមកពីណាហ្នឹង? (តាសនក៏ដើរចូលមកទាំងយកឈើច្រត់គាស់ឆ្កែចេញឱ្យឆ្ងាយពីជើងខោថ្នេរប្រាំរបស់គាត់)។ ពូពេទ្យហេងលើកកៅអីជូនគាត់អង្គុយក្បែរនាងមុំដែរ ហើយលើកទឹកសុទ្ធមួយដបជូនគាត់ដោយសេចក្តីគោរពកោតក្រែង។ តាសនញញឹមតាមបែបអត់ធ្មេញមួយក្បាច់ដាក់អ្នកទាំងពីរយ៉ាងគួរឱ្យជក់ចិត្ត ទាល់តែនាងមុំអត់ទ្រាំមិនបានក៏សួរ៖ អ៊ំ! ដើម្បីដោះស្រាយបញ្ហាទុក្ខតើព្រះពុទ្ធបានពន្យល់ប្រាប់យើងឱ្យចាប់ផ្តើមពីត្រង់ណាទៅអ៊ំ? ត្រូវចងចាំក្នុងចិត្តឱ្យបានច្បាស់មិនត្រូវសោកស្តាយ ឬអាល័យកើតទុក្ខទោមនស្សចំពោះរឿងរ៉ាវដែលកន្លងហួសហើយនោះទេ ព្រោះវាកន្លងហួសអស់ហើយយើងមិនអាចធ្វើឱ្យវាវិលត្រឡប់មកវិញ

បានទេ មិនត្រូវ សង្ឃឹមចំពោះរឿងដែលមិនទាន់កើតឡើង ព្រោះវានាំឱ្យ ខកចិត្តឥតប្រយោជន៍ ចូរប្រើជីវិតជាបច្ចុប្បន្នជីវិតដែលដង្ហើមកំពុងតែ សញ្ចរចេញចូលទៅមក ព្រោះអាស្រ័យចិត្តករជ្ជកាយ និង ក្តោងច្រមុះឯ នេះវិញទើបជាតថភាពខ្យល់ដង្ហើមដកចូលឱ្យដឹងថាចូល ចេញឱ្យដឹង ថាចេញ។ បើរវល់តែចេញដឹង ចូលដឹងតែអញ្ចឹងពេកតើបានស្អីស៊ីទៅ ពូ? (ពេទ្យហេងសួរជ្រែកគំនិតរបស់តាសនយ៉ាងតក់ក្រហល់) ណាវិបត្តិ ហិរញ្ញវត្ថុពិភពលោក ស្អីៗឡើងថ្លៃទាំងអស់ងាកមកប្រាក់ខែវិញមិន ត្រឹមតែមិនឡើងទេ បែរជាត្រូវកាត់បន្ថយទៅវិញ ផែនដីឡើងកំដៅក្តៅ សឹងតែប្រេះលលាដ៏ក្បាលខ្លោចអស់សក់ ពួកមហាអំណាចនាំគ្នាផ្តើល ឈូឆរទៅប្រជុំដូចនាំគ្នាទៅដើរលេងស៊ីផឹក លេងស្រីឱ្យសប្បាយចិត្ត ព្រោះប្រជុំចង់អត់បានការអីទាំងអស់ គ្មានអ្នកណាម្នាក់ហ៊ានដេកអត់ ម៉ាស៊ីនត្រជាក់អត់ដើរលេងរ៉ាកង ខ្លះនៅវាលយន្តហោះប្រាំនាទី យន្ត ហោះឡើងមួយជិះគ្នា១០នាក់ក៏មាន ២ទៅ៣នាក់ក៏មានគ្រាន់តែទៅដើរ លេងតែប៉ុណ្ណោះ អ៊ំដឹងស្រាប់ហើយថាចំហេះរបស់សុាំងដែលឆេះប្រើ ប្រាស់ហើយ គឺវាគ្រាន់តែទៅបំផ្លាញបរិយាកាសរបស់ផែនដីតែប៉ុណ្ណោះ វាមិនបានប្រគល់អ្វីទៅឱ្យធម្មជាតិវិញទេ។ ម្នាក់ៗកាលនៅរស់ស៊ីជីវិត

សត្វរាប់មិនអស់ឡើងមាឌមួយថ្ងៃៗដូចយក្ស ខ្លះស្លាប់ព្រោះស៊ីក៏មាន ប៉ុន្តែបែរជាពេលស្លាប់ទៅវិញនៅប្រកាន់រូបហើមប៉ោងស្អុយរលួយដូច ខ្មោចឆ្កែនោះទៀត (**ជីវិតដែលទទួលបានពីធម្មជាតិសោះបែរជាមិនចង់ប្រគល់ឱ្យធម្មជាតិវិញ**) មិនព្រមកប់ផ្ទាល់ដី ឬដុតចោលដើម្បីឱ្យធាតុកាបូន អាសូត អ៊ីដ្រូសែន អ៊ុកស៊ីសែន ផូស្វ័រ កាល់ស្យូម ទៅធម្មជាតិវិញទេ ម្នាក់ៗដាក់មឈូសដែកឱ្យជីវិតជិតឈឹង អាខ្លះនៅស្រែកផ្តាំថាមឈូសអញ ចេតិយអញ ម៉ុងអញ ផេះឆ្អឹងអញ ត្រូវរៀបចំទុកដាក់យ៉ាងនេះ យ៉ាងនោះ វានៅផេះអញទៀតអស្ចារ្យមែន។ ពេលកើតដែលគ្រាន់តែជាកំណើររបស់ទុក្ខ តែបែរជានាំគ្នាជប់លៀងរាំលេង ស៊ីផឹកសប្បាយចិត្តទៅវិញ ដល់ពេលស្លាប់គឺជាការបញ្ចប់ទុក្ខមួយរយៈ តែបែរជានាំគ្នាយំសោកបោកប្រាណស្តាយស្រណោះទុក្ខ ចង់ឱ្យទុក្ខត្រឡប់មកវិញ គិតសព្វៗទៅឡិកឡក់ដូចកូនក្មេងយំចង់បានព្រះអាទិត្យ។ ពិភពលោករស់១ថ្ងៃលំបាកជាងមួយថ្ងៃ ហើយត្រូវថ្ងៃនិងយប់ផ្លាស់ប្តូរវេនគ្នាហូរទៅជាប់មិនដាច់ គួចយកគ្រប់រឿងរ៉ាវទាំងល្អទាំងអាក្រក់ ទីបំផុតជីវិតសល់ត្រឹមតែស្នាមអនុស្សាវរីយ៍ដែលមិនគួរចង់ឱ្យរំលឹកព្រោះចង់ក្អួត អញ្ចឹងម៉េចមិនទៅក្អួតសិនទៅហេង? (**តាសនបន្ទរតាម**) ចេះ

មកលូកមាត់កាត់ធម៌ឯងអញ្ចឹងទៅណ៎ា ហេងអើយ! ជីវិតតាមសេចក្តីពិត គឺមិនគួរប្រកាន់ពេកឡើយ តើហេងឯងនេះមកពីណាហ្ន៎ះ? ពេលដែលមេជីវិតញីឈ្មោលភាពប្រសប់គ្នា តើមាននៅក្រោមអំណាចយើងទេ? បើនៅក្រោមអំណាចយើងមែនមិនកើតជាកូនអ្នកមានគ្រប់គ្នាអស់ហើយ ចាប់ផ្តើមពីធាតុ កាបូន អ៊ីដ្រូសែន អុកស៊ីសែន អាសូត ដូចសាំង។ ឯងថាវាមើលមិនឃើញហើយក៏ប្រែបានរូបកូនង៉ាហេង ទៅកុមារាហេង ទៅកំលោះហេង ទៅពូហេង ទៅអ៊ំហេង ទៅតាហេងតៗគ្នាយ៉ាងនេះតើក្រោមអំណាចហេងឯងទេ? មិន គឺជាការតាក់តែងរបស់ធម្មជាតិសុទ្ធៗ ឆ្អឹង សាច់ សរសៃសក់ រោម ក្រចក អស់ហ្នឹង មានហេងឯងជាអ្នកធ្វើឯណា គឺធម្មជាតិធ្វើឱ្យទាំងអស់ ហេតុនេះហេងឯងគឺជារបស់ធម្មជាតិទេ (គ្រាន់តែជាសមិទ្ធិផលធម្មជាតិតែប៉ុណ្ណោះ) ខ្លួនឯងមិនមានខ្លួនឯងផង នៅចង់ឱ្យអ្វីៗជាខាងក្រៅឱ្យតាមចិត្តខ្លួនឯងទៀត បើរូបនេះជារបស់ខ្លួនឯងមែន ហេងឯងគប្បីបង្គាប់បានថា រូប ឯងពុំគប្បីក្លាយជាយ៉ាងនេះ យ៉ាងនោះ ពុំគប្បីក្លាយជាចាស់ ឈឺ ស្លាប់ឡើយ តើបង្គាប់បានទេ? ជីវិតដែលត្រឹមតែជាបញ្ញាត្តិកម្មនេះពុំគួរ ជាប់ប្រកាន់ (ពេក) ទេ ព្រោះអ្វីៗទាំងអស់ត្រឹមតែជាធម្មជាតិតែប៉ុណ្ណោះ មើលហេងឯងថា

ជីវិតនេះវាសំខាន់បំផុតក្នុងលោក អញ្ចឹងជីវិតហ៊ីត្លែរ ម៉ូសូលីនី ប៉ុលពត អីនេះសំខាន់ណាស់មែនទេ? ជីវិតបើគ្មានគុណធម៌ក៏មិនសំខាន់ដែរ មានគុណធម៌បើគ្មានរូបក៏គុណធម៌មានមិនបាន មានរូបបើគ្មានអាហារ គ្មានទឹក គ្មានខ្យល់ គ្មានពន្លឺ ក៏ជីវិតរូបរស់មិនបាន តើមានហេងឯងកើតឡើងទោលតែឯងក្នុងធម្មជាតិនេះទេ? ធម៌ទាំងឡាយកើតឡើងអាស្រ័យគ្នានិងគ្នារលត់ទៅវិញក៏អាស្រ័យគ្នានិងគ្នា ធម៌ណាកើតឡើងទោលតែឯងជាធម៌ភ្លាវទេ ជាធម៌ទិដ្ឋិមានៈ ប្រភពនៃបញ្ហាតែម្យ៉ាងតែប៉ុណ្ណោះ ពូហេងក៏បានលូកមាត់កាត់ៈ អញ្ចឹងមានតែអ្នកមានទាំងអស់មិនមានទុក្ខ? តាមពិតនៅមានអ្នកមានលេបថ្នាំសម្លាប់ខ្លួន ចងក ឬលោតទឹកសម្លាប់ខ្លួនម៉ាគរគោក អ្នកមានខ្លះលែងប្តី លែងប្រពន្ធហើយកើតរោគចិត្តម៉ាសន្ទឹក (**នេះហេតុតែមិនដឹងធម៌តាមសេចក្តីពិត**) សច្ចៈធម៌ក្នុងសកលចក្រវាឡ គឺជាដំណើរធម្មជាតិដែលសុទ្ធតែអាស្រ័យគ្នានិងគ្នានេះឯង នេះជាការត្រាស់ដឹងរបស់ព្រះពុទ្ធបរមគ្រូដែលព្រះអង្គសម្តែងក្នុងគម្ពី **មហាប្បដ្ឋាន** ដែលជាគម្ពីទី៧ក្នុងគម្ពី **ព្រះអភិធម្ម** ពេលនោះព្រះពុទ្ធបរមគ្រូជាម្ចាស់ទ្រង់ពិចារណា ហើយទ្រង់រកអត្តាតួខ្លួនព្រះអង្គឯងពុំឃើញ គឺឃើញតែហេតុបច្ច័យដែលប្រព្រឹត្តិទៅក្នុងធម្មជាតិតែ

ប៉ុណ្ណោះ ពេលនោះសេចក្តីបរិសុទ្ធនៃព្រះញាណបានញុំាងឱ្យពន្លឺរស្មីជះចេញពីព្រះរកាយរបស់ព្រះអង្គទៅលើដល់ជតាកាសឯណោះ។ អញ្ចឹងតាឯងកើតទាន់បានឃើញពេលនោះឬ? (ពូហេងបើទោះជាដឹងខ្លះក៏ធ្វើជាសួរស្មក) តាសនបែបរាងគាំងថ្កាមបន្តិចទើបប្រមូលបញ្ញាញាណពន្យល់បន្ត មែនហើយ! ពួកមនុស្សមានត្រឹមតែភ្នែកសាច់ គ្មានទិព្វចក្ខុ គឺដូចជាមនុស្សខ្វាក់ពីកំណើតសម្លឹងឃើញត្រឹមតែតណ្ហារបស់ខ្លួន មើលមិនឃើញភាពស្អាតរបស់ចិត្តនេះ ប្រៀបដូចជាកង្វាក់៥នាក់មិនដែលស្គាល់ដំរី ត្រូវនាយហ្មុំដំរីដឹកដៃឱ្យស្ទាប ម្នាក់ស្ទាបជើងថាដំរីគឺជាសរសរផ្ទះ ម្នាក់ស្ទាបត្រចៀកថាដំរីជាចង្អេរ ម្នាក់ស្ទាបប្រមោយថាដំរីដូចឈើង ម្នាក់ស្ទាបកន្ទុយថាដំរីដូចជាមេអំបោស ម្នាក់ស្ទាបខ្លួនថាដំរីដូចជាធុងទឹក ហើយក៏ប្រកែកគ្នាយកឈ្នះ វាយគ្នាបែកក្បាលបែកត្បូងអស់ នេះហើយជាទោសមកពីមានអវិជ្ជា មានអវិជ្ជាគឺមានជំងឺខ្វាក់។ ពេទ្យហេងហ្អា ចង់ដឹងការពិតពីព្រះធម៌ដែលជាព្រះពុទ្ធដីកានោះ ម៉ែចមិនរៀនធម៌ហើយបដិបត្តិតាមឱ្យត្រឹមត្រូវសាកលមើលទៅ មានអស់លុយឯណា សាលាផ្លូវលោកទំរាំបានបរិញ្ញាអស់លុយរាប់ពាន់ រាប់ម៉ឺនដុល្លារ រៀនចប់ចេះត្រឹមតែម៉ាបោកប្រាស់គ្នារំពុះរំពង ឯបរិញ្ញាក្នុងព្រះពុទ្ធ

សាសនារៀនចប់បដិបត្តិពិសោធន៍ឃើញការពិតក៏កើតសន្តិភាពក្នុងចិត្ត ត្រជាក់ថ្លាក្សេមរូចផុតចាកទុក្ខឥតកង្វល់តាំងពីជាតិនេះរហូតដល់បរលោក ដូចជាព្រះអរហន្ត ជាបុគ្គលអស់តណ្ហាមួយអង្គបានជួបព្រានព្រៃហើយសួរថា ព្រួញអ្នកមួយគ្រាប់បាញ់បានសត្វប៉ុន្មាន? ព្រានតបថា បើតម្រង់ចំហ្វូងធំអាចបាន ២ទៅ៣ក្បាលដែរ។ ព្រះអរហន្តអង្គនោះញញឹមបន្តិច ហើយមានថេរៈដីការថា ព្រួញអាត្មាបាញ់បានសត្វតែមួយ ប៉ុន្តែសត្វដែលអាត្មាបាញ់បានគឺបានសុខគ្រប់ៗជាតិ ពោលហើយក៏និមន្តហួសទៅ។ **ហេងហ្អា** ឯងនៅតែម្នាក់មិនអាចទូលផែនដី ឬយកទ្រូងពាំងអសន្តិសុខពិភពលោកនេះបានទេ ហើយនេះក៏មិនមែនជាទោសរបស់អ្នកណាដែរ គឺជាទោសនៃកិលេសវដ្តៈតែប៉ុណ្ណោះ ដោយសារតែមានកិលេសវដ្តៈដែលជាបិសាចប្រចាំវដ្តៈនេះ ទើបមានកម្មវដ្តៈដែលជាអំពើ ឬការតាក់តែងកម្មសកម្មខ្មៅកើតឡើង ហើយទង្វើដែលប្រកបដោយតណ្ហាទាំងនេះ គឺតែងតែឱ្យផលជានិច្ចហៅថា វិបាកវដ្តៈនេះឯង។ រស់ក្នុងការគិតត្រូវ យល់ត្រូវទើបបានសុខ ព្រោះលះការប្រកាន់បានដូចជាសុបិន្តនិមិត្តរបស់ព្រះពុទ្ធឃើញព្រះអង្គនិមន្តចង្រ្កមលើភ្នំលាមក ប៉ុន្តែព្រះបាទារបស់ព្រះអង្គឥតមានប្រឡាក់លាមកនោះ

ឡើយ។ លាមក គឺតំណាងអំពើបាប ដែលបង្ហូរចេញពីអកុសលចិត្ត១២ ដែលជាចិត្តចោរហារយ (**ជាកិលេសវដ្ដៈដែលធ្វើឲ្យលោកនេះវិនាសទៅ**) ។ វេលាណាលោភៈកើនឡើងខ្លាំង វេលានោះផែនដីនឹងត្រូវវិនាសទៅ ដោយខ្យល់ ទាំងអស់នេះមិនមែនជាស្នាដៃរបស់ព្រះអាទិទេពណា បង្កើតទាំងអស់ គឺជាធម្មជាតិសុទ្ធៗ ផែនដីឆេះម្តងហៅថា **មួយកប្ប។** ផែនដីឆេះអស់ហើយទើបបិតក្រោមច្បាប់អន្តរកម្ម គឺអំពើរវាង ធាតុ និង ធាតុ (**ធាតុទឹក ដី ភ្លើង ខ្យល់ និងអាកាស**) កំណកំណើតជីវិតក៏ចាប់ផ្តើមមានជាថ្មីឡើងវិញ ហើយចេះតែវិវដ្ដចម្រើនឡើងជាបន្តបន្ទាប់ពីសត្វផ្សេងៗ រហូតមកដល់សត្វមនុស្ស តាំងពីមិនចេះស្លៀកពាក់ ចេះត្រឹមតែរស់នឹងធ្វើការបន្តពូជរហូតដល់ចេះស្លៀកពាក់ និងបំផ្លិតបំផ្លាញគ្នា (**មនុស្សគឺជាសត្វដែលចេះធ្វើនយោបាយ**) ចេះស្អប់ស្រលាញ់ហើយគុំគួនសងសឹក មនុស្សគឺជាមេរោគរបស់ផែនដី ទីបំផុតក៏ធ្វើឱ្យផែនដីនេះឆេះអស់ទៅវិញ ឆេះហើយកើត កើតពីឆេះចេះតែយ៉ាងនេះរហូតទៅទើបឱ្យឈ្មោះថា **វដ្ដ (រង្វង់វិលតជាប់គ្នាមិនដាច់**) នៅប្រមាណ១៥លានឆ្នាំទៀតប៉ុណ្ណោះទើបប្រភពអ៊ីដ្រូសែន តូលុយអែនក្នុងព្រះអាទិត្យត្រូវឆេះអស់ ហើយនៅពេលដែលតារាដ៏ធំមហិមានេះហៀបនឹងរលត់ វាបាន

ឆក់ក្លួចយកភពតូចៗមានផែនដីជាដើមចូលក្នុងគុំនួចភ្លើងដ៏ធំនោះ ឆេះសុសអស់ជាស្តាពរ នេះឯងជាមរណៈភាពរបស់ក្លួសារព្រះអាទិត្យ ក្រោមច្បាប់អនិច្ចតាធម៌ក្នុងសកលចក្រវាឡនោះ។ តើហេងឯងនិងខ្ញុំ នាងមុំ នាមស៊ុម អាផេង នាំគ្នាទៅណា? វាមិនចប់ទេព្រោះក្នុងអរូបកម្ម ដ្ឋាននាំឱ្យបានអរូបឈាន ឬអរូបសមាបត្តនោះ ព្រះពុទ្ធទ្រង់សម្តែងថា៖

១- **អាកាសាញ្ចាយតនៈឈាន** អាកាសមិនមានទីបំផុត (ហ្គាឡាក់ស៊ីក្លួសារផ្កាយក្នុងសកលចក្រវាឡក៏មិនអាចកំណត់បាន បើទីនេះមានជីវិតកកើតឡើងទីនោះក៏មាន បើទីនេះគ្មានទីនោះក៏គ្មាន)។

២- **វិញ្ញាណាញ្ចាយតនៈឈាន** វិញ្ញាណមិនមានទីបំផុត វិញ្ញាណកើតរលត់រាល់ថ្ងៃ រាល់សែនលានដងទាំងយប់ទាំងថ្ងៃ លុះត្រាវិញ្ញាណណាអស់តណ្ហាបីគឺ **កាមតណ្ហា ភវតណ្ហា វិភវតណ្ហា** ទើបវិញ្ញាណនោះរលត់ចូលក្នុងថាមពលសកលចក្រវាឡ (**កូស្មិចអឺណែជី**) លែងកើតទៀត បើវិញ្ញាណនៅមានតណ្ហាគឺនៅតែកើតរស់ ដូរជាតិដូរភពជាប់មិនដាច់ដូច្នេះឯង។

៣- **អាកិញ្ចញ្ញាយតនៈឈាន** ទីបំផុតបញ្ញាសំលឹងឃើញលោកនេះសូន្យទទេ សូន្យចាកសត្វបុគ្គលសូន្យចាកតួខ្លួន លោកនេះមិនមាន

អ្វីត្រឹមតែខន្ធទាំងឡាយ៥ **រូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ និង វិញ្ញាណខន្ធ** មិនមានអ្នកណាមានលើសមានខ្វះ គឺធម្មជាតិជាអ្នកប្រគល់ឱ្យស្មើរៗគ្នាក្នុងបញ្ហវោការភព (**ភពរបស់ខន្ធ៥**) មិនមានអ្វីគួរឱ្យកង្វល់ ព្រោះម្នាក់ៗសុទ្ធតែមានម្ចាស់គឺធម្មជាតិ ការកើតឡើងបាន ធំឡើងបាន ចាស់ទៅបាន ស្លាប់ទៅបាន គឺសុទ្ធតែធម្មជាតិជាអ្នកធ្វើទាំងអស់ (**ឥន្ទ្រិយចិត្ត កម្ម អាហារ រដូវ គឺក្តៅ ត្រជាក់**) លោកនេះមិនមានអ្វីគួរឱ្យប្រកាន់មាំព្រោះអ្វីៗសុទ្ធតែជាការភូតកុហកទាំងអស់ ស្រលាញ់ៗប្រែថាស្អប់ សុខៗប្រែថាទុក្ខ អ្វីដែលមានប្រែមិនមានវិញ មានយថាភូតញាណទស្សនៈ (**ការឃើញតាមសេចក្តីពិត**) អ្វីដែលកើតឡើងយ៉ាងណា មានយ៉ាងណា ប្រព្រឹត្តទៅយ៉ាងណា គឺពិតយ៉ាងហ្នឹង ចិត្តដែលប្រណីតកើតឡើងតាមរបៀបប្រណីត តាំងនៅតាមរបៀបប្រណីត រលត់ទៅវិញតាមរបៀបប្រណីត ចិត្តដែលថោកទាបតាំងកើតឡើងតាមរបៀបថោកទាប តាំងនៅតាមរបៀបថោកទាប រលត់ទៅតាមរបៀបថោកទាប ហើយការជួបជាបច្ច័យដល់ការព្រាត់ មានកើតទើបមានស្លាប់ មានហេតុទើបមានផល ពាក្យចែដន្យគឺបញ្ជាក់ពីអវិជ្ជារបស់ចិត្ត។ ប្រគល់អ្វីៗទៅឱ្យធម្មជាតិទាំងអស់ទៅយើងឥតកង្វល់ សក់រោមក្រចកស្បែក

ឆ្អឹង សាច់ សរសៃសុទ្ធតែជារបស់ធម្មជាតិ បើវាឈឺមើលបានក៏ចេះតែមើលទៅ បើមើលមិនបាន ក៏មិនបាច់ព្រួយខ្វល់ ព្រោះបើស្លាប់ទៅក៏គេចពីធម្មជាតិមិនរួច ត្រូវធម្មជាតិចាត់ចែងឱ្យត្រឡប់មកកើតជួបទុក្ខវិញដដែល។ លើលោកនេះគ្មានអ្វីពេញគ្មានអ្វីទទេ គ្មានអ្វីស្លាប់គ្មានអ្វីកើត គ្មានអ្វីចាស់គ្មានអ្វីថ្មី មានតែទុក្ខទេដែលតាំងនៅ មានតែទុក្ខទេដែលប្រែប្រួលទៅ ការកើតឡើងឡើង គឺជាកំណើតទុក្ខតែប៉ុណ្ណោះ។ ពេលជួបសុខមិនត្រូវត្រេកត្រអាល ភ្លើតភ្លើននឹងសុខនោះពេកទេ ព្រោះសុខនោះមិនទៀង ពេលជួបទុក្ខក៏មិនត្រូវកើតទុក្ខខ្លាំងពេកដែរ ព្រោះទុក្ខនោះក៏មិនទៀងដូចគ្នា (**លេះការប្រកាន់ឈ្មោះថា លេះហេតុនៃទុក្ខ**) ។ តាមពិតទៅហែងអើយ មនុស្សម្នាក់ៗដែលអាចរស់បានគឺសុទ្ធតែមានទស្សនវិជ្ជា (**វិជ្ជានៃការយល់ឃើញវិជ្ជាស្វែងរកសុខ**) ផ្ចាល់ខ្លួនដូចជារូបខ្ញុំកាលជំនាន់លោកពត ប្រពន្ធកូនត្រូវស្លាប់ចោលអស់ខ្ញុំរស់មានធម៌ជាទីពឹង ខ្ញុំយល់សច្ចៈធម៌ក្នុងធម្មជាតិ រូបខ្ញុំជាប់គុកលោកិយ ត្រូវហែលក្នុងរលកកំហឹងរបស់ចិត្តអកុសលនៃពួកអង្គការអាវខ្មៅ ខ្ញុំទទួលបានបទពិសោធន៍ពិតពីធម្មជាតិដែលមានព្រះធម៌ជាប្រទីបបំភ្លឺផ្លូវជីវិតរបស់ខ្ញុំ។ ស្មារតីខ្ញុំរឹងមាំណាស់ បើធ្វើអ្វីមិនបាន បានត្រឹមគិតនាំឱ្យចិត្តខ្សោះ

ថាមពល នាំឱ្យបញ្ញាទុរពលឥតប្រយោជន៍ **ហោងហ្អា** មិនមែនថា យើងព្រមវិនាសតាមគ្រប់រឿងនោះទេ ប៉ុន្តែសម័យណាដែលយើងគិតហើយធ្វើមិនកើតសម័យនោះសឹមគិតសឹមធ្វើ កុំយល់សប្តិបើកភ្នែកឱ្យសោះហើយក៏មិនត្រូវបិទភ្នែកបំភ្លេចខ្លួនឯងនោះដែរ អ្វីៗគឺមានតែត្រូវថ្លឹងថ្លែងឱ្យបានសមរម្យតែប៉ុណ្ណោះ ទើបព្រះពុទ្ធលោកប្រដៅឱ្យគិតត្រូវ យល់ត្រូវដែលជាតួវិបស្សនាសុទ្ធសាធនេះឯង។ **អើហ៎ហោង**! អរូបសមាបត្តិទី៤ គឺនេវសញ្ញានាសញ្ញាយតនៈ ប្រែមកថា មានសញ្ញាដ៏ល្អិតថាមានក៏បានថាគ្មានក៏បាន តើនេះហោងឯងយល់ដូចម្តេច? ស្តាប់ពូមានប្រសាសន៍កំពុងតែពិរោះស្តុងចិត្ត ស្រាប់តែមកសួរឯងផូងឯណេះទៅវិញ ប៉ុន្តែខ្ញុំនឹងព្យាយាមឆ្លើយជូនពូខុសត្រូវយ៉ាងណាសូមជួយបំពេញផង។ តាមពិតអាណាចក្រជាបញ្ញាផ្លូវលោក គឺពិតជាត្រូវដើរទន្ទឹមនឹងពុទ្ធចក្រមិនអាចខ្វះបានឡើយ វាដូចជាបញ្ញា និងមេត្តាករុណា ត្រូវដើរស្របគ្នាដូច្នោះដែរ ព្រោះមានតែបញ្ញាគ្មានមេត្តាទើបទីក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្គាណាគីរបស់ប្រទេសជប៉ុនត្រូវគ្រាប់បែកបរមាណូធ្លាក់ពីលើ ស្លាប់អស់មនុស្សឥតកំហុសវាល់លាននាក់ ព្រោះមានតែមេត្តាឥតបញ្ញាទើបក្សត្រកូលត្រូវស្តេចវិឌូឌភៈ កាត់កឱ្យស្លាប់វិនាសផុតពូជពីផែនដីអស់ ហើយត្រូវ

កើតជាថ្មីដោយកែឈ្មោះ កែត្រកូល។ ចំពោះអរូបសមាបត្តិ៤ បើតាមខ្ញុំយល់គឺ ព្រះពុទ្ធទ្រង់សម្តែងយ៉ាងខ្ពស់ សញ្ញាដ៏ល្អិតថាមានក៏បាន ថាគ្មានក៏បាន នោះគឺអ្វីក្រៅពីធម្មធាតុដ៏សែនតូចល្អិតឆ្មារ សម្លឹងឃើញដោយសព្វញ្ញាតញ្ញាណ (**បញ្ញាដឹងសព្វឥតចន្លោះ**) គឺអាតូមនិងម៉ូលេគុលដែលជាធាតុផ្សំឱ្យកើតរូប និងវិញ្ញាណនេះឯង វាល់លានរូប វាល់លានវិញ្ញាណសុទ្ធតែជាការគួបផ្សំនៃអាតូម និងម៉ូលេគុលនេះទាំងអស់ដល់វេលាដែលសម្ព័ន្ធកូវ៉ាឡង់របស់វាសឹករិលអស់កាលណា ទោះជាគេខំយកធាតុគីមី (ថ្នាំ) ថ្មីៗបែបណាយកមកប៉ះប៉ូវក៏សម្ព័ន្ធកូវ៉ាឡង់នោះនៅតែបែកធ្លាយ មិនអាចគង់វង្សបាន។ បញ្ញាថ្នាក់ភវនាឃើញច្បាស់យ៉ាងនេះ ទើបលែងប្រកាន់ហួងហែងក្នុងរូប ក្នុងសម្លេង ក្លិនរស ផោដ្ឋព្វៈ និងអារម្មណ៍ លែងប្រកាន់ថាជាយើង ភ្នែកត្រចៀក ច្រមុះ អណ្តាតកាយចិត្តជារបស់យើង ចិត្តក៏បានស្ងប់ស្ងាត់ចាកកាម ព្រោះកើតវិវេគនឿយណាយឆ្ងាយចាករឿងរ៉ាវក្នុងលោក ហើយលើកចិត្តចូលកាន់សញ្ញាវេទយុតនិរោធ ឬនិរោធសមាបត្តិចម្រើនវិបស្សនាបានរលត់អស់អាសវៈកិលេស និងអវិជ្ជាសវៈបានជាព្រះអរហន្តផ្ទែកចេតោវិមុត្តិ សមថយានិកបុគ្គល។ ប៉ុន្តែការចូលនិរោធសមាបត្តិ គឺទាល់តែបានសម្រេចរូប

សមាបត្តិ៤ និងអរូបសមាបត្តិ៤តាមលំដាប់សិនទើបចូលបាន ហើយ ព្រះអរហន្តចេតោវិមុត្តិបើលោកចង់បានចម្រើនវិបស្សនា លោកក៏បង្អោនចិត្តចូលកាន់វិបស្សនាតាមកាលគួរ ឯព្រះអរហន្តបញ្ញាវិមុត្តិ លោកអស់អាសវៈកិលេសដោយវិបស្សនាបញ្ញាកំណត់សតិទល់ទាន់សភាវៈខាងក្រៅ ធ្វើឱ្យកិលេសរីងស្ងួតអស់ ហើយបើលោកយល់ថា លោកនៅខ្វះសមាបត្តិលោកក៏បង្អោនចិត្តមកចម្រើនសមថៈឱ្យបានសមាបត្តិតាមកាលគួរ ព្រោះការចូលនិព្វានតាមសមថៈយានិកបុគ្គល គឺលោកផ្អែកលើឈានសមាបត្តិលោកកំណត់កាលបរិនិព្វានហើយ ទើបចូលឈានជាអនុលោមបដិលោកបិទដង្ហើមបិទបេះដូងរំលត់វេទនានិងសញ្ញា ក្រោយពីចូលតេជោកសិណឧទ្ធិសដ្ឋានចិត្តឱ្យតេជោធាតុចម្រើនឡើងឆេះកាយរលាយខ្សុល ឥតសេសសល់ ត្រលប់ចូលថាមពលសកលចក្រវាឡ (**ថាមពលកូស្មេច**) លែងត្រលប់កើតទៀតគឺជាជោគជ័យដ៏ធំជ័យជំនះឈ្នះលើសេចក្តីស្លាប់ជាស្ថាពរ លោកដាក់ភារៈលែងជួបកង្វល់នៅក្នុងបញ្ហាទុក្ខតទៅទៀត។ ចូលបរិនិព្វាន គឺជាមរណៈធម៌ដ៏សុខអស្ចារ្យ ព្រោះមិនស្លាប់តាមកម្មចាត់ចែងឱ្យឈឺពីតចុកចាប់ នៅកើតទុក្ខវេទនាគ្រាំគ្រាយូរអង្វែង មិនដូចពួកបថុជ្ជន ជនក្រាស់ដោយ

កាមដែលត្រូវស្លាប់តាមកម្មគ្រប់ៗគ្នា។ ឯព្រះអរហន្តបញ្ញាវិមុត្តិ ឬសុក្ខ
វិបស្សកៈដែលជាវិបស្សនាយានិកបុគ្គលសុទ្ធសាធ គឺលោកមិនអាច
កំណត់កាលវេលាដើម្បីចូលបរមនិព្វានបានទេ លោករងចាំកាលមរ
ណៈមកដល់ ហើយកំណត់ទុក្ខវេទនាដែលកើតឡើងឱ្យត្រឹមតែជាទុក្ខ
វេទនាប៉ុណ្ណោះ ហើយក៏បរិនិព្វានទៅ។ ហេតុនេះដើម្បីសោះស្រាយ
បញ្ហាទុក្ខ តាមគំនិតខ្ញុំគឺត្រូវតែដោះស្រាយឱ្យដល់រឹសគល់បញ្ហាទើបជា
ការបញ្ចប់ទុក្ខពិត នោះគឺជាមធ្យោបាយរំលត់តណ្ហាតាមអដ្ឋង្គិកមគ្គ
ដែលជាមគ្គមានអង្គ៨ ដ៏បរិសុទ្ធស្អាតផូរផង់នោះឯង ថ្វីត្បិតតែអាចមាន
ការរំខានពីកិលេសតណ្ហាខ្លះ តែសំខាន់ដែលយើងមានឆន្ទៈក្នុងការដោះ
ស្រាយឱ្យចប់បញ្ហាទាំងស្រុងនោះទើបជាការគួរ។ **ខ្ញុំថាហ្នឹងត្រូវទេពូ?**
អើហ៎រ៉ឺ! ដល់អ្នកវិទ្យាសាស្ត្រគេចេះធម៌ ដៃរនេះស្តាប់ទៅកំពុងតែពិរោះ
ជក់ចិត្តសម្បើមណាស់តែបែរជាឈប់ទៅវិញ គួរឱ្យស្តាយព្រោះកំពុងតែ
ក្រេបធម្មរសផ្អែម ត្រជាក់ដល់ខួរឆ្អឹង ផ្សាយបីតិឱ្យព្រឺព្រួចសព្វសាច់
សរសៃដង្ហើមរកកលរលត់ម្តងៗ ឯបេះដូងវិញសម្រាកស្ងប់សឹងលែង
កម្រើកព្រោះតែចិត្តស្ងប់ក្នុងធម៌។ អស្ចារ្យណាស់ មជ្ឈឹមបដិបទារបស់
លោកឪ ចង់អ្នកវិទ្យាសាស្ត្រក៏យល់តាមបែបវិទ្យាសាស្ត្រទៅ ចង់អ្នក

សេដ្ឋកិច្ចស្តាប់ក៏យល់តាមបែបអ្នកសេដ្ឋកិច្ចទៅ ចង់អ្នកនយោបាយស្តាប់ក៏យល់តាមបែបអ្នកនយោបាយទៅ ហ្ន៎ក! វាស៊ីយឯពួករៀនធម៌តែមួយមុខឯនេះវិញ ដែលស្តាប់ហើយស្រាប់តែមានៈប្រកាន់ក្នុងធម៌ប្រកែកគ្នាតាមប៉ុស្តិ៍វិទ្យុបែកពពុះមាត់ អត់មានអ្នកណាហុចក្រដាស់ជូតមាត់ឱ្យមុខគួរឲ្យសង្វេគណាស់ សួរថា ក្នុងខន្ធ៥មានអញទេ? ឆ្លើយថាអត់ទេ តែបែរជាត្រកងកន្ទុយតាមទិចគ្នាដូចខ្ជួយកុំឱ្យតែអ្នកណានិយាយប៉ះពាល់ទិដ្ឋិខ្លួន ធ្វើដូចជា ធម៌ព្រះនេះជាធម៌របស់ខ្លួន អញ្ចឹងសម្តែងធម៌ព្រះវិលៗសម្តែងតែពីទិដ្ឋិរបស់ខ្លួន មិនសម្តែងតាមធម៌ឱ្យបានត្រឹមត្រូវទេ នេះបានជាចំជាព្រឹត្តិការណ៍ចុងកប្បមែន។ **លោកក្ជួយហេងហ្ក៉ា** យើងនាំគ្នានិយាយតែធម៌ក្រៅៗមិនដឹងថា នាងមុំស្តាប់បានខ្លះឬអត់ទេហ្ន៎? ខ្ញុំអត់ចេះអីទេ តែស្តាប់ទៅហើយបញ្ជូនចិត្តត្រិះរិះតាមក្រសែធម៌ ក៏ចេះតែពិរោះឡើងពិរោះឡើង។ **ណ៎ោ** តើក្ជួយមុំឯងពិរោះនឹងសម្លេង ឬពិរោះសាច់ធម៌ ខ្លឹមសារធម៌ហ្ន៎ះ? (តាសនសួរនាងមុំយ៉ាងសង្វើញ) **យ៉ស់តា!** ពិរោះតែទាំងពីរយ៉ាងហ្នឹងណា អាណាទៅពិរោះមនុស្សត្រដិត ឬក្លរសម្តែងធម៌ល្មេចកើតទេនែក៎ និយាយរួចមុំសើចកាច់កកាច់ស្រង់ ឯតាសនធ្វើច្រមុះម្រីកៗដូចក្របីហិតបាវស្រូវ។ ឯពូហេង

បុកពោះចង់សើចដែរ តែនឹកអាណិតអ្នកក្បែរ លោតែគ្នាចេះធម៌ដែរហើយ ចង់សម្តែងធម៌ មិនដឹងជាគ្នាពិបាកយ៉ាងណាទេ? កំពុងតែស្តុងអារម្មណ៍ស្រាប់តែត្រូវពញ្ញាក់ស្មារតីដោយសារដៃលោកតាសនលូកកេះ ៖ **ណ៎ាក្មួយ អញឆ្ងល់!** ពីដើមឪអញ តាអញ ជក់បារីគ្រប់គ្នា តែមិនដែលឮថាមានអ្នកណាមួយស្លាប់ដោយសារផ្សែងបារីលាន់ទឹកលាន់ដី តើរឿងនេះវាយ៉ាងម៉េចហ្ន៎លោកក្មួយ? **ពូពេទ្យហោងតប៖** វាមិនដែលថាពីដើមនោះមិនមានអ្នកស្លាប់ដោយសារផ្សែងបារីខ្ញុំមិនជឿទេពូ វាមានស្លាប់ដូចតែគ្នាហ្នឹង គ្រាន់តែប្រព័ន្ធព័ត៌មានវាមិនសូវសំបូរដូចសព្វថ្ងៃនេះ ហើយនេះវិទ្យាសាស្ត្រគេជឿនលឿនគេស្រាវជ្រាវដឹងពីមូលហេតុនិងគ្រោះថ្នាក់ដោយសារផ្សែងបារីហ្នឹងណាពូ ប៉ុណ្ណឹងហើយនៅអ្នកជក់គេថាបារីគឺជាអាហារផ្សែងដ៏ពិសិដ្ឋទៀតផង។ នៅក្នុងផ្សែងបារីមានសារធាតុពុលប្រមាណជាង ៤000ប្រភេទ ដែលក្នុងនោះនោះគេចែកចេញជា៥ក្រុមគឺ៖

១- **ក្រុមធ្វើឱ្យពុលផ្ដាល់ទៅលើគ្រាប់ឈាមក្រហម** គឺកាបូនឌីអ៊ុកស៊ីតធ្វើឱ្យអ្នកជក់មានសភាពស្លេកស្លាំងជាប់ជាប្រចាំ។

២- **ក្រុមធ្វើឱ្យរលាកក្រអូមមាត់ រលាកអញ្ចាញធ្មេញ រលាកអណ្តាត រលាកក្រពះ រលាកទងសួត** ជាតិពុលនេះជ្រាបចូលក្នុងឈាមធ្វើឱ្យរលាកសរសៃឈាម ក្រិនសរសៃឈាម កើតជំងឺលើសសម្ពាធឈាម ឡើងឈាម ក្រិនសរសៃឈាមចិញ្ចឹមបេះដូងដែលនាំឱ្យស្ទះឈាមមិនអាចចិញ្ចឹមសាច់បេះដូងបាន នាំឱ្យរលួយសាច់ដុំបេះដូង រលួយសាច់ខួរក្បាល ស្លាប់មួយចំហៀងខ្លួន។ ជាតិពុលនេះនាំឱ្យខ្វិនព្រុយរំញ័រ សម្រាប់សំអាតទងសយត ជាហេតុនាំឱ្យមេរោគដែលចូលតាមផ្លូវដង្ហើមទៅក្នុង សាច់សួតមិនអាចបោសសំអាតឱ្យចេញតាមកំហាកវិញ បានបណ្តាលឱ្យរលាកសាច់សួត កើតបូសសួត ងាយកើតរបេង ក្រិនទងសួត រីកទងសួត។ ជាតិពុលនេះធ្វើឱ្យប្រព័ន្ធការពារទប់ទល់នឹងមេរោគចុះខ្សោយ នាំឱ្យងាយកើតជំងឺឆ្លងច្រើនបែបច្រើនយ៉ាង នឹងងាយកើតជំងឺមហារីក។

៣- **ក្រុមដែលនាំឱ្យមានបាតុភូតរលាកកើនឡើង** ដែលជំរុញនាំឱ្យកើតប្រព័ន្ធបំផ្លាញខ្លួនឯងនាំឱ្យឈឺសន្លាក់ ចុកចាប់សាច់ដុំ។ល។

៤- **ក្រុមដែលបង្កឲ្យកើតមហារីកដោយផ្ទាល់** គឺកំណកហ្គូជ្រុង (បឺតផ្សែងបារី រួចផ្លុំដាក់ក្រចកមេដៃនាំឱ្យឃើញប្រេងខ្មៅកកលើក្រចក) នាំឱ្យមានមហារីកក្រពះ មហារីកជើងធ្មេញ អណ្តាត ទងសួរ។ល។

៥- **សារធាតុនាំឱ្យញៀនគឺកូទីន** វាក៏នាំឱ្យឡើងកម្តៅក្នុងខ្លួនរ៉ាំរ៉ៃ ជាហេតុនាំឱ្យអ្នកជក់មានរាងកាយស្គមស្គាំង ស្បែកជ្រីវជ្រួញ មុខជាំ។ បារីដែលជក់លឿនអស់៤កញ្ចប់ ក្នុងរយៈពេល១៥នាទីនាំឱ្យស្លាប់បាន ស្លាប់ដោយសារជាតិកាបូនឌីអ៊ុកស៊ីត ភ្ជាប់នឹងអេម៉ូក្លូប៊ីនមិនអាចឱ្យ ចាប់យកអុកស៊ីសែនបាន។ បើធៀបការចំណេញដោយសារពន្ធអាករ នឹងវិនាសកម្មរបស់ប្រជាជនគេពុំគួរផលិតបារី ដើម្បីសម្លាប់មនុស្សនោះ ឡើយ។ បារីធ្វើឱ្យកូនក្នុងផ្ទៃងាយរលូត ឬកើតមិនគ្រប់ខែ ឱ្យកូនកើត មិនគ្រប់គីឡូ បារីធ្វើឱ្យដំបៅព្រះ ធ្វើឲ្យរលួយចុងដៃចុងជើងជក់បារីមិន ត្រឹមតែដុតលុយចោលប៉ុណ្ណោះទេ គឺបំផ្លាញសុខភាពហើយត្រូវមក ចំណាយលុយទៅលើថ្នាំព្យាបាលការធ្វើទុក្ខរបស់បារីទៀតផង។ **តាសន ជញ្ជក់មាត់ចក់ៗហើយគ្រវីក្បាលតបកាត់**ៈ បារីបំផ្លាញជាតិដល់ម្តងហ្ន៎? មួយខែៗគេជក់រាប់តោន ខ្លះមិនបានជក់ខ្លួនឯងមិនអស់ចិត្ត ទៅទិញ ប្រគេនលោកឱ្យលោកឆាន់ឱ្យឆាប់សុគតទៀត។ ឯលោកនោះទៀត

សោត ប្រឹងឆាន់អត់ដឹងដាច់សិក្ខាបទពីការប្រើប្រាស់គ្រឿងញៀនស្រវឹងទេនោះ។ **តែអ៊ំឆ្ងល់ហេតុអីគេមិនចេញច្បាប់ឈប់ឱ្យជក់បារីហ្ន៎?** គេចង់ធ្វើដែរតែទាក់ទងនឹងច្បាប់សិទ្ធិមនុស្សគេមិនអាចបង្ខិតបង្ខំ បំបិទសិទ្ធិសេរីភាពអ្នកជក់បារីរ៉ាល់លាននាក់បាននោះទេ គឺមានតែបង្កើតច្បាប់ហាមជក់បារីនៅក្នុងទីប្រជុំជនក្នុងទីធ្លាសាធារណៈ ត្រូវជក់ក្នុងកន្លែងដែលគេអនុញ្ញាតតែប៉ុណ្ណោះ គេកំណត់អាយុដែលមិនអាចឱ្យជក់បានផងដែរ។ ម៉ូយខ្ញុំសុទ្ធតែជក់បារី ធឹកស្រាភាគច្រើន តើអាចមានគ្រោះថ្នាក់ដល់ខ្ញុំទេពូ? (នាងមុំសួរ) ។ គ្រោះថ្នាក់ដូចគ្នា ព្រោះឯងហឺតផ្សែងបារីជាមួយគេដែរ (ពូពេទ្យតប)។ **ហ៊ឺ!** មុខរបរចិញ្ចឹមជីវិតខ្ញុំត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ច្រើនបែបច្រើនយ៉ាងណាស់ហ្ន៎? (នាងមុំពោល) ។ បើដើរចេញពីមុខរបរនេះទៅប្រកបមុខរបរដែលប្រសើរជាងនេះវិញតើអាចទេ? (តាសនបែរមកសួរដោយជ្រួញចិញ្ចើមផង)។ ថាខ្ញុំទៅរាវរែទនាមានមិត្តភក្តិខ្ញុំខ្លះត្រូវរងទុក្ខវេទនាជាងខ្ញុំទៅទៀត ខ្ញុំរកស៊ីឯករាជ្យទេពេលណាអស់កម្លាំងខ្ញុំមិនចេញរកនៅសំងំសម្រាកផ្ទះទៅ អ្នកខ្លះសម្រេចចិត្តថា ឈប់រកស៊ីលក់ខ្លួនហើយទៅទទួលបន្លែផ្លែឈើលក់វិញ តែត្រូវពួកអាអ្នកធ្លាប់ស្គាល់វាតាមទៅគោះទ្វារហៅសុំដេកជាមួយង៉ោ

ចៗ រំលងអាគ្រាត្រក៏មិនទៅណា ពេលខ្លះវាចូលចាប់ដល់បន្ទប់ផងក៏មាន គ្នាពិបាកពេកក៏ត្រឡប់ចូលដានចាស់វិញដដែល។ ខ្លះដល់ទៅហ៊ានស្បថសច្ចាថ្វាយចេកយាយពេញ យាយម៉ៅ ស្មាលា ឈប់ប្រព្រឹត្តិអំពើបាបនេះតទៅទៀត គ្រាន់តែចុះពីបន់ពីចេតិយវត្តភ្នំភ្លាម ត្រូវពួកវាអូសដៃឡើងឡានយកទៅវ៉ែសិចបាត់ នេះបានចំ! គ្នាខំពន្យល់ថាប្រយ័ត្នបាប វាថាធ្លាក់នរកល្អណាស់ព្រោះមានញីមានឈ្មោល មានអ្នកលក់ស្រា អ្នកខ្វៃផ្លែក ជល់មាន់ បៀរ អាប៉ោងអីជួបជុំគ្នាទាំងអស់មិនគួរអូនព្រួយទេ មើលវានិយាយចុះពូ! អ្នកមានសាច់ស្អាត ត្រូវតាៗលបចិញ្ចឹមដោយលួចលាក់ គាត់យកទៅពិនិត្យឈាមរាល់ខែគេគ្រាន់មានសំណាង ប៉ុន្តែត្រូវរស់នៅភ្នែកសេកភ្នែកលលក ព្រោះភ្នាក់ងារយាយប្រពន្ធដើមតាមស៊ើបអង្កេតគ្រប់ជំហាន តាមប្រមាញ់ទឹកអាស៊ីត តាមបាញ់សម្លាប់ផងក៏មាន។ មាន់គកដែលអន់ គឺអាគកដែលឈរមើលមេមាន់ជល់សម្លាប់គ្នាព្រោះតែវាម្នាក់ វានៅរងាវធ្វើឫកក្រអឺតក្រទមទៀត មិនព្រមជន្លៀសមេឆ្នាស់ ឬមេខ្សោយឱ្យជៀសផុតពីការប្រហារគ្នា ខុសតែមេមាន់ខ្ញុំ បើដល់កខ្ញុំពិតជាកាត់ខ្នាយអាគកនោះចោលជាមិនខានសុខចិត្តឱ្យវាអត់លិទ្ធទាំងអស់គ្នាទៅចុះ។ **ណ៎ាក!** នៅមានអ្នកពិបាក

បំផុតទៅទៀត ណាអ៊ំ! គឺពួកអ្នកលេងថ្នាំញៀនតាមហាងរបស់គេ ណា ត្រូវខំរកលុយបង់ថ្លៃបន្ទប់ ថ្លៃអាហារ និងថ្លៃថ្នាំញៀនដែលថៅកែលក់ឱ្យ ទីបំផុតការញៀនថ្នាំចេះតែបំផ្លាញសុខភាពឱ្យទ្រុឌទ្រោមទៅៗ ស្មារតី ត្រូវរង្វេងលែងដឹងទិសតំបន់អ្វីទាំងអស់ ដឹងតែទារថ្នាំតែម្យ៉ាង ពេល ស្វាងថ្នាំអស់ជាតិថ្នាំពីក្នុងឈាមគឺធ្វើទុក្ខខ្លាំងណាស់ ចុកចាប់សព្វ សរពាង្គកាយទៅជាប្រកាច់ អត់លុយទិញថ្នាំត្រូវគេប្រើឱ្យធ្វើអី គឺធ្វើហ្នឹង ឱ្យសម្លាប់គេក៏សម្លាប់ ឱ្យលួចគេក៏លួច ឆ្នាំមុននៅក្បែរលូរទឹកស្អុយ គ្រាន់តែប្រពន្ធជក់ថ្នាំលើសប្តីបន្តិច ត្រូវប្តីកាប់ដាច់កស្លាប់ចោលកូន បាត់ទៅ។ នាងៗអ្នកញៀនថ្នាំហ៊ីហាតែពីដំបូង ទីបំផុតនៅពេលដែល រកលុយឱ្យថៅកែលែងបាន ហើយក៏ត្រូវគេធាក់ក្បាលបណ្តេញចេញ ក្លាយជាមេឆ្កែអង្កែស៊ីមួយក្បាលដើររើសអាហារសំណល់ក្នុងគំនរ សម្រាម ស៊ីឥតមានគេរាប់រកយ៉ាងអាណោចអាធមជាទីបំផុត។ តើនេះ មកពីផលកម្មអ្វីដែរទៅ? **ហ៎្គលោកតា?** ពូពេទ្យហែងនឹកដល់ត្រង់នេះគឺ គាត់គិតឃើញមានជាប់ ដោយហេតុបច្ច័យច្រើនណាស់ មិនដឹងថាតើ ត្រូវឆ្លើយពីណាទៅចប់ត្រឹមណា មានតែក្រាលចិត្តមេត្តាករុណាគ្របដ ណ្តប់លើសត្វទន់ខ្សោយ សត្វល្ងង់ខ្លៅអស់នោះតែប៉ុណ្ណោះ គាត់ចាប់

ភាវនាផ្សាយមេត្តាទៅសព្វសត្វដើម្បីរំងាប់ក្តីរំជួលចិត្ត ព្រោះក្នុងប្រវត្តិសាស្ត្រដ៏យូរលង់ ស្តេចសាងបាបរាស្ត្រធ្លាក់នរក ៖ **រូប១ ប្រាណ១ បុគ្គល១ អត្តភាព ១ ភូត១** ទៅលើរហូតដល់ជតាកាសទៅក្រោមដល់អវចីមហានរក ទិសទទឹងទាំង៨ដល់សែនកោដិចក្រវាឡ សូមបានទទួលនូវក្តីសុខគ្រប់ៗគ្នា កុំបីមានក្តីវិនាសចាកកុសលធម៌ ចាកគុណធម៌ជាមនុស្ស ជាទេវតា ជាព្រហ្ម សូមបានរក្សាខ្លួនជាសុខចុះ កំពុងតែសង្វេគស្រាប់តែលោកតាសនចាប់មានប្រសាសន៍៖ អ្វីៗកើតឡើងព្រោះមានហេតុទាំងអស់ ហេតុតែល្ងង់ទើបគិតចេះតែខុស មានមនុស្សល្ងង់សុទ្ធតែព្រមធ្វើនុយឱ្យមនុស្សឆ្លាត ប្រើប្រាស់ទាំងអស់ ព្រះអាទិទេពបង្កើតផែនដីមកនេះ គឺទុកសម្រាប់តែមនុស្សឆ្លាតនៅតែប៉ុណ្ណោះ ឯមនុស្សល្ងង់នឹងត្រូវស្លាប់រកដីកប់គ្មាន ធម្មជាតិនៃទឹក គឺអាចទ្រ នឹងអាចពន្លិច រីឯអំនួតក៏ដូចគ្នា នៅលើក្តារអុកជីវិតមនុស្សឆ្លាត បើត្រូវដើរតួជាកូនអុក ត្រូវគេឱ្យច្រៀងក៏មិនសប្បាយភ្លើតភ្លើនភ្លេចខ្លួនចងក្រឡាការពារជីវិតដែរ ចំណែកមនុស្សល្ងង់បើត្រូវគេឱ្យច្រៀងក៏ចេះតែប្រឹងច្រៀងរហូតដល់ត្រូវបច្ចាមិត្រអុកដួល បះជើងស្លាប់ទាំងមិនដឹងខ្លួន នេះឯងជីវិត គឺជាការស៊ីគ្នានោះ។ លោកនេះមានយុត្តិធម៌តាមឋានានុក្រម

របស់វា យុត្តិធម៌ក្នុងសង្គមមនុស្សគឺគ្មានទេព្រោះវាកើតឡើងក្នុងចិត្តមនុស្សតែប៉ុណ្ណោះ មនុស្សយកកិលេសផ្ទាល់ខ្លួនទៅថ្លឹងព្រឹត្តិការណ៍ហើយវាយតម្លៃតាមតណ្ហារៀងៗខ្លួន អ្នកឈ្នះទទួលបានយុត្តិធម៌ ឯអ្នកចាញ់ឈឺចាប់តូចចិត្តហើយស្រែកថាទទួលបានអយុត្តិធម៌ អ្នកឈ្នះបានត្រឹមបង្ករពៀរ អ្នកចាញ់ព្យាយាមចងពៀរស៊ីសងគ្នារហូត។ ព្រះដែលបង្កើតលោកមកនេះ មិនបានផ្តល់សុខឱ្យដល់សត្វលោក ដូច្នោះមិនដឹងជាប្រឹងបង្កើតមកធ្វើអី ហើយពេលសត្វលោកបួងសួងសុំរកយុត្តិធម៌ក៏ធ្វើអីមិនកើត នេះជាព្រះគ្មានអានុភាព ព្រះមានពុតត្បុត ព្រះមានកិច្ចកលមាយា ជាព្រះភូតភរតាមបច្ចេកទេសសណ្តំព្រលឹងឥតសច្ចៈធម៌ឡើយ។ អ្វីៗកើតឡើងព្រោះមានហេតុតណ្ហាជាហេតុទុក្ខជាផល អវិជ្ជាជាហេតុ ទុក្ខជាផល មិនទៀងជាហេតុ ទុក្ខជាផល។ អ្វីដែលលើសពីសមត្ថភាពយើង យើងមិនអាចធ្វើបានឡើយ ព្រះពុទ្ធទ្រង់មានព្រះទ័យករុណាចង់ប្រោសប្រទាន ឱ្យសព្វសត្វបានរួចផុតចាកទុក្ខ ហេតុនេះ អ្វីដែលមនុស្សអាចធ្វើបាន គឺចាប់ផ្តើមពីខ្លួនឯងនេះហើយយើងមិនអាចទៅស្វែងយល់ ពីពិភពដែលយើងមិនដែលស្គាល់ មិនដែលឃើញ ដូចជា ស្វែងយល់ពីជីវភាពព្រះអាទិទេព ស្វែងយល់ពីបុគ្គលិកលក្ខណៈ

របស់តួអង្គអាទិទេពណាមួយក្នុងលោក ដែលពិបាកដឹងបាននោះឡើយ។ ប៉ុន្តែយើងមិនអាចចេះដឹងយល់បានភ្លាមហើយដែលអាចពិសោធន៍បាននោះគឺ សេចក្តីពិតដែលបិតនៅក្នុងខ្លួនយើងនេះហើយជាថ្នាក់ដំបូងដែលត្រូវពិចារណាឱ្យបានល្អិតល្អន់ ទៅលើកិច្ចការងារក្នុងជីវិតប្រចាំថ្ងៃ នឹងការប្រព្រឹត្តរបស់យើង កិច្ចបដិបត្តិនោះមិនមានអ្វីក្រៅពីហេតុនិងផល ដែលមានខ្លួនយើងជាអ្នកប្រព្រឹត្តិនេះឯងជាមហាបញ្ញាត្តិកម្ម ដែលជាផលវិបាកតាមហុចឱ្យយើងគ្រប់ជំហាន ហេតុនេះបើយើងចេះសាងកម្មល្អយើងនឹងទទួលផលល្អ បើយើងសាងតែកម្មអាក្រក់នឹងទទួលផងអាក្រក់ (**កម្មដ៏តិចតួចលើលោកមែងមិនឲ្យផលមិនមាន**) បើយើងឈរហើយបោះដុំថ្មមួយដុំឱ្យត្រង់ឡើងទៅលើហើយយើងកុំគេច ពេលនោះបើទោះជាក្បាលស្តេច ក្បាលមន្ត្រីសេដ្ឋី អ្នកមាន អ្នកក្រ អ្នកសុំទាន ឬអ្នកបួសក៏នឹងត្រូវរយះក្បាលមួយដុំថ្មហូរឈាមកក្លាក់ដូចគ្នា (**អ្នកណាធ្វើអ្នកហ្នឹងជាអ្នកទទួល**) ព្រោះហេតុនេះចង់ដោះស្រាយបញ្ហាទុក្ខ គឺត្រូវចាប់ផ្តើមដោះស្រាយពីក្នុងចិត្តយើងនេះទៅជាមុនសិន ដោះស្រាយឱ្យឈ្នះខ្លួនឯង ឈ្នះមានះ តណ្ហា ឧបាទាន ការប្រកាន់មាំជាដើម។ ធម៌ទាំងឡាយកើតពីហេតុ គប្បីរំលត់ហេតុនោះ

ចោលចេញទើបបានដល់នូវសេចក្តីសុខ។ លាភសក្ការៈតែងជាន់ពន្លិចជនថយថោកបានយ៉ាងណា ហើយបើលាភសក្ការៈនោះជាផលនៃអកុសលកម្ម នោះវានឹងជាន់ពន្លិចយើងក្នុងថ្ងៃណាមួយជាមិនខានគ្រាន់តែយូរនឹងឆាប់តែប៉ុណ្ណោះ។ នេះឯងសេដ្ឋកិច្ចកំណត់មនសិការនោះ ស្ថានភាពធ្លាក់ចូលក្នុងសភាពស្ងប់ស្ងាត់ អស់មួយស្របក់ទើបលោកតាសនគ្រហែម ហើយពោលទាំងជ្រួញចិញ្ចើម៖ សង្គមសព្វថ្ងៃមានទំនោរទៅសេពគ្រឿងញៀនស្រវឹងនេះច្រើនណាស់ណាលោកក្មួយ។ តើសុរានេះមានផលប៉ះពាល់យ៉ាងណាខ្លះដែរមកលើសុខភាពមនុស្ស? ពូពេទ្យហេងទ្រឹងមិនទាន់ឆ្លើយដោយយកម្រាមដៃច្បូតចង្ការហើយនិយាយមួយៗថា មានការប្រជុំវិទ្យាសាស្ត្រមួយផ្នែកសុខភាពនៅទីក្រុងទ្បុងដ៏ ពិភាក្សាគ្នាពីរឿងសុរានេះ បើគេទទួលទានស្រាទំពាំងបាយជូរមួយកូនកែវរាល់ថ្ងៃជាប់ជាប្រចាំ នោះនឹងអាចកាត់បន្ថយគ្រោះថ្នាក់ ដែលបណ្តាលមកពីជំងឺបេះដូងបាន។ ប៉ុន្តែបញ្ហាចោទជាសំខាន់នោះគឺ ពិបាកទប់ទល់ត្រង់ជាតិអាល់កុលវានាំឱ្យញៀន ដោយតម្រូវឱ្យអតិថិជនមានការប្រើប្រាស់កាន់តែច្រើនឡើងដែលនាំឱ្យខូចថ្លើម រលាកខួរក្បាលដោយសារ៉ាឌីកាល់អាល់កុលនេះ។ ពេលដែលជាតិអាល់កុល

ក្នុងស្រាប៊ីយែ ជ្រាបចូលដល់កោសិកាប្រសាទវាទៅភ្ជាប់នឹងរ៉ែសិបទ័រ ពិសេសផ្នែលរបស់វានាំឱ្យកើតផលស្រួលអារម្មណ៍ រំភើបចិត្ត ចិត្តស្រឹម ត្របកភ្នែកស្រទន់ បបូរមាត់ធ្លាក់ហៀរទឹកមាត់កក្លាក់ ចិត្តរវើរវាយអណ្តែតត្រសែតទៅកាន់ភពថ្មី ដោយស្រពិចស្រពិលមិនមានភាពប្រាកដប្រជា លះក្តីកង្វល់ក្នុងលោកិយ ភ្លេចរឿងរ៉ាវក្នុងលោកនេះទាំងអស់។ ជាតិស្រានេះ ធ្វើឱ្យអ្នកខ្លះកក្រើកស្មាមអនុស្សាវរីយ៍ដែលបង្កប់យ៉ាងជ្រៅក្នុងក្រអៅបេះដូង បញ្ចេញមកក្រៅដោយពោលរៀបរាប់យំអណ្តើកអណ្តក ខ្លះធ្វើឱ្យខ្លាហានអង់អាច ហ៊ានចូលបោកចំបាប់ជាមួយដំរីចុះប្រេង ឬតោខ្លាក៏បាន ខ្លះប្រែថាកាចសាហាវកាប់ចាក់បោកប្រាស់ជេរប្រទេសគេឯង ខ្លះត្រូវស្រាទន់ដេកលែងក្រោក ដេកទាល់តែរុយឆ្ងល់ស្រមោចឡើងធ្វើតេស្តត្របកភ្នែក។ល។ អាល់កុលភ្ជាប់រ៉ែសិបទ័រយូរទៅរ៉ែសិនទ័រក៏លិចចូលក្នុងស៊ីតូប្លាសរបស់កោសិកាអស់មួយចំនួនធំ (**ហ្វាហ្គោស៊ីត**) ពេលនោះគាត់ផឹក១០នាក់ ឥឡូវ១ដបគាត់ផឹកតែពីរនាក់តែប៉ុណ្ណោះ។ ពេលណាចុះជាតិអាល់កុលពីក្នុងឈាម រ៉ែសិបទ័រក៏ចាប់អណ្តែតឡើងវិញ វាក៏ទាមទារឱ្យយើងចង់ផឹកឡើងវិញដោយមានអាការៈរញ៉ើរញ៉ៃចង់ក្អួត ឈឺក្បាល ចង់ប្រេះ ឡេះឡោះពេលព្រឹកព្រលឹម

ទាល់តែរត់ទៅ ផឹកស្រាមួយតយបានអាការៈធ្វើទុក្ខនេះវាបានធូរស្បើយ អាចបំពេញការងារបាន របៀបនេះគេហៅថា **ដុះមេហើយ** ។ ដោយសារមានការធ្វើទុក្ខឱ្យញៀនបែបនេះ បើយើងប្រៀបធៀបផលចំណេញរបស់វាឃើញថា អ្នកជំងឺអាចស្លាប់មុនពេលកំណត់ដោយសារការញៀនសុរា ហេតុនេះគ្រូពេទ្យមិនត្រូវឱ្យបប្រាប់អ្នកជំងឺថា សុរាគឺជាឱសថនោះឡើយ។ ជាតិសុរាក្នុងធម្មជាតិវាគ្រប់គ្រងលើអ្នកសេពមានពីរសណ្ឋាន៖

១- គ្រប់គ្រងលើស្មារតី

២- គ្រប់គ្រងលើរាងកាយ

សុរា (អាល់កុល) ជ្រាបចូលកោសិកាថ្លើមធ្វើឱ្យពុលផ្ទាល់ទៅលើសាច់ថ្លើម។ កោសិកាថ្លើមពិបាកបំពេញការងារកាន់តែខ្លាំងឡើងៗ ផឹកយូរទៅលែងក្លែមសាច់ ទៅក្លែមក្តិបអំពិល ក្តិបកន្ធូត ឬផឹកស្រាសុទ្ធៗ លែងចង់ក្លែមអ្វីទាំងអស់ ធ្វើឱ្យក្នុងឈាមចុះជាតិសាច់ (**អាស៊ីតអាមីនេ**) ឈ្មោះមេត្យូនីនដែលមានភារៈដឹកជញ្ជូនជាតិខ្លាញ់ចេញពីកោសិកាថ្លើមនាំឱ្យហើមថ្លើម (**រីកថ្លើម**) ការដក់ខ្លាញ់ក្នុងកោរិកាថ្លើមយូរទៅនាំឱ្យកោសិកាថ្លើមស្លាប់អស់ទៅក្លាយជាគ្រាប់គ្រើមៗ ក្រិនក្នុងសាច់ថ្លើម ធ្វើឱ្យថ្លើមទាំងមូលមានបាតុភូត៣យ៉ាងគឺ៖

១- រលួយសាច់ថ្លើម (ស៊ីតូលីស)

២- រឹងសាច់ថ្លើម (ហ្វីប្រូស)

៣- លេចចេញដុំ (ណូឌុល)

បើមិនឈប់ផឹកហើយព្យាបាលឲ្យបានត្រឹមត្រូវទេនោះ ថ្លើមនឹងក្រិនជាស្ថាពរ។ ពេលដែលថ្លើមក្រិនហើយវាក្តោបយ៉ាងតឹងទៅលើសរសៃវ៉ែនពក នាំឱ្យសម្ពាធសរសៃពកកើនឡើង ហើយសម្ពាធក្នុងតំណសរសៃពក និងសរសៃវ៉ែនការ៉ក៏កើនឡើង នាំឲ្យរីកជ្រាបទឹកប្លាស្មាឈាមចេញមកក្រៅនាំឱ្យកើតទាចទឹក (ដក់ទឹកក្នុងស្រោមពោះ) កើតរឹសដូងបាតរីកសរសៃនៅមួយភាគបីនៃបំពង់អាហារនាំឱ្យបែកក្អួតឈាម។ សុរាគ្រប់គ្រងលើរាងកាយមនុស្សមានរយៈពេលខុសៗគ្នា ទៅតាមភាពធុននៃកោសិកាថ្លើម នឹងតាមរបបអាហារសំបូរជីវជាតិ ឬគ្មានជីវជាតិ ខ្លះផឹក៤ទៅ៥ឆ្នាំបានក្រិនថ្លើម ខ្លះផឹកបាន១ទៅ២ឆ្នាំក៏ក្រិនថ្លើមអស់។ ជាតិអាល់កុល ជាសារធាតុនាំឱ្យរលាកដោយផ្ទាល់រលាកបបូរមាត់ ឡើងក្រហមពពាល និងអញ្ចាញធ្មេញ រលាកក្រពះ រលាកពោះវៀន រលាកបេះដូង។ ការគ្រប់គ្រងទៅលើស្មារតីធ្វើឱ្យញៀនហើយដុះមេអត់សុរាមិនបាន ធ្វើការមិនកើតប្រមឹកប៉ែឡាឡូឡាបន្ទោរបង់អត់ដឹងខ្លួន

មានដំណោកដូចសត្វតិរិច្ឆាន។ ហូបសុរាយូរទៅលែងចង់ហូបអាហារនាំ
ឱ្យចុះជីវជាតិបេ។ ដែលនាំឱ្យវង្វេងស្មារតីឆ្កួតឡប់លែងស្គាល់ឈ្មោះខ្លួន
ឯង លែងស្គាល់កូនប្រពន្ធ ដើរឆ្លងថ្នល់ឡានបុកស្លាប់ទៅ។ ចុះជីវជាតិ
នាំឱ្យញ័រចុងដៃចុងជើង មិនអាចទប់លំនឹងរាងកាយបាន ថ្លើមខ្សោយ
មិនអាចបំបែកជាតិអាម៉ូញាក់បាន វាចាល់ជ្រាបចូលក្នុងសាច់ខួរក្បាល
ទៅបន្សាបជាតិអាល់ហ្វាសេតូឡូយតារិច ឱ្យក្លាយជាអាស៊ីតឡូយតាមិច
ហើយវាទប់ការបំបែកចោលរបស់ដូរប៉ាមីន នាំឱ្យដូប៉ាមីនកើនឡើង
ច្រើនទៅជារវើរវាយ ឃើញនេះឃើញនោះ ចេះតែឮគេហៅ គេនិយា
ជាមួយ វិញ្ញាណទាំងអស់ទទួលព័ត៌មានពីខាងក្រៅ ហើយបកប្រែ
សុទ្ធតែខុស គេឱ្យស្ករបៀមថាគេឱ្យអំបិលៗល។ ណាចំណាយលុយ
លើស្រាហើយបែរជាមកចំណាយលុយព្យាបាលទៀត ទីបំផុតប្រពន្ធ
កូនត្រូវលក់កេរ្តិ៍មរតកអស់ហើយជាប់បំណុលគេវែនក ជនប្រមឹកនោះត្រូវ
សងបំណុលទៅផែនដីនៅទីបំផុត ហើយបន្សល់ទុកបំណុលជាច្រើនឱ្យ
កូនប្រពន្ធដោះស្រាយបន្ត។ ទោសនៃការជាច់សិក្ខាបទសុរាមេរ័យត្រូវ
ឆ្កួតតាំងពីជាតិនេះ រហូតដល់អនាគតជាតិក៏ងាយកើតជំងឺឆ្កួតនេះទៀត
ដែរ។ ចំណែកអ្នកលក់គ្រឿងញៀនស្រវឹងក៏ឈ្មោះថាមានការរស់នៅមិន

បរិសុទ្ធដែរ មិច្ឆាអាជីវៈក្នុងអកុសលកម្មបថ១០ដែលនាំឱ្យមានវិបាកមក លើខ្លួនឯង និងក្រុមគ្រួសារវិញដែរ ដែលគេពុំគួរនឹងរកស៊ីជួញដូរបំផ្លាញ ស្មារតីមនុស្សយ៉ាងនេះឡើយ។ បើអ្នកផឹកនៅមានស្មារតីដឹងខុសត្រូវ នៅឡើយ ត្រូវមានសន្ទុះចិត្តក្នុងការផ្តាច់ហើយត្រូវរត់រកជំនួយ ព្រោះ ពេលបញ្ឈប់សុរានាំឱ្យបែកញើស ចង្វាក់ជីពចរឡើងលើសពី១០០ ក្នុង មួយនាទី ក្អួតចង្អោរឡេះឡុះថប់បារម្ភស្រមើស្រមៃផ្តេសផ្តាស់ ប្រកាច់ក ន្ត្រាក់រហូតសន្លប់ក៏មាន។ ក្រុមញាតិដែលមិនដឹង ក៏ចេះតែជេបន្ទោស ថារឹងចចេសមិនព្រមឈប់ផឹកអត់ខ្លាចស្លាប់ទុកឱ្យវាស្លាប់ទៅ។ បើគ្មាន ការជួយសង្គ្រោះក្នុងការផ្តាច់នេះទេគាត់ពិតជាស្លាប់មែន។ ដើម្បីបន្ធូរ ភាពតានតឹងចិត្ត ពូហេងក៏បញ្ចេញខ្យល់ធំហឺ តាសនឆ្លៀតឱកាស ពោលកាត់ៈ ធម៌ទាំងឡាយមានចិត្តជាធំ ធ្វើបានសម្រេចក៏ព្រោះចិត្ត មិនបានសម្រេចក៏ព្រោះចិត្ត ចិត្តគិតខុសនាំឲ្យមានការប្រព្រឹត្តិខុសតាម កាយវាចា ចិត្តគិតត្រូវក៏នាំឱ្យមានការប្រព្រឹត្តិត្រូវ ព្រោះហេតុនោះទើប ព្រះពុទ្ធទ្រង់ត្រាស់ឱ្យចេះប្រដៅអប់រំចិត្ត មិនគួរឱ្យគ្រឿងញៀនស្រវឹងវា មកនាំចិត្តបានសោះ នេះមកពីមិនស្គាល់លក្ខណៈរបស់ចិត្ត។ ព្រះពុទ្ធ ទ្រង់ពន្យល់ថា ចិត្តមានលក្ខណៈ៥យ៉ាងៈ

១- ចិត្តជាធម៌

២- ចិត្តកើតរលត់ជាប់មិនដាច់

៣- ចិត្តមាននាមរូបជាបទដ្ឋាន

៤- ចិត្តដឹងច្បាស់នូវអារម្មណ៍

៥- ចិត្តសន្សំនូវវិបាក។

ចិត្តជាចៅហ្វាយ កាយជាបាវព្រាវ បើមិនចេះដឹងចិត្តខ្លួនឯងទេ មុខជានឹងត្រូវវិនាសខ្លួនដោយសារតែចិត្តនេះជាមិនខាន។ គុណភាពរបស់ចិត្តបើពោលដោយសង្ខេបមកគឺមានតែពីរ គឺចិត្តល្អ និងចិត្តអាក្រក់ ចិត្តល្អនាំឱ្យគិតតែរឿងល្អៗ និយាយល្អធ្វើល្អ ចិត្តល្អនាំមកនូវសេចក្តីសុខ ចិត្តអាក្រក់នាំឱ្យវិនាសអន្តរាយ នឹងបានតែទុក្ខទោសបៀតបៀនខ្លួនឯងនឹងអ្នកដទៃ។ បញ្ញានិងសតិ ដែលជាអ្នកអារកាត់នឹងរលឹកទាន់ដើម្បីកុំឱ្យនិយាយខុស ។ បញ្ញា និង សតិ នេះបើមិនបានហ្វឹកហាត់ឱ្យកើតគឺវាមិនអាចកើតឡើងបានឡើយ ឯរបៀបហ្វឹកហាត់គឺមិនមានការប្រៀនប្រដៅណាឱ្យល្អិតអស់ជើង ដូចជាការប្រៀនប្រដៅនៅក្នុងព្រះពុទ្ធសាសនានោះឡើយ។ ប៉ុន្តែម្នាក់ៗឱ្យតែឮពាក្យថា វត្តគឺធុញ ព្រោះមិន

ទាន់សម័យ វត្តនេះគឺសម្រាប់តែមនុស្សចាស់អត់ការងារធ្វើ សម្រាប់តែមនុស្សមានទុក្ខ រួចហើយសម្រាប់ជនពិការ និងឆ្កែឆ្មាដែលត្រូវគេយកទៅបំបរបង់ចោល បើអញ្ចឹទៅមានតែទៅបង្អួតម៉ូតសំលៀកបំពាក់គ្នាទៅវាំឌីស្កូញ៉ៅជៃព្រៃ ទ្បេបខាយឌឺដងដាក់គ្នាយួរបាយមួយស្រាក់ទៅដាក់ទានលោក រួចត្រឡប់មកផ្ទះវិញប្រញាប់ទៅដើរលេងទៀត ឱអ្នកនាងហ្អើយ! អត់ដឹងថា ព្រះពុទ្ធគោតមនេះជាអ្នកណា? ព្រះអង្គ គឺជាស្តេចនៃអ្នកប្រាជ្ញ ជាស្តេចវេជ្ជបណ្ឌិត ដែលបានព្យាបាលជំងឺពិភពលោកនេះទាំងមូល ឲ្យបានជាជំងឺខ្លាក់ងងឹតរាប់ពាន់ឆ្នាំមកហើយ។ អ្នកវិទ្យាសាស្ត្ររូបធាតុនិយមវិចារវិទ្យា ដែលមិនសូវច្បាស់លាស់តែងពោលថា សាសនា គឺជាអាភៀនកាន់តែជក់គឺកាន់តែញៀនគ្មានបានការអីទាំងអស់ វាជារឿងហួសសម័យ តើចិត្តនិងអារម្មណ៍នេះ វាចេះហួសសម័យទេ? ក្រសែ **លោភៈ ទោសៈមោហៈ** នេះចេះតែប្រែប្រួលទេ? ហេតុនេះហើយការប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺត្រូវគ្រប់សម័យកាល ព្រោះជាការសិក្សារពីច្បាប់ធម្មជាតិនៃចិត្តអារម្មណ៍ សិក្សាពីទុក្ខ ពីហេតុនាំឱ្យកើតទុក្ខពីការរលត់ទុក្ខ នឹងរបៀបរំលត់ហេតុដែលនាំឱ្យកើតទុក្ខ សិក្សាពីធម្មជាតិអាស្រ័យគ្នាដើម្បីកើត អាស្រ័យគ្នាដើម្បីរលត់ ដែល

សុទ្ធតែជាធម្មជាតិសុទ្ធៗទាំងអស់។ បុព្វហេតុសានាគឺជាការស្វែងរកចំលើយប្រស្នាទុក្ខ ព្រោះហេតុនេះចំលើយត្រូវបានគេរកឃើញខុសៗគ្នា ព្រះពុទ្ធរកឃើញថាកាលណាគេយល់ពីរបៀបរស់នៅ យល់ការពិតរបស់ជីវិត យល់ពីសច្ចៈភាពនៃសកលចក្រវាឡ គេក៏បានស្ងប់ចិត្តហើយសោះអង្គើយនឹងភាពឥតប្រយោជន៍ ការប្រលាក់ប្រឡូសអកុសលធម៌ដែលនាំឱ្យជំពាក់វាក់វិនក្នុងភព **ជាតិ ជរា ព្យាធិ មរណៈ** ដែលហៅថា វដ្តទុក្ខមិនមានទីបំផុត។ ខ្លះយល់ថា ម៉្លេនឹង ស្លាប់ជៀសមិនផុតដដែល កុំពិបាកចិត្តពេកនាំគ្នារាំច្រៀងក្នុងវិហារសរសើរព្រះទៅ ព្រោះឱ្យតែយើងគោរពជឿព្រះ ដើរតាមព្រះបន្ទូលរបស់ទ្រង់ យើងនឹងបានលោះលាងអំពើបាបទាំងអស់ ហើយបានរស់នៅនគរផងព្រះមានជីវិតអស់កល្បក្រោមសិរីរុងរឿងរបស់ទ្រង់ ឱ្យតែជឿដឹងតែបានឡើងឋានសួគ៌ ទោះបីជឿបានកន្លះដងម្ដើមហើយស្លាប់ក៏ដោយ គឺដឹងតែបានឡើងឋានសួគ៌ហើយ។ ខ្លះដឹងថា ជីវិតគង់តែស្លាប់ទេ ហើយមុនស្លាប់ គឺមានការឈឺចាប់ខ្លាំងណាស់ ហេតុនេះទាន់ជីវិតនៅរស់គឺត្រូវខំហ្វឹកហាត់អត់ធ្មត់ ខំអត់សង្កត់ចិត្ត អត់ទ្រាំចំពោះក្ដីស្រេកឃ្លានពេញៗមួយថ្ងៃមិនលេបអ្វីសោះសូម្បីតែទឹកមាត់ សុខចិត្តពេលថ្ងៃដើរទិញនំចំណីទុកហូបពេលយប់ បើ

ស្រក់ទឹកមាត់ត្រូវស្តោះចោល កុំលេប បង្វឹកខ្លួនឲ្យធ្លាប់ អត់ធន់នឹងតណ្ហាសព្វបែបយ៉ាង ដើម្បីបានទទួលជោគជ័យពេលជិតស្លាប់។ ទាំងអស់នេះសុទ្ធតែជាការយល់ឃើញ ដែលមិនអាចមានអ្នកណាម្នាក់បដិសេធន៍ថាគេខុស ឯងត្រូវបានឡើយ ព្រោះសុទ្ធតែជាអធ្យាស្រ័យរបស់មនុស្ស បើចង់វែកញែករកខុសត្រូវនេះឯងជាបុព្វហេតុនៃអសន្តិសុខពិភពលោក អធិករណ៍ទាំងឡាយកើតឡើងព្រោះទិដ្ឋិ។ ព្រះពុទ្ធទ្រង់ប្រឈមមុខចំពោះសំនួរមហាជនក្នុងក្រុងរាជគ្រឹះ ដែលពេលនោះសាស្ត្រាចារ្យទាំងឡាយកំពុងតែឃោសនា រកសម្លេងគាំទ្រគគ្រឹកគគ្រេង មេសាសនាទាំងអស់សុទ្ធតែប្រកាសតែតាំងថា លទ្ធិរបស់ខ្លួន គឺត្រឹមត្រូវសុក្រិត្យឥតខ្ចោះគ្រប់ជំពូកគ្រប់មាត្រា ក្រិត្យវិន័យសុទ្ធតែជាចម្លើយបរមសុខទាំងអស់ ព្រះពុទ្ធអង្គទ្រង់ឆ្លើយតបដោយទឹកព្រះភ័ក្ត្រស្មោះស្មើ នឹងមិនមែនក្នុងបំណងបង្កើតអធិករណ៍ថា ការប្រៀនប្រដៅណាដែលមិនបានបៀតបៀនដល់ខ្លួនឯង និងបៀតបៀនដល់អ្នកដទៃទេ ចូរអ្នកទាំងឡាយកាន់យកហើយប្រតិបត្តិតាមចុះ ចូរកុំចេះតែជឿតាមដោយគ្រាន់តែឮតាមគ្នា លឺតៗគ្នា ឬជឿតាមតែឃើញស្នាមគំនូសអក្ខរាការប្រៀនប្រដៅទាំងនោះ មិនអាចឱ្យគេពិសោធន៍បានយ៉ាង

នេះជាដើម តថាគតឲ្យឈ្មោះថា **បណ្ឌិតគឺជាអ្នកផ្តល់សេចក្តីសុខឱ្យខ្លួនឯង និងអ្នកដទៃ ដល់មនុស្សជំនាន់ខ្លួន និងមនុស្សជំនាន់ក្រោយផងដែរ។** ព្រះអង្គមិនបានពោលកៀងគរថា ចូរមកតាមតថាគតចុះព្រោះមានតែការប្រៀនប្រដៅរបស់តថាគតទេ ដែលត្រឹមត្រូវជាងគេនោះ។ ប៉ុន្តែព្រះអង្គបានផ្តល់ចម្លើយប្រកបដោយតក្កៈវិទ្យា ក្នុងបទវិភាគស្វែងរកសេចក្តីសុខពិត ក្នុងចំណោមបណ្តាទស្សនៈចលាចលនៃមនុស្ស ស្រែកឃ្លានសុខសន្តិភាព ហើយចង់ចូលឱ្យដល់សេរីភាពក្នុងផ្លូវគំនិតវិញ ព្រះអង្គត្រាស់ទូន្មានថា ចូរកុំស្ទាបអង្អែលហើយកាន់យកទិដ្ឋិដទៃទាំងលះទិដ្ឋិខ្លួនឯងផង នេះឯងគឺជាខ្លឹមសារពិតនៃអនត្តាធម៌។ លោកតាសនបញ្ចប់កន្ទុយពាក្យ រួចគាត់ចុចសំនួរពេទ្យហោងភ្លាមៗ មើលលោកពេទ្យលក្ខណៈចិត្តបួនយ៉ាងដែលខ្ញុំបានសម្តែងខាងដើមនេះតើមានសារៈសំខាន់ដែរទេក្នុងវិជ្ជាពេទ្យសព្វថ្ងៃនេះ? **អូហ៍លោកអ៊ំ** ខ្ញុំរវល់តែបញ្ជូនចិត្តតាមក្រសែធម៌ ឃើញភាពរស់រវើកនៃបញ្ញាញាណរបស់ព្រះពុទ្ធ សឹងតែស្ទុះចុះលត់ជង្គង់ថ្វាយបង្គំឆ្ពោះព្រះពុទ្ធនិវេសន៍ទាំង៤កន្លែងទៅហើយ ពូហ្អើយភ្លឺណាស់ ច្បាស់ណាស់ ដូចជាគេផ្ងាររបស់ដែលផ្កាប់ឱ្យបានឃើញច្បាស់ ដូចជាគេដឹងដៃពីទីងងឹតទៅទីភ្លឺ ដូចព្រះច័ន្ទពេញបូរមី

ចេញចាកពពកខ្មៅងងឹតនៃវេលារាត្រីកាល។ **ពូហ្អើយ!** ខ្ញុំចេះតែនៅមានសំណាងបានក្រេបព្រះធម្មរស អស្ចារ្យណាស់សេចក្តីស្លាប់របស់ខ្ញុំ គឺផុតស្រឡះភាពជាប់ជំពាក់ទាំងឡាយក្នុងលោកមិនលិចចុះក្នុងលោក ខ្ញុំមិនជាប់ជំពាក់បំណុលផែនដីទៀតទេ ព្រោះតែព្រះធម៌បានស្រង់ខ្ញុំពីវណ្តៅអវិជ្ជមានឱ្យបានរស់ផុតតណ្តា។ ខ្ញុំមកនេះល្អហើយព្រោះបានដើរតាមព្រះយុគលបាទ ហើយបានបម្រើនឹងទ្រទ្រង់ព្រះពុទ្ធសាសនា ថ្វីត្បិតតែសេចក្តីស្លាប់ដោយគ្មានវិប្បដិសារីយ៍ គឺជាការលំបាក ប៉ុន្តែវិប្បដិសារីយ៍របស់ខ្ញុំ គឺមិនបានបម្រើគុណធម៌សាងក្តីសុខជូនមនុស្សឱ្យបានច្រើនតែប៉ុណ្ណោះ។ ហេតុនេះសុំប្រាថ្នាទៅជាតិមុខសូមកុំបីបានឃើញថារូបនោះល្អហើយឈ្លក់វង្វេង កុំបីបានឮសម្លេងហើយពិឆោះជាប់ចិត្ត សូមឆាប់បានជួបសេពគប់នឹងអ្នកដឹកនាំឱ្យបានសាងផ្នួស កុំបីវង្វេងក្នុងលោកធម៌ហើយសូមបានបរិនិព្វានក្នុងសង្ឃជាបរិយោសានជាតិទៅចុះណាពូ។ **អើហ៎!** សូមឱ្យក្តីប៉ងប្រាថ្នានេះបានសម្រេចទៅចុះណាក្មួយ សាធុ សាធុ សាធុ។ នេះក្មួយសូមឆ្លើយនឹងសំនួរអំុម្តង **ទីមួយគឺចិត្តជាធំ** ធម្មជាតិណាធំស្មើចិត្តរមែងមិនមាន ចិត្តឱ្យរួបរស់រួបរស់ ចិត្តឱ្យរួបស្លាប់រួបស្លាប់ ចិត្តគឺជាអ្នកវិចិត្រនូវលោក សំភារៈក្នុងលោកសុទ្ធ

សឹងតែកើតពីចិត្តទាំងអស់ ចិត្តដឹកនាំលោកឱ្យវិនាស លោកក៏វិនាស ចិត្តដឹកនាំលោកឱ្យរីកចម្រើនលោកក៏រីកចម្រើន។ ចិត្តគេបង្កើតសំភារៈបរិក្ខារទំនើបសព្វបែបយ៉ាង ព្រោះចង់ទាក់ទាញចិត្តអ្នកដ៏ទៃឱ្យងប់ងល់ឈ្លក់វង្វេងតាមចិត្តយើងធ្វើអី មិនបានដូចចិត្តគេក៏កុំទៅក្រឡកចិត្តតាមគេពង្វក់នោះឡើយ ជីវិតដែលរស់បាន គឺបរិភោគអាហារមិនមែនបរិភោគមាសពេជ្រ វីឡា ឡានេាះទេ។ ចិត្តខ្លះមិនបានអប់រំ កាន់តែមានកាន់តែឈ្លោះព្រោះប្រកាន់តែក្រ ចិត្តខ្លះយល់ថា មានប្រាក់គឺមានអ្វីៗទាំងអស់ ប៉ុន្តែពេលខ្លះរូបនេះវាមានអមតៈឯណា ព្រោះវាគ្រាន់តែជាសម្ព័ន្ធធាតុគីមីតែប៉ុណ្ណោះ វាអាចលើស អាចខ្វះដែលនាំឱ្យបែកធ្លាយបានគ្រប់ពេលវេលា។ ខ្លះកំពុងតែសប្បាយនឹងមានបាន ស្រាប់តែបែកធ្លាយសរសៃឈាមក្នុងខួរក្បាលស្លាប់បាត់ទៅ ខ្លះទើបតែសង់ផ្ទះរួចប៉ុនភ្នំព្រះសុមេរុ មិនទាន់បាននៅឱ្យស្កប់ស្កល់ផង ក៏កើតជំងឺមហារីកខ្សាយថ្លើម ខ្សាយតម្រងនោម លក់ផ្ទះលក់ដីយកលុយមកព្យាបាលរោគអស់ ហើយក៏ស្លាប់បាត់ទៅក៏មាន។ ខ្លះលក់ដីបានរាប់ម៉ឺនបែរជាដេកកើតទុក្ខយំសោកបោកដៃបោកជើង ស្តាយថាកាលនោះបើ ទិញដីទុកឱ្យច្រើនម្លេះលក់បានចំណេញច្រើនជាងនេះ។ ចេះតែឈូសរដណ្តើម

ជីគ្នាដែលដីនៅតែជាដី ឯម្ចាស់ចេះតែស្លាប់ចោលតៗគ្នា អត់មានអ្នកណាបានអីពីលោកនេះទៅទាំងអស់ ដីរបស់អញ ឬអញរបស់ដី? សុខទុក្ខ គឺស្រេចហើយនៅលើចិត្តគិត ចិត្តគិតឱ្យកើតទុក្ខវាទុក្ខ មធ្យោបាយនៃការគិតមានច្រើនណាស់ បើគិតទៅនាំឱ្យកើតទុក្ខខំគិតវាធ្វើអី ចង់បានសុខតែមិនចេះលះទុក្ខ អត់ដឹងខឹងគីល្ងង់ ស្អប់គីឆ្កួតទេឬ? ជីវិតមនុស្សមិនអភ័ព្វទេ គឺចិត្តមនុស្សទេដែលអភ័ព្វមិនចេះគិតឱ្យបានសុខខ្លួនឯង ចេះតែត្រិះរិះឱ្យកើតក្តីក្រៅក្រហាយ មួរម៉ៅ អន្ទះសារ នាំឱ្យកើតរោគចិត្តឥតប្រយោជន៍។ បញ្ញាដោះទុក្ខចេញពីចិត្ត គឺជាបញ្ញាដ៏ឧត្តម បុគ្គលកាលបើជួបទុក្ខហើយមិនកំណត់ដឹងថាជាទុក្ខ នឹងធ្លាក់ក្នុងអន្លង់ទុក្ខកាន់តែជ្រៅ។ ទាំងអស់នេះសុទ្ធតែជាអាថ៌កំបាំងនៃសេចក្តីបរិសុទ្ធក្នុងការគិត ព្រោះបើគិតមិនឃើញសច្ចៈរបស់វាគឺ **កិលេស ទិដ្ឋិ មានៈ តណ្ហា ឧបាទាន** ទាំងអស់នេះទេដែលចេញមុខក្នុងការគិត មិនមែនជាការគិតប្រកប បញ្ញាដ៏វិសុទ្ធនោះឡើយ។ ចិត្តជាធំ បើវាសុទ្ធតែកិលេសនោះហើយយើងអត់មានសតិបញ្ញាទប់ទល់វាទេ នោះវានឹងប្រើយើងឱ្យរហេមរហាម ឱ្យឡិកឡក់លីលា សស្លាក់ស្លើតឡេឡាអត់ដឹងទិសតំបន់ ឱ្យតក់ស្លុតនឹងរូបសម្លេង ក្លិនរស ឱ្យសើចឲ្យចំដូចក្មេងបៀមដៃ អត់ដឹង

ថាបើសើចតើបានអី ហើយបើយំតើបានអី បើសប្បាយតើវាយ៉ាងម៉េច បើកើតទុក្ខតើវាយ៉ាងម៉េច? កិលេសចិត្តកើតចេញពីចិត្ត ហើយបំផ្លាញចិត្ត ប្រៀបដូចជាច្រេះកើតពីដែកហើយស៊ីបំផ្លាញដែកដូច្នោះដែរ។ ព្រោះហេតុនេះសត្រូវដ៏ធំបំផុតរបស់យើង គឺមិនមែនជាអ្នកដទៃនោះឡើយ តែគឺជាកិលេស (ធម្មជាតិនាំចិត្តឱ្យសៅហ្មង) ឯនេះវិញទេដែលនាំឱ្យយើងធ្លាក់នរកទាំងរស់ វាប្រើយើងទល់ថ្ងៃស្លាប់ហើយឱ្យទៅនៅក្នុងអបាយភូមិ (**ភូមិអត់បាយ ឬភូមិដែលសោយតែទុក្ខ**) ជារៀងរហូតទៀតផង តើយើងគួរគាំទ្រកិលេស (**លោភៈ ទោសៈ មោហៈ មានៈ ប្រកាន់**) របស់យើងតទៅទៀតទេ។ **ចិត្តជាធំដោយគុណធម៌** នោះវឌ្ឍនធម៌នឹងចម្រើនឡើង ចិត្តនេះជាចិត្តរឹងមាំក្នុងសេចក្តីល្អ ជាចិត្តមហារាជដែលគ្រប់គ្រាន់តតខ្វះចន្លោះ កាលបើចិត្តនោះឆ្អែតគ្រប់គ្រាន់ហើយក៏ចេះផ្តល់ឱ្យអ្នកដទៃបានសម្រេចនូវក្តីប៉ងប្រាថ្នារៀងៗខ្លួន ធ្វើឱ្យមានការលើកកម្ពស់ផ្នែកស្មារតីបានចម្រើនឡើង។ **ចិត្តកើតរលត់ជាបើមិនដាច់** ចិត្តមនុស្សចេះតែប្រព្រឹត្តទៅចេញពីរឿងមួយចូលរឿងមួយជាហូរហែរ ប្រៀបដូចជាគេរោយគ្រាប់ខ្សាច់តូចៗតៗគ្នា ក្នុងមួយយប់មួយថ្ងៃចិត្តកើតរលត់ដល់ទៅជាង៩លានដង សូម្បីពេលដេកលក់ក៏សភាពនៃចិត្តកើត

រលត់ចេះតែប្រព្រឹត្តទៅដែរ។ កំពុងតែគិតរឿងនេះស្រាប់តែឮសម្លេងផ្លូងឯណោះ ចិត្តក៏ស្លាប់ពីទីនេះទៅកើតក្នុងទីនោះភ្លាម (**ទៅគិតក្នុងព្រឹត្តិការណ៍ថ្មី**)។ ប៉ុន្តែចិត្តដែលកើតរលត់១៧ដងក្នុងបញ្ចទ្វារនាំឱ្យរូបរលត់មួយ គឺចិត្តកើតរលត់តាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ១៧ដង កោសិកាធ្វើចំណែកលើរាងកាយ (មីតូស) ធ្វើចប់មួយ (កោសិកាមេមួយធ្វើចំណែកជា២) ឯចិត្តកើតរលត់ក្នុងមនោទ្វារ ១២ដងនាំឱ្យរូបរលត់១ បានន័យថាបើចិត្តកើតរលត់នៅសាច់ខួរខាងមុខ (ក្លៃបក្រោយថ្ងាស) ១២ដង សភាវៈនៃសរីរាង្គកាយប្រែប្រួលរលត់មួយ ហេតុនេះហើយ បើយើងគិតព្រួយច្រើននាំឱ្យកោសិកាធ្វើចំណែកជាច្រើនដង ជាហេតុជំរុញរាងកាយឱ្យឆាប់ចាស់ទ្រុឌទ្រោមងាយកើតមហារីកដោយការបាក់បែក ឌីអិនអេ ស្បែកមុខជាំខ្មៅជ្រីវជ្រួញ ព្រោះតែការគិតច្រើន។ ការព្រួយចិត្តគិតច្រើនយូរៗទៅនាំឱ្យកើតបាតុភូតចប់តឹងណែនក្នុងអារម្មណ៍តាមរបៀបដូចជាភ័យខ្លាចស្លាប់ ខ្លាចក្លាយជាឆ្កួត ខ្លាចទីប្រជុំជន ខ្លាចទីខ្ពស់ ឬទីងងឹត។ ចិត្តព្រួយខ្លាចនោះចេះតែផុសឡើងផ្ទួនៗ រហូតក្លាយជាចរន្តនៃការគិតមួយដែលពិបាកទ្រាំ យើងថាមិនគិតទេ ឈប់គិតហើយតែចិត្តនោះចេះតែផុសឡើងមកឱ្យគិតទៀត។ បើយើង

ស្គាល់លក្ខណៈកើតរលត់របស់ចិត្ត គឺថាចិត្តកើតឡើងហើយវាគ្រាន់តែតាំងនៅ១ឬ២នាទី វាក៏រលត់ទៅវិញហើយ យើងកុំមួរម៉ៅជាមួយវាដោយគ្រាន់តែកំណត់សតិដឹងកុំតក់ស្លុតភ័យតាមវា បន្តិចក្រោយមកវាក៏រលត់វិញទៅ។ ជំងឺចិត្តប្រភេទអិនសាយធីនេះ កើតឡើងក្រោយពីយើងជួបនឹងការរំខានចិត្តធ្ងន់ធ្ងរ (ស្ត្រេស)។ អារម្មណ៍ដែលផុសឡើងមកឱ្យគិតយើងគ្រាន់តែកំណត់សតិដឹងហើយវាក៏រលត់ទៅវិញ បើពិបាកទ្រាំពេកយើងអាចបង្វែរចិត្តមកត្រួតពិនិត្យខ្យល់ដង្ហើម ចេញដឹង ចូលដឹងក្នុងឥរិយាបថពែនភ្នែនជើងស្តាំដាក់លើជើងឆ្វេង ដៃស្តាំដាក់លើដៃឆ្វេងដាក់រាងកាយឱ្យត្រង់ពេលអារម្មណ៍នោះផុសឡើង យើងយកចិត្តទៅពិនិត្យអារម្មណ៍ ចាំមើលលក្ខណៈរបស់វា ដែលវានឹងរលត់ទៅវិញក្នុងពេលបន្តិចក្រោយមក ពេលវារលត់ហើយយើងយកចិត្តមកពិនិត្យខ្យល់ដង្ហើមវិញ ព្រោះយើងមិនងាយពិនិត្យរឿង២ព្រមពេលតែមួយបានទេ បន្តធ្វើយ៉ាងនេះលុះត្រាតែឈ្នះលើអារម្មណ៍រាយមាយទាំងអស់ ទីបំផុតយើងនឹងបានទទួលជោគជ័យវិញ ដោយកើតក្តីសុខដុមរមនាតាមផ្លូវកាយផ្លូវចិត្ត ឈ្នះរាល់អកុសលធម៌ដែលបណ្តាលមកពីការគិតខុសរបៀបពីមុនមក។ ព្យាបាលជំងឺផ្លូវចិត្ត គឺអប់រំចិត្តខ្លួនឯង នេះគឺជាគន្លឹះ

នៃជោគជ័យ គឺជាកូនសោរជីវិតដែលអាចចាក់បើកទ្វារឱ្យអ្នកចេញពីគុក កម្មលោកិយ ឆ្ពោះទៅរកសេរីរុងរឿងក្នុងផ្លូវគតិបណ្ឌិតវិញ ប៉ុន្តែបើសភាពជំងឺធ្វើទុក្ខខ្លាំងក្លាពេករហូតដល់អ្នកមិនអាចទប់ទល់បាន អ្នកគួរប្រើប្រាស់ឱសថរំងាប់អាម្មណ៍ ដែលផ្តល់ជូនដោយគ្រូពេទ្យឯកទេសព្រមជាមួយកិច្ចប្រតិបត្តិលំហាត់ខ្យល់ដង្ហើមជាប់ជាប្រចាំ។ អ្នកមានទំលាប់គិតច្រើនមិនមែនត្រូវមកឈប់គិតបានងាយៗនោះទេ តែត្រូវបង្វែរការគិត ដែលអត់បានការមកគិតពិចារណារកផ្លូវត្រូវសច្ចៈធម៌ឯនោះវិញ។ **តើលោកនេះទៀងឬទេ?** អ្វីដែលទៀងនោះគឺកើតហើយត្រូវតែស្លាប់ទៅវិញជាធម្មតា១ មិនទៀងបីគឺ **មិនដឹងស្លាប់ពេលណា មិនដឹងស្លាប់កន្លែងណា និង មិនដឹងស្លាប់ដោយសារអ្វី?** មិនទៀងព្រោះមិនអាចតាំងនៅក្នុងសភាពដើមបាន ត្រូវប្រែប្រួលទៅរកសភាពអស់ទៅនឹងសូន្យទៅជាធម្មតា ចិត្តមិនទៀងរូបមិនទៀងស្រលាញ់ៗប្រែជាស្អប់ អ្វីៗដែលមានហើយប្រែជាមិនមានវិញ មានប្រែជាបាត់ បាត់ប្រែជាមាន សុខត្រូវប្តូរជាទុក្ខ ទុក្ខត្រូវប្តូរជាសុខ ឥតមានអ្វីអមតៈឡើយ។ ពិភពលោកនេះ គឺជាការហូរទៅជាប់មិនដាច់នៃចរន្តរូបធាតុជីវៈ គីមីក្នុងលំហរនៃសកលចក្រវាឡតែប៉ុណ្ណោះ ហេតុនេះ គឺមិនមានរូបធាតុណាមួយនៅឈប់ស្ងៀម

ទ្រឹងនោះឡើយ។ បម្រែបម្រួលដែលក្លាយជានិរន្តរភាពនេះ ធ្វើឱ្យធម្ម ជាតិផ្លាស់ប្តូរសំបូរបែបនិងវិនាសអន្តរាយទៅវិញជាធម្មតា។ ហេតុដូច នេះ សត្វណាមិនយល់ពីវិបរិណាមធម៌នេះក៏រមែងលិចចុះក្នុងទុក្ខ អ្នក ខ្លះពេលត្រូវបាត់បង់តំណែងឋានៈតួនាទី បាត់បង់ព្រោត់ប្រាស់ចាកសត្វ សង្ខារជាទីស្រលាញ់ក៏ប្រែជាខូចចិត្ត ខ្លះគិតច្រើនទៅជាកើតជំងឺធ្លាក់ ទឹកចិត្ត ខ្លះទៅចងក លោតទឹក លេបថ្នាំសម្លាប់ខ្លួន ស្លាប់អាសារឥត ការក៏មាន ព្រោះតែរូបនេះមិនទៀងទើបរូបនេះជាទុក្ខ បើរូបនេះជាទុក្ខទេ រូបនេះពិតជាពុំមានខ្លឹមសារប៉ុន្មានឡើយ កុំប្រកាន់ហួងហែងពេក បិត ក្រោមថ្ងៃដៃ ទេពកោសល្យតាក់តែងរបស់របស់ធម្មជាតិឱ្យស្តឹកស្រពន់ ចិត្ត ព្រោះអ្វីដែលសន្មត់ថាពិតដូចជាមិនពិត មិនពិតដូចជាពិត ប៉ុន្តែគឺ គ្មានអ្វីពិតគ្មានអ្វីក្លែងក្លាយនោះឡើយ ហេតុនេះចិត្តណាមានបញ្ញាមុត ធ្លុះជ្រៅ ពិនិត្យឃើញសច្ចៈធម៌នេះរមែងមិនចាញ់កលក្នុងការបោក ប្រាស់របស់ធម្មជាតិ សន្តិភាពចិត្តក៏កើតឡើង។ ជីវិតនេះ គឺជា ផលិតផលធម្មជាតិទេ ត្រូវម្ចាស់គេយកទៅវិញពេលណាថ្មើរណា? ក៏ យើងមិនចាំបាច់រត់គេចទៅណាឡើយ ព្រោះក្នុងខ្លួនយើងគឺមានមច្ចុរាជ ស្ថិតនៅក្នុងនោះស្រេចទៅហើយ ពិភពលោកនេះគឺជាលោកនៃសេចក្តី

ស្លាប់នេះឯង ការចេះគិតពិចារណាពីសេចក្តីស្លាប់របស់ខ្លួនឯង គឺជាកំពូលគុណធម៌ ដែលអាចនាំទីដល់សេចក្តីសុខសន្តិភាពមហាសាល។ យើងអាចចាកចេញពីជីវភាពបាន តែជីវភាពមិនអាចចាកចេញពីយើងបានឡើយ ទើបជីវិត គឺជាប្រភពនៃបញ្ហា។ ទុក្ខគឺជាការធន់ទ្រាំមិនបានបញ្ហាណាដែលយើងនៅដោះស្រាយបាន គឺមិនទាន់ជាទុក្ខទេ បញ្ហាណាដែលយើងដោះស្រាយមិនបានហើយត្រូវប្រឈមមុខ នោះឯងគឺជាទុក្ខ ហេតុរបស់ទុក្ខគឺតណ្ហា ការដែលចេះតែមិនពេញចិត្តចំពោះអ្វីដែលខ្លួនមាន ភាពមិនចេះឆ្អែតស្កប់ស្កល់របស់ចិត្តធ្វើឱ្យចិត្តក្លាយជាក្រីក្ររហេមរហាមមិនដែលស្គាល់ក្តីសុខទសល់ថ្ងៃស្លាប់។ ទុក្ខកើតឡើងព្រោះត្រូវសភាពមិនទៀងបៀតបៀនរឿយៗ ការកំណត់ដឹងនូវទុក្ខ ជាធម្មតាចិត្តបានយល់យ៉ាងនេះក៏អស់ឆ្ងល់ការអស់ឆ្ងល់គឺជាសុខ។ ធម្មជាតិណាដែលធ្វើចិត្តឱ្យក្រៀមក្រំសោកសៅ ស្តួតរន្ធត់ ញាប់ញ័រភ័យព្រួយ ធម្មជាតិនោះគឺជាទុក្ខ។ ការត្រិះរិះពិចារណាប្រកបដោយសតិសម្បជញ្ញៈឆ្ពោះទៅកាន់មាគ៌ាជីវិត ដែលជាគោលដៅកាត់បន្ថយនូវបញ្ហាទុក្ខ នោះគឺជាការសន្សំសុខ ការកំណត់ដឹងនូវទុក្ខគឺជាសុខ ព្រោះទុក្ខក្នុងសុខខុសពីសុខក្នុងទុក្ខ។ កុំចេះតែមានលុយគឺមានអ្វីៗទាំងអស់

ត្រូវចេះនឹកគិតពីពេលវេលា ដែលមានលុយតែមិនអាចទិញបានអ្វីសោះ ខ្លះផង ព្រោះលុយមិនអាចទិញ ចាស់ ឈឺ ស្លាប់ មិនអាចសូកប៉ាន់មកុ្នរាជបានឡើយ។ លុយជាអ្នកបម្រើដ៏ល្អតែជាចៅហ្វាយដ៏អាក្រក់ វាប្រើយើងគ្មានស្គាល់យប់ថ្ងៃ ប្រើទាល់តែធ្លាក់នរកទាំងរស់ក៏មាន។ សុភមង្គលពិតមិនបិតនៅលើការបំប៉ោងតណ្ហានោះឡើយ កាយនេះនៅមិនយូរប៉ុន្មានទេ តែវិញ្ញាណប្រាស់ទៅចោលហើយក៏ត្រូវដួលដេកសង្កត់លើផែនដីដូចជាសង្កត់អុសរកប្រយោជន៍គ្មានឡើយ ហេតុនេះកុំ (**ពេក**) **។** រូបនេះកើតឡើងបានក៏ព្រោះធម្មជាតិធំឡើងបាន ចាស់ទៅបាន ស្លាប់ទៅបាន កើតឡើងវិញបាន ក៏ព្រោះធម្មជាតិទាំងអស់មិនបិតក្រោមអំណាចយើងឡើយ។ រូបនេះបង្គាប់បញ្ជាកុំឱ្យចាស់ កុំឱ្យឈឺ កុំឱ្យស្លាប់ បង្គាប់បញ្ជាមិនបាន មិនមានអ្វីលុះក្រោមអំណាចចិត្តរបស់យើងឡើយ។ ពេលទំនេរត្រូវបង្អោនចិត្តមកគិតពីការពិតទាំងអស់នេះទើបបានសុខ កុំរវល់តែគិតខុស គិតឱ្យកើតទុក្ខក្តៅក្រហាយចិត្ត គិតពីកាមរាគៈតណ្ហា គិតពីការនិន្ទាព្យាបាទ ដែលសុទ្ធតែជាការគិតឱ្យឆាប់ស្លាប់ខ្លួនឯងទេ កុំសាងអារម្មណ៍ធ្វើបាបខ្លួនឯង ពេលដែលចិត្តអាក្រក់នេះកើតឡើងហើយបបួលឱ្យចិត្តយើងគិតខុសត្រូវមានសតិរលឹកទាន់ ហើយ

ពោលតិះដៀលវាក្នុងចិត្ត វាក៏អស់កម្លាំងហើយរលត់បាត់ទៅ។ ការដែលចេះដឹងលក្ខណៈចិត្តកើតរលត់យ៉ាងនេះ ហើយចេះរាំងប្រៀនប្រដៅចិត្តកុំឱ្យគិតខុស ព្យាយាមចាប់កំហុសខ្លួនឯង គឺជាសន្តិបុគ្គល ព្យាយាមចាប់កំហុសអ្នកដទៃ គឺបង្កើតបញ្ហាឱ្យខ្លួនឯង។

ចិត្តមាននាមរូបជាបទដ្ឋាន ត្រង់នេះគឺជាធម៌អាស្រ័យគ្នានិងគ្នាក្នុងលោកសន្និវាសនេះ មិនមានអ្វីដែលកើតឡើងទោសតែឯងមិនអាស្រ័យគ្នានិងគ្នានៅក្នុងធម្មជាតិនោះឡើយ។ ចិត្តអាស្រ័យរូបទើបអាចគង់វង្សបាន ចិត្តជ្រកក្នុងរូបដែលជាល្អាងគុហា បើរូបនោះបែកធ្លាយ ចិត្តក៏ត្រូវត្រាច់រង្គាត់ទៅរកភព រកទីតាំងថ្មីទៀតតាមវិបាករបស់ខ្លួន។ ឯរូបក៏ដូចគ្នា ទាល់តែមានចិត្តទើបតាំងនៅបាន ទាល់តែមានចិត្តទើបរូបមានខ្យល់ដង្ហើម រូបមានកម្តៅ រូបមានអាយុ ពេលរូបឈឺចិត្តក៏ឈឺ ពេលចិត្តឈឺរូបក៏ឈឺ ពេលចិត្តស្ងប់រូបកាយក៏ស្ងប់ ពេលចិត្តសប្បាយរូបកាយក៏ស្រស់ថ្លា។ គេឯងគ្រប់គ្នាចេះតែប្រឹងខឹងមិនចេះប្រើបញ្ញាអប់រំពន្យល់ចិត្តឲ្យត្រជាក់វិញទេ ចិត្តចង់បានអីក៏ចេះតែអន្ទក់អន្ទោលតាម ព្រោះហេតុតែតណ្ហាខ្លួនឯងទោះត្រូវសម្លាប់អ្នកណាក៏សម្លាប់។ ចិត្តនិងរូប គឺជាប់ប្រាស្រ័យទាក់ទងគ្នា មិនអាចថែទាំងតែមួយ

ចោលមួយបាននោះទៀយ កុំអាងតែគិតបានក៏ចេះតែប្រើចិត្តឱ្យគិតមិនឈប់ ចាំមើលតែពេលណាចិត្តលែងស្តាប់បញ្ជាយើងទើបបានដឹងខ្លួន ពេលនោះចិត្តទាមទារក្តីសប្បាយជ្រុល រហូតដល់យកកាកអំពៅចងសក់ជាលំអរ ឈរទទួលទូរស័ព្ទពីមហាមេឃ ឬឈរកាន់អំបោសធ្វើចរាចរណ៍បានថាចប់។ ការហាត់សម្រាកចិត្តមិនមែនទៅឈរ រាំចាក់ក្បាច់រលាស់ដៃជើងតាមភ្លេងនៅតាមចិញ្ចើមថ្នល់នោះទេ ព្រោះកីឡាគេលេងតាមអាយុ អាយុណាអាចរត់បាន អាយុណាត្រូវដើរយឺតៗ អាយុណាហែលទឹកបាន អាយុណាអាចវាយសីវាយថេនីសបាន ហាត់រយៈពេលកន្លះម៉ោងនាំឱ្យចុះជាតិស្ករក្នុងឈាម សម្រាប់អ្នកញ៉ាំបាយមិនបាន សំរាន្តមិនលក់ ហាត់លើសកន្លះម៉ោងនាំឱ្យចុះជាតិខ្លាញ់ក្នុងឈាម សម្រាប់អ្នកធាត់ជ្រុលហាត់លើសកម្លាំងនាំឱ្យបាក់កម្លាំង ខូចសន្លាក់ឆ្អឹង ទឹកដក់ក្នុងសន្លាក់។ល។ ខ្ញុំអ្វីវេជ្ជបណ្ឌិតដែលមរណៈភាពដោយសារកីឡានាំឱ្យរលួយសាច់ដុំបេះដូង ហាត់ពេកនាំឱ្យគាំងបេះដូង ដួលស្លាប់ទាំងព្រឹកព្រលឹម ព្រោះតែអាកាសធាតុត្រជាក់ពេក។ សម្រាកកាយចិត្តតាមការអប់រំក្នុងព្រះពុទ្ធសាសនា គឺមិនគ្រាន់តែបានក្តីសុខ

តាមកាយវាចាចិត្តប៉ុណ្ណោះទេ ថែមទាំងនាំឱ្យកើតបញ្ញាអាចរួចផុតចាកទុក្ខបានទៀតផង។

ចិត្តដឹងច្បាស់នូវអារម្មណ៍ ចិត្តគឺជានាមធម៌ដែលគេអាចដឹងបានតាមតែការឱ្យឈ្មោះទើបពិបាករក្សា ពិបាកអប់រំ ពិបាកប្រដៅ។ ធ្វើអ្វីក៏ដោយទោះល្អ ទោះអាក្រក់ក៏យើងមានខ្លួនជាអ្នកដឹងដែរ គឺយើងដឹងខ្លួនឯងដោយខ្លួនឯង តែពេលខ្លះយើងបំពានដោយមានះទៅលើការដឹងនោះ សតិ គឺជាលេខាផ្ទាល់របស់ចិត្ត ពេលចិត្តជិតកើតកំហឹង លេខាប្រាប់ថា លោកម្ចាស់! កំហឹងជិតកើតឡើងហើយ។ តែចិត្តបែជាយារដៃទះកំភ្លៀងលេខាហើយស្រែកថា ឯងកុំចេះ។ ធម្មជាតិនៃកំហឹង គឺជាកំហឹងមិនមែនកំហឹងបញ្ញាវន្តស្រាលជាងកំហឹងកម្មករ អ្នកធាក់ស៊ីក្លូមិនមែនកំហឹងពុទ្ធបរិស័ទស្រាលជាងកំហឹងគ្រីស្តបរិស័ទអ្វីនោះឡើយ ប៉ុន្តែបើយើងមិនបានហ្វឹកហាត់ឱ្យស្គាល់ចិត្ត ស្គាល់អារម្មណ៍បានច្បាស់ទេ យើងច្បាស់ជាងាយនឹងប្រព្រឹត្តិខុសតាមកាយវាចាជាពុំខានឡើយ។ ការដែលគ្រាន់តែដឹងចិត្តដឹងអារម្មណ៍តែប៉ុណ្ណោះ វានាំឱ្យកើតមានការត្រិះរិះពិចារណាពីហេតុ និងផលរបស់ចិត្តនោះ នាំឱ្យចិត្តដែលកើតឡើងប្រែជាចុះខ្សោយថមថយកម្លាំងរួចរលត់បាត់អស់ទៅ ចិត្តយើងក៏បានរួច

រំដោះពីទុក្ខហើយមានសេរីភាពចិត្តឡើងវិញ។ ពេទ្យហេងគាត់លេបទឹកមាត់បន្តិច តែត្រូវនាងមុំមើលឃើញទាន់ នាងក៏លើកកែវទឹកតែជូនពេទ្យហេង ដោយដៃទាំងពីរក្នុងក្តីគោរពដ៏ខ្ពង់ខ្ពស់។ ពេទ្យហេងក្រេបតែរួចញញឹមបន្តិចហើយពោលៈ មិនទាន់ចប់ទេពូសន ខ្ញុំសុំសម្តែងលក្ខណៈចិត្តបន្ថែមមួយទៀតគឺ **ចិត្តមានលក្ខណៈសន្សំនូវវិបាក** ចង់មានន័យថាអ្វីដែលយើងបានធ្វើទៅលើអ្នកដទៃទាំងល្អក្តីទាំងអាក្រក់ក្តី ផលនៃអំពើទាំងអស់នោះមិនបានបាត់បង់ឡើយ គឺតែងតែវិលត្រលប់មកឱ្យផលដល់យើងវិញក្នុងកំឡុងថ្ងៃហ្នឹង សប្តាហ៍ហ្នឹង ខែហ្នឹង ឆ្នាំហ្នឹង ឆ្នាំក្រោមឬជាតិក្រោយទៀតជាមិនខានឡើយ។ បើមិនបានតបស្នងដោយបុគ្គលហ្នឹង ក៏មានអ្នកផ្សេងគេធ្វើមកលើយើងវិញដែរ បើយើងសម្លាប់គេ គង់នឹងមានគេមកផ្តាច់ផ្តិលជីវិតយើងវិញ បើយើងកាន់យកទ្រព្យដែលគេមិនបានឱ្យយើងក៏នឹងត្រូវវិនាសទ្រព្យវិញ បើយើងបាកកុហកបោកប្រាស់គេ កង់នឹងមានគេមកបោកប្រាស់យើងវិញ បើយើងទៅលបផិតក្បត់នឹងកូនចៅគេ គង់នឹងមានគេមកលបផិតក្បត់កូនចៅយើងវិញដែរ។ ពេលដែលចិត្តបំពេញការងារ ឬចិត្តលែងមានអារម្មណ៍ពាល់ត្រូវ ចិត្តនេះបានត្រលប់មកកាន់សភាពដើមវិញ ព្រះលោកហៅថា **ភវង្គ (ភវ+អង្គ គឺ**

ចិត្តរក្សាភព) ភវង្គ គឺជាសភាពនៃចិត្តដែលស្ងប់ស្ងាត់ ហើយកត់ត្រាយកគ្រប់ទិន្នន័យដែលជាទង្វើររបស់យើង បត់ទុកជាផ្នត់គំនិតវាល់លានប្រធានបទ។ ពេលដែលផ្នត់គំនិតនោះវេលាចេញមកវិញ វាក៏ចាប់ឱ្យផលនៅវេលារៀបស្លាប់ ភវង្គតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ដែលបានសន្សំកត់ត្រាយកការប្រព្រឹត្តិរឿយៗក្នុងបច្ចុប្បន្នជាតិ វាបានផ្តល់អារម្មណ៍ធំណាមួយឱ្យចិត្តក្នុងមនោទ្វារតោងដើម្បីធ្វើកិច្ច **ចុតិបដិសន្ធិ (ស្លាប់-កើត)** ហេតុនេះបើយើងសន្សំកាប់សម្លាប់ សន្សំបៀរ អាប៉ោង សន្សំបុណ្យទាន ធម្មជាតិគឺកម្មក៏ចាត់ចែងឱ្យយើងបានភពប្រសព្វនឹងមាតាបិតា ដែលមានចំណូលចិត្តដូចយើងដែរ។ ពេលបានកំណើតហើយវេលាធំឡើងភវង្គចិត្តនោះក៏ចាប់ផ្តើមរលាចេញចរិត និស្ស័យពីបុព្វជាតិឡើងមកជាថ្មីវិញ ព្រោះហេតុនេះទើបក្មេងខ្លះអាយុត្រឹមតែ ៤ទៅ៥ឆ្នាំ ក៏ចេះដាក់ទានគោរពចាស់ព្រឹទ្ធាចារ្យ ក្មេងខ្លះចេះភូតកុហក ចេះហ៊ានសម្លាប់សត្វ ចេះលួចដោយគ្មានគេបង្គាប់។ ទាំងអស់នេះសុទ្ធតែជាច្បាប់ធម្មជាតិ ឥតមានព្រះអាទិទេពណាសាងទុកឱ្យឡើយ អ្នកណាធ្វើអ្នកហ្នឹងទទួល សាងកម្មអីទទួលបានកម្មហ្នឹង បើគ្រាន់តែជ្រមុជទឹក ហើយថាអស់បាបកម្មមែននោះម្លោះសមខ្យង ខ្ចៅ ត្រី អ

ណ្តើក ក្រពើ កន្ធាយវាអស់បាបកម្មអស់ហើយ បើយើងខ្លាចនៅមានអំពើបាប យើងកុំតែសាងបាបទៅវាមានបាបមកពីណា? ហើយបាបណាធំជាងបាបដាច់សីល៥នេះទៀត (លួច សម្លាប់ កុហក ប្រើគ្រឿងញៀនស្រវឹង ប្រព្រឹត្តខុសក្នុងកាម)។ បើយកជីវិតសត្វទៅថ្វាយព្រះអាទិទេព ហើយអាទិទេពនឹងផ្តល់ក្តីសុខនោះ អាទិទេពនោះមិនគួរឱ្យគោរពបូជាទេ ព្រោះអីក៏សាហាវម្លេះ ហើយដែលយើងខំថ្វាយតង្វាយទៅលោកនោះ តើយើងអាចកែប្រែឱ្យអាទិទេពនោះផ្លាស់ប្តូរចិត្តមកមានមេត្តា ករុណាបានទេ? បើយើងធ្វើល្អនាំឱ្យមានវិបាកជាសុខ បើយើងធ្វើអាក្រក់ នាំឱ្យមានវិបាកជាទុក្ខបុគ្គលមានខ្លួនកាត់ទោសខ្លួនដោយខ្លួនឯង អត់មានព្រះណាធ្វើជាតុលាការចាំវិនិច្ឆ័យទោសឱ្យយើងក្រៅពីតុលាការកម្មនេះទេ។ បើអារម្មណ៍ឱ្យចិត្តតោងពេលជិតស្លាប់វាកើតឡើងត្រង់មនោទ្វារ (ក្លៀបខួរក្រោយថ្ងាស) នេះជាអារម្មណ៍របស់កម្មពីអតីតជាតិដែលចេញមុខធ្វើកិច្ចចុតិបដិសន្ធិ ហេតុនេះកម្មដ៏តិចតួចឯណាមិនឱ្យផលរមែងមិនមានសោះឡើយ។ ចិត្តគិតពិចារណា ពីសច្ចៈធម៌នាំឱ្យមានវិបាកជាសុខសូប់ដល់ចិត្តកាយខ្លួនឯង ចិត្តគិតពិចារណាពីភាពក្តៅក្រហាយនិន្ទាព្យាបាទគេ បេះដូងត្រូវដើរញាប់រហូតគាំង

លើសសម្ភាធឈាម រលាកក្រពះពោះវៀនខ្លួនឯងឈឺស្លាប់ក៏មាន នេះឯងធម្មជាតិបានកាត់ទោសយើងភ្លាមៗ មិនមែនព្រះឯណាមកកាត់ទោសយើងនោះឡើយ។ យើងម្នាក់ៗ គឺជាធាតុមួយរបស់ធម្មជាតិកើតឡើងហើយតាំងនៅក្នុងធម្មជាតិ រួចក៏រលត់ចូលទៅក្នុងធម្មជាតិវិញ ហេតុនេះយើងត្រូវចេះព្រមប្រគល់អ្វីៗទាំងអស់ឱ្យធម្មជាតិតាមបរមត្ថសច្ចៈ ប៉ុន្តែបើគិតតាមបញ្ញត្តិសច្ចៈ ព្រះពុទ្ធក៏ទ្រង់ប្រដៅមិនឱ្យយើងដេកដួលតាមកម្មផលនេះពេកដែរ គឺត្រូវចុះចាញ់ធម្មជាតិ ត្រូវប្រើបាតដៃកែច្នៃធម្មជាតិឱ្យមកស្ថិតក្រោមអំណាចបញ្ញា ដើម្បីមានការរីកចម្រើនដល់ជីវភាពសង្គមមនុស្សជាតិទាំងមូល។ បរមត្ថទេសនាពន្យល់ថា ចាប់តាំងពីកើតទល់ថ្ងៃស្លាប់ អ្វីៗសុទ្ធតែជាធម្មជាតិទាំងអស់ដោយសារតែអវិជ្ជមានមនុស្សម្នាក់ៗបានបង្កើតចំណងសម្រាប់ខ្លួនឯងចងហើយ ស្រាយ ស្រាយហើយចងវង្វេងងប់ងល់ក្នុងល្បែងជីវិត ប៉ុន្តែអរិយបុគ្គលដែលលោកមានវិជ្ជាអាចជ្រាបច្បាស់ នូវធម៌ទាំងអស់បាន ពិភពលោកនេះនិងលោកុត្តរភព ហ្វូងតារានានា ព្រះសូរិយានិងលោកធាតុជាច្រើនមិនអាចនឹងគណនាបាន ដែលវិលទៅតាមវិថីត្រឹមត្រង់ឥតខ្ចោះប្រកបដោយអច្ឆរិយៈភាព មិនប៉ះពាល់គ្នាដោយការភាន់ច្រឡំ មានលក្ខ

ណៈផ្សេងពីគ្នាតែមានសភាពមូលចូលគ្នាតែមួយឯកឯងពិតប្រាកដ តែដោយឡែកៗពីគ្នា។ អ្វីដែលកើតឡើងយ៉ាងណា មានយ៉ាងណាគឺពិតយ៉ាងហ្នឹងឯង នោះគឺជារលកនៃអនិច្ចតាធម៌ជានិរន្ត ដែលជាកាលសម្រាប់លោកចម្រើនឡើងនឹងវិនាសទៅ។ អនន្តចក្រវាឡព្រមទាំងចក្រវាឡនីមួយៗ សុទ្ធតែមានទំនាញនឹងចំហាយច្រានចេញ ដែលបង្កើតបានជាច្បាប់អន្តរអំពើមួយផ្តល់នូវវឌ្ឍនធម៌ និង ហាយនៈធម៌ដែលមានសភាពឥតប្រែប្រួល ហើយព្យាយាមប្រតិបត្តិយ៉ាងស្ងប់ស្ងាត់ប្រកបដោយឆន្ទៈចង់ឱ្យក្លាយពីស្រមោលវិវត្តន៍ទៅកាន់ពន្លឺ ពីពន្លឺទៅកាន់ទីងងឹត ពីជីវៈទៅកាន់មរណៈ ពីមរណៈទៅកាន់ជីវៈ បំពេញធម្មជាតិដែលមានចន្លោះប្រហោង អាកាសរចនាឱ្យមានទម្រង់នូវធាតុណាដែលគ្មាន ប្រែពីសភាពគ្រោតគ្រាតទៅកាន់សោភ័ណ ពីសោភ័ណទៅកាន់សុក្រឹត្យដែលគ្មានបុគ្គលណាចាត់ចែងរៀបចំឡើងឡើយ ប៉ុន្តែគ្មានបុគ្គលណាអាចជំទាស់នឹងនិន្នាការនៃសេចក្តីបង្គាប់នោះបានទេ ព្រោះនេះជាច្បាប់និច្ចតាភាព ជានិយាម ជាអចិន្តៃភាព ទាំងជាឧត្តមភាព នៃអំណាចអស្ចារ្យមួយត្រួតត្រាលើធម្មជាតិទាំងអស់ ច្បាប់នេះគ្មានអ្វីក្រៅពីអន្តរអំពើរវាងធាតុ និងធាតុ ក្នុងធម្មជាតិនោះឡើយ។ ផលិតផលអន្តរ

កម្មបង្កើតឱ្យបានជារូប រួចវិញ្ញាណហើយអកុសលចិត្តចេតសិកផ្សេងៗ កើតឡើងបន្តៗក្រោមឥទ្ធិពលបរិយាកាសសង្គម ទារកដែលកើតមក ហើយចេះតែចម្រើនឡើងៗជាលំដាប់រហូត បើមិនបានទទួលការអប់រំឱ្យ បានត្រឹមត្រូវទេចិត្តអាក្រក់នោះនាំឱ្យប្រព្រឹត្តិបាបធម៌ និងអំពើលាមក សព្វបែបយ៉ាង។ ការអប់រំដែលសុក្រិតបំផុតនោះ គឺព្រះធម៌ក្នុងព្រះពុទ្ធ សាសនានេះឯង ព្រោះកុំសង្ឃឹមថាសញ្ញាប័ត្រផ្លូវលោកអាចសាងសុខ ឱ្យមនុស្សបានទាំងស្រុងឱ្យសោះនោះ ខ្វះអីមហាបណ្ឌិតដែលរស់មិន ចុះសម្រុងនឹងសង្គម បរាជ័យក្នុងការកសាងគ្រួសារ បរាជ័យក្នុងការងារ ព្រោះតែអស្មិមានៈ ការប្រកាន់អត្តទត្ថបុគ្គលនិយមតាមតែចិត្តខ្លួនឯង មិនដែលចេះយល់ចិត្តអ្នកដទៃឡើយ។ គេចេះតែសាងទុក្ខឱ្យចិត្តអ្នក ដែលមានទុក្ខស្រេចទៅហើយគេទាមទារការយកចិត្តទុកដាក់ពីអ្នកដទៃ តែឯងមិនដែលចេះធ្វើសម្បទាន ឬអនុញ្ញាតិឱ្យអ្នកណាបានសម្រេចក្តី ប៉ងប្រាថ្នាតាមឆន្ទៈរបស់ខ្លួន ជៀសពីការរិនិវច្ឆ័យរបស់គេឡើយ។ សញ្ញាប័ត្រផ្លូវលោកនាំឱ្យថ្កោសធំតែអញ ឯព្រះធម៌នាំឱ្យស្តើងអញទំ លាក់ការមានៈប្រកាន់ ដែលជាមូលហេតុនៃបញ្ហាទើបព្រះធម៌គឺជា ប្រទីបបំភ្លឺជីវិត ព្រះធម៌ដេញភាពខ្វាក់ងងឹតនៃអវិជ្ជា ព្រះធម៌រមែង

គ្រប់គ្រងរក្សាអ្នកប្រព្រឹត្តធម៌។ ពូហេងពោលបានត្រឹមនេះ សម្លេងឆ្កែព្រុសរ៉ូសៗនៅមាត់ទ្វាររបង អ្នកទាំងបីសម្លឹងទៅព្រមគ្នា គឺពូផេងនិងមីងស៊ុមបណ្តើគ្នាដើរចូលមក។ លោកតាសនស្រែកសួរមុន៖ **អើហ៎ ផេង! នាងស៊ុម ពួកឯងមកពីណាហ្នឹង?** ខ្ញុំជូននាងទៅរកទិញគ្រឿងអលង្ការខ្លះទុកគ្រាន់ពាក់ទៅញ៉ាំការគេខែក្រោយហ្នឹងណាពូ (ពូផេងតប)។ អើហ៎ មកអង្គុយលេងសិនមក (តាសនហៅគាត់ទាំងពីរនាក់) លុះពូមីងអង្គុយបានស្រួលបួលហើយ លោកតាសនក៏សួរភ្លាម៖ **អើហ៎ ស៊ុមអើយ!** តើឯងចង់បានអីខ្លះពីក្នុងលោកនេះ? មីងស៊ុមធ្វើមុខអឹមអៀនបន្តិចទើបឆ្លើយ ស្អីទេពូនេះពីរពាន់ដប់ហើយណា ឱ្យប្តីទិញគ្រឿងអលង្ការឲ្យតើមានខុសនឹងសិក្ខាបទណាទៅពូ? វាមិនខុសទេ តែតណ្ហាបើយើងមិនដឹងពិសវាទេវានឹងប្រើឯងទាល់តែឆ្កួតណាក្មួយ (តាសនតប) នៅទីបំផុត គឺគ្មានអ្នកណាម្នាក់បានអីពីក្នុងលោកនេះទៅទេ ព្រះរាជាទាំងឡាយ សេដ្ឋីទាំងឡាយ ដង្ហៅគហបតីទាំងអស់តាំងតែពីបុរាណកាលរៀងមកសុទ្ធតែទៅបាត់ចោលទ្រព្យសម្បត្តិអស់ អត់ដែលបានអីយកទៅតាមខ្លួនទេ សូម្បីតែព្រះណាក៏ដោយ ចុះទម្រាំយើងតើនៅចង់បានអីទៀត? បានខ្សែដៃមាស ចិញ្ចៀនពេជ្រមក បានត្រឹមម៉ា

ឃើញចិត្តត្រេកអរ ម៉ាខ្ញាកហើយរលត់បាត់អស់ទៅ ហ៊ានតែដេកអរ ឬ ដេកកើតទុក្ខលើសពីពីរសប្តាហ៍ ពេទ្យផ្លូវចិត្តគេថាមនុស្សហ្នឹងកើតរោគចិត្តហើយ។ មនុស្សតែងខ្វាយខ្វល់ពីទ្រព្យសម្បត្តិ ដែលសូម្បីតែខ្លួនឯងក៏មិនមែនជាទ្រព្យរបស់ខ្លួនឯងផង។ ជនទាំងឡាយតែងសោកសង្រេងព្រោះតែប្រកាន់ថាអ្វីៗជារបស់ខ្លួន សេចក្តីប្រកាន់ក្នុងរបស់ដែលទៀងក្នុងលោកនេះមិនមានឡើយ ជីវិតនេះតែងព្រាត់ប្រាស់ចាកចោលជាធម្មតា បណ្ឌិតឃើញហេតុដូច្នេះ រមែងលះការប្រកាន់ទាំងពួងចោលការរលត់ទៅនៃជីវិត គឺជាការរលត់ទៅនៃខន្ធទាំងឡាយ៥ មិនមានអ្វីរលត់នៅក្រៅខន្ធ៥នេះឡើយ ការរលត់នេះគឺមិននៅក្រោមអំណាចយើងទេ គឺនៅក្រោមកម្មនិយាមទាំងអស់។ ឆ្អឹងក្តីសាច់ក្តី មានយើងជាអ្នកបង្កើតឯណា? យើងគ្រាន់តែចាំប្រើស្រាប់ៗ ហើយតាំងប្រកាន់ថាជារបស់យើង ចេះថែទាំលំអរវាជារការល្អហើយ តែក៏មានកុំមានៈប្រកាន់មាំហួងហែងវាពេកដែរ។ កុំចេះតែតុបតែងឱ្យរូបមិនចេះតុបតែងចិត្តដុសសំអាតតែរូប មិនដុសសំអាតចិត្ត រូបគ្រាន់តែជាផ្ទះសំណាក់ដែលពុកផុយមួយប៉ុណ្ណោះ ហើយយើងត្រូវចាកចេញចោលគ្រប់ពេលវេលា។ អញ្ចឹងមិនបាច់ខំធ្វើការរកស៊ីអីទេពូ ដេកចាំឱ្យរូបវាបែកធ្លាយទៅ ទ្រឹស្តីពូ

គ្មានអភិវឌ្ឍខ្លួនសោះ! (ពូផេងនិយាយតបដោយធ្ងន់សម្លេង) ប្រដៅយូរៗទៅដូចជានាំមនុស្សឱ្យខ្ជិល ឱ្យក្រទៅវិញទេនែ៎ក។ ស្តាប់ពូសិនផេង វិស័យមនុស្សពាលតែងក្របួចយកតែផលមកត្រិះរិះ មិនបានពិចារណាពីហេតុរបស់រឿងរ៉ាវណាមួយឡើយ ចោរកើនឡើងច្រើនក្នុងរាជគ្រឹះព្រះបាទពិម្ពិសារប្រឹងតែឲ្យអាមាត្យចាប់ចោរដាក់គុក លុះព្រះពុទ្ធនិមន្តចូលទៅព្រះរាជាក៏ចូលថ្វាយបង្គំ ព្រះពុទ្ធទ្រង់ត្រាស់ថា៖ បរពិត្រមហារាជ បើទោះជាព្រះអង្គចាប់រាស្ត្រទាំងនគរដាក់គុកក៏មិនអស់ចោរដែរ សូមមហាបរពិត្រទ្រង់ព្រះតំរិះមើលថា តើហេតុអីបានជារាស្ត្រអស់នោះធ្វើចោរ? គឺមកតែពីសេចក្តីក្រីក្រនៅលើផ្ទៃមុខដែលមានតែស្នាមក្រីក្រ ហើយបបួរមាត់មិនដែលពោលពាក្យពិតឡើយ ឯដៃនិងជើងក៏ធ្វើអំពើបរិសុទ្ធមិនបានដែរ។ សូមមហារាជចែកពូជស្រូវ ចែកដីធ្លី ពូជគោក្របី សាងប្រឡាយទឹកឱ្យប្រជារាស្ត្ររបស់ព្រះអង្គទៅ បំបាត់ល្បែងស៊ីសងអំពើពាលអាវ៉ាសៃ រៀបចំរកស៊ីនឹងនគរដទៃ អប់រំបង្ហាត់បង្ហាញកូនចៅប្រជារាស្ត្រឱ្យប្រកបគុណធម៌ ទាំងអស់នេះ សុទ្ធតែជាហេតុដែលមហារាជដោះស្រាយឲ្យបានហ្មត់ចត់ តើសេចក្តីចម្រុងចម្រើនឯណានឹងកើតឡើងមិនបាន? សូមដូចសិលាចារឹករបស់ខ្មែរយើងដែលបានឆ្លាក់ព្រះ

បន្ទូលនៃព្រះបរមក្សត្រជ័យវរ្ម័នទី៧ ថាបញ្ហាផ្តួលរំលំយករាជបល្ល័ង្កពុំ
បានធ្វើឱ្យអញព្រួយបារម្ភឡើយ គឺការដឹកនាំឱ្យរាស្ត្របានសុខសំបូរ
សប្បាយឯនោះទៅវិញទេ ដែលធ្វើឱ្យអញព្រួយ។ គតិបណ្ឌិត
ទាំងឡាយក្នុងលោក គឺប្រៀបដូចជាប្រទីបជ្វាលាដែលយើងត្រូវថែរក្សា
ក្នុងគេហដ្ឋានរៀងៗខ្លួន ឬត្រូវថែរក្សាក្នុងចិត្តគំនិតរបស់យើង។ ប្រទីប
គឺជាភ្លើង បើយើងរក្សាមិនបានល្អវានឹងរលត់ បើវារលត់យើងងងឹតរក
ទិសតំបន់មិនឃើញឡើយ ផ្ទុយទៅវិញបើបណ្តោយឱ្យវាឆាបឆេះខុស
បែបបទ វានឹងឆេះបំផ្លាញយើងវិញទេ។ ព្រះធម៌នាំឱ្យខ្ជិល ឱ្យខ្លាច ឱ្យក្រ
នេះមកពីយើងប្រើឧត្តមគតិនោះខុស ព្រោះតែការចេះមិនត្រឹមត្រូវ
ជំនាន់ពុទ្ធកាលមានអ្នកក្លាយជាមហាសេដ្ឋីច្រើនណាស់ ព្រោះតែបាន
សេពគប់នឹងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងបានបម្រើសេចក្តីសុច្ចរិត
យើងគ្រប់គ្នាស្អប់អំពើទុច្ចរិត ស្អប់អំពើមិនបរិសុទ្ធ បើដឹងថាមានមនុស្ស
ម្នាក់ប្រកាន់សុច្ចរិត ទៀងត្រង់ របស់សុទ្ធថាសុទ្ធ មិនប្រវ័ញ្ចអារកហុត
ឈាម ទាំងអស់គ្នាច្បាស់ជានាំគ្នាទៅរកស៊ីជួញប្រែជាមួយតែមនុស្ស
ម្នាក់នោះជាពុំខាន។ ក្រិត្យវិន័យ និងបញ្ញា ក្នុងព្រះពុទ្ធសាសនាមិនមែន
ប្រដៅមនុស្សឱ្យខ្ជិលទេ ព្រោះព្រះអង្គប្រដៅឱ្យបរិស័ទខំស្វែងរកទ្រព្យ

ដោយសុច្ចរិត បានទ្រព្យហើយត្រូវចេះថែរក្សា ចេះធ្វើបុណ្យដាក់ទានខ្លះ នឹងត្រូវចេះធ្វើចិត្តឱ្យជ្រះថ្លាសប្បាយរីករាយចំពោះទ្រព្យ មិនមែនឱ្យទ្រព្យជិះជាន់ចិត្តនោះទេ ដែលឱ្យមនុស្សខ្ជិលគឺខ្ជិលសាងបាប ខ្ជិលធ្លាក់ទៅកើតជានរកប្រេតតិរច្ឆាននិងអសុរកាយ ព្រះធម៌នាំមនុស្សឲ្យក្រ គឺក្រលោភៈ ទោសៈ មោហៈ ក្រកិលេស រាគៈ តណ្ហាឯនេះវិញទេ។ តាសនមិនទាន់ពោលចប់ផង ពូផេងលាន់មាត់ៈ **អូហ៎!** ខ្ញុំសុំខមាលទោសផង ពូសុំអហោសិកម្មចំពោះសត្វថយថោកល្ងង់ខ្លៅដូចជារូបខ្ញុំណាពូ។ **ល្អហើយក្មួយ** ដែលចេះដឹងខុសត្រូវ ចេះស្តាប់ហេតុផលនឹងបានជាសម្មាទិដ្ឋិជន ទៅថ្ងៃខាងមុខកុំឱ្យមច្ឆាទិដ្ឋិវាបៀតបៀន វាចូលខ្លួនបាន តែខំធ្លាក់ជ្រៅជាងអនន្តរិយកម្ម៥យ៉ាង **សម្លាប់មាតា បិតា ព្រះអរហន្ត ធ្វើឱ្យព្រះពុទ្ធពោរពុងព្រះលោកហិត នឹងសង្ឃភេទ** ទៅទៀត មិច្ឆាទិដ្ឋិធ្លាក់ទៅលោកន្តរនរក ដរាបណាមានចិត្តដឹងថាធ្វើកម្មមានផលរបស់កម្ម ទើបបានរួចខ្លួនពីឋានមហាអវចីនេះ។ **អើហ៎!** ជជែកគ្នាលេងៗសោះថ្ងៃបាក់រសៀល មហាមេឃជិតព្រួសទឹកដាក់ផែនដីទៀតហើយណ៎ាក ផេងនិងស៊ុម ប្រញាប់រូតរះទៅចុះឯក្មួយមុំ ម្នាយឯងសុខទុក្ខយ៉ាងម៉េចដែរហើយនេះ? ចាស៎អឹំ ម៉ែក្មួយមួយថ្ងៃចាស់ជាងមួយថ្ងៃដូចចង្កៀងជិតអស់ប្រេង

ទៅហើយ។ ឥទ្ធិពលថ្នាំលើរូបគាត់ចេះតែខ្សោយទៅៗ ពូហេងជួយដូរ មុខថ្នាំឲ្យរហូត ប៉ុន្តែស្មារតីម៉ែនៅរឹងមាំល្អណាស់ ព្រោះធ្លាប់ជាញាតិព្រះធម៌ អភ័ព្វតែរូបខ្ញុំដែលរស់ដូចខ្វះមុខរបរ ប៉ុន្តែបានស្តាប់អ៊ំ ពូ មានប្រសាសន៍រឿយៗ ឃើញកំហុសខ្លួនឯងកាន់តែច្បាស់ បើមិនឆាប់ផ្លាស់ប្តូរទេខ្លាច តែព្រះព្រោសមិនបានទេជាតិនេះ។ កុំអស់សង្ឃឹមកូនស្រីព្រះមិនដែលច្រានចោលនរណាម្នាក់ឱ្យនៅក្រៅសំណាញ់ញាណរបស់ព្រះអង្គនោះទេ កាលព្រះពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ព្រះអង្គធ្លាប់និមន្តទៅព្រោសនាងស្រីផ្កាមាសឈ្មោះ **អម្ពបាលី** ឱ្យបានត្រាស់ដឹងធម៌ក្លាយជាអរិយបុគ្គលរួចផុតចាកទុក្ខទៀតផង ហើយសូម្បីតែសត្រូវតាមធ្វើគត់ព្រះអង្គគ្រប់ជំហ៊ានដូចជាព្រះភិក្ខុទេវទត្ត ក៏ព្រះអង្គនៅតែមានហឫទ័យមេត្តាករុណាព្រោសប្រណីជានិច្ចដែរ ចុះព្រះលោកមកស្អប់អីក្មួយឯងនោះ។ នាងមុំបញ្ចេញស្នាមញញឹមបង្កប់ដោយវិប្បដិសារីយ៍បន្តិច ក៏បង្អោនកាយគោរពលាចេញទៅក្រោមក្រសែភ្នែកអាណិតអាសូរ របស់បុព្វការីជនទាំងពីរដែលជាតំណាងឱ្យឈាមជ័រខ្មែរពីបរមបុរាណមក។ លុះស្រមោលនាងមុំរលត់ផុតទៅល្មម ពេលនឹងរស្មីកែវភ្នែកព្រឹទ្ធាចារ្យសនជះប៉ះនឹងកែវភ្នែកពូពេទ្យហេងដែរ លោកតាសនញញឹមខុបដូចចំពុះ

សេក ព្រោះមាត់អស់ធ្មេញមានតែអញ្ចាញហើយបន្លឺសម្លេងច្បាស់ៗ៖ សូមឲ្យបានដល់នូវសេចក្តីសុខស្ងប់ចុះកុំបីមានក្តីវិនាសឡើយ សូមឱ្យមនុស្សសត្វដែលបានទទួលនូវអំពើមិនបរិសុទ្ធទាំងឡាយ ទាំងការបង្ខិតបង្ខំលើរាងកាយចិត្តដោយអំពើហឹង្សាឯណានីមួយ សូមឱ្យបានរួចរំដោះហើយមានសេរីភាពដូចគេឯង សូមអ្នកមានអំណាចទាំងឡាយបានកែប្រែចិត្ត បរិបូរណ៌ដោយអធិវាសនខន្តីនិងក្តីអាណិតអាសូរដល់អ្នកទន់ខ្សោយ សូមសត្វលោកបានទទួលភាគកក់ក្តៅពីព្រះធម៌ ដោយការស្វែងរកពន្លឺត្រាស់ដឹងក្នុងចិត្តខ្លួនឯងឱ្យបានគ្រប់ៗគ្នាកុំបីខានឡើយ។ ដៃដែលលើកបន្ទុលបួងសួងដាក់លើក្បាល ត្រូវបានរាងកាយទ្រទ្រង់ហើយនាំចេញទៅទាំងមិនបាននិយាយថាលា។ លោកតាសន ជាសន្តបុគ្គលគំរូនៅក្នុងភូមិបានចេញពីរបងផ្ទះពូផេងបន្សល់នូវក្តីសង្ឃឹមថា នឹងបានជួបគ្នាជាថ្មីទៀតប្រសិនបើអនិច្ចតាធម៌មិនមកគ្របសង្កត់លើរូបគាត់ទេ។ មិនបានមួយស្របក់ផង ព្រះភិរុណក៏បង្អុរចុះលើដែនពសុធាយ៉ាងញាប់រន្ទើន ដោយក្តីស្រលាញ់ឥតប្រកាន់ចំពោះមនុស្ស សត្វ និងរុក្ខជាតិថា មួយណាគួរឱ្យស្អប់ មួយណាគួរឱ្យស្រលាញ់អ្វីនោះឡើយ។

កំហឹងមហាមេឃ បានចាប់ផ្តើមផ្ទេរពេញទំហឹងមកលើដែនប្រថពី ហើយមេឃញាក់ចិញ្ចើមដាក់ផែនដីព្រឺតៗ ឆ្វែលឆ្វាត់លើវេហាទឹកមុខប្រែជាខ្មៅកកដុំៗ ហើយព្រួសទឹកភ្ញុណដូចគេចាក់មកលើដំបូលផ្ទះស្រីមុំ ផ្ងួនគ្នានឹងខ្យល់បោកលើបង្អួចដែលដាច់ត្រចៀកម្ខាងមហាមេឃគ្រហឹមងឹលៗ ហើយកណ្តាស់ផាំងៗ សឹងប៉ើងផ្ទះជារបស់នាងមុំ។ នាងមុំខ្វែងដៃខ្វែងជើងស្ទុះយកចានដែក ដាក់ត្រងទឹកដែលបាញ់នោះចុះតាមដំបូលដូចក្មេងបន្ទោរបង់ទឹកមូត្រចំពីលើក្បាល រួចហើយលូកដៃប្រឹងទប់ទាញបង្អួចដែលចង់ជំរាបលានាងហក់ទៅដី ឯជើងប្រឹងរុញធុងធ្លាយគូថមួយដាក់ឱ្យចំទឹកធ្លាយតាមទរបាញ់មកចំចង្រ្កានបាយ ដែលកំពុងដាំឆ្នាំងប្រុងរំងាស់ថ្នាំជូនម៉ែ។ ភ្នែកនាងលួចឆ្មៀងមើលគ្រែដំណេកអ្នកម្តាយ ក្រែងមានលិចទឹកលើ ឃើញម៉ែប្រឹងអង្គុយជើងរំកិលខិតចុះក្រោមគេចតំណក់ទឹកភ្លៀងទាំងរងារញ័រប្រាណ។ ទឹកភ្លៀងបានចាប់ហូរចាក់បំពេញថ្លុកត្រពាំង ហូរច្រោះកាត់ជើងសរសរផ្ទះនាងដែលជំទើតលើថ្មជើងតាំងកាច់ផ្ងៀងចង្កេះដូចចង់រកកលរលំម្តងៗ។ លុះបានបន្ធូរកំហឹងរួចហើយ មហាមេឃបានប្តូរទឹកមុខប្រែជាភ្លឺថ្លាមានរស្មីបន្តិចម្តងៗ រួចក៏បង្ហួសទៅកំញើញដាក់ស្រុកផ្សេង បន្សល់ទុកតែវាយោបក់

ត្រសៀកអង្រួនស្លឹករុក្ខជាតិឱ្យជ្រុះតំណក់ទឹកភ្លៀង ដើម្បីបញ្ចេញភាពស្រស់បំព្រងរបស់ខ្លួនក្រោយពេលភ្លៀងធ្លាក់។ អាកាសធាតុចាប់ផ្តើមចុះត្រជាក់យ៉ាងនេះសមនឹងពេលក្បាលព្រលប់ផង បើអ្នកណាមិនបានប្រុះខ្លួនតម្រង់ខ្នងគឺប្រាកដជាស្តាយក្រោយជាពុំខាន មុំមិនចង់ឱ្យខាតពេលយូរព្រោះហត់នឿយផង ក៏ប្រុះខ្លួនទម្រេតពីក្រោយខ្នងម្តាយ ហើយដើម្បីកែអផ្សុក ដៃម្ខាងរាវលើក្បាលដំណេករកកូនវិទ្យុសូនីអត់សន្ទុះគ្រាប ថ្ម ដែលនាងទិញជូនម៉ែទុកគ្រាន់ស្តាប់ធម៌ ដើម្បីបានមកស្តាប់ចម្រៀងកំសាន្តចិត្ត នាងរាវរកប៉ុស្តិ៍បានមួយស្របក់ ស្រាប់តែចំលើសម្លេងបុរសម្នាក់ផ្សាយយ៉ាងក្រអួនគួរឱ្យជក់ចិត្ត៖ សួស្តីប្រិយមិត្តអ្នកស្តាប់ជាទីគោរពរាប់អាន ដើម្បីបម្រើសោតិន្ទ្រីយារម្មណ៍លោកអ្នកឱ្យកាន់តែមានភាពស្រស់ថ្លាថែមទៀត តទៅនេះវិទ្យុសម្លេងបក្ស ធម្មៈ របស់យើងខ្ញុំដែលមានបាវចនាជាតិ ជរា ព្យាធិ មរណៈ សូមនាំយកចម្រៀងមួយបទដែលមានចំណងជើងថា ស្តាយកេរ្តិ៍ដូនតា អ្នកនិពន្ធបានតែងឡើងក្នុងកំឡុងទសវត្សឆ្នាំ៦០ មកផ្សាយជូនសណ្តាប់ដូចតទៅ៖

១- ស្តាយអើយ សែនស្តាយ ដីដើមដង្ហើមជាតិខ្មែរ ព្រាប់ប្រាស់គ្នាបាត់បង់ទាំងគ្រួសារ បាត់បង់ទាំងគ្រួសារ។

២. ស្តាយទឹកដីម្លេះទេ កេរ្តិ៍ដំណែលដូនតា អស់ឱជាតិខេមរា ថ្ងៃណាឆ្នាំណាជួបគ្នាវិញ ថ្ងៃណាឆ្នាំណាជួបគ្នាវិញ។

បាទ! ចម្រៀងដែលអស់លោកអ្នកទើបតែបានសណ្តាប់មកនេះកាលពីជំនាន់នោះ គឺថ្នាក់កុមារដ្ឋានបឋមភូមិ គេច្រៀងក្រោយពេលគោរពទង់ជាតិ។ បាទ! ហើយជាបន្តទៅទៀតពីនាទីយើង សូមគោរពអញ្ជើញបងប្អូនប្រុសស្រី បង្វែរអារម្មណ៍មកទទួលសណ្តាប់ការថ្លាថ្លែងអំពីសេចក្តីសង្ឃឹមរបស់ឪពុកម្តាយ ការពោលពីគុណូបការៈរបស់លោកទាំងទ្វេរ បើទោះជាយកទឹកសមុទ្រធ្វើជាទឹកខ្មៅ យកផ្ទៃផែនដីធ្វើជាក្រដាស់ ក៏យើងមិនអាចសរសេរឱ្យអស់អំពីគុណរបស់លោកដែរ។ ជីវិតពិតជាមានខ្លឹមសារគ្រប់អត្ថន័យពិតប្រាកដមែន ប៉ុន្តែវាដូចជាពន្លឺភ្លើងកាំជ្រួចដែលគេបាញ់នារាត្រីកាល ជះបំភ្លឺលោកគ្រប់ពណ៌ គ្រប់សណ្ឋាន មានទ្រង់ទ្រាយប្លែកៗ ហើយក៏ត្រូវស្បែអន្ធការលេបត្របាក់យកបាត់ស្ងាត់សូន្យសុងអស់ទៅវិញ ងងឹងចាក់ភ្នែកមិនធ្លុះដដែល បានត្រឹមតែម៉ាបញ្ឆោតឱ្យក្មេងល្ងង់ខ្លៅហ៊ោរកញ្ជ្រៀវគឹកកងរំពង វាគ្មានអ្វីជាការពិតនោះទេ។ មនុស្សគ្រប់រូបក៏ដូចគ្នា កើតហើយធំ ធំហើយចាស់ ចាស់ហើយឈឺ ឈឺហើយស្លាប់។ ប៉ុន្តែមុននឹងចាស់នៅ ខំឆ្លៀតបម្រើតណ្ហា

តាក់តែងឱ្យកើតសង្ខារថ្មីៗជាច្រើនទៀត រួចក៏ប្រយុទ្ធដើម្បីអត្ថិភាពលើសមរភូមិអវិជ្ជាដែលជួនកាលត្រូវបំផ្លិចបំផ្លាញខ្លួនឯងខ្លះ បំផ្លិចបំផ្លាញអ្នកដទៃខ្លះដើម្បីបន្តសង្សារវដ្តដ៏វែងឆ្ងាយរបស់ខ្លួន ដែលមិនដឹងចាប់ផ្តើមពីត្រឹមណាហើយទៅបញ្ចប់នៅត្រឹមណាឡើយ។ នេះជាសម្លេងពុកម៉ែស្រែកផ្តាំកូនប្រុសស្រី នៅថ្ងៃណាដែលកូនៗបានឃើញថាពុកម៉ែចាស់ជរាហើយនោះ សូមកូនៗព្យាយាមអត់ធ្មត់ចំពោះឪពុកម្តាយ ហើយបើសិនជាឪពុកម្តាយធ្វើឱ្យប្រឡាក់ប្រឡូសមុខមាត់ ពេលទទួលទានអាហារ ពិបាកក្នុងការស្លៀកពាក់ សូមអត់ធ្មត់ចំពោះគាត់ ហើយត្រូវចងចាំថា រឿងទាំងអស់នេះសុទ្ធតែពួកគាត់បានធ្វើនឹងបង្រៀនកូនៗកាលកូនៗនៅតូច។ នៅពេលដែលគាត់មិនអាចដើរបានដូចមុន សូមជួយឪពុកម្តាយដូចដែលពួកគាត់បានជួយដឹកដៃបង្រៀនកូនៗឱ្យរៀនដើរជាលើកដំបូងអញ្ចឹងដែរ។ បើឪពុកម្តាយនិយាយដដែលៗទៅកាន់កូនៗ សូមកុំធុញទ្រាន់ចំពោះឪពុកម្តាយ កុំខឹងនឹងពួកគាត់ សូមស្តាប់គាត់និយាយផង ព្រោះកាលកូននៅតូចៗ កូនៗបានឱ្យឪពុកម្តាយនិទានរឿងដដែលៗ ឱ្យកូនៗស្តាប់ជារៀងរាល់ថ្ងៃ រហូតដល់កូនបានគេងលង់លក់ស្តប់ស្តល់ ទើបហ៊ានទៅបំពេញការងារផ្សេងៗទៀត ពួក

គាត់រីករាយសប្បាយចិត្តក្នុងការធ្វើរឿងដដែលៗនេះខ្លាំងណាស់។ ពេលឪពុកម្តាយជរាមិនអាចងូតទឹកខ្លួនឯងបាន ឬបន្ទោរបង់ដាក់សំលៀកបំពាក់ សូមកុំបន្ទោសពួកគាត់ កុំខឹងហើយកុំខ្ពើមឪពុកម្តាយ ចូរចងចាំថាឪពុកម្តាយតែងតែងូតទឹកឱ្យកូនៗកាលនៅតូច ពេលខ្លះត្រូវកូនៗបន្ទោរបង់ដាក់លើខ្លួនប្រាណគាត់ តែគាត់បែរជាសើចសប្បាយហើយលួងលោមច្រៀងបំពេរដោយសម្លេងថ្នាក់ថ្នមពិរោះខ្វើយៗ ដោយពាក្យពេជន៍ផ្អែមល្ហែម ក្រៅពីពាក្យថា មាស ពេជ្រ បណ្តូលចិត្តតែមួយគឺ មិនប្រើឡើយដើម្បីឱ្យកូនបានងូតទឹក ឬឲ្យកូនគេងលក់។ ពេលខ្លះដើម្បីឱ្យកូនៗបានសប្បាយចិត្ត គាត់ធ្វើជាវាយទះតប់ខ្លួនឯងដើម្បីលុបលាងកំហុសដែលបានប្រព្រឹត្តិឆ្គាំឆ្គងមកលើកូនៗ ពេលខ្លះត្រូវធ្វើជាគោ ក្របី វារជើងបួនឱ្យជិះ ឲ្យកូនតោងបោចសក់ក្បាលវាយទះជាភ្លេងឱ្យតែកូនៗបានសើចសប្បាយ។ បើឃើញពុកម៉ែមិនដឹង ឬមិនយល់ពីបច្ចេកវិទ្យាទំនើបៗសូមកុំសើចចំអកឱ្យគាត់ ព្រោះពុកវល់តែភ្ជួរស្រែ និងឡើងភ្នោតខំសន្សំប្រាក់ផ្តល់ឱ្យកូនបានរៀននៅទីក្រុង ឯម៉ែខំចិញ្ចឹមជ្រូក គោក្របី គាត់គ្មានទាំងពេលសំរាន្តថ្ងៃត្រង់ផង។ ត្រូវមានមោទនភាពចំពោះពុកម៉ែ ពេលគាត់មកលេងទីក្រុងត្រូវហ៊ានអួតប្រាប់គេឯងថា លោកទាំងពីរ

គឺជាព្រះអរហន្តរបស់ខ្លួន ដែលមិនត្រូវគោរពមនុស្សដទៃឱ្យលើសពួកគាត់ឡើយ។ អ្វីដែលពួកគាត់មានចំងល់ សូមទុកពេកឱ្យគាត់ស្វែងយល់ផង ពុកម៉ែធ្លាប់ទុកពេលឱ្យកូនៗ ដើម្បីសាកសួរនិងស្វែងយល់ពីអ្វីដែលថ្មីៗ ហើយបានបង្រៀនដល់កូនៗដោយមិនចេះធុញទ្រាន់បង្រៀនអំពីរបៀបស្លៀកពាក់ របៀបទទួលទាន របៀបរស់នៅ ការប្រព្រឹត្តិល្អ សេចក្តីក្លាហាន ការតស៊ូព្យាយាម មានភាពរឹងមាំតាមផ្លូវចិត្ត ការចេះប្រឈមមុខចំពោះរាល់បញ្ហានៅក្នុងជីវិត អ្នកមិនត្រូវភ្លេចទេថា បុគ្គលិកលក្ខណៈក្នុងស្មារតី និងឈាមដែលកំពុងហូរយ៉ាងកក់ក្តៅគគុកក្នុងសរសៃរបស់អ្នក គឺជាការផ្តល់ឱ្យរបស់ពុកម៉ែទាំងអស់។ ពេលខ្លះពុកម៉ែវង្វេងភ្លេចភ្លាំង ឬពិបាកក្នុងការនិយាយ សូមទុកពេលឱ្យពុកម៉ែរកនឹកវាឡើងវិញ ហើយបើគាត់មិនអាចរកនឹកឃើញ សូមអ្នកកុំមួរម៉ៅហើយគំហកកំហែងមាត់ធំតូចដាក់គាត់ កុំធុញទ្រាន់នឹងឪពុកម្តាយរហូតដល់នឹកគិតក្នុងចិត្ត ចង់ឱ្យគាត់ឆាប់ស្លាប់ឱ្យផុតៗពីមុខពីមាត់ឱ្យសោះ សូមកុំធ្វើប្រដើយកន្តើយ ឬតមពាក្យសំដីនឹងពួកគាត់ ព្រោះអ្វីដែលសំខាន់ជាងគេសម្រាប់ឪពុកម្តាយគឺ ចង់រស់នៅក្បែរកូនចៅ ចង់និយាយជាមួយកូនចៅ។ ប្រសិនបើពុកម៉ែមិនចង់បរិភោគសូមកុំបង្ខំ

គាត់ ព្រោះគាត់ដឹងខ្លួនឯងច្បាស់ថាតើពេលណាគាត់ចង់បរិភោគ ហើយពេលណាដែលគាត់មិនចង់បរិភោគ។ បើសិនជាមានថ្ងៃណាមួយ ឪពុកម្តាយនិយាយទៅកាន់កូនៗថា ឪពុកម្តាយមិនចង់រស់នៅតទៅទៀតទេ នោះមានន័យថាពួកគាត់ចង់ស្លាប់ហើយ សុំកុំខឹងនឹងឪពុកម្តាយព្រោះថ្ងៃណាមួយកូនៗនឹងបានយល់។ ចូរអ្នកចងចាំថា ពេលណាដែលកូនសើចចំអកដាក់ភាពជារបស់ពុកម៉ែ សំណើចរបស់កុនបានលាន់ឮឡើងហាក់ដូចជាបានរួចខ្លួន ប៉ុន្តែមនុស្សយើង គឺមិនអាចគេចជៀសពីមរតកនេះបានឡើយ **កើត ចាស់ ឈឺ ស្លាប់ ព្រាត់ប្រាស់ ទុក្ខព្រួយ** មិនមែនជាធម៌សម្រាប់និគមឯណាតែមួយៗឡើយ គឺជាធម៌សកល ព្រោះធម្មជាតិណាកើត ធម្មជាតិនោះត្រូវវិនាសទៅវិញជាធម្មតា។ អ្វីដែលកូនៗបានធ្វើចំពោះពុកម៉ែ គឺកូនរបស់ឯងកំពុងរំពៃតាមមើលយកទុកជាគំរូដើម្បីយកតម្រាប់តាមនៅពេលដែលវាធំឡើង វាក៏នឹងធ្វើដាក់ឯងវិញពេលដែលឯងចាស់ទៅដូចគ្នា ហេតុនេះបុព្វហេតុជីវិតមានមនុស្សគឺគ្មានអ្វីក្រៅអំពើល្អនេះឡើយ។ សូមឱ្យក្តីស្រលាញ់កើតមានចំពោះកូនៗគ្រប់រូប កូនត្រូវចេះស្រលាញ់គ្នា ចេះអត់អោនឱ្យគ្នា ចេះជួយគ្នាត្រូវស្មោះត្រង់នឹងគ្នា ព្រោះឯងមិនអាចស្វែងរកសាច់បង្កើត

នៅក្នុងពិភពលោកនេះបានឡើយ។ ថ្ងៃណាមួយកូនៗនឹងយល់ថា ការប្រព្រឹត្តិកំហុសឆ្គងជាច្រើនរបស់ឪពុកម្តាយ គឺតែងតែចង់ឱ្យកូនបានល្អទាំងអស់ ចង់ឱ្យកូនរស់នៅមានការងារសុច្ចរិត មានមុខមាត់សមរម្យក្នុងសង្គម មានជីវិតថ្លៃថ្នូរឱ្យសមនឹងថ្លៃកំណើតមនុស្ស។ ចង់ឱ្យកូនៗក្លាយជាវិស្វកររប្រវត្តិសាស្ត្រសម្រាប់ប្រទេសជាតិ មិនចង់មានដង្ហើមចុងក្រោយដែលពោរពេញទៅដោយវិប្បដិសារីនោះឡើយ។ ព្រោះហេតុនេះហើយ សូមកូនៗកុំមានអារម្មណ៍ធុញទ្រាន់នឹងវ័យជរារបស់ឪពុកម្តាយ សូមរស់ក្បែរឪពុកម្តាយ ហើយសូមព្យាយាមស្វែងយល់ថា តើជីវិតជរាជាចុងក្រោយរបស់ឪពុកម្តាយនេះគឺរស់នៅដើម្បីអ្វី? សូមជួយជូនដំណើរឪពុកម្តាយ ជួយបញ្ចប់ជីវិរបស់គាត់ដោយក្តីស្រលាញ់នឹងអត់ធ្មត់ អ្វីដែលឪពុកម្តាយចង់បានជាចុងក្រោយពីកូនៗ គឺត្រូវចេះរស់នៅឱ្យបានក្តីសុខ ចេះប្រើបាតដៃជាស្នាំងបាយ ត្រូវចេះស្រលាញ់ខ្លួនឯង ស្រលាញ់បងប្អូន និងស្រលាញ់ជាតិមាតុភូមិរបស់ខ្លួនដែលជាចំណងដៃរបស់ជូនតាឱ្យបានបិតថេរគង់វង្ស។ កុំចាំដល់ថ្ងៃមុខត្រូវមកអង្គុយសុំខមាលទោសចំពោះមុខផ្នះ ឬពំនូកដី ហើយស្តាយក្រោយថា មិនបានធ្វើអំពើជាកតញ្ញូចំពោះពួកគាត់ឱ្យសោះ ព្រោះពេលនោះអ្វីៗគឺហួស

ពេលអស់ហើយ។ (អ្នកអានអត្ថបទព័ត៌មានចប់គេចាក់ចម្រៀងមួយបទជូនបន្ត) (**ជនណាសម្លាប់មាតាបិតា ទទួលទោសាដែលមានឈ្មោះថាអនន្តរិយកម្ម)** បបូរមាត់របស់ម៉ុំប្រែជាញ័រទទ្រើកហើយតំណក់ទឹកភ្នែកក្តៅឧណ្ហៗបានរមៀលកាត់ផែនដីថ្ពាល់របស់នាងធ្លាក់លើក្រមាដែលមួរទ្រាប់ក្បាលក្បែរម្តាយ នាងដឹងច្បាស់ណាស់ថា តើផ្លូវជីវិតរបស់នាងកំពុងដើរនោះត្រូវឬខុស? តើនាងអាចកែប្រែវាសនានោះបានទេ? មាណវីនឹកដល់ត្រង់នេះ នាងភ្លាត់មាត់ហៅម្តាយ ម៉ែ.....ទាំងមិនដឹងខ្លួន ឯដៃនាងក៏ក្រសោបខ្លួនប្រាណអ្នកមានគុណ ឱ្យមកផ្ទឹបជាប់នឹងដើមទ្រូងរបស់ខ្លួនយ៉ាងតឹង រួចនាងឈ្ងុលថើបខ្នងដែលសុទ្ធតែឆ្អឹងរបស់ម្តាយដោយក្តីគោរពស្រលាញ់។ យាយចាស់ខំសម្តែងក្តីក្លាហាន ដើម្បីលាក់បំបាំងក្តីរំភើបរបស់គាត់ដែលមានចំពោះកូនហើយពោលទាំងសម្លេងស្អកស្អា រថា កូនស្រីម្តាយ ម៉ែដឹងថាឯងរឹងមាំជាងគេក្នុងចំណោមកូនអ្នកភូមិ ត្រូវចេះដឹកនាំជីវិតឱ្យល្អតាំងពីនេះទៅ មិនត្រូវរងចាំដល់ថ្ងៃស្អែកឡើយ ពុំនោះទេកូននឹងត្រូវរស់នៅដូចជាសម្រាមតាមចិញ្ចើមថ្នល់ ធ្វើឱ្យស្អុយដល់គេឯង ហើយម៉ែនឹងថោកជាងឡានដឹកសម្រាមទៅទៀត ព្រោះបង្កើតបានត្រឹមតែសម្រាមឱ្យដល់សង្គមជាតិ។ កូនម៉ែ.....ការងារមិន

ដែលធ្វើឱ្យមនុស្សថោកទាបនោះទេ គឺមនុស្សទេដែលធ្វើឲ្យការងារថោកទាប (មុំរឹងខ្លួនសួកព្រោះអាសូរម៉ែដែលមិនដឹងការងាររបស់ខ្លួនបំពេញរាល់ថ្ងៃ) ទោះបីជាបោសសម្រាមតាមចិញ្ចើមថ្នល់ក្តីក៏យើងនៅតែថ្លៃថ្នូរព្រោះយើងមិនបានដើរបោកប្រាស់គេ ឬលួចឆក់ទ្រព្យសម្បត្តិអ្នកណាឡើយ យើងអាចធ្វើបុណ្យបានយ៉ាងត្រជាក់ចិត្ត។ ហ៊ាក! បោសសម្រាមសោះមានលុយធ្វើបុណ្យដែរហ្អីម៉ែ? (មុំសួរកាត់សំដីម្តាយ) ដូនចាស់លេបទឹកមាត់ឱ្យសើមបន្តិចទើបពោលបន្ត៖ **កូនម៉ែ** បុណ្យធំបំផុតក្នុងព្រះពុទ្ធសាសនាហើយដែលជាបុណ្យចេញចាកទុក្ខពិតៗ។ ម៉ែស្តាប់ប៉ាត់យ៉ាល់យប់គេហៅថា **វដ្តៈគាមិនីកុសល** នោះគឺជាបុណ្យដែលធ្វើអត់អស់ប្រាក់១សេនទេកូន បុណ្យណាដែលធ្វើអស់ប្រាក់ហើយប្រកបដោយទិដ្ឋិមានៈ និងតណ្ហាបុណ្យនោះសុទ្ធតែមានកម្មវិបាកឱ្យជាប់ក្នុងភព ជាបុណ្យសាងចំណងឱ្យជីវិតខ្លួនឯង ព្រោះត្រូវរែកពុនកិត្តិយសផ្តាប់មុខធ្វើបុណ្យចប់ហើយបានត្រឹមតែម៉ាដេកភ័យ ព្រោះខ្លាចមិនបានបុណ្យ បុណ្យប្រភេទនេះព្រះលោកហៅថា **វដ្តៈគាមិនីកុសល** (បុណ្យឲ្យជាប់ក្នុងវដ្តៈ)។ បុណ្យធំបំផុតក្នុងព្រះពុទ្ធសាសនា ធ្វើអត់អស់លុយនោះទេ គឺបុណ្យធ្វើឱ្យខ្លួនឯង ធ្វើទីពឹងសម្រាប់ខ្លួនឯង ឱ្យខ្លួនបាន

ជាទីពឹង របស់ខ្លួនដើម្បីចាកចេញទុក្ខ ចេញចាកភព ឬផុតភពទាំង៣ បើជាអ្នកបួសចង់ធ្វើបុណ្យនោះព្រះលោកហៅថា **អធិសីលសិក្ខា ។ អធិសីលសិក្ខា និង អធិបញ្ញសិក្ខា ឬហៅថា សីល សមាធិ បញ្ញា** ណាកូនហើយបើមិនមែនជាអ្នកបួសចង់ធ្វើបុណ្យនោះព្រះលោកហៅថា **ទាន សីល ភាវនា** យ៉ាងនេះវិញ។ អញ្ចឹងម៉ែ! ពាក្រថា ធ្វើទាននោះគឺមិនត្រូវអស់លុយដៃរមែនទេ? ទាន មានច្រើនប្រភេទណាកូន ទានដែលមិនចាំបាច់អស់លុយនេះមានក្នុងបុញ្ញកិរិយាវត្ថុ១០ ប៉ុន្តែ១០យ៉ាងនេះម៉ែក៏មិនទាន់ចាំច្បាស់ដែរ ចាំថ្ងៃណាតាសនមកលេង ចាំសួរគាត់ឱ្យពិស្តា។ ក្នុងរ៉ាត់យ៉ូគេពន្យល់ ម៉ែចាំថា ការជួយខ្នះខ្នែងពេលញាតិជិតខាងមានធុរៈ ក៏ជាបុណ្យ ការរីករាយអនុមោទនាបុណ្យពីអ្នកដ៏ទៃ ឬជូនបុណ្យអ្នកដទៃក៏បានបុណ្យ ការបម្រើចាស់ទុំឪពុកម្តាយក៏ជាបុណ្យ ប៉ុន្តែហ្ន៎ក បុណ្យអស្ចារ្យដែលម៉ែចាំច្បាស់បំផុត គឺការធ្វើទានឱ្យខ្លួនឯងដោយការរក្សាចិត្តកុំឲ្យកើតទោសៈ កើតកំហឹងក្នុងចិត្ត ត្រេកអរចំពោះអ្វីៗដែលខ្លួនមាន បួងសួងផ្សាយមេត្តាសុំឱ្យខ្លួនឯងបានសេចក្តីសុខ **អហំ សុខិតោ ហោមិ និ ទុក្ខោ** (សូមឱ្យអាត្មាអញបានដល់នូវសេចក្តីសុខចុះ) បួងសួងសុំឱ្យសត្វលោកទូទៅបានក្តីសុខ សូមរក្សាខ្លួនជាសុខ

កុំបីមានក្តីវិនាសចាកញាតិ ចាកសត្វសង្ខារជាទីស្រលាញ់នឹងគ្នា សូមអហោសិកម្មបញ្ចប់កម្មពៀរឲ្យគ្នានឹងគ្នាត្រឹមជាតិហ្នឹង **សព្វេ សត្តា អវេរា ហោន្តុ និទុក្ខាហោន្តុ** អ្នកផ្សាយចេញទៅបានច្រើនប៉ុណ្ណា នឹងបានក្តីសុខច្រើនប៉ុណ្ណឹង។ អើហ៍! ប៉ុន្តែតំបូងមិនត្រូវផ្សាយទៅកាន់មនុស្សដែលយើងស្អប់ទេ ព្រោះវានាំឱ្យកើតបដិឃៈចិត្ត ការថ្នាំងថ្នាក់ចិត្តកើតឡើងនាំឱ្យប្រទូស្តអារម្មណ៍ កុំផ្សាយទៅកាន់បុគ្គលដែលខ្លួនស្រលាញ់នាំឱ្យកើត លោភៈ គឺផ្សាយទៅកាន់សត្វលោកជាទូទៅគ្រប់ទិសទាំងពួង។ បុណ្យនេះអត់អស់លុយសូម្បីតែមួយកាក់ ប៉ុន្តែសព្វថ្ងៃនេះកូនមើលចោះអ្នកក្រលែងហ៊ានដើរកាត់មុខវត្ត ឬលែងចូលវត្តតែម្តង អស់យ៉ាងចូលវត្តប្រើឱ្យលោកស្រោចទឹកឱ្យតែប៉ុណ្ណឹង។ បុណ្យកាន់បិណ្ឌឥឡូវក្លាយជារដូវដប់លៀងលោក អាចារ្យមិនបានជួយដាស់តឿនក្រើនរំលឹកឲ្យឱ្យលោកខំប្រឹងរៀនធម៌អាថ៌ចម្រើនកម្មដ្ឋានអ្វីឱ្យប្រាកដប្រជាទេ ប្រឹងតែពីកត់ត្រាវេនទីមួយសល់បានប៉ុន្មាន វេនទីពីរសល់បានប៉ុន្មាន? ពាក្យបុណ្យបច្ចុប្បន្នប្រែមកថាលុយពេញទំហឹងក៏ពិតមែន ប៉ុន្តែយើងត្រូវខិតខំតស៊ូដើម្បីរក្សាសម្បត្តិ បញ្ញាដ៏ឧត្តម នេះឲ្យបានជាប្រយោជន៍ដល់ជនច្រើនជាអង្វែងតទៅទៀតណាកូន។ សាសនានេះមិនបានវិនាសដោយទឹក ឬ

វិនាសដោយភ្លើង ដោយខ្យល់ ភ្លៀងផ្គរន្ទះអីនោះទេ ហើយក៏មិនអាច វិនាសដោយសារតែអ្នកដទៃពីខាងក្រៅមកបំផ្លាញក៏ទសដែរ គឺវិនាស ដោយសារតែអ្នករក្សារហ្នឹងឯង។ ព្រលឹមឡើងលោកដឹងតែពីនិមន្តបិណ្ឌ ង៉ក់ៗ អត់ដឹងថ្ងៃណាមួយគ្មានបាយសូម្បី១ស្លាបព្រាចូលក្នុងបាត្រ ទំរាំ តែដឹងខ្លួនគឺយឺតពេលអស់ហើយ។ បរិស័ទធ្វើបុណ្យអត់យល់ចង់បាន មុខមាត់ ប្រឹកយកលុយទៅពង្វក់លោកឱ្យវក់ភ្លេចវិន័យ ប្រឹងតាំងគ្រឿង សង្ហារឹមពេញកុដិ លែងចេះបក់ផ្លិត ប្រើសុទ្ធតែម៉ាស៊ីនត្រជាក់ មាន ឡានផ្ទាល់ខ្លួន មានវីឡាកុដិចង់អ្នកស្រុកត្រូវទឹកលិចស្លាប់ក៏មិនជួយ ត្រូវភ្លើងឆេះភូមិអស់ក៏ធ្វើមិនឮ ដឹងតែពីនិយាយបញ្ឆោះកិលេសគេដើម្បី ប្រមូលលាភសក្ការៈ រកស៊ីសម្តែងធម៌។ ម៉ែអាសូរហើយស្រណោះមហា សង្ឃជាន់ដើម ដែលខំតស៊ូរក្សាមរតកព្រះពុទ្ធសាសនានេះហើយត្រូវ មកវិលាយដោយសារ ស្នាដៃក្មេងៗជំនាន់នេះ។ សង្ឃជាន់ដើមយកខ្លួន ជាវិហារ ប្រឹងតុបតែងចិត្តឱ្យថ្លាផូរផង់ប្រាសចាកមន្ទិលសៅហ្មង សង្ឃ ទេពទាំងនោះជាអ្នកបម្រើរាស្ត្រសុទ្ធសាធ អ្នកស្រុកឱ្យតែលេចកូនចេញ ប្រិចកាលណា ចិញ្ចឹមឱ្យចេះដើរ ចេះនិយាយស្រេចនឹងអាលយកទៅផ្ញើ រលោកឱ្យអប់រំទូន្មានប្រៀនប្រដៅឱ្យល្អ លោកឪស្តីប្រដៅ ទាល់តែកូន

អស់នោះកើតប្រយោជន៍បានលោកឱ្យត្រលប់ចូលភូមិវិញ។ មីការភឹមមីងឯងវាខូចកាលនោះ អាទុយបងជីដូនមួយឯងមិនទាំងចេះនិយាយឱ្យបានច្បាស់ផង វាហ៊ានផ្តាច់ដោះយកអាទុយទៅបោះដាក់លោក ឲ្យលោកតាឪរក្សាលាងអាចម៍ច្របាច់នោមតាំងពីតូច ដៃម្ខាងកំពៀកអាទុយ ដៃម្ខាងបញ្ចុកបបរ ធំឡើងលោកបំបួសផ្គាល់ដៃឱ្យកម្មដ្ឋានផ្គាល់មាត់ **កេសា លោមា នខា ទន្តា តចោ** ជាតបញ្ចកម្មដ្ឋាន អញនឹកដល់ត្រង់នោះអញអួលដើមកសឹងប្រេះទ្រូង អញស្រណោះលោកជាន់ដើមណាស់កូន។ ពេលចំបាំងសៀមយួន ពេញស្រុកទេសអ្នកភូមិរត់ចូលព្រៃយកព្រះអាយ៉ូស លោកសង្ឃខ្មែរត្រូវកាប់គាត់ភ្ជួររាស់ដាំដំណាំ ចំអែតផ្ទៃតស៊ូរក្សាកេរ្តិ៍ព្រះពុទ្ធ កាលនោះយាយឯងថែមទាំងបានខ្ចីស្រូវលោក១ចាំង មកបុកយកអង្ករសំរូបដាំបាយឱ្យពួកបងប្អូនម៉ែស៊ីបានរួចជីវិតទល់សព្វថ្ងៃ មិនទាំងទាន់បានសងស្រូវលោកវិញផង។ ម៉ែជំពាក់ជីវិតក្នុងសាសនានេះបើទោះជាសងរាប់រយជាតិក៏ពុំគ្រប់ផងណាកូន នេះជាផ្លូវដែលម៉ែពេញចិត្តដើរមិនចេះឆ្អែតឡើយ ម៉ែដើរគ្រប់ៗជាតិកុំឲ្យវង្វេងចេញពីផ្លូវនេះ ថ្ងៃក្រោយបើកូនឯងពេញចិត្តនឹងជឿក្រៅពីសាសនានេះ កូនមិនត្រូវប្រាប់គេឯងថា ឯងជាកូនរបស់ម៉ែឡើយ ឆ្លើយត្រឹមតែថា ខ្ញុំ

ជាឆ្កែអង្កែសីមួយក្បាលដែលឥតពូជអំបូរទៅចុះ។ មុំទ្រាំមិនបានស្ទុះក្រោកអង្គុយសើចកាច់កកក្អៀកលូកដៃទះគូថម៉ែថ្នមៗ ហើយពោលថា អីក៏កាចម្លេះស្រីពៅនេះ សក់ហើរពណ៌អស់មិនគិត មកប្រឹងគិតរឿងថ្ងៃមុខដែលគ្មានអ្នកណាអាចដឹងបានថា មានអ្វីកើតឡើងខ្លះសោះ ម៉ែសំណព្វរបស់កូន ថ្ងៃមុខបើម៉ែអស់បុណ្យទៅកូននឹងទៅនៅវត្តកោរសក់ស្លៀកស បម្រើព្រះសង្ឃសងគុណម៉ែដោយសុទ្ធចិត្តណាម៉ែ។ កូនសុំតែក្តីករុណាពីព្រះ សុំឱ្យជាតិទៅមុខកុំបីបានជួបប្រុសចិត្តព្រាន ប្រមាញ់តណ្ហា សូមបរវាសជៀសឆ្ងាយពីជនពាល កុំបីបានពោលជាមួយសូម្បីតែកន្លះម៉ាត់សូមបានជួបតែបណ្ឌិតសប្បុរសហើយបានស្តាប់ធម៌ ត្រូវពួកលោកដឹកនាំចេញពីតណ្ហាលោកិយកុំបីអាល័យឡើយ។ សូមឱ្យភ្នែកកុំបីបានឃើញរូបហើយសម្គាល់ថាល្អ សូមឱ្យត្រចៀកកុំបីបានឮសម្លេងហើយសម្គាល់ថាពិរោះ ឱ្យប្រុសៗឃើញរូបខ្ញុំហើយមានចិត្តស្មោះស្មើទុកជាប្អូនស្រី កុំបីកើតរាគៈចំពោះរូបខ្ញុំនេះឡើយ។ សូមឱ្យកូនបានចេះធម៌ដូចម៉ែ លោកយាយវិសាខាមានសភាពយ៉ាងណា សូមឲ្យខ្ញុំមានសភាពយ៉ាងនោះដូចគ្នាដោយអំណាចការធ្វើបុណ្យបំពេញកុសល

ដែលកូនបានបម្រើម៉ែនេះ កូនសូមតាំងសច្ចៈវាចាពោលឧទ្ទិសចំពោះ

មុខពពួកទេវតា ឱ្យបានជាកូនម៉ែពុកតទៅជាតិមុខគ្រប់ៗជាតិកុំបីខាន បានជាកូនម៉ែកុំឱ្យម៉ែទាស់ចិត្តណាម៉ែណា.....។ ម្តាយមុំប្រឹងទប់ទឹកភ្នែក កុំឱ្យហូរកាត់ស្នាមជ្រីវជ្រួញលើផ្ទៃមុខ រួចគ្រហែមបន្តិចឱ្យបាត់អួលដើម កកុំឱ្យខ្មាស់ធម្មជាតិដែលកំពុងតែរងចាំពង្រាត់អ្នកទាំងពីរគ្រប់ដង្ហើមចេញចូល។ គាត់និយាយបន្ត៖ សព្វថ្ងៃសាសនាដទៃគេចូលពេញស្រុក គេមានយុទ្ធសាស្ត្រទិញទឹកចិត្ត កិច្ចប្រតិបត្តិរបស់គេធូររលុងជាងយើង ទ្រឹស្តីមនោគមវិជ្ជាគេប្រើបើយើងគ្មានបញ្ញាក្នុងថ្នាក់ភាវនាទេអាចវង្វេងជឿបានយ៉ាងងាយ។ ថ្ងៃមុនកូនឯងមិននៅ ពួកនោះគេបានមកលេងសួរសុខទុក្ខម៉ែ ហើយថែមទាំងជូនថ្នាំសង្កូវ នំចំណីខ្លះឱ្យម៉ែថែមទៀតផង។ គេពន្យល់ម៉ែថា ឱ្យតែម៉ែព្រមជឿព្រះគេសូម្បីតែសល់ជីវិតនៅត្រឹមតែកន្លះដង្ហើមហើយព្រមទទួលជឿ នោះនឹងត្រូវបានសង្គ្រោះប្រោសប្រណីមិនឱ្យធ្លាក់នរកជាដាច់ខាត ហើយត្រូវបានរស់នៅនគរព្រះមានជីវិតអស់កល្បជានិច្ចទៀតផង។ ម៉ែញញឹមហើយគិតថា ការនេះទៅពុំរួចទេ ព្រោះអ្នកសាងអំពើបាបតែងមានភាពសៅហ្មងដល់ចិត្តខ្លួនឯង ហើយដោយអំណាចកម្មនោះវាមកប្រទាញព្រោះតែការសន្សំរឿយៗរបស់ខ្លួនដែលជាបយោគៈនោះឯង ហេតុនេះបើទោះជាព្រះលោកស្រលាញ់យើង

ហើយព្រមទទួលបាបជំនួសយើងមែនក៏ដោយក៏បាបកម្ម នោះវាមិនអត់អោនឱ្យយើងតែដដែលហ្នឹង។ ពេលនោះម៉ែក៏បានសាកសួរអ្នកព្យាការីនោះថា បើមានមនុស្សម្នាក់សម្លាប់គេហើយគាត់រត់ទៅជឿព្រះរបស់អ្នក តើមនុស្សនោះបានរួចទោសទេ? គេឆ្លើយប្រាប់ម៉ែវិញថា ផ្នែកព្រលឹងវិញ្ញាណគឺត្រូវបានសង្គ្រោះទាំងស្រុង ជននោះមិនបានធ្លាក់នរកឡើយ ប៉ុន្តែផ្នែកសាច់ឈាមក្នុងលោកិយនេះវិញ ឃ្នោះឃ្នាងនិទ្វារគុកនៅតែចំហរសម្រាប់ទទួលគាត់ដដែល ប៉ុន្តែផ្លូវចិត្តគាត់ត្រូវមានការស្ងប់អារម្មណ៍លែងភ័យព្រួយអ្វីទាំងអស់ ព្រោះព្រះបានទទួលអំពើបាបជំនួសគាត់និងលើកលែងទោសឱ្យដូចជាឪពុកម្តាយ ដែលតែងតែមានការអត់អោនចំពោះកំហុសឆ្គងរបស់កូនដូច្នោះផង។ ម៉ែនឹកសរសើរក្នុងចិត្តចំពោះឧបាយដោះទុក្ខរបស់ពួកគេនេះដែរ ព្រោះក្រោយពីស្លាប់ទៅពួកយើងគឺខ្វាក់ទាំងអស់គ្នាទេ ប្រវត្តិជីវិតក្រោយពេលស្លាប់នឹងក្លាយជាប្រលោមលោកឥតន័យចំពោះភ្នែកសាច់ទាំងអស់គ្នាតែប៉ុណ្ណោះ ព្រោះហេតុនេះអ្នកនិពន្ធចង់ចងក្រងអធិប្បាយយ៉ាងណាក៏បានតាមចិត្ត។ គេពន្យល់ម៉ែទៀតថា ព្រះគេគឺជាព្រះរស់ ព្រះសង្គ្រោះជីវិតបច្ចុប្បន្ន អ្នកដែលទទួលជឿនឹងមិនត្រូវអត់នំប៉័ងបរិភោគឡើយ។ បើអ្នកណាចង់រៀប

ការក្នុងព្រះវិហារគេ គេជួយគ្រឿងបណ្ណាការគេចងដៃគោ អំពៃ ជួយឱ្យមានមុខរបររកទទួលបានយ៉ាងសមរម្យ គេជួយបងប្អូនក្រុមជំនុំមិនឱ្យមានអ្នកណាដាច់បាយឡើង។ ត្រង់នេះណាកូនម៉ែ បើយើងប្រៀបធៀបនឹងលោកសង្ឃស្រុកយើងដែលខំរៀនតែភាសាគេ រៀនតែផ្លូវលោក ពែនចាំតែគេលើកជូនស្រេចៗ ទៅថ្ងៃមុខអញ្ចឹងប៉ះតែគ្មានអ្នកណាលើកអីជូនទៀតទេ។ ខាងគេសុទ្ធតែជួយ ខាងឯងសុទ្ធតែចាំ ម្នាក់ៗចង់ធំខំប្រឹងតែទិញបុណ្យស័ក្តិ ឱ្យលោកធម៌ពាល់ត្រូវគ្រប់គ្នា ពុលនឹងលាភសក្ការៈចេញក្អួតចំពោះមុខភាពក្រីក្រ បើតែយ៉ាងហ្នឹងវិនាសហើយកូន។ ហេតុនេះទាន់ព្រះសាសនាគង់រង្សីនៅឡើយត្រូវខំរួតរះ ប្រឹងប្រែងបដិបត្តិតាមកុំដំអក់ក្នុងភពដែលមានតែទុក្ខយ៉ាងហ្នឹងណាកូន។ **អើហ៎** នេះជាអនិច្ចតាធម៌ទេ ព្រោះថ្ងៃមុនម៉ែស្តាប់ឮគេផ្សាយរ៉ាត់យ៉ូថា ពួកបារាំងវាព្រមទទួលស្គាល់ព្រះពុទ្ធគោតមថាជាព្រះពិតប្រាកដ ហើយវាបានក្រាបក្បាលថ្វាយបង្គំនិមន្តព្រះធាតុរបស់ព្រះពុទ្ធពីស្រុកលង្កា ទៅទីក្រុងប៉ារីស ហើយមានមនុស្សក្រាបសំពះចាំទទួលរាប់ម៉ឺននាក់ទៀតផង។ កាលពីដើមវាចាត់ទុកថា ព្រះពុទ្ធគោតម គឺត្រឹមតែជាគ្រូទស្សនៈវិជ្ជាធម្មតាតែប៉ុណ្ណោះ ហើយព្រះធម៌ក្នុងព្រះពុទ្ធសាសនា គឺត្រូវបានមនុស្ស៥០០

នាក់នាំគ្នាតាក់តែងចងក្រងឡើង មិនមែនជាការត្រាស់ដឹងអ្វីនោះឡើយ។ ឥទ្ធរស្រុកអ្នកមាន គេចូលចិត្តស្តាប់តែការពិត ហេតុនេះគេនាំគ្នាស្តាប់ព្រះពុទ្ធហើយ ព្រោះគេមិនត្រូវការអង្ករកំប៉ុងនិងមីកញ្ចប់ដូចពួកយើង ឯស្រុកក្រីក្រដូចយើងវិញគឺត្រូវប៉ាន់ហើយ។ ហេតុនេះទៅថ្ងៃមុខព្រះពុទ្ធសាសនានឹងត្រូវរៀវរាយ រលត់ពីស្រុកខ្មែរ ព្រោះតែការបិទភ្នែកជឿរបស់ពួកយើង ។ ព្រះពុទ្ធសាសនាដែលអាចគង់វង្សបានដល់ ៥០០០ឆ្នាំ ព្រោះតែព្រះពុទ្ធអង្គទ្រង់ត្រាស់ប្រកាសសម្តែងតែពីពាក្យពិត ហើយពាក្យពិតជាពាក្យមិនស្លាប់ គឺជាអរិយសច្ចៈ ការពន្យល់ក្នុងព្រះធម៌គឺសុទ្ធតែមានពិសោធន៍ ហើយដែលយើងអាចពិសោធន៍បានគ្រប់គ្នា មិនផុតវិស័យមនុស្សលោកឡើយ។ បញ្ញាកើតឡើងត្រឹមការស្តាប់ (**សុតមយបញ្ញា**) គឺជាបញ្ញាខ្ចីគេទេ លឺគេថា ថាតាមគេ តែជម្រៅន័យការពិតគឺមិនដឹងថានៅទីណាឡើយ។ ការយកពាក្យគេមកត្រិះរិះដុសខាត់ឱ្យកើតបញ្ញា (**ចិន្តាមយបញ្ញា**) ក៏ត្រឹមតែបញ្ញាក្នុងថ្នាក់ត្រិះរិះ ប៉ុន្តែវាគ្រាន់បើជាងបញ្ញាកើតឡើងពីការស្តាប់បន្តិច ព្រោះត្រឹមតែការស្តាប់ហើយជឿមិនបានគន់គិតពិចារណា នេះជាជំនឿងងឹតងងល់ហើយ។ ជំនឿងងឹតងងល់យ៉ាងម៉េចទៅម៉ែ? (មុំសួរព្រោះទ្រាំចំហរមាត់យូពេក

មិនបាន) អើហ៍ កូនមិនមើលខ្មោចម៉ាទេឡង ចិនសែវាយកគុយទាវទៅបញ្ចុកខ្មោចហើយយកមកឱ្យកូនចៅស៊ី រួចនាំគ្នាដុតផ្ទះក្រដាស់ ឡានក្រដាស់ផ្ទៃឱ្យគាត់ បើវាបានដល់គាត់មែនតើគាត់យកទៅប្រើការអីកើត បើកូនចៅវាស្រលាញ់គាត់ណាស់ម៉េចមិនដុតផ្ទះមែនទែន ឡានមែនទែន បញ្ជូនឱ្យគាត់ទៅ ចាំបាច់បោកប្រាស់ខ្មោចធ្វើអី អាហ្នឹងឯងហៅថាជំនឿងងឹតងងល់នោះ។ តែហេតុអីក៏កូនចៅគេរកស៊ីមានបានម្លេះម៉ែ? បើថាគេអត់បញ្ញាមែននោះ? (មុំសួរ) អើហ៍ អារឿងរកស៊ីនេះវាជារឿងផ្សេងទេ ព្រះពុទ្ធទ្រង់បានប្រដៅយើងៈ

១- ត្រូវចេះស្វែងរកទ្រព្យដោយក្តីសុច្ចរិត កុំខ្ជិលច្រអូស

២- បានទ្រព្យមកហើយត្រូវចេះថែរក្សាកុំចាយវាយខ្ជះខ្ជាយ

៣- កុំសេពគប់បានមិត្ត

៤- សេពគប់តែសប្បុរស។

តែប៉ុណ្ណឹងទៅមានយកទៅណាអស់ ហេតុបច្ច័យដែលនាំឱ្យខ្មែរក្រមានច្រើនណាកូន។ មិនមែនខ្មែរខ្ជិលទេ ខ្មែរដែលរស់នៅស្រុកក្រៅខ្លះសុទ្ធតែយកជាតិគេធ្វើកម្មករផងក៏មាន គ្រួសារមួយដែលមានម្តាយឬ

ឪពុកកើតជំងឺឆ្កួតជ្រូក ឬមានសន្តានជាមនុស្សប៉ែឡាដែលអញ ឮអាគួយចៅរបស់អ្នកឆយតែងតែស្រែកថា កុំតាប៉ែពេក នោះតើវាសនាកូនចៅពួកគេនឹងក្លាយទៅជាយ៉ាងណាទៅ? ម៉ែឪល្ងង់បង្រៀនតែមេរៀនល្ងង់ឱ្យដល់កូននេះម្យ៉ាង។ ម្យ៉ាងវិញទៀត ម៉ែឪសុទ្ធតែឆ្លាតៗតែកើតបានកូនសុទ្ធតែល្ងង់ខ្លៅ កូនរាហ៍កន្លង អត់គ្រប់ទឹក សម្បត្តិម៉ែឪខំរកបានមកវាមិនជួយរក្សា វាប្រឹងតែបំផ្លាញ ចេះត្រឹមតែលួចគ្រប់គ្នា តើក្រុមគ្រួសារនោះនឹងថ្កុំថ្កើងរុងរឿងម្តេចបាន? សង្គមណាដែលសំបូរមនុស្សល្ងង់ច្រើន សង្គមនោះត្រូវតែរស់នៅដោយក្តីវេទនា ហើយនឹងវិនាសផៅពង្សអស់ពីផែនដីនេះ ទៅជាធម្មតាទេណាកូន នេះគេហៅថាច្បាប់ជំរើសក្នុងធម្មជាតិ។ ម៉ែសោកស្តាយណាស់ ដែលប្រឹងតស៊ូចិញ្ចឹមឱ្យឯងរៀនមិនបានចប់បាក់ឌុបនឹងគេ ប៉ុន្តែកូនស្រីកុំខឹងនឹងម៉ែណា មនុស្សគ្រប់រូបគ្មាននរណាម្នាក់ចង់អាក្រក់នោះទេ ពេលខ្លះគិតត្រូវតែធ្វើមិនបាន ពេលខ្លះគិតខុសតែធ្វើបានធូរល្ហុយវិនាសហ្មត់ នេះឯងជាការចំអកព្រហ្មលិខិត ដែលមានចំពោះមនុស្សលើលោកនោះ គ្មានអ្វីពិត គ្មានអ្វីក្លែងក្លាយនោះឡើយ ហេតុនេះបើសើចបានអីចាំសើច ហើយបើយំទៅបានអីចាំយំ បើសើចនិងយំហើយវាគ្មានបានអីទេ កូនមិនត្រូវសើចយំចំពោះ

អ្នកណាម្នាក់ឡើយ ពុំនោះទេឯងនឹងក្លាយជាស្រវឹងធម្មជាតិជាក់ជាពុំខាន។ ទៅថ្ងៃមុខកិលេសមនុស្សកើនឡើងខ្លាំងគេធ្វើអ្វីគឺដើម្បីតែបានតែប៉ុណ្ណោះ គេទ្រាំអត់ខ្លះមិនបានទេ ចង់បានខ្លាំងពេកប្រឹងតែពីជឿដើរកទីពឹង តាំងពីសត្វតិរិច្ឆានឡើងទៅព្រោះពឹងរិទ្ធិមនុស្សគ្នាឯងវាមិនសូវឆុតឆាប់ទាន់ចិត្ត។ ហេតុអីក៏ព្រះពុទ្ធសាសនាត្រូវវិនាសអន្តរធានអស់ទៅវិញ? គឺវិនាសដោយសារតែបរិស័ទទាំង៤ពួកនេះឯងនាំគ្នាពុលធម៌។ បុព្វហេតុរបស់នយោបាយគឺកាមលោកព្រោះតែមនុស្ស គឺជាសត្វដែលចេះធ្វើនយោបាយ ហេតុនោះទីណាដែលមានសង្គមមនុស្ស ទីនោះត្រូវតែមានការបំពុលគ្នាទៅវិញទៅមក គឺព្រះពុទ្ធតែមួយអង្គគត់ដែលបានបើកបង្ហាញរឿងនេះ ដោយឥតមានលាក់លៀម។ ព្រះអង្គត្រាស់ពន្យល់អំពីអត្ថប្រយោជន៍របស់នេក្ខម្មៈ គឺដើម្បីគេចចេញពីការបំពុល ប៉ុន្តែទីបំផុតបរិស័ទរបស់ព្រះអង្គនៅតែរស់មិនផុតពីតណ្ហា ទើបត្រូវពុលជាមួយគេឯងអញ្ចឹងទៅ។ ត្រូវសម្តែងធម៌ប្លមៗមិនពិតថាពិត មិនមែនជាធម៌វិន័យថាជាធម៌វិន័យ សម្តែងទិដ្ឋិក្នុងធម៌រៀងៗខ្លួន សម្តែងធម៌យល់មុខបរិស័ទពេកទៅ លោកនាំគ្នាច្រៀងបំពេរកិលេស។ ជ័យៗ សូមលោកឯកឧត្តមទាំងប្រុសទាំងស្រី ជំទាវតូចធំ ក្រមុំមួលមែ មានជោគ

មានជ័យសព្វទិនទីវា គ្រាន់នឹកប្រាថ្នា សព្វគ្រឿងបរិក្ខារ ខ្ញុំកំដរប្រុសស្រី កើតឡើងគ្រប់ទិស មុខស្រស់ប៉ប្រៃ បម្រើជំទាវស្រីឥតទាស់ចិន្តា។ ងាប់ហើយម៉ែ ម៉ែឯងចេះធម៌អស់នេះមកពីណា? (មុំសួរទាំងហួសចិត្ត) ម៉ែដេកស្តាប់ឮតាមមេក្រូឯកើតភូមិ បែបជាផ្ទះលោកម៉ែងគេធ្វើបុណ្យហ្នឹងណាកូនន។ **មុំហ្អើយ** អន្តរធាន៥ យ៉ាងក្នុងព្រះពុទ្ធសាសនានេះតើដូចម្តេច?

១- **បដិវេធអន្តរធាន** គឺវិនាសអស់អ្នកយល់ដល់ជម្រៅធម៌ អ្នកអស់អវិជ្ជាលែងមាន

២- **បដិបត្តិអន្តរធាន** សាបសូន្យកិច្ចបដិបត្តិមានតែអ្នកចេះធម៌ហើយមិនធ្វើតាមធម៌

៣- **លិង្គអន្តរធាន** សាបសូន្យសមណៈលែងមានអ្នកបួសតទៅទៀត

៤- **បរិយត្តិអន្តរធាន** សាបសូន្យព្រះធម៌ លែងមានអ្នកសិក្សារៀនសូត្រធម៌វិន័យតទៅទៀតហើយ

៥- **ធាតុអន្តរធាន** ព្រះសារីរិកធាតុ គឺព្រះធាតុនៃព្រះពុទ្ធបរមគ្រូ កាលបើអស់មានការគោរពពីមនុស្ស ហើយដោយអំណាចពុទ្ធាធិដ្ឋាន ជានិយាមរបស់ពុទ្ធវិស័យ ព្រះធាតុបានធ្វើសមោធានធាតុ គឺបានហោះពីគ្រប់ទិសទីឥតសេសសល់សូម្បីប៉ុនគ្រាប់ល្ង ទៅប្រជុំគ្នាបានជារូបធាតុដូចជាព្រះសម្មាសម្ពុទ្ធបរមគ្រូ គង់នៅច្រឡឹងៗក្រោមម្លប់ព្រះសិរីពោធិព្រឹក្សនៅដែនគយាសីសៈ ពេលនោះគឺមានតែពពួកទេវតាទេដែលបានគេគោរពថ្វាយបង្គំ ហើយស្រែកទួញយំពោលថា លោកនេះវិនាសហើយ អំណឹះអត់ពីព្រះសាស្តាទៅ លោកនេះត្រូវងងឹតសូន្យសុង ត្រូវអំណាចអវិជ្ជា និង តណ្ហាគ្របសង្កត់គ្មានថ្ងៃស្គាល់ក្តីសុខឡើយ សត្វលោកនឹងប្រកាប់ប្រចាក់គ្នា ទ្វារអបាយភូមិនឹងត្រូវបើកឡើងពេញទំហឹង ឯទ្វារសួគ៌និព្វានគឺត្រូវបិទទាំងស្រុងៗ ទេវតាប្រជុំគ្នាមើលព្រះធាតុយាងចូលបរមនិព្វានដោយក្តីសោកសង្រេង តេជោធាតុដ៏ចម្រើនឡើងក្នុងព្រះធាតុរួចក៏ឆេះរលាយខ្សុលអស់ទៅ។ **មុំហ្អ៊ា**! សូមឲ្យកូននឹងម៉ែ ពេលនោះបាននៅជុំគ្នាជាទេវតាហើយបានក្រាបបង្គំលាព្រះធាតុវិលទៅទេវលោកវិញទាំងអស់គ្នាណាកូន។ សាធុ សាធុ សាធុ ម៉ែ។

ដំបូន្មានរបស់ម៉ែ

ម៉ែ! (មុំលើកដៃផ្គុំសំពះចំពោះអ្នកម្តាយដោយក្តីកោរគោរព) សូមម៉ែសម្តែងអំពីហេតុនាំឱ្យវិនាសកិច្ចបដិបត្តិក្នុងព្រះពុទ្ធសាសនានេះមើល?

អើហ៍កូន! ព្រោះតែមនុស្សនិយមជឿយ៉ាងងងឹតងងល់នេះឯង ឯព្រះពុទ្ធសាសនា គឺជាសាសនាដែលមានពិសោធន៍ដោយកិច្ចបដិបត្តិតាមព្រះធម៌ដោយផ្ទាល់ ដើម្បីបានឃើញច្បាស់ដោយខ្លួនឯង មិនថាតាមគេ ឬថាតាមព្រោះបានលឺតៗគ្នា បើគេបានពិសោធន៍ឃើញច្បាស់ដោយខ្លួនឯងហើយ គេនឹងយល់ច្បាស់ហើយឈានទៅជឿដោយក្តីជ្រះថ្លា នេះឯងហៅថាសទ្ធាក្នុងព្រះពុទ្ធសាសនា គឺយល់ហើយបានជឿ នេះជាជំនឿមុតមាំស៊ប់សួនឥតកក្រើកព្រោះគតិបណ្ឌិតទាំងអស់ គឺត្រូវបានបង្កើតឡើងពីការត្រិះរិះរបស់ខ្លួនគេផ្ទាល់ ការជឿរបៀបនេះទើបសាសនាអាចនៅគង់វង្សបានគំរប់៥០០០ព្រះវស្សា ឬលើសនេះផង បើមានត្រឹមតែការជឿដោយឥតបានពិសោធន៍ គឺនាំឱ្យវិនាសសាសនាទៅវិញទេ ដោយការប្រកាន់មាំថា ជំនឿរបស់ខ្លួនជាជំនឿត្រឹមត្រូវឥតខ្ចោះក៏ចេះតែគោរពការពារទៅរហូត ពេលខ្លះស្លាប់ទៅទាំងមិនបានស្គាល់រសព្រះធម៌ដែលខ្លួនខំគោរពនេះផងក៏មាន ព្រោះតែជឿថាឱ្យតែបានជឿ គឺដឹងតែពីបានឡើងឋានសួគ៌ជាក់ជាពុំខាន។ ហើយបើមានការជឿតែយ៉ាងនេះគឺ

ជាហេតុនៃទំនាស់ទេ ព្រោះសាសនាដទៃគេក៏អួតថាគេជឿត្រូវដែរ ឯយើងក៏ថាយើងជឿត្រូវដែរ នេះគឺជាហេតុនៃទំនាស់ហើយ។ ព្រះពុទ្ធសាសនា គឺស្ទុះចេញពីការជឿឆ្ពោះទៅពិសោធន៍រកការពិត អំណឹះទៅថ្ងៃមុខមនុស្សនិយមតែជឿគ្មានបានពិសោធន៍ ទើបនាំឱ្យសាសនាវិនាសទៅណាកូន។ **អើហ៎** មុននេះម៉ែបានប្រាប់ឯងរួចហើយពីបញ្ញាថ្នាក់ស្តាប់ ថ្នាក់ពិចារណា ឯបញ្ញាទី៣គឺជាបញ្ញាថ្នាក់ពិសោធន៍ ព្រះលោកថាភាវនាមយបញ្ញាដែលជាបញ្ញចាក់ឆ្លុះ ដល់ទីជម្រៅនៃវិសគល់អាថ៌កំបាំងច្បាប់ធម្មជាតិចុះក្នុងអត្ថថា (**អនត្តា**) នេះឯង។ បញ្ញានោះឯងនាំឱ្យឃើញថា លោកនេះសូន្យទទេ សូន្យចាកសត្វបុគ្គល ចាកតួខ្លួនទៅ បញ្ញាឃើញយ៉ាងនេះហៅថា **អធិបញ្ញាវិបស្សនា**..... ហ៊ាម! ខមាទោសម៉ែ! កូនស្ងាបហើយ ណាងុយដេក ណាពិរោះសាច់ធម៌ ធម៌នេះកូនធ្លាប់ស្តាប់លោកពូពេទ្យហេង និងលោកតាសន បានសម្តែងពីមុនមកដែរតែនៅតែពិរោះជក់ចិត្ត (ពេលសឹងផុតមាត់មិនទាន់តរុណីកំសត់ នាងប្រែខ្លួនគេងលង់លក់ស្រមុកខុលៗបាត់ភ្លាមមួយរំពេច) ម៉ែចាស់ប្រឹងប្រារតោងក្បាលគ្រែ ឈោងចាប់ទំលាក់ជើងមុងដាក់ឱ្យកូនដោយក្តីករុណា រួចគាត់អោនថើបក្បាលកូនស្រីថ្នមៗហាក់បីដូចជាចង់

បញ្ជាក់ថាម៉ែខំពរពោះ ៩ខែ១០ថ្ងៃហើយប្រឹងបង្កើតកូនបានមកនេះគឺដោយក្តីស្រលាញ់ទេ ម៉ែឥតចង់បានការតបស្នងអ្វីពីកូនទាំងអស់ សុំឱ្យកូនចេះរស់នៅឲ្យបានសុខ កុំបីមានទទួលក្តីប្រមាថពីអ្នកដទៃឡើយ។ ម្តាយមាន ម្តាយក្រ គឺមានព្រហ្មវិហារធម៌ចំពោះកូនខ្លួនឯង យើងស្រលាញ់កូនយើងប៉ុណ្ណា អ្នកដទៃក៏ស្រលាញ់កូនគេប៉ុណ្ណឹងដូចគ្នា។ កុំចេះឈឺចាប់តែសាច់ខ្លួនឯងហើយប្រមាថសាច់អ្នកដទៃ។ គិតបានត្រឹមណេះនាទីវប្បធម៌ ជើងចាស់ក៏ច្រត់ដៃទប់ខ្លួនយ៉ាងថ្នមៗផ្តេកលើត្រែហើយគ្រាប់ភ្នែកដ៏សល្អក់របស់គាត់ បានសម្លឹងឆ្ពោះទៅកាន់ពន្លឺភ្លើងព្រឹមៗ ដែលជះចេញពីកូនចង្កៀងប្រេងកាតអត់អំពូលដ៏តូចមួយដែលមុំបានអុជរួចជាស្រេច មុននាងប្រុះខ្លួនគេង។ អណ្តាតភ្លើងចង្កៀងកំពុងលោតរាំពត់ពេន ជាមួយជំនោរខ្យល់ដែលបក់តាមប្រហោងជញ្ជាំងឃ្លេៗម្តង សម្លេងឆ្កែលូដូចជាត្រុមប៉ែតផ្លុំកំដរលាយឡំនឹងសម្លេងចង្រិតយំតាមគុម្ពស្មៅ ដូចជារនាតស្បែកកកិតគ្នា បង្កើតបានជាតន្ត្រីធម្មជាតិពិរោះរណ្តំកំដររាត្រីកាល ប្រគុំឡើងដោយក្តីមេត្តាករុណាចំពោះសព្វសត្វដែលមានទុក្ខសោកបានមួយរយៈពេលខ្លី រងចាំថ្ងៃស្អែកទុក្ខថ្មីៗទៀតនឹងមកដល់។ យាយចាស់នោះស៊ូទ្រាំ ទប់ទល់នឹងថ្នាំសណ្តំរបស់ធម្ម

ជាតិមិនបាន ព្រលឹងក៏ត្រូវចាកចេញចោល រូបទៅតាមមនោសញ្ចេតនា ផ្ទាល់ខ្លួននាពេលរាត្រី ទុកឱ្យរូបដេកផ្ទារចំហរមាត់ព្រមទាំងជង្គង់ រលាស់បបូរមាត់ភឺត! ភុយៗ! ទៅតាមចង្វាក់ដង្ហើមចេញចូលតាមសភាពជាមនុស្សចាស់អត់ធ្មេញ។ នៅពេលរំលងអាធ្រាត្របន្តិចទៅ ខ្យល់កាន់តែត្រជាក់បក់បោកលើស្លឹកត្នោតទុំឮសូរឆ៉ោកៗ យ៉ាងស្រកៀរ ត្រចៀកតាមភ្លឺស្រែ មនុស្សចាស់តែងលង់ដំណេកយ៉ាងងប់ងល់ ម្តាយមុំបែរជាភ្ញាក់ពីដំណេក ព្រោះគាត់ពឹតក្បាលខ្មោកៗចំពីក្រោយដូចគេដំនឹងញញួរ។ គាត់សាកល្បងអត់ធ្មត់មិនចង់ដាស់រំខានកូន ប៉ុន្តែស្ថានភាពលើកនេះគឺខុសរាល់ដង ទើបដាច់ចិត្តលើកដៃអង្អួនស្មាកូន តែគាត់ចាប់អារម្មណ៍ថា ដៃគាត់មិនអាចបញ្ជាឱ្យលើកបានទាល់តែសោះ ពេលប្រឹងស្រែកហៅស្រីមុំ បានដឹងថាមាត់គាត់ក៏ខ្វិនវៀចហៅទាំងលំបាក សឹងតែស្តាប់មិនបាន។ មុំភ្ញាក់ដូចគេកន្ត្រាក់ ស្ទុះក្រោកម្ដីម្នា អង្អួនទ្រូងម្តាយទាំងស្រែកសួរយ៉ាងម៉េចហ្នឹងម៉ែ? ម៉ែ! ម៉ែតឹងទ្រូង ឈឺក្បាលណាស់ មុំស្ទុះចុះពីលើគ្រែលោតផ្លោតៗតាមជណ្តើរ រត់កាត់តាមវាលស្រែតម្រង់ទៅផ្ទះពូពេទ្យហែង។ រត់បណ្តើរនាងលើកដៃបួងសួងបណ្តើរ សូមទេវតាជួយថែរក្សាម៉ែខ្ញុំផង ខ្ញុំមិនអាចរស់នៅអត់ម៉ែបានទេ

លោកអើយ រត់បានមួយស្របកនាងបានមកដល់មុខផ្ទះពូពេទ្យហេង។ នាងស្រែកពីចម្ងាយ៖ ពូអើយពូ! ជួយម៉ែខ្ញុំផងពូ ម៉ែអត់ស្រួលខ្លាំងហើយ។ ពេទ្យហេងមានទម្លាប់ជាមនុស្សរវាសរវៃ មុំមិនទាន់បិទមាត់បានស្រួលផង ពូហេងបានមកឈរប្រាកដចំពោះមុខនាងរួចជាស្រេច។ ស្រមោលអ្នកទាំងពីរប្រដេញគ្នាតាមវាលស្រែ តម្រង់ទៅផ្ទះមុំយ៉ាងលឿនខ្មឹត ពូហេងរត់ឡើងលើផ្ទះមុំញាប់ជើងស្មេរ។ ពេលដល់ក្បែរគ្រែឃើញសភាពរបស់ដូនចាស់យ៉ាប់យឺនណាស់ទៅហើយ ភ្នែកបញ្ឈរទៅលើ បបូរមាត់ស្គុល ដៃគាត់កន្ត្រាក់រមួលនៅលើទ្រូង ពូហេងប្រញាប់វាស់សម្ពាធឈាម រួចស្តាប់ចង្វាក់បេះដូងបានមួយស្របក់ស្រាប់តែគាត់ប្រែទឹកមុខ ហើយទំលាក់សំភារៈទាំងអស់ចេញពីដៃ។ គាត់ស្រែក៖ ពុទ្ធោយាយ ពុទ្ធោ! ពុទ្ធោអរហំ យាយតោងគុណព្រះរតនត្រ័យឱ្យជាប់ណា សត្វទាំងឡាយរមែងប្រព្រឹត្តទៅតាមកម្មរៀងៗខ្លួន យាយកុំអាល័យអ្នកណាទាំងអស់ ត្រូវរក្សាសតិស្មារតីឲ្យមាំក្នុងគុណព្រះរតនត្រ័យ កុំឱ្យភ្លាត់សតិណាយាយ។ មាត់និយាយបណ្តើរ ដៃស្តាំគាត់សង្កត់លើខ្នងដៃឆ្វេង ដាក់ចំមួយភាគបីនៃឆ្អឹងសន្ទះទ្រូងផ្នែកខាងក្រោម សង្កត់យ៉ាងញាប់រន្ទើន សង្កត់១៥ដងគាត់ផ្លុំមាត់យាយម្តង ធ្វើ

បែបនេះបានប្រហែលមួយនាទី គាត់ក៏ចាប់ជីពចរយោយម្តងប្រមាណ ១៥នាទីស្រាប់តែគាត់ដកដង្ហើមធំឃូ។ មុំ! នាងតាំងស្មារតីឱ្យល្អណាកូន ម្តាយឯងគាត់លាចាកលោកនេះទៅហើយ មាណវីនាងស្រយុតស្រយង់អស់ដៃជើង ទិសទាំងទ្បាយលែងប្រាកដដល់នាង នាងវិលអស់ស្មារតីហ៊ឹងត្រចៀកងឹង ដាក់គូថអង្គុយលើគ្រែក្បែរចុងជើងម្តាយ ទឹកភ្នែកហូរធ្លាក់ដូចទឹកបាក់ទំនប់ នាងប្រឹងខាំបបូរមាត់ពង្រឹងស្មារតីព្រោត់ហើយអញ វិនាសហើយ.....ពីល្ងាចម៉ែនិយាយស្តីប្រដៅឱ្យកកោក តែត្រូវមកដេកសូកស្តឹងហៅលែងឆ្លើយ អង្រួនលែងដឹងខ្លួនយ៉ាងនេះទៅវិញ។ កាន់តែនឹកកាន់តែអាសូរ នាងស្ទុះទ្រាបអោបននាលលើទ្រូងម្តាយដោយមិនដឹងខ្លួន។ ម៉ែដឹងខ្លួនឡើងម៉ែ ម៉ែកុំទៅណាចោលកូន ឱ្យខ្ញុំរស់នៅជាមួយអ្នកណាម៉ែ? ពុទ្ធោ! តើម៉ែពិតជាអស់សង្ឃឹមមែនឬពូ? ពូហេងអង្អែលក្បាលនាងថ្នមៗ ទើបតបថាគាត់ដាច់ខ្យល់ហើយក្មួយ កាត់ចិត្តខ្លះទៅ ចាំពូជួយប្រាប់អ្នកភូមិ ឱ្យជួយរៀបចំទុកដាក់សពគាត់តាមប្រពៃណី។ បើឯងយល់ថា ស្រែកយំអាចបានធូរស្រាលក្នុងចិត្តក៏យំចុះ ប៉ុន្តែការជួបជុំដែលគ្មានការបែកគ្នាគឺមិនជាហានៈឡើយ ពូជឿថាឯងយល់ច្បាស់ណាស់ក្នុងរឿងនេះ។ បើគ្មានការកើតក៏

គ្មានការស្លាប់ បើមានការកើតត្រូវតែមានការស្លាប់ទៅវិញជាធម្មតា គាត់ទៅមុនបានសុខហើយបន្តិចទៀតក៏គង់នឹងដល់វេនយើងគ្រប់ៗគ្នាដែរ ចូរគិតរឿងយើងវិញប្រសើរជាង សង្ខារធម៌ទាំងឡាយមិនទៀងមែនពិត មានកិរិយាកើតឡើងហើយរមែងតែងតែវិនាសទៅវិញជាធម្មតា លុះត្រាតែរលត់សង្ខារទាំងពួង ទើបបានដល់នូវសេចក្តីសុខគ្រប់យ៉ាង។ កាយយើងនេះក៏នៅមិនយូរប៉ុន្មានឡើយ តែវិញ្ញាណប្រាសទៅហើយនឹងត្រូវដួលដេកសង្កត់លើធរណី ដូចជាអង្កត់អុសរកប្រយោជន៍គ្មានឡើយ។ សត្វលោករមែងរកទីពឹងទីពួនទីអាស្រ័យគ្មាន កាលបើជារាតាំងមាំហើយបើនោះ ជាមានទ្រព្យសម្បត្តិ មាស ប្រាក់ បុណ្យសក្តិ កិត្តិយសសុកស្តម្ភធំមាំ យ៉ាងណា មានរបងខ្ពស់ក្រាស់បិទបាំងយ៉ាងណា ក៏នៅតែស្តេចមច្ចុរាជតាមរកឃើញ ទោះជាប្រឹងរត់ទៅជ្រកពួនសំងំនៅក្រហែងថ្មគីរីបព្វតាណា ក៏នៅតែយកខន្ធ៥ដែលជារបស់បែកធ្លាយទៅតាមរហូត ក្មួយស្រី! ចូរនាងតាំងស្មារតីឡើង សេចក្តីព្រាត់ប្រាសនិរាសរបស់សត្វលោក គឺតែងតែមានជាធម្មតាទេ គ្មានអ្នកណាមានជីវិតអមតៈឡើយ ពូជយើងជាពូជអ្នកស្លាប់ទេ ហើយយើងមិនមែនមិនដែលស្លាប់ឯណា ក្នុងសំសារវដ្តដ៏វែងឆ្ងាយនេះ សេចក្តីកើតស្លាប់ ស្លាប់

កើតតែងអន្ទោលតាមប្រាណ ដូចជាស្រមោលគ្រប់ៗរូប។ យើងម្នាក់ៗ មានញាតិក្នុងសំសារវដ្តជាអនេករាប់មិនអស់ ជាតិខ្លះបានជាម្តាយ ជាកូន ជាប្រពន្ធ ហើយត្រូវព្រាត់គ្នាជាហូរហែ តំណក់ទឹកភ្នែកដែលស្រក់ព្រោះតែក្តីព្រាត់ប្រាស់គឺច្រើនលើសទឹកមហាសាគរទៅទៀត។ ម្នាក់ៗ មានម៉ែរាប់មិនអស់ ហេតុដូច្នេះតើឯងយំសោកប្រារព្ធចំពោះម្តាយមួយណា? អ្នកស្លាប់ទៅហើយ គឺមិនអាចរស់ឡើងវិញបានទេការយំសោកគឺអត់បានការឡើយ មនុស្សទាំងឡាយតែងមានការសោកស្តាយ នៅពេលដែលគេទទួលការបាត់បង់ទៅ ប៉ុន្តែពេលដែលមានការជួបជុំគេមិនចេះស្តាយស្រណោះពេលវេលា ហើយថែទាំឱ្យបានល្អសោះ។ ក្តីព្រាត់ប្រាសដែលមានតម្លៃព្រោះតែមានការជួបជុំ ឯការជួបជុំដែលមានតម្លៃក៏ព្រោះតែមានក្តីព្រាត់ប្រាសនេះដែរ។ ដំណើររបស់ព្រះអាទិត្យ គឺចាប់ផ្តើមពីរះឡើង ហើយត្រូវលិចចុះទៅវិញជាធម្មតា សត្វណាដែលយំស្រែកចង់ឱ្យព្រះអាទិត្យមិនលិចទៅសត្វនោះ គឺមានវិបល្លាសចិត្តហើយ ព្រោះការទាមទារយ៉ាងនេះគឺមិនជាហានៈឡើយ។ រូបកាយយើងក៏ដូចគ្នា ការកើតឡើងគឺដើម្បីតែស្លាប់ទៅវិញតែប៉ុណ្ណោះ ហេតុនាំឱ្យកើតមានតែមួយគឺតណ្ហា ឯហេតុនាំឱ្យស្លាប់រាប់មួយយប់មួយថ្ងៃមិនចង់អស់ ដេកក៏អាច

ស្លាប់បាន កំពុងតែស៊ីក៏អាចស្លាប់បាន ដើរក៏អាចស្លាប់បាន ឈរក៏អាចស្លាប់បាន ដូច្នេះតើមនុស្សអាចគេចជៀសពីស្លាប់ដូចម្តេចនឹងរួច? ឪពុកម្តាយរបស់យើងកើតពីយាយតារបស់យើងដែលមិនទៀង ពួកលោកសុទ្ធតែមានខន្ធបែកធ្លាយអស់ទៅហើយ អញ្ចឹងយើងកើតចេញពីលោកដែលមិនទៀង ហេតុនេះតើយើងនឹងទៀងមកពីណា? នាងកុំតូចចិត្តថាខ្លួនក្រគ្មានប្រាក់ព្យាបាលម្តាយ សូម្បីស្តេច មន្ត្រី សេដ្ឋី អ្នកមាន អ្នកក្រ អាក្រក់ល្អ សខ្មៅ ប្រណីតថោកទាប គឺមុននឹងក្រោយសុទ្ធតែស្លាប់ទាំងអស់គ្នាទេ អំបាល បើព្រះមោគ្គល្លានមានរិទ្ធិដល់ម្លោះព្រះសារីបុត្តមានបញ្ញាមុតធ្លុះអាចរាប់ចំនួនតំណក់ទឹកភ្លៀងបាន រីឯព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គលក្នុងថ្ងៃតែមួយអាចឱ្យគេឃើញទាំងបីឋាន ក៏គង់កន្លងសេចក្តីវិនាសនេះមិនបាន ចុះទំរាំជនថយថោកដូចជាពួកយើងនេះ តើនឹងគេចពីសេចក្តីស្លាប់នេះម្តេចនឹងបានទៅ? ណ្តើយ! ការយំសោក គឺជាមារយាទរបស់សត្វល្ងង់ខ្លៅទេ សង្ឃតាទក្ខិណាទានទើបជាប្រយោជន៍សម្រាប់យើងដែលជាអ្នកមានជីវិតរស់នៅ។ មុំប្រឹងងើបមុខឡើងពីលង្វែកទ្រូងម្តាយ ទាំងមានសរសៃសក់ជាប់រសេមរសាមពេញមុខមាត់ ហើយពោលទាំងសម្លេងអង្វរកះ ពូជួយខ្ញុំផង ខ្ញុំវង្វេងអស់ហើយមិនដឹង

ថាត្រូវចាប់ផ្តើមពីត្រឹមណាទេពូ ហ៊ឺម៉ែហ្អើយម៉ែ។ ក្នុងសភាពបែបនេះ ការតក់ស្លុតភ័យរន្ធត់ញាប់ញ័រ គឺមិនអាចដោះស្រាយបញ្ហាបានឡើយ ចូរកុំយកការភ័យស្លន់ស្លោរធ្វើជាត្រីមុខឲ្យសោះ ជំហ៊ានណាដែលឯងយល់ថាអាចឈានដើរបាន ឯងដើរចុះ។ ភ្លាមៗត្រូវធម្មជាតិវាយប្រហារខ្លាំងយ៉ាងនេះ ពូយល់ថាឯងពិបាកទទួលយកបានណាស់ ប៉ុន្តែតើយើងត្រូវកែប្រែសភាពការណ៍នេះបានដូចម្តេចទៅ? មានតែត្រូវបែរមុខឆ្ពោះមករកការពិតវិញទើបជាការត្រឹមត្រូវ។ ចូរលុបគំនិតសោកស្តាយដោយយល់ថាខ្លួនមានកំហុសនេះចោលចេញ ព្រោះមនុស្សបើគ្មានខុសទេគឺវាមិនចេះស្លាប់ឡើយ ហើយតើគេត្រូវរកសុក្រិត្យភាពនោះបានមកពីណា? អ្នកមានលុយចេះតែវេចលុយរត់រកពេទ្យល្អៗ ឲ្យជួយជីវិត អត់ដឹងថាអាពេទ្យហ្នឹងក៏ងាប់ដែរនោះទេ។ ហើយពេទ្យនេះមើលបានតែមនុស្សដែលប្រុងរស់ទេ បើមនុស្សដែលប្រុងស្លាប់ហើយគ្មានពេទ្យអាទិទេពណាអាចជួយបានឡើយ។ តស់ក្រោកឡើងក្មួយ ឯងយកប្រាក់នេះទៅទិញសំពត់សពីរម៉ែត្រ ទៀនធូប ហើយជួបអ្នកណាជម្រាបអ្នកហ្នឹងផងទៅអំពីដំណឹងមរណៈភាពនេះ ឯពូនៅជួយរៀបចំផ្ទះសំបែងហើយឆ្លៀតរត់ទៅជម្រាបលោកតាសនឱ្យគាត់អញ្ជើញមកបានជាចាស់ទុំផ

ង។ មុំទទួលប្រាក់ដៃពីរហើយសំពះពូហេង៖ អរគុណពូ (រួចនាងវារចុះចេញទៅ) ដើរបណ្តើរនាងយកដៃជូតទឹកភ្នែកបណ្តើរ ចំណែកឯទិសបូព៌រស្មីពណ៌មាសនៃបច្ចូសសម័យ បានប្រាកដឡើងសន្សឹមៗ ហើយព្រះអរុណោទ័យបានចាប់ផ្តើមអើតមើលសត្តនិករ ដែលមានសង្ហារធម៌កំពុងកក្រើកញាប់ញ័រគ្រប់ទិសទាំងពួង ដូចត្រីប្រឹងបំរះនៅលក្នុងទីដែលមានទឹកតិច ព្រោះតែប្រឹងដោះស្រាយបញ្ហាទុក្ខរៀងៗខ្លួន។ កំពុងតែដើរលឿនស្តេវដូចជាឥតវិញ្ញាណ ស្រាប់តែមីងស៊ុមស្រែកពីម្ខាងផ្លូវមកថា៖ អើហ៍ខ្ចុម! អញកំពុងតែរកមុខដូចបូសចង់ធ្លាយខ្ទុះនេះ ឯងដឹងរឿងយប់មិញទេ? អញមើលទូរទស្សន៍ឃើញប៉ូលិសចេញប្រតិបត្តិការចាប់ស្រីរកស៊ីផ្លូវភេទដាក់ឡានខ្ទេចខ្ទីរ ហើយគេប្រកាសបិទទាំងស្រុងឈប់ឱ្យមានពួកមីចិត្តល្អ ដើរថែទាំប្តីគេរកស៊ីតទៅទៀតហើយ តើឯងគិតយ៉ាងម៉េចហ្អ? មុំផុតតែពីកើតទុក្ខនឹកក្តៅឆេវ ផែនការណ៍នេះល្អណាស់ ដើរចាប់បានតែពួកស្រីទន់ខ្សោយ ម៉េចមិនចាប់ពួកអាប្រុសខូចផងដែរទៅ បើគ្មានពួកអាអស់ហ្នឹងទេក៏គ្មានពួកមីស្រីខូចដែរ ល្អណាស់! ហារមាត់ឡើងចាប់ ហារមាត់ឡើងបិទត្រង់ការងារមិនប្រឹងរកឱ្យគ្នាធ្វើទេ បានអីស្រណោះដល់រាស្ត្រដែលជាកូនចៅរបស់ខ្លួនខ្លះលោកអើយ កិច្ចការ

ធំៗមិនប្រឹងធ្វើសម្រាប់ស្រុកទេសទេ អំពើពុករលួយស៊ីរួងដល់ឆ្អឹងឱ្យ ប្រទេសវិនាស ថ្នាំញៀនប្រើពេញភូមិគ្មានអ្នកណាធ្វើដឹង ធ្វើឮទេ បែរ ជាមកតាមចងគំនុំតែជាមួយពួកសំធឹង មិនដឹងជានាំឱ្យវិនាសសេដ្ឋកិច្ច ជាតិនៅត្រង់ណា? ពួកឯងបានលុយយកមកស៊ីចាយ ឯស្រីមេអំបៅ អស់នោះគ្នាគ្រាន់តែតាមសុំស៊ីតែប៉ុណ្ណឹងសោះ ធ្វើដូចជាគ្នាជាអ្នកវិច្ឆេទ្ធ កម្មសេដ្ឋកិច្ចអើយ។ ធ្វើបាបតែពួកមីដោះវែងសក់ស ចំណែកពួកមីដោះ សសក់ខ្លីវិញលោតរាំខើចមុខ ខើចក្រោយពេញទូរទស្សន៍ តើវាទុកឱ្យ អាណាវាចាំមើល? ប្រស្នាមួយឃ្លាចុងក្រោយនេះ ធ្វើឱ្យមីងស៊ុមបែក អំពិលអំពែក នឹងខ្ជិលចង់និយាយជាមួយមុំតទៅទៀតក៏សួរយកគួរ ឯង ទៅណាទាំងព្រលឹមហ្នឹង? មុំតបៈ ខ្ញុំទៅផ្សារមួយភ្លែតមីង ម៉ែខ្ញុំខូចទៀប ភ្លឺនេះបាត់ហើយ នាងគ្រាន់តែប្រាប់ជាដំណឹង មិនអញ្ជើញដោយត្រង់ ព្រោះដឹងថាមីងស៊ុមមិនសូវចូលចិត្តនាងប៉ុន្មានទេ បើគាត់មានសទ្ធា ជ្រះថ្លានឹងបុណ្យចង់ជួយក៏ជួយចុះ។ ស្អីហ្អះ? យាយគាត់ផុតហើយហ្អី ខ្ទុម? ចាស៎មីង.....។ ពុទ្ធោព្រះហ្អើយ! អហោសិកម្មឱ្យមីងផង ចាំមីងរត់ ទៅប្រាប់ប៉ាវាឱ្យទៅជួយ យ៉ាងណាៗម៉ែឯងគាត់ជាមនុស្សគួរឱ្យគោរព ស្រលាញ់ណាស់ អើហ៍ទៅចុះ ចាំមីងទៅតាមក្រោយ។ មុំដើរឆ្ពោះទៅ

មុខទាំងធីងធោង នេះចំជាទុក្ខត្រួតលើទុក្ខមែន ណាទុក្ខព្រោះខ្លួនឯង ណាទុក្ខដែលគេបង្កឡើងមកឱ្យ តើត្រូវរកច្រកដោះស្រាយតាមវិធីណា? នាងបារម្ភដល់មិត្តភក្តិឯទៀតដែលមានមុខរបរដូចនាងដែរ តើវាសនាពួកគេនឹងទៅជាយ៉ាងណា?

សម្លេងខ្លងខែកតាមមេក្រូម្តងខ្លាំងម្តងខ្សោយ តាមកម្លាំងខ្យល់បក់យ៉ាងណា ក៏បណ្តោយឱ្យអ្នកដែលទើបនឹងមានការព្រាត់ប្រាសគ្នាថ្មីៗ ពិបាកនឹងទប់ទឹកភ្នែកដែរ។ ថ្ងៃទីមួយនេះមុំហាក់ដូចជាមានអារម្មណ៍ថាម៉ែនៅសំរាន្តលើផ្ទះនៅឡើយទេ ហើយមនុស្សម្នាក់មកចូលបុណ្យ ក៏ដូចជាជួយគាំទ្រលើកទឹកចិត្តនាងកុំឱ្យសោកពេកដែរ។ នាងរៀបចំបត់ខោអាវចាស់ៗរបស់ម៉ែ ដើម្បីដាក់ក្នុងក្តារបូជាជូនម្តាយ កំពុងតែរើរៀបស្រាប់តែនៅបាតកញ្ជែង នាងឃើញមានក្រដាស់សរសេរដោយខ្មៅដៃពីរបីសន្លឹក និងអត្តសញ្ញាណប័ណ្ណមានបិទរូបថតម៉ែកាលពីម្ភៃឆ្នាំមុន។ មាណវីផ្ទៀងពិនិត្យមើលរូបថតគួរឱ្យស្រលាញ់ ដែលកំពុងតែញញឹមយ៉ាងខ្លាហានមករកនាង។ តាមពិតម្តាយនាង គឺជាអតីតសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរមួយរូប ដែលត្រូវនិរទេសចាកស្រុក ព្រោះតែរលកនយោបាយអត់ខ្លឹមសាររបស់ពួកមនុស្សអធម៌ ទាំងនាងផ្ទាល់ក៏ធំដឹងក្តី

ឡើង មិនដឹងថាឪពុកម្តាយនៅឯណា? សួរម៉ែម្តងៗ គាត់ចេះតែញញឹមស្ងៀមរហូត ហើយពេលខ្លះក៏តបថា មានម៉ែម្នាក់វាគ្រប់គ្រាន់ណាស់ទៅហើយ កូនទៅចង់បានពុកមកធ្វើអីទៀត? មុំចាប់រលាស់ក្រដាស់សំបុត្រនោះយកមកអានដោយក្តីយកចិត្តទុកដាក់ កូនស្រីមាសម្តាយ ពេលដែលកូនកំពុងតែអានសំបុត្រនេះ គឺប្រហែលជាម៉ែត្រូវលាចាកលោកនេះផុតបាត់ទៅហើយ ឱ្យម៉ែសុំទោសកូនផង កុំខឹងនឹងម៉ែណា! ដែលម៉ែមិនអាចថែរក្សាកូនឱ្យបានចប់ចុងចប់ដើម នេះជាបំណងធម្មជាតិទេ ឯចិត្តម៉ែគឺពុំដូច្នោះឡើយ។ ម៉ែគ្មានអ្វីទុកជាកេរ្តិ៍មរតកឱ្យកូនក្រៅពីការផ្តាំផ្ញើរនេះទេ ធ្វើម៉េចបើម៉ែឈឺច្រើនយ៉ាងនេះ ហើយសង្គមខ្មែរគេរវល់តែហែកហួរគ្នា គេគ្មានពេលគិតគូរដល់ពួកយើងឡើយ។ អ្នកធំសាងបាបរាស្ត្រធ្លាក់នរកវាប់តំណ មេដឹកនាំរបស់ខ្មែរយើងម្នាក់ៗសុទ្ធតែប្រកាសខ្លួនថាជាពុទ្ធបរិស័ទ ខ្លះមានដល់ទៅបួសទៀតផង ប៉ុន្តែនៅពេលដែលពួកគេបានជួបបញ្ហា គេមិនដែលបានយកព្រះពុទ្ធដីកាយកមកដោះស្រាយបញ្ហាម្តងណាឡើយ គឺមានតែយកកំហឹងទល់នឹងកំហល់ ដាក់បងប្អូនឯងដែលជាជនរួមលោហិតតែមួយ។ **កូនហ្អើយ**! ស្រុកយើងតាំងពីណាពីណាមក គឺមិនដែលមានក្តីសុខពិតប្រាកដឡើយ ព្រោះជាព្រះ

រាជាណាចក្រអសមត្ថភាព។ ប៉ុន្តែចូរកូនកុំខឹងនឹងដូនតាអី យ៉ាងណាៗ ក៏ពួកខ្មែរក្រវិនាសជាងពួកក្រិចរ៉ូម៉ាំងពែរ្សព្រួសដែរ កាលយើងសាងអង្គរវត្ត ពួកនោះគេចេះធ្វើដល់ទៅកែឆ្លុះមើលផ្កាយ។ មួយអាទិត្យមាន៧ថ្ងៃ ក៏ដោយសារតែពួកនោះគេឆ្លុះឃើញភពរណបព្រះអាទិត្យឃើញបាន៧ ភព បើគេឆ្លុះឃើញ៩ភពម្លោះសម១អាទិត្យមាន៩ថ្ងៃដែរហើយ។ ពួកនោះពូកែដល់ម្លេះក៏នៅតែរលាយពូជសាសន៍ផុតអស់ពីផែនដីទៅ ព្រោះនេះជាអនិច្ចតាធម៌ ជាដំណើររបស់ធម្មជាតិទេ។ ចូរកូនកុំសោកសៅនឹងរឿងអត់ប្រយោជន៍នេះពេក លើលោកនេះតាមពិតវាគ្មានអ្វីពេញ គ្មានអ្វីទទេ គ្មានអ្វីកើត គ្មានអ្វីស្លាប់ឡើយ។ ព្រោះអត្តភាពនេះ ស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន កើតទៀតខ្លះក៏មិនមែន មិនកើតទៀតខ្លះក៏មិនមែន។ បើមានខ្លួនជាអ្នកគិត ចិត្តនឹងត្រូវវង្វេងនៅក្នុងចិត្តសុខទុក្ខ គឺនៅលើចិត្តគិតទាំងអស់ទេ ចិត្តគិតឲ្យសុខវាសុខ ចិត្តគិតឱ្យទុក្ខវាទុក្ខ ព្រោះជីវិតគឺវាតែអញ្ចឹង ចង់ឱ្យក្លាយជាយ៉ាងដទៃមិនបានឡើយ។ សេចក្តីសុខក្នុងលោក ម៉ែសុំឱ្យកូនស្វែងរកការងារចិញ្ចឹមជីវិតដោយក្តីសុច្ចរិត ឈប់ប្រកបមុខរបរដូចសព្វថ្ងៃនេះទៅទៀត ហើយកុំបាច់ឆ្ងល់ថាហេតុអីម៉ែដឹងរឿងរបស់ឯងឱ្យសោះ ព្រោះម៉ែគឺជាម៉ែតែមួយ

គត់របស់ឯង បើម៉ែមិនដឹងនោះម៉ែមិនសមជាម៉ែរបស់កូនឯងឡើយ។ យើងគ្មានអំណាចកែប្រែអតីតកាលបានទេ ប៉ុន្តែយើងអាចគ្រប់គ្រងបច្ចុប្បន្នកាលបាន គឺការត្រិះរិះពិចារណា ឃុំគ្រងបច្ចុប្បន្នកាលឱ្យមានសុច្ចរិតជារៀងរហូតទើបសមជាកូនខ្មែរ កូនអ្នកមានពូជ។ រហូតអរុណសម័យមកដល់ ធម្មជាតិដែលបញ្ចេញមកមុនគឺរស្មីពណ៌មាសនៃសូរ្យសែងព្រះសូរិយា យ៉ាងណាមិញ យោនិសោមនសិការៈគឺការធ្វើទុកក្នុងចិត្តក្រោមឧបាយត្រូវទំនង (ពិចារណាត្រូវ) គឺជាបុព្វភាគខាងដើមនៃអរិយមគ្គអង្គ៨ ដែលជាបេះដូងធម៌នៃការត្រាស់ដឹងរបស់ព្រះយោគាចរក្នុងព្រះសាសនានេះ។ ចូរចាំសំដីម៉ែណាកូន! ពេលណាកូនមានទុក្ខកូនត្រូវស្តាប់ធម៌ និងសិក្សារៀនសូត្រធម៌ឱ្យបានចេះជ្រៅជ្រះ ព្រោះបញ្ញាថ្នាក់ស្តាប់នឹងនាំទៅដល់បញ្ញាថ្នាក់ភាវនា ហើយទិសដៅរបស់វា គឺឈានទៅលះការប្រកាន់មាំក្នុងខន្ធ៥ (ឧបាទានខន្ធ៥) ដែលជាមូលហេតុរួមរបស់ទុក្ខ គិតឃើញយ៉ាងនេះឈ្មោះថាបញ្ញាជាសម្មាទិដ្ឋិ។ ការពិតចារណាដោយយោនិសោមនសិការៈរឿយៗ សារចុះសារឡើងនាំឱ្យបញ្ញាជាន់ខ្ពស់កើតឡើង នេះជាសម្មាសង្កប្បៈ។ តាមប្រក្រតី បុគ្គលដែលមិនធ្លាប់ទូន្មានចិត្តមកនោះ ចិត្តរមែងត្រាច់ចុះកាន់អារម្មណ៍ក្នុង

អកុសលវិតក្កៈ ត្រិះរិះស្វែងរកកាម ត្រិះរិះឱ្យកើតកំហឹងក្តៅក្រហាយ ត្រិះរិះព្យាបាទដោយច្រើន។ ចំណែកបុគ្គលដែលព្យាយាមលះបង់អកុសលវិតក្កៈ ដោយឧបាយផ្សេងៗតាមពុទ្ធឱវាទរហូតទាល់តែអាចលះអកុសលវិតក្កៈបាន ហើយបែរត្រឡប់មកត្រិះរិះ ក្នុងកុសលវិតក្កៈវិញ សេចក្តីព្យាយាមនេះហៅថា **សម្មាវាយាម។** អ្នកចេះធម៌ព្រះពុទ្ធហើយអាចរលឹកស្វាធ្យាយរឿយៗយកមកការារាំងអកុសល មិនឱ្យប្រព្រឹត្តខុសតាមកាយវាចាចិត្ត ឈ្មោះថា **មានសម្មាសតិ។** អ្នកទូន្មានចិត្តឱ្យអាស្រ័យនៅក្នុងកុសលធម៌ប្រព្រឹត្តិទៅស្មើចំពោះគ្រប់សភាវៈលក្ខណៈ រក្សាឧបេក្ខាចិត្តបាន មិនឱ្យលោកធម៌ទាំង៨ពាល់ត្រូវធ្វើជីវិតឱ្យចុះសម្រុងជាមួយសាមញ្ញលក្ខណៈ មានក្តីរីករាយជ្រះថ្លាជាប្រចាំក្នុងកិច្ចបដិបត្តិព្រះធម៌ ជាប្រក្រតី ឃើញទោសក្នុងវត្ថុកាមទាំងពួង ហើយបានធ្វើជាប់ជាបន្តគ្នាជារៀងរហូតលុះត្រារលត់សង្ខារ តែងមកប្រជុំគ្នាជាធម្មតាក្នុងខណៈមគ្គចិត្តកើតឡើងណាកូន។ បើជឿព្រះត្រូវចូលទៅឱ្យកៀកដល់ព្រះទើបបានក្តីសុខពិតប្រាកដ នៅត្រឹមសទ្ធាអណ្តើកលឹមលៗ គឺនៅតែទុក្ខពាល់ត្រូវរឿយៗដដែលទេ ហើយកុំឆ្ងល់ថា ម្តេចក៏មនុស្សជំនាន់ព្រះគេអស់អាសវៈកិលេសអីងាយម្លេះ? ចំណែកមនុស្សជំនាន់

នេះចេះយល់ធម៌ល្អិតអស់ជើង នៅតែធ្លាក់នរកទាំងរស់ ផ្លូវទៅសួគ៌ដើរ គ្រាន់តែទក់ៗផ្លូវទៅនរក ដើរឡើងបែកភក់ អ្នកទៅសួគ៌ចំនួនស្មើនឹងស្នែងគោ អ្នកទៅនរកចំនួនស្មើនឹងរោមគោ។ កូនម៉ែ! ជាតិនេះយើងមានវាសនាបានសេពគប់គោរពរាប់អានព្រះពុទ្ធសាសនា ត្រូវតែខំស្វែងរកប្រយោជន៍ពីក្នុងនោះឱ្យបានដល់ទីបំផុត កុំឱ្យខំជាអ្នកគោរពព្រះពុទ្ធសាសនានឹងគេដែរ តែរស់នៅមានចិត្តក្រហាមដូចអណ្តើកចូលភ្លើង ម្ល៉ៃៗបើកតែភ្នែកឡើងដាំតែពូជក្រនិងបង្កាត់ទោសៈដុតខ្លួនឯង អ្នកព្យាយាមបង្កាត់នឹងក្តៅខ្លួនឯង អ្នកព្យាយាមពន្លត់ក៏នឹងត្រជាក់ទៅបាន។ កូនម៉ែ! ចូលនាងចាំហេតុនាំឱ្យកើតក្តីសុខដល់ជីវិតប្រចាំថ្ងៃ បើកូននៅមានកម្មមិនអាចបញ្ចប់បាន ចំពោះរឿងប្តីសឹ ចូរកូនរស់នៅជាមួយអ្នកណាដែលគេស្រលាញ់យើងពិតប្រាកដ ប៉ុន្តែមិនត្រូវផ្ញើរបេះដូងទាំងមូលទោះលើគេនោះទេ ប្រយ័ត្នទៅបាត់ឯងត្រូវអត់បេះដូងប្រើដើរលើលឺដូចឆ្កែអង្កែស៊ីតាមចិញ្ចើមថ្នល់ មិនត្រូវសង្ឃឹមមុននាំតែខកចិត្តនៅពេលក្រោយនោះទេ ព្រោះស្នេហាគឺដូចជាស៊ីអំពៅពីគល់ទៅចុង ឯការសិក្សាព្រះធម៌ គឺដូចជាស៊ីអំពៅពីចុងទៅគល់ កាន់តែស៊ីគឺកាន់តែផ្អែមណាកូន តើសេចក្តីសុខមានសមុដ្ឋានដូចម្តេចខ្លះ? កិរិយាសណ្តាប់នូវ

ព្រះធម៌ និងសម្តែងព្រះសទ្ធម្ម គឺជាហេតុនៃសេចក្តីសុខ ព្រោះអវិជ្ជាគឺជាកំណើតរបស់ជីវិត ហើយបរិញ្ញាបត្រក្នុងលោកនេះ គឺជាការតម្កើងមានះប្រកាន់ទេ ពុំមែនជាវិជ្ជានាំមកនូវសេចក្តីខុសពិតប្រាកដឡើង កាន់តែចេះកាន់តែអញ មិនអាចស្តាប់អ្នកណានិយាយបានទេ នេះហៅថាចេះតែមិនដឹង ខុសពីបរិញ្ញាបត្រក្នុងបវរព្រះពុទ្ធសានាដែលកាន់តែចេះកាន់តែទន់ភ្លន់ និង រឹងមាំតាមផ្លូវចិត្ត ជាបុគ្គលសន្តិភាព ព្រោះជាមនុស្សមានហេតុផល។ ចេះស្តាប់អ្នកដទៃនិយាយ ចេះអនុញ្ញាតិឱ្យអ្នកដទៃបានសម្រេចនូវសេចក្តីប៉ងប្រាថ្នារបស់ខ្លួន ដឹងឯងដឹងអញ ដឹងខ្វះដឹងលុម ដឹងគ្រប់ដឹងព្រមចេះឃ្លាន ចេះទ្រាំ មិនខ្វាមស៊ីអត់ចេះខ្មាស់ចេះសួរខ្លួនឯងថាតើបានផ្តល់ប្រយោជន៍អ្វីខ្លះពីជាតិមិនធ្វើជាអណ្តើកចំពោះមុខជាតិដទៃ ហើយសំងំស៊ីសាច់ស្នូកឯងអត់ចេះខ្មាស់ព្រលឹងដូនតា។ ទំរាំសល់ដីកេរ្តិ៍ប៉ុនបាតដៃនេះ ដូនតាយើងបានបង្ហូរឈាមស្រោចធរណីរាប់តំណ ឆ្អឹងគរដូចភ្នំ ត្រូវចងចាំឧបការគុណនេះឱ្យបានច្បាស់។ ការមិនហួងហែង មិនមានះប្រកាន់ គឺជាហេតុនៃសេចក្តីសុខ ត្រូវកំណត់ឱ្យឃើញច្បាស់ថា **រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ** នេះគឺជាទុក្ខទេ ព្រោះជាសំបុករោគ សំបុកដំបៅ ដុំពកមហារីក រូបគ្រាន់តែជា

បង្គន់កាន់តែចាស់កាន់តែស្អុយ រូបជាអំរែកទុក្ខ ព្រោះត្រូវព្រួយថែរក្សា ផ្គត់ផ្គង់សព្វបែបយ៉ាង រូបគឺជាទុក្ខយ៉ាងនេះតែយើងបែរជាប្រកាន់មាំគាំ ទ្រហួងហែងថា រូបមានខ្លឹមសារ រូបជារបស់ខ្លួនគេប៉ះពាល់តិះដៀលមិន បាន បញ្ញាត្រូវបិទបាំងដោយអវិជ្ជា ការកើតគឺជាកំណើតនៃទុក្ខ តែបែរ ជានាំគ្នារីករាយអបអរសាទរជប់លៀងស៊ីផឹក សើចសប្បាយ ការស្លាប់គឺ ជាការរសាយទុក្ខ តែបែជានាំគ្នាយំសោកស្តាយស្រណោះអាឡោះ អាល័យទុក្ខ មិនចង់ឱ្យទុក្ខព្រាត់ទៅជីវិតរស់នៅអត់បញ្ញ មើលមិន ឃើញសេចក្តីពិតទើបត្រូវរស់នៅឡិកឡក់ ឡេឡាដូចកូនក្មេង។ ទីណា មានការមានះប្រកាន់ ទីនោះគឺវិនាសហើយ សូម្បីតែប្តីប្រពន្ធដែល ស្រួលនិយាយគ្នាបំផុត ចង់និយាយកណ្តាលយប់ក៏បាន ថ្ងៃក៏បាន ប៉ុន្តែ បើនិយាយដោយមានះប្រកាន់គឺប្រាកដជាផ្អើលភូមិជាមិនខាន។ ឱ្យតែ មានការប្រៀបធៀបវា គឺជាសារនាំឱ្យកើតការមានះប្រកាន់ ហើយការ ជជីករកហេតុផលហួសពេក ក៏ជាហេតុនៃទំនាស់ក្នុងគ្រួសារដែរ។ សង្គមដែលសំបូរមនុស្សមានះប្រកាន់ សង្គមនោះគ្មានសាមគ្គីធម៌ទេ នេះឯងជាមារយាទរបស់មេដឹកនាំខ្មែរយើង កូនឯងមើលជាតិគេ គេ ឈ្លោះគ្នាបែកពពុះមាត់ពីព្រឹក ល្ងាចឡើងគេនិយាយរកគ្នាជាធម្មតា ឯ

ខ្មែរយើងហ៊ានតែប៉ះលើសលោះតែបន្តិច គឺមានៈ តមសំដី គុំគួនតាម សងសឹក ស៊ីសាច់ហុតឈាមគ្នារាប់ជាតិ។ នេះឯងជាចំណុចខ្សោយ របស់ជាតិយើង ទើបបានជាតិដទៃវាអាចបំបែកបំបាក់ឱ្យវិនាសហិន ហោចបាន។ បើគេមាត់ទិព្វ យើងត្រូវមានភ្នែកទិព្វណាកូនបានមិនធ្លាក់ ខ្លួនខ្ញុំគេ។ យើងចេះតែឆ្លាតជ្រុលលើសបណ្តាំដូនតា ដូនតាផ្តាំមកថា ឧត្តរិមនុស្សធម៌ (**ធម៌ដ៏ឧត្តមរបស់មនុស្ស**) គឺសច្ចៈ ខន្តី កត្តញ្ញូតាធម៌ នេះ លោកឱ្យប្រើចំពោះជាតិខ្លួន បងប្អូនរួមលោហិតរបស់ខ្លួន តែខ្មែរបែ ជាយកទៅប្រើជាមួយជាតិដទៃ បើបានជាថាឱ្យដីទៅគេគឺរក្សាសច្ចៈ ឱ្យបាន ហើយបើទោះជាត្រូវគេជេប្រមាថយ៉ាងណាក៏ទ្រាំរក្សាខន្តីទល់ថ្ងៃ ស្លាប់។ គេឱ្យថ្នាំពុលធឹកហើយឲ្យថ្នាំបន្សាបតាមក្រោយ ក៏ប្រឹងរក្សាកត្ត ញ្ញូតារាថយ ក្នុងវង់ល្បែងក៏សច្ចៈក្នុងឆាកនយោបាយ ដែលគ្រាន់តែជា ការបោកប្រាស់ក៏សច្ចៈ។ លេងល្បែងចាញ់គេ ភ្នាល់ដាក់គោ សុខចិត្ត ដឹកគោយកទៅឱ្យគេ បើប្រពន្ធហ៊ានតែដេរ សុខចិត្តវាយតប់ប្រពន្ធបែក មាត់ បាក់ធ្មេញឱ្យតែបានរក្សាសច្ចៈកុំឱ្យគេមើលងាយបាន ក្នុងចិត្ត មានៈគិតថា ហ្នាំកពូជអញថ្លៃថ្នូរអញ្ចឹងណា ឯងកុំចង់មើលងាយឱ្យ សោះ។ សុច្ចរិតតាមកាយវាចាចិត្តក៏ជាហេតុនៃសេចក្តីសុខដែរ ប៉ុន្តែក្តី

សុច្ចរិតនេះគឺត្រូវប្រកបជាមួយបញ្ញាផងដែរទើបត្រូវ។ ក្នុងព្រះពុទ្ធសាសនាព្រះអង្គសម្តែងយ៉ាងខ្ពស់ គឺដល់ថ្នាក់បញ្ញាវិសុទ្ធិឯណោះ ទៅពោលដល់ថ្វីត្រឹមបញ្ញាជាលោកិយៈ។ មិនសេពគប់ជាមួយពាល មិនសេពគប់ជាមួយស្តេចនិងមន្ត្រី ពាលរមែងតែងនាំទៅកាន់តែក្តីវិនាសតែប៉ុណ្ណោះ អំពើទាំងឡាយណាដែលបៀតបៀនខ្លួនឯង និងបៀតបៀនដល់អ្នកដទៃគឺជាអំពើពាល ពាលមានខ្លួនឯងជាសត្រូវ សេពគប់បណ្ឌិតទើបនាំទៅកាន់ក្តីសុខចម្រើន។ ហើយចុះស្តេច និងមន្ត្រីជាពាលឬជាបណ្ឌិតទើបយើងមិនគួរសេពគប់? កុំធ្វើឫកក្រអឺតពេលបានអ្នកធំគេរាប់អានណាកូន ចូរកុំធ្វើជាបង្គួយពាក់ខ្សែកនៅក្បែទ្វារវាំង ចូរធ្វើជាបង្គួយតាមព្រៃភ្នំទើបមានឥស្សរភាពជាង។ រាប់អានអ្នកធំគឺគ្មានសមភាពទេ បានត្រឹមតែទទួលការប្រមាថពីគេតែប៉ុណ្ណោះ។ គេអាចទំលាក់កំហុសបានគ្រប់ពេលវេលា បើចង់ធ្វើជាកូនអុកររបស់គេ បើគេឱ្យងាប់ៗឱ្យរស់ៗ (ដូចត្រីដែលគេប្រោសទុកក្នុងពាង ឬខាប់បើគេចង់គេនឹងសម្លាប់ស៊ី) មិនអាស្រ័យបុណ្យរបស់ខ្លួនឯងឡើយ។ ពេលគេខ្វីលុយឯង ឯងត្រូវហុចដៃពីរ ពេលចង់ទារប្រាក់នោះមកវិញ ឯងត្រូវតែអង្គុយបត់ជើងហើយពោលភ្ជុញត្អែរបញ្ឆិតបញ្ឆៀងឱ្យគេដឹង ឯងចាំតែខុសរ

ហូត។ មានការព្រមព្រៀងទើបមានសេចក្តីសុខ ការព្រមព្រៀងគឺជាបុព្វ ហេតុនៃការសាមគ្គីធម៌ នាំឱ្យមានភាពរឹងមាំក្នុងសង្គមប្រជាជាតិ នេះគឺ ជាចំណែកមួយនៃអបរិហានីយធម៌ (ធម៌មិនវិនាសសាបសូន្យ)។ ការ សន្សំបុណ្យនាំមកនូវសេចក្តីសុខ ធ្វើអំពើល្អគង់នឹងមានទុក្ខ ទំរាំធ្វើតែ អំពើអាក្រក់ទៀតតើនឹងបានសុខមកពីណា? ព្យាយាមបដិបត្តិតាមធម៌វិ នយ គឺជាការឡើងថ្នាក់របស់ចិត្តឆ្ពោះទៅកាន់គតិបណ្ឌិត ដែលជាកិច្ច ចេញចាកទុក្ខបានយ៉ាងពិតប្រាកដ។ ការមិនប្រមាថគឺជាហេតុនៃសេច ក្តីសុខ មិនប្រមាថពេលវេលា មិនប្រមាថសត្រូវ សត្រូវធំបំផុតគឺកិលេស ខ្លួនឯងសេចក្តីមិនប្រមាថសព្វសារពើគឺជាការរស់នៅប្រកបដោយសតិ សម្បជញ្ញៈ។ នេះគឺជាពុទ្ធមរតក ជាបណ្តាំចុងក្រោយរបស់ព្រះពុទ្ធដែល ព្រះអង្គទ្រង់ត្រាស់សង្ឃេបទៅលើព្រះធម្មទេសនារបស់ព្រះអង្គ ដែល បានសម្តែងអស់រយៈពេលបីពោធិកាល មួយពោធិកាលរយៈពេល១៥ ឆ្នាំ បណ្តាំដ៏មានសារៈសំខាន់ទាំងនោះមានពីរយ៉ាងគឺ៖

១-**ការរស់នៅមិនប្រមាថ** គឺរស់នៅប្រកបដោយសេចក្តីភ្ញាក់រលឹក អង្គធម៌បានដល់សតិនេះឯង។

២-សេចក្តីសង្ស័យ ធ្វើកិច្ចការអ្វីក៏ដោយ បើមិនច្បាស់លាស់នៅមានការសង្ស័យ កិច្ចការនោះមិនត្រឹមតែមិនសម្រេចជោគជ័យទេ តែអាចបង្ករជាក្តីអន្តរាយដល់ខ្លួនឯង ឬដល់អ្នកដទៃទៀតក៏មាន ធ្វើកិច្ចការណាមួយបើនៅមានមន្ទិលសង្ស័យគួរកុំធ្វើល្អជាង។

រំងាប់ក្តីក្រោធដោយចម្រើនខន្តី គឺជាហេតុនៃសេចក្តីសុខ មានសេដ្ឋីនីថៃម្នាក់ដែលចាំបណ្តាំរបស់ជីដូនដែលរៀបនឹងស្លាប់ថា ចូររំងាប់ក្តីក្រោធដោយមិនក្រោធតប។ ដោយសារពុទ្ធដីកានេះ ជីដូនបានរក្សាតួនាទីជាភរិយាដ៏ឧត្តមរបស់ជីតាឯងរហូតដល់ថ្ងៃស្លាប់ ឯងត្រូវមានសតិស្មារតី យកពុទ្ធដីកានេះមកប្រើដើម្បីដោះស្រាយបញ្ហាក្នុងជីវិតឱ្យបានជោគជ័យ។ ក្នុងពុទ្ធដីកាទាំង ៨៤០០០ព្រះធម្មខន្ធ ឃ្លាណាក៏ដោយឱ្យតែឯងយកមកប្រតិបត្តិតាមដោយគោរព គឺសុទ្ធតែអាចចេញចាកទុក្ខបានទាំងអស់។ មនុស្សបើគ្មានការអត់ធន់ទេ គឺមិនអាចរំងាប់ក្រោធបានឡើយ ហើយការអត់ធន់ជាបុព្វហេតុសម្រេចជោគជ័យការងារធំៗក្នុងការងារប្រចាំជីវិត។ ចិត្តដែលគ្រប់គ្រងបានល្អហើយ នាំមកនូវសេចក្តីសុខ ត្រូវចេះត្រិះរិះពិចារណាដើម្បីអប់រំចម្រើនបញ្ញាការព្រមតាមហេតុបច្ច័យ តាមដំណើរធម្មជាតិគឺជាហេតុនៃសេចក្តីសុខ សុខព្រោះចេះលះ

ទុក្ខ ដឹងថាសេចក្តីស្រលាញ់ សេចក្តីស្អប់ មានៈ តណ្ហា ការប្រកាន់ គឺជាទុក្ខតែលះចោលមិនបាន តើនឹងរកសេចក្តីសុខឯណាឃើញក្នុងជីវិត? សុខ ព្រោះចេះសង្កត់សង្កិនកិលេសដោយសតិមិនធ្វេសប្រហែសស្មារតី បថុជ្ជនសុខព្រោះតែការបាន ឯអរិយបុគ្គលសុខព្រោះកំណត់ដឹងសុខបថុជ្ជនជាសុខគូនឹងទុក្ខ ឯសុខរបស់អរិយបុគ្គលគឺជាសុខដែលមិនមែនជាគូនឹងទុក្ខ។ សុខព្រោះស្ងប់ស្ងាត់ចាកអកុសល ចាកនីវណៈធម៌ សុខដទៃខុសពីសេចក្តីស្ងប់ស្ងាត់មិនមាន សុខក្នុងនិព្វានដែលជាសេចក្តីសុខទៀងទាត់ប្រាសចាកទុក្ខទាំងពួងណាកូនម្តាយ នេះគឺជាទិសដៅពិតរបស់យើងក្នុងនាមជាពុទ្ធបរិស័ទ្ធ។ ធម្មជាតិណាដែលពពួកជនប្រាថ្នាមិនងាយបាននោះ គឺជាសេចក្តីសុខនេះឯង ប៉ុន្តែកុំចេះតែខំស្វែងរកនូវអ្វីដែលខ្លួនពេញចិត្តនោះពេក ត្រូវចេះទទួលយកនូវអ្វីដែលផ្តល់មកឱ្យជីវិតរបស់ខ្លួនវិញផង កុំដឹងតែបាន ត្រូវដឹងអាមិនបាននោះខ្លះផង។ អំពីរឿងលុយ មានលុយអាចទិញសៀវភៅបានគ្រប់បែបយ៉ាង តែមិនអាចទិញការយល់ដឹងរបស់សៀវភៅទាំងនោះបានឡើយ មានលុយអាចទិញបានគ្រែល្អៗ តែមិនអាចទិញយកការដេកលក់បានឡើយ មានលុយអាចទិញយកសញ្ញាបត្របានគ្រប់យ៉ាង តែមិនអាចទិញសេច

ក្តីសុខពិតប្រាកដបានឡើយ។ មានលុយអាចជួបវិជ្ជបណ្ឌិតណាក៏បាន តែមិនអាចទិញសុខភាពពីគាត់បានឡើយ មានលុយអាចហានៈតំណែងតួនាទី តែមិនអាចទិញការគោរពពីអ្នកដទៃបានឡើយ មានលុយអាចទិញភេទបាន តែមិនអាចទិញជីវិតបានឡើយ។ អត្តភាពនេះគឺជានាម និងរូប វាកើតពីហេតុនិងបច្ច័យទាំងអស់ របស់ណាដែលកើតពីហេតុបច្ច័យយ៉ាងនេះ វាអត់មានខ្លួនឯងទេ។ ហេតុនេះតើចាំបាច់ចង់បានអ្វីពីលោកនេះ? លោកនេះអត់មានអ្នកណាបានអ្វីក្រៅតែអំពីវិបាករបស់កម្មតែប៉ុណ្ណោះ ដោយសារតែអវិជ្ជាធាតុនាំឱ្យមានតណ្ហាកើតឡើង ហើយអភិសង្ខារ ការតាក់តែងកម្មក៏កើតឡើងដែលនាំឱ្យភពនិងជាតិក៏កើតឡើង។ អស់អវិជ្ជាតណ្ហា នាំឱ្យអស់អភិសង្ខារ នាំឱ្យអស់ភពនិងជាតិ នាំឱ្យអស់ទុក្ខ តែបើមិនអស់អវិជ្ជា និងតណ្ហានោះទេ រឿងជីវិតនៅតែមានកុសលវិបាក និងអកុសលវិបាកជាធម្មតា។ ឯបញ្ចធម៌មានទិដ្ឋិមានៈ តណ្ហា ឧបាទាន កម្ម គឺជាធម៌នាំឱ្យមានវដ្តយឺតយូរ មានៈនាំឱ្យមានទំនាស់ចាប់ពីពីរនាក់ឡើងទៅ ទិដ្ឋិនាំឱ្យមានជំលោះសេដ្ឋកិច្ច និងសាសនា តណ្ហាឧបាទាននាំឱ្យសាងកម្មសកម្មខ្មៅវិលជាប់មិនដាច់។ មុំ! អ្វីដែលម៉ែចង់ប្រាប់ឯងអស់ហើយ ចូរកុំព្រួយពីការព្រាត់ប្រាស់គ្នា

ខ្លាំងពេក ជីវិតម៉ែប្រៀបដូចជាចង្កៀងដែលជិតអស់ប្រេងទៅហើយ ខ្យល់បក់តែបន្តិចក៏នឹងរលត់បាន ទៅមុននឹងបន្តិចក៏ជាការល្អដែរ សោះនឹងនាំទុក្ខដល់កូនយូរ រឿងនេះម៉ែដឹងខ្លួនឯងច្បាស់ណាស់ ព្រោះផលរបស់ថ្នាំពីមួយថ្ងៃទៅមួយថ្ងៃចេះតែខ្សោយតទ្វិពលទៅៗ ជំងឺក៏កាន់តែធ្វើទុក្ខខ្លាំងឡើង ម៉ែស៊ូជាមួយនឹងជរាព្យាធិនេះតទៅទៀតលែងបានហើយ! កូនម៉ែអភ័យទោសឱ្យម៉ែផង បើចង់ជួបម៉ែនៅជាតិមុខ ចូរខំធ្វើតាមបណ្តាំម៉ែណា! ណ្តើយ! ម៉ែលាត្រឹមនេះចុះ រក្សាខ្លួនឱ្យល្អផងណាកូន! ពីម៉ែ។

មុំអានចប់ក៏ល្មម ដល់ពេលជូតទឹកភ្នែកឱ្យបានស្អាតល្អពីផ្ទៃមុខដែរ នាងហាក់ដូចជាយល់ច្បាស់ពីខ្លឹមសារជីវិតនេះ ពេលបានជួបរឿងអាក្រក់មិនត្រូវឈឺចាប់តូចចិត្តថាយើងអភ័ព្វពេកនោះដែរ ត្រូវចេះប្រើរឿងមិនល្អទាំងនោះឱ្យត្រឡប់មកជារឿងល្អវិញ ទើបបានសមជាមនុស្សដែលរឹងមាំ។ នឹកដល់ត្រង់នេះ តាសនក៏មកដល់ល្មមដោយទឹកមុខប្រកបដោយព្រហ្មវិហារធម៌ គាត់ផ្អែកឈើច្រត់ទៅជញ្ជាំងបណ្តើរ ចេញវាចាបណ្តើរថា៖ យាយស្លាប់ដោយសារមូលហេតុអីហ្ន៎លោកក្មួយ ពេទ្យហែង? ពេទ្យហែងសម្រួលទឹកមុខបន្តិចទើបពោលតប៖ បាទពូ

យាយហើមសួត! ទឹកចាល់ចូលសួត ភាសាបារាំងហៅថា អូ អា ប៉ៃ បណ្តាលមកពីខ្សោយបេះដូង ដែលជាផលវិបាករបស់ជំងឺលើសសំពាធឈាមរ៉ាំរ៉ៃហ្នឹងណាពូ!។ ជំងឺលើសសំពាធឈាមសំបូរណាស់ តាមពិតកម្រិតសំពាធឈាមរបស់មនុស្សវាកើនតាមអាយុ មានន័យថាអាយុកាន់តែច្រើន សំពាធឈាមគឺកាន់តែខ្ពស់។ តាមអង្គការសុខភាពពិភពលោកបានកំណត់ថា អាយុក្រោម៦០ឆ្នាំកំរិតសំពាធឈាមនៅក្រោម ១៤០/៩០ម.មបារត ឬគេនិយមនិយាយហៅកាត់ថា ១៤លើ៩ ហើយអាយុលើសពី៦០ឆ្នាំកំរិតសំពាធឈាមនៅក្រោម១៦០/៩០ម.មបារត ឬ ១៦លើ៩។ បើមនុស្សមានកម្រិតសំពាធឈាមច្រើនជាងនេះ គេថាមនុស្សនោះលើសសំពាធឈាម ហើយត្រូវតែធ្វើលំហាត់ប្រាណ របបអាហារកុំសូវហូបប្រៃ និងខ្លាញ់ច្រើន កុំប្រើម្សៅស៊ុបឬប៊ីចេងក្នុងអាហារតមបារី ស្រាម្លូរថ្នាំចុក រៀបចំការគិតឱ្យមានរបៀប កាលណាគួរគិតសឹមគិតកាលណាមិនគួរគិតកុំគិត កុំគិតព្រួយចង់មានចង់បានដោយគ្មានហេតុផល កុំព្រួយបារម្ភមុន។ ក្រីក្រយ៉ាងណា អត់លុយយ៉ាងណា ក៏ចប់ត្រឹមស្លាប់តែប៉ុណ្ណោះ មិនចាំបាច់ព្រួយមុនច្រើនឡើយ។ ប៉ុន្តែការហាត់ប្រាណនេះ ធ្វើត្រូវវាជាឱសថ បើធ្វើខុសវាថ្នាំពុលសាហាវណាស់

ក្នុងធម្មជាតិ មនុស្សខ្លះស្រណុកពេកដេកស៊ីលើសឈាម ខ្លះធ្វើការហត់ពេកលើសឈាម ហេតុនេះយើងត្រូវចេះប៉ាន់ប្រមាណខ្លួនឯងផង។ ចលនាហាត់ប្រាណត្រូវតែប្រែប្រួលទៅតាមវ័យ មិនមែនត្រូវខំទាល់តែសំពាធឈាមស្ទុះឡើងដាច់សរសៃឈាមក្នុងខួរក្បាលស្លាប់នោះទេ។ ឯតួលេខកំរិតសំពាធឈាម ដែលអង្គការសុខភាពពិភពលោកបានកំណត់នោះ វាជាស្តង់ដារបស់មនុស្សក្នុងពិភពលោក ដែលភាគច្រើនគឺសិក្សាទៅលើពួកមនុស្សមាឌធំៗ ចំណែកខ្មែរយើងមាឌតូចៗ ដូចនេះកុំផ្អែកទៅលើតួរលេខនេះខ្លាំងពេកក៏មិនបានដែរ។ ត្រូវដឹងពីសភាពធម្មជាតិរបស់គាត់ តើសំពាធឈាមរបស់គាត់ប៉ុន្មាន ពេលដែលគាត់ស្រួលខ្លួនធម្មតា? មនុស្សខ្លះមានសុខភាពស្រួលខ្លួនធម្មតាត្រឹម៧ ទៅ៨ ឱ្យតែឡើងដល់១០ទៅ១១ គឺធ្វើទុក្ខឱ្យគាត់វិលមុខភ្លតចង្អោរឈឺក្បាលព្រិលស្រវាំងភ្នែក ទាល់តែប្រើថ្នាំបញ្ចុះសំពាធឈាមទើបបានស្រួលខ្លួនធម្មតាវិញ។ សំពាធឈាមតែងប្រែប្រួលពេលផ្លាស់ប្តូរអាកាសធាតុច្រើនតែស្ទុះឡើងខ្ពស់ ពេលចាប់ពីពាក់កណ្តាលអាធ្រាតទៅទៀបភ្លឺ ពេលដែលចាស់ៗច្រើនលង់ដំណេក។ ហេតុនេះការប្រើឱសថគឺត្រូវរើសឱសថដែលអាចគ្រប់គ្រងសម្ពាធឈាមឱ្យបានពេញ២៤ម៉ោង ពេល

ដែលកម្រិតសំពាធឈាមស្ទុះឡើងខ្ពស់ វាបានធ្វើឱ្យប្រេះបែកសរសៃឈាមរួចទៅហើយ ទើបបានគាត់ដួលសន្លប់ មិនមែនការដួលធ្វើឱ្យដាច់សរសៃឈាមទេ។ គ្រួសារអ្នកជំងឺខ្លះប្រឹងតែជេស្តីបន្ទោសអ្នកថែទាំផ្ទាល់ថា ធ្វេសប្រហែសបណ្តាលឱ្យគាត់ដួលបានជាឈឺធ្ងន់បែបនេះ ការគិតបែបនេះគឺមិនត្រឹមត្រូវទេ។ ធ្វើលំហាត់ប្រាណ អនាម័យចំណីអាហារ តមការប្រើប្រាស់អ្វីដែលនាំឱ្យលើសឈាម បើធ្វើបែបនេះហើយសំពាធឈាមនៅតែខ្ពស់ គេត្រូវចាប់ផ្តើមប្រើឱសថបញ្ចុះសំពាធឈាមហើយត្រូវតាមដានវាស់សំពាធឈាមឱ្យបានទៀងទាត់។ គេត្រូវពិនិត្យឈាម ដើម្បីតាមដានផលប៉ះពាល់ទៅលើសរីរាង្គសំខាន់ៗដូចជាតម្រងនោមជាដើម។ គេពិនិត្យអត្រា ត្រែអាទីនីន (វាឡើងបញ្ជាក់ថាខ្សោយតម្រងនោម) ត្រង់សាមីណា(វាឡើងបញ្ជាក់ថារលាកថ្លើម) កូលេស្តេរ៉ុល ទ្រីគ្លីសេរីត(ជាតិខ្លាញ់ក្នុងឈាម បើវាលើសនាំឱ្យមានការក្រិនសរសៃឈាម និងនាំឱ្យដាច់រហែកសរសៃឈាម)។ កម្រិតជាតិស្ករក្នុងឈាម (ក្រែងមានជំងឺទឹកនោមផ្អែមកើតសង្កំជាមួយ)។ ចំពោះផលវិបាកនៃជំងឺលើសសំពាធឈាម គឺវាធ្វើឱ្យការលើសម្តងម្កាលក្លាយមកជាលើសជាប់រហូត ធ្វើឱ្យក្រិនសរសៃឈាម រីកប៉ោងសរសៃឈាម

ដោយអន្លើជាពិសេសក្នុងខួរក្បាល ការក្រិនសរសៃឈាមចិញ្ចឹមបេះដូង នាំឱ្យរលួយសាច់ដុំបេះដូង លើសសំពាធឈាមយូរទៅបេះដូងប្រឹងធ្វើការនាំឱ្យរីកសរសៃបេះដូង ហើយវិវត្តន៍ទៅជាខ្សោយបេះដូង និងធ្វើឱ្យប្រើសបេះដូងចំហរ ធ្វើឱ្យដាច់សរសៃឈាមក្នុងខួរក្បាលស្លាប់ភ្លាមៗ ដូចម្តាយមុំ ឬនាំឱ្យស្លាប់មួយចំហៀងខ្លួនពិការអវយវៈណាមួយ ឱ្យពិការភ្នែក កើតជំងឺទឹកនោមផ្អែម (ប្រភពតម្រងនោម) ឬជំងឺទឹកនោមប្រៃ (ផលវិបាកយូរអង្វែង) ជាដើម។ សព្វថ្ងៃអាហារសំបូរជាតិគីមីច្រើនក៏ជាការជម្រុញឱ្យកើតជំងឺនេះច្រើនដែរ។ អើហ៎! ត្រង់នេះពូជឿហើយក្មួយ ប៉ុន្តែហេតុអីក៏មិនឃើញអ្នកធំគេជួយគិតគូរឿងនេះផងហ្ន៎។ (លោកតាសនសួរទាំងជ្រួញចិញ្ចើម) ពូហោងតបៈ រឿងនេះមានហេតុបច្ច័យចូលរួមច្រើនណាពូ! ស្រុកយើងក្រ ត្រូវខំប្រឹងស្វែងរកចំណូលជូនរដ្ឋឱ្យបានច្រើន តាមរយៈការបង់ពន្ធតាក់អីជាដើមដើម្បីមានប្រាក់ខែបើកជូនបុគ្គលិករដ្ឋ ប៉ុន្តែផលចំណេញពីការបង់ពន្ធ និងផលចំណាយរបស់ប្រជាជន ទៅលើជំងឺដំកាត់ដែលបណ្តាលមកពីការបំពុលតាមរយៈចំណីអាហារ និងរបស់របរប្រើប្រាស់គឺវាខុសគ្នាឆ្ងាយណាស់ទាល់តែការគ្រប់គ្រងរបស់យើងបានល្អ ទើបសុវត្ថិភាពចំណីអាហារ និង

របស់ប្រើប្រាស់ធានាគុណភាពបានត្រឹមត្រូវ។ ហេតុនេះជាបន្ទាន់គឺត្រូវមានច្បាប់ ហើយអ្នកដឹកនាំគឺធ្វើគម្រូគេក្នុងការគោរពច្បាប់ ពុំនោះទេស្រុកទេសនៅតែត្រូវរស់រខេករខាក ក្រោមស្លាកនិតិរដ្ឋតែស្លាកនឹងណាពូ! នេះជាបច្ច័យខាងអ្នកដឹកនាំ ឯខាងប្រជាជនគឺត្រូវតែមានបញ្ញាក្នុងការរស់នៅ កុំចេះតែបន្ទោសមេដឹកនាំ ព្រោះនេះជាបញ្ហារបស់យើង ទាំងអស់គ្នាទេ កុំស្រមៃឱ្យសោះថា អញគិតតែពីក្រពះអញរៀងៗខ្លួនអ្នកណាចង់យ៉ាងម៉េចក៏យ៉ាងម៉េចទៅ កុំគិតយ៉ាងនេះហើយថាបានរួចខ្លួនឱ្យសោះនោះ ព្រោះក្នុងធម្មជាតិឥតមានធម៌ណាមួយលេចចេញទោលតែឯង ហើយមិនទទួលឥទ្ធិពលពីគ្នាទៅវិញទៅមកនោះទេ។ យុគសម័យនេះគឺជាកាលវិបត្តិនៃពិភពលោក ព្រោះតែសំភារៈដឹកនាំលោកទើបឆ្ពោះទៅកាន់ក្តីវិនាសទាំងអស់។ កាលខ្ញុំទៅធ្វើកម្មសិក្សានៅបរទេស កសិកម្មស្រុកគេធ្វើអ្វីក៏ប្រើជីគីមីដែរទាំងជីធម្មជាតិក៏ប្រើ ប៉ុន្តែពលករគេមានការយល់ដឹងខ្ពស់ណាស់ ចំពោះការប្រើប្រាស់ផលិតផលទាំងអស់នោះ ដូចជាក្រោយការប្រើជាតិគីមីតើត្រូវបន្តក់ទុកប៉ុន្មានថ្ងៃទើបវាសាបជាតិអស់នោះ ហើយពេលនាំចូលទីផ្សារបុគ្គលិកផ្នែកសុវត្ថិភាពចំណីអាហារគេចាំបាច់ពិនិត្យឆែកឆេរយ៉ាងម៉ត់ចត់ ឱ្យតែឃើញ

ផលិតផលណាមានចំហាយជាតិគីមី ត្រូវតែចោលក្នុងធុងសំរាម ហើយ ម្ចាស់ផលិតផលត្រូវបានភ្នាក់ងារកសិកម្ម គេអញ្ជើញឱ្យចូលរួមវគ្គ សិក្សាបង្កើនការយល់ដឹងក្នុងថ្ងៃនោះភ្លាម។ ស្រុកយើងរឿងប៉ុណ្ណឹងៗខ្ញុំ ជឿថាអាចធ្វើបាន ឱ្យតែយើងមានឆន្ទៈធ្វើ ព្រោះជាសុខភាពរបស់យើង ទាំងអស់គ្នា។ អ្នកប្រើប្រាស់ផលិតផលត្រូវមានការចេះដឹង ត្រូវចេះ ជ្រើសរើសផលិតផលណាគួរប្រើ ដូចប្រទេសឥណ្ឌាកាលមហាបុរសគន្ធី លោកដឹកនាំ ពេលលោកអំពាវនាវឱ្យប្រជាជនឈប់ប្រើផលិតផលរបស់ អង់គ្លេស ព្រោះទីមួយគឺគេអាចបំពុលតាមរយៈរបរប្រើប្រាស់ ទីពីរ អាណានិគមគឺនៅតែប្រព្រឹត្តទៅបាន ព្រោះវានៅតែស្រូបទិញផល ប្រយោជន៍ទៅបានពីប្រជាជនឥណ្ឌា ការយល់ដឹងរបស់ប្រជាជនគេ ខ្ពស់ គេនាំគ្នាឈប់ប្រើប្រាស់ផលិតផលនាំចូលទាំងអស់នោះ ធ្វើឱ្យ ឈ្លើងអង់គ្លេសទាមជញ្ជក់ឥណ្ឌាតទៅទៀតលែងបាន ទើបនាំគ្នាត្រ ឡប់ទៅស្រុកអស់វិញ ព្រមពេលជាមួយគ្នានឹងមហាកុប្បកម្មអត់អាហារ ចលនារើបំរះអហឹង្សាដែលដឹកនាំដោយមហាត្មៈគន្ធីនោះផង ទើបឥណ្ឌា បានទទួលឯករាជ្យពិតប្រាកដមកវិញ។ ស្រុកយើងផលិតផលខ្មែរមាន សព្វគ្រប់ មានត្រូវចាំបាច់អីនឹងទៅប្រើប្រាស់ផលិតផលនាំចូលពីខាង

ក្រៅ អំបោស ចង្អេរ កញ្ជើរ ល្អី បន្លែបង្គារសព្វសារពើ។ សក្តានុពលធម្ម
ជាតិយ៉ាងសំបូរបែប រ៉ែមាស រ៉ែបុកស៊ីត រ៉ែដែក.....សុទ្ធតែអាចឱ្យយើង
ទាញមកប្រើប្រាស់បានតាមតម្រូវការ ប៉ុន្តែច្បាប់និងការអនុវត្តន៍ច្បាប់
ត្រូវតែវិជ្ជមានតាំងពីថ្នាក់លើ ដល់ថ្នាក់ក្រោម បើពុំនោះទេ ការប្រើប្រាស់
ផលិតផលធម្មជាតិទាំងនោះ នឹងក្លាយទៅជាការបំផ្លិតបំផ្លាញធម្មជាតិ
ទៅវិញ។ តើយើងនៅខ្វះធនធានមនុស្សឬខ្វះសិទ្ធិសេរីភាពក្នុងការ
សម្រេចចិត្តដើម្បីធ្វើ? គ្មានអ្នកណាស្គាល់ទុក្ខលំបាករបស់ខ្មែរជាងខ្មែរ
នោះទេ ហើយក៏គ្មានអ្នកណាចង់រស់នៅដោយមានការឆក់ប្លន់សិទ្ធិសេរី
ភាពពីអ្នកដទៃផងដែរ ខ្មែរត្រូវចេះយល់ចិត្តថ្លើមគ្នា អាក្រក់ល្អយើងមាន
ឈាមជ័រតែមួយ មិនត្រូវព្យាយាមធ្វើទេ គឺត្រូវតែធ្វើដើម្បីថែរក្សានិរន្ត
ភាពរបស់ជាតិយើង។ អ្នកមានរក្សាខ្សត់ដូចសំពត់ព័ទ្ធពីក្រៅ អ្នកចេះ
រក្សាខ្លៅដូចសំពៅនូវសំប៉ាន។ សេចក្តីវិនាសគឺគ្មានអ្នកណាធ្វើឱ្យក្រៅពី
ខ្លួនយើងជាអ្នកធ្វើនោះឡើយ នេះជាច្បាប់កម្មផលដ៏ល្បីល្បាញរបស់
ព្រះពុទ្ធ។ ក្នុងច្បាប់បដិច្ចសមុប្បាទរបស់ព្រះពុទ្ធបរមគ្រូ ដែលមាន
ជម្រៅលើសមហាសាគរឆ្ងាយជាងអង្កត់ផ្ចិតរបស់ផែនដី ហើយគ្របដ
ណ្តប់ទាំងសកលចក្រក្រៅឡនោះគឺ អ្វីៗសុទ្ធតែកើតឡើងមានហេតុ

បច្ច័យរលត់ទៅក៏មានហេតុបច្ច័យ ជាធម៌អាស្រ័យគ្នានិងគ្នាដើម្បីកើត អាស្រ័យគ្នានិងគ្នាដើម្បីរលត់ កង់ច្រវាក់ទាំង១២ របស់ចាប់ផ្តើមតាំង អំពីអវិជ្ជាទៅទល់នឹងទុក្ខ ហេតុនេះទីណា សង្គមណា ជាតិណាដែល មានអវិជ្ជាចម្រើនឡើងទីនោះ សង្គមនោះ ជាតិនោះ ត្រូវតែមានទុក្ខកើត ឡើងជាធម្មតា ចង់ផ្តាច់កង់ច្រវាក់នោះដើម្បីកុំឱ្យវាវិលទៅរកទុក្ខ គឺត្រូវ តែកាត់ផ្តាច់ត្រង់អវិជ្ជានេះចោល ដោយយកប្រទីបវិជ្ជាទៅរំលត់អវិជ្ជា ព្រោះទីណាមានភ្លើងទីនោះត្រូវតែគ្មានទីងងឹត ទីណាមានវិជ្ជាទីនោះត្រូវ តែគ្មានអវិជ្ជា។ សព្វថ្ងៃនេះយើងបានធ្វើហើយ វិជ្ជាកើតឡើងហើយរក សម័យណាឱ្យជឿនលឿនដូចគ្មានក្នុងប្រវត្តិពង្សាវតាខ្មែរ។ ជំនាន់អង្គរ យុវជន យុវតី ចង់សិក្សារៀនសូត្រយើងមានសាកលវិទ្យាល័យបាយ័ន តែមួយប៉ុណ្ណោះដែលមានមហាវិទ្យាល័យ៥គឺ មហាវិទ្យាល័យវិចិត្រ សិល្បៈ មហាវិទ្យាល័យវេទសាស្ត្រ មហាវិទ្យាល័យស្ថាបត្យកម្ម មហា វិទ្យាល័យយោធា និងមហាវិទ្យាល័យសមាធិ ដែលគ្រប់គ្រងដោយ សាកលវិទ្យាធិការិនីព្រះអង្គម្ចាស់ក្សត្រី **តន្ត្រីរទេវី**។ បុព្វនិស្សិត ទាំងឡាយកំរនឹងបានទៅសិក្សាណាស់ ប៉ុន្តែព្រះករុណាជ័យវរ្ម័នទី៧ ព្រះអង្គធ្វើអ្វីក៏មាន ការសិក្សាអភិរក្សគ្រប់គ្រងរក្សា និងការតាមដាន

អង្កេតពិនិត្យសិក្សាមើលពីបច្ច័យល្អ និង អាក្រក់ដែលកើតឡើងពីគម្រោងរបស់ព្រះអង្គដែរមន្ទីរពេទ្យ សាលាឆទានរាប់រយសុទ្ធតែមានការថែទាំ និងមានដំណើរការល្អ។ ប៉ុន្តែជំនាន់យើងសំបូរតែអ្នកបិនសរសេររបាយការណ៍បញ្ជើចបញ្ជើរ បញ្ឆោរលើកជើង មិនសូវមានការពិតសាលារៀនដែលខំធ្វើហើយកន្លែងខ្លះគ្មានគ្រូក៏មាន កន្លែងខ្លះសិស្សចូលរៀនបានតែមួយស្រេបក់ អត់លុយបង់សាលានាំគ្នាឈប់ទៅធ្វើស្រែភ្លឺអស់ទៅ។ យើងគួរតែមានការអង្កេតពិនិត្យតាមក្រោយដែលភាសាអង់គ្លេសហៅថា ហ្វូឡូអាប់ (Follow Up) បើគ្មានការតាមដាននោះទេគឺដូចជាគេដើរបំផើមចោល នេះឯងជាការខ្វះចន្លោះរបស់យើងណាពូដែលជាហេតុធ្វើឱ្យយើងកាត់ផ្តាច់កង់ច្រវាក់នៃអវិជ្ជាចោលចេញមិនបាន។

សរុបមក ដើម្បីឈរជើងឱ្យបានហ្នឹងលើផែនដីនេះបាន គឺគ្មានអ្វីក្រៅពីការខិតខំស្វែងយល់ ដើម្បីបង្កើនចំណេះដឹងរបស់ខ្លួនតែប៉ុណ្ណោះ។ ស្រុកយើងសំបូរមនុស្សល្ងង់ ហើយត្រូវគេកាប់សម្លាប់អ្នកចេះដឹងចោលអស់ទៀតពូហ្អើយ តើផលវិបាកដ៏ធ្ងន់ធ្ងរនេះនឹងទៅជាយ៉ាងណាទៅ? ប៉ុន្តែការនេះនឹងក្លាយទៅជាងាយស្រួលទៅវិញបើយើង

មានចិត្តស្រលាញ់ជាតិពិតប្រាកដ ព្រោះអត្ថន័យរបស់ក្តីស្រលាញ់ គឺ ស្រលាញ់តែងមានការលើកលែងអត់អោន អធ្យាស្រ័យ ផ្តល់ឱកាសឱ្យ ហ៊ានតិះទៀនកែលំអរ ស្រលាញ់តែហ៊ានប្រឆាំងតប។ អញ្ចឹងមានតែ ជាតិយើងនៅខ្វះក្តីស្រលាញ់ឬក្អួយ? (**តាសនសួរផ្ទាល់**) ពូហេងបន្ត៖ ហេតុបច្ច័យនាំឱ្យខ្វះក្តីស្រលាញ់គឺនៅលើទិដ្ឋិ ការមានគំនិតខុសគ្នា យល់ឃើញខុសគ្នា ប៉ុន្តែនៅតែអាចបំបែកបានកាលបើគ្មានមានៈ ប្រកាន់ចូលរួមទេ ការដែលត្រូងប្រុងប្រយ័ត្នបំផុតនោះគឺ បិសាចតណ្ហា ដែលវាតែងតែសណ្ឋិតក្នុងចិត្តមនុស្សគ្រប់រូប ព្រោះធម្មជាតិរបស់តណ្ហា គឺជាសេចក្តីប្រាថ្នាមិនចេះឆ្អែតឆ្អន់ទៅលើមាស ប្រាក់ បុណ្យសក្តិ កិត្តិយស និងអំណាច។ ហេតុបច្ច័យទាំងនេះធ្វើឱ្យរលត់មេត្តាករុណា រលត់បញ្ញា យកខ្លួនឯងជាសត្រូវ ឯឱសថសម្រាប់ព្យាបាលជំងឺនេះគឺ គ្មានអ្វីពូកែជាងធម្មឱសថ និងពុទ្ធមន្តនេះទៀតទេ ព្រោះក្រៅពីនេះគឺខ្ញុំ គិតរកមិនឃើញឡើយ។ ហេតុនេះម៉ែវាអើយ! រស់នៅត្រូវតែចេះគិត ការ ណាគួរគិត ការណាគួរធ្វើ ការណាគួរប្រើ និងការមិនគួរ (ពូផេងពោល ទាំងមុខសួតចែស) កុំដឹងតែពីចង់បានហើយអត់ដឹងខ្យល់អីទាំងអស់ នោះ។ ធើជួយមើល៍ពូ! ជួយស្តាប់ខ្ញុំជួយធើសាក្សីផង អាក្រក់បំផុតគឺ

មនុស្សណាដែលពូកែតែខាងថាហើយមិនធ្វើតាម ពូកែតាខាងប្រដៅគេ មិនប្រដៅខ្លួនឯងសោះ ប៉ុនណាស់ខាងចាប់កំហុសគេ បានតែទ្រឹស្តី ត្រគាកស្លាប់ស្តូកនេះ ឪវាឯងបើនៅជំនាន់ប៉ុលពតម្លេះសមត្បូងចប ឡើងក្បាលបាត់ទៅហើយ លោកតាសនរហ័សលូកមាត់កាត់កុំឱ្យផ្អើលបុណ្យនាងមុំ៖ អើហ៍! ព្រះលោកថាបុគ្គលដែលចេះប្រដៅខ្លួនឯងគឺជាបុគ្គលកម្រណានាងស៊ុមហ្អើយ ឯងកុំតាមទាន់ជាន់កែងអន្ទិតផេងពេក មើលយ៉ាងណាៗក៏វាជាប្តីដែរ។ ធម្មជាតិរបស់ចិត្តវាឃ្លេងឃ្លោងពិបាកប្រដៅ ឯភាពឆ្លាតវៃរបស់បណ្ឌិតគឺការហ៊ានទទួលកំហុសហើយកែប្រែទៅ ខឹងអីជាមួយអ្នកថា បើយើងខុសមែន ត្រូវជំរុសកំហុសនោះចោលចេញ កុំរវល់តែសងសឹកគ្នា គេទិតៀនរឿយៗ ថ្ងៃណាមួយយើងនឹងឈានឡើងដល់កំពូលនៃគតិបណ្ឌិត ព្រោះដោយសារតែភាពឆ្លាតវៃក្នុងការកែប្រែរបស់យើង មានតែអ្នកដែលមិនធ្វើទេទើបមិនខុស ពាលតែងតែការពារបិទបាំងកំហុសរបស់ខ្លួនដោយការសងសឹកតបត និងបំភ្លៃ អើហ៍! រវល់តែជជែកគ្នាតើមានអ្នកណាទៅនិមន្តលោកហើយនៅហ្នឹង? មុំឆ្លើយ៖ ពូមេក្រុមគាត់ទៅនិមន្តហើយតា ។ មុំ! តាមយោបល់តា សព

ម្តាយឯងគួរបូជាម៉ោងពីររសៀលថ្ងៃហ្នឹងតែម្តងទៅឬ? តាមតែលោកតាជួយគិតខ្ញុំផងចុះ (នាងឆ្លើយតបទាំងក្តីក្រៀមក្រំ)។

ថ្ងៃជិតត្រង់ជាក់ហើយ កិត្តទាំងឡាយតាមប្រពៃណីខ្មែរក៏បានបំពេញយ៉ាងសមរម្យ សពយាយត្រូវបានគេលើកដាក់ឱ្យសម្រាន្តក្នុងការរួចជាស្រេច។ ម៉ោងជិតមួយដើម្បីកុំឱ្យបុណ្យប្រព្រឹត្តិទៅដោយឥតបញ្ញា លោកតាសនបានឆ្លៀតឱកាសនិមន្តព្រះសង្ឃសំដែងធម្មទេសនា ដើម្បីជួយលះកាត់ក្តីសោកសង្រេងរបស់ញាតិសព។ ក្រោយពីបានរៀបចំទីសេនាសនៈថ្វាយសង្ឃរួចហើយ ព្រះភិក្ខុសង្ឃដែលបានទទួលភារៈសំដែងព្រះធម៌ ក៏និមន្តឡើងគង់លើធម្មាសនៈព្រអង្គបានសំរួលឥរិយាបថ រួចព្រមពេលនិងការក្រាបថ្វាយបង្គំរបស់ពុទ្ធបរិស័ត្តប្រមាណ ២០នាក់។ មុំអង្គុយក្រោយខ្នងលោកតាសននាងផ្គុំប្រណមអញ្ជលីហើយឧទ្ទិសផលានិសង្សជូនមាតាបិតា ព្រមទាំងពពួកញាតិក្នុងសំសារវដ្តដោយក្តីជ្រះថ្លាក្នុងចិត្តៈ អ្នកម៉ែ! ដោយអំណាចផលបុណ្យដែលកូនបានបំពេញក្នុងថ្ងៃនេះ កូនសូមតាំងសច្ចៈវាចា ឧទ្ទិសបួងសួងផ្សាយផលបុណ្យ សូមឱ្យបានដល់លោកអ្នកដ៏មានគុណមានអ្នកម្តាយ និងលោកឪពុក សូមដួងវិញ្ញាក្ខន្ធលោកទាំងទ្វេរបានអនុមោទនាសំគាល់

ទទួលយកថាជារបស់នៃខ្លួនទាំងអស់នេះ បើលោកបដិសន្ធិទៅជាអមនុស្សនៅឡើយ ហើយបើមានកំណើតនៅទីណាក្រែងជាទីទាបមិនរាបស្មើយ៉ាងណា សូមកំលាំងបុណ្យនេះតាមជួយទ្រទ្រង់លោកឱ្យបានឡើងកាន់ទីខ្ពង់ខ្ពស់ ហើយបើមានកំណើតទៅកាន់ទីខ្ពង់ខ្ពស់ហើយក៏សូមផលបុណ្យនេះតាមជួយឧបត្ថម្ភ ដឹកនាំលោកឱ្យបានទៅកាន់តែខ្ពង់ខ្ពស់ឡើងទៀត គឺដើម្បីបានទៅដល់បញ្ញាវិសុទ្ធិជាបច្ច័យបានដល់ព្រះនិព្វានតែម្យ៉ាង ដែលជាការបានរួចចាកផុតទុក្ខជាអវសាន្តជាតិ។ ម្យ៉ាងវិញទៀត កូនសូមឧទ្ទិសផលនៃទាន រីផលនៃទានដែលខ្ញុំបានបំពេញហើយ ព្រះគុណអើយមានទាំងបាយសម្លរ នំចំណី ទឹកអំពៅបង្អែមចំអាបទាំងអស់នេះ ដែលខ្ញុំព្រះករុណាបានថ្វាយឧទ្ទិសចំពោះសង្ឃមានព្រះពុទ្ធជាប្រធាន ម្ហូបអាហារដែលពេញហៀរក្នុងបាត្រព្រះសង្ឃ ដែលជាបដិគ្គាហកៈមានសីលបរិសុទ្ធល្អផូរផង់លោកបានទទួល សូមតាំងសច្ចៈវាចា ឧទ្ទិសផលទាននេះសូមបានក្លាយជាអាហារដ៏ជាទិព្វប្រតិស្ឋឡើងជូនអ្នកម្តាយ កុំបីមានខ្វះចន្លោះឡើយ។ នឹកបណ្តើរបបូរមាត់មាណវីកម្រើកញ័រព្រិចៗបណ្តើរ ចំណែកឯតំណក់ទឹកភ្នែកដែលកើតឡើងដោយអំណាចបីតិចិត្ត ក៏រមៀលធ្លាក់ចេញពីប្រឡង់កែវ

ភ្នែកមូលក្រឡង់របស់នាង តំណក់ទឹកភ្នែកភ្លឺថ្លាដូចគ្រាប់ពេជ្រនេះជាតំណាងក្តីដឹងគុណដ៏ជ្រាលជ្រៅរបស់នាងចំពោះអ្នកមានគុណ។ កំពុងតែស្តុងចិត្តក្នុងការពិចារណា អារម្មណ៍នាំឱ្យវិវេគ៣កើតឡើងកាយវិវេគគឺតន្ត្រីយ៍ទាំងឡាយរបស់នាងបានសំរួមចុះក្នុងសីល រហូតដល់សីលវិសុទ្ធិ មើមួយភ្លែតដូចជាព្រះភិក្ខុនីដែលបានបួស១០០ព្រះវស្សាមកហើយ។ ចិត្តវិវេគ ជម្រៅចិត្តរបស់នាងស្ងួតស្ងប់ដូជាទឹកបឹងឥតខ្យល់ពាល់ត្រូវ នាងបានតំកល់ចិត្តជាកុសលតែម្យ៉ាងមូលឆ្ពោះកាន់អារម្មណ៍កត្តញ្ញូចំពោះម្តាយក្នុងសភាពជាសមាធិ ចិត្តស្ងប់ចុះយ៉ាងជ្រៅផុតសាកនីវរណៈធម៌ទាំង៥ហើយ ឧបធិវិវេគកំពុងតែមជំរុញជវនចិត្តឱ្យវិបស្សនាញាណប្រព្រឹត្តិទៅក្នុងមគ្គវិថីតាមលំដាប់តាំងពីបរិកម្មទៅឧបចារៈ ឆ្លងឧបចារចូលអនុលោមញាណដែលជាញាណកំណត់ឃើញច្បាស់ថា រូបនេះពិតជាមិនទៀងមែន រូបនេះពិតជាទុក្ខពិតនិងមិនមានអ្វីជារបស់ខ្លួនពិតប្រាកដឡើយ។ អំណាចវិបស្សនាញាណទាំង៣នេះញុំាងបេះដូងនាងឱ្យមានកំលាំងចំលែកដែលជាឥទ្ធិពលរបស់ហទយវត្ថុ ផ្សាយចេញនូវកំលាំងបីតិពេញសព្វសព៌ាង្គកាយធ្វើឱ្យកាយស្រាលឡើង (កាយលហុតា) ញុំាងឱ្យចិត្តលហុតាកើតឡើង កាយមុទុតាញុំាងចិត្តមុទិតា

កើតឡើង ហើយកាយបស្សទ្ធិ ចិត្តបស្សទ្ធិ បីតិបាមោជ្ជៈរឹងរឹតតែចម្រើនឡើងញុំាងអនុលោមញាណឱ្យឆ្លងចូលដល់គោត្រភូញាណ ដែលជាអរិយគោត្រ ជាខ្សែខាងដើមនៃអរិយបុគ្គលក្នុងជួរឆ្ពោះកាន់ព្រះនិព្វាន។ វាសនាមុំថាបានជួបទុក្ខក្នុងលោកសន្និវាស តែបែជាមានភ័ព្វវាសនាដោយការទ្រទ្រង់របស់ព្រះធម៌ ជម្រុញឱ្យចិត្តនាងក្លាយជាអរិយបុគ្គលទាំងមិនដឹងខ្លួន នេះក៏ព្រោះតែមានការសន្សំនិស្ស័យអំពីអ្នកម្តាយដែលលោកបានបំពេញគុណូបការៈ ឱ្យដល់នាងរាល់ពេលទំនេរពីកិច្ចការងារនារាត្រីកាល។ អំណាចបារមីធម៌ គឺបុគ្គលណាដែលបានរំពឹងស្វាធ្យាយគន់គិតត្រិះរិះពិចារណាអំពីអនិច្ចំ ទុក្ខំ អនត្តា នាំឱ្យកើតសមាធិ៣គ អនិមិត្តសមាធិ អប្បណិហិតវិមោក្ខ និងសុញ្ញតវិមោក្ខ ឬនិព្វាន៣គឺ អនិមិត្តនិព្វាន អប្បណិហិតនិព្វាន និងសុញ្ញាតនិព្វាន។ ក្នុងស្ថានភាពកន្លះភ្នែនរបស់នាង ទំរគឺសីលកំពូងឃុំគ្រងរក្សាតួកាយ គឺសមាធិ សតិនាងផ្ងង់ឡើងក្នុងការកំណត់ដឹងខ្យល់ដង្ហើមចេញ ចូល ឯកំលាំងវិបស្សនា គឺកំពុងតែដុសខាត់លាងជំរះស្នឹមអនុស័យដែលត្រាំក្នុងសន្តានដ៏យូរលង់។ ជាបណ្តើរៗ លោភៈ ទោសៈ មោហៈ ក្នុងចិត្តនាងកាន់តែស្រាលស្តើងឡើងៗ មគ្គចិត្តត្រូវផ្លាស់ប្តូរជាផលចិត្តលឿនរហ័ស

ដូចផ្លែកបន្ទោរ ការយល់ត្រូវកើតឡើង ការយល់ខុសរលត់ទៅ អវិជ្ជាសរៈត្រូវអស់កំលាំងទន់ដៃទន់ជើង ព្រោះមានវិវេគ៣ជំរុញឱ្យវិជ្ជារះឡើងបំភ្លឺចិត្តតរុណីឱ្យកាន់តែភ្លឺស្វាងឡើង ទីបំផុតឧបចារជវនត្រូវផ្តាច់ខ្សែរបស់ខ្លួន ទុកឱ្យអប្បនាជវនប្រព្រឹត្តទៅក្នុងវិថីអរិយបុគ្គលរឹតតែខ្ពស់ទៀត។ ទន្ទឹមគ្នានឹងសំលេងគ្រហែមរបស់ព្រះធម្មកថិក ក្រសែចិត្តមុំបានឡើងកាន់ថ្នាក់សកទាគាមីរួចជាស្រេចហើយចិត្តរបស់នាង ក៏បានទ្រឹងមួយរយៈដោយសារសំលេងនោះទៅព្រោះផស្សៈរមែងតែមានសំលេងជាបន្លា កុំអីមុំត្រូវបានស្គាល់ រសព្រះធម៌ក្នុងលំដាប់អារម្មណ៍ណូបណិជ្ឈាន ឬលក្ខណូបណិជ្ឈានជាពុំខាន។ ព្រះសង្ឃដីកាក៏បានបន្លឺឡើងមួយៗ ហើយស្អកស្អារបន្តិចតាមសភាពព្រះភិក្ខុជរៈ អាត្មាភាពចម្រើនពរញ្ជោមទាំងអស់គ្នា សូមឱ្យញាតិញ្ជោមបានតាំងចិត្តប្រកបដោយសោមនស្សញ្ជាណសម្បយុត្តិក្នុងការស្តាប់នូវព្រះធម៌ ដែលអាត្មាភាពនឹងសម្តែងក្នុងកាលនេះ។ សូមញាតិញ្ជោមបានសម្លឹងសភាពក្នុងក្តារមឈូសនោះថា តើគាត់មាននៅសល់អ្វីខ្លះទៀតទេ? ក្តីស្អប់ ស្រលាញ់ ភាពច្រណែននិន្ទា ការមួរម៉ៅក្តៅក្រហាយ ការចងអាឃាដព្យាបាទភាពក្រែកត្រអាលភ្លើតភ្លើន គំនុំគំគួន និងសេចក្តីប្រាថ្នាលោភលន់មហិច្ឆតា

ទាំងឡាយ យ៉ាងណាៗគឺត្រូវបានបញ្ចប់ទាំងស្រុងក្នុងគំនរភ្នក់ភ្លើងនៅពេលបន្តិចទៀតនេះហើយ។ ឆាកល្ខោនជីវិតត្រូវបានបញ្ចប់អស់មួយរឿង រងចាំកម្មនិពន្ធឱ្យលេងរឿងថ្មីៗទៀតនៅពេលដែលសិល្បៈការសិល្បៈការិនីនៅតែមានចំណងក្នុងអាជីពនេះ ម្នាក់ៗបានត្រឹមតែម៉ាលេង ឯថៅកែល្ខោនគឺ មច្ចុរាជ ជាអ្នកទទួលចំណេញកំរើ សុខទុក្ខបន្តិចបន្តួចដែលថៅកែវដ្តៈឱ្យ គឺគ្រាន់តែធ្វើឱ្យសិល្បៈការញៀនញ៉ាមក្នុងការសម្តែងតែប៉ុណ្ណោះ។ រឿងមុនដើរតួរកាត់កគេ រឿងក្រោយត្រូវគេកាត់កខ្លួនឯងវិញហើយ ខំសម្តែងយំដោកទួញអង្វរកឱ្យធម្មជាតិអាណិត ឱ្យជួយរកយុត្តិធម៌ ហើយខំលើកដៃចង្អុរគេថា គេនោះអាក្រក់ កាចឃោរឃៅណាស់ សម្លាប់តាំងពីកូនង៉ាវ អត់ដឹងក្តី អាស្រូវជួរជាតិ។ អ្នកដែលដឹងច្បាសពីសោកនាដកម្មនៃល្ខោនជីវិត រមែងលួចលោត ចោលរោងហើយរត់រកពួនជ្រកឱ្យឆ្ងាយ កុំឱ្យថៅកែល្ខោនវាតាមរកឃើញ។ អ្នកដែលមិនដឹង នៅស៊ីជោរលោតហក់តាមឆាកជីវិតដូចសត្វមានដែលគេលូកដៃស៊កក្រោមទ្រូង ហើយលើករលាក់ទ្បើងនឹកស្មានថាគេស្រលាញ់ខ្លួន ខំធ្វើភ្នែកជោរឡិកឡក់ អត់ដឹងគេលើកស្មានគីឡូដើម្បីកាប់លក់ទេ ឬដូចសត្វជ្រូកគេមុជទឹកដុសក្អែលឱ្យក៏ថ្ងូរស្រួលខ្លួនអ៊ូកៗ ហើយនឹកថា

សាច់អញ ស្បែកអញ រោមអញស្អាតលើសគេ ដល់តែគេចងជើងព្យួរ ចាក់កបានស្រែកអាក្រោសហៅគេឯងឱ្យជួយ ទីបំផុតសូម្បីតែឆ្អឹងក៏គេលក់អស់ឥតសេសសល់មានត្រង់ណានៅជារបស់ខ្លួនទៀត។ ជីវិតបថុជ្ជន គឺជនក្រាស់ដោយកាម រមែងប្រព្រឹត្តិទៅដូចជាជ្រូក ដូចជាមាន់ ដូច្នេះឯងញាតិញោម! ម៉្លេះៗគេគ្មានសតិពិចារណាពីសេចក្តីស្លាប់នេះឡើយ ពេលឮភ្លេងខ្មោចគេនឹកថាមានតែគេទេដែលស្លាប់ ឯអញគឺមិនចេះស្លាប់ឡើយ គេស្រេវឹងនឹងជីវិត និងការបានរាល់ថ្ងៃ ឥតដឹងថាខ្លួនកំពុងតែអស់អាយុរាល់ថ្ងៃដែរទេ។ ពុទ្ធដីកាត្រាស់ថា បុគ្គលដែលបានពិចារណាពីសេចក្តីស្លាប់ រស់នៅបានត្រឹមបានតែមួយថ្ងៃប្រសើរជាងបុគ្គលដែលឥតបានពិចារណាពីសេចក្តីស្លាប់ រស់ដល់រយនៃឆ្នាំ។ ដូចកាលជំនាន់ពុទ្ធកាល មានកុដុម្ពីរស្រុកស្រែម្នាក់រស់នៅមានប្រពន្ធកូននិងទាសាទាសីក្បែរជើងភ្នំផុតឆ្ងាយពីទីក្រុង។ កុដុម្ពីក:នោះតែងតែប្រៀនប្រដៅប្រពន្ធកូនឱ្យពិចារណា មរណានុស្សតិ ជារឿយៗរៀងរាល់ថ្ងៃ។ សម័យថ្ងៃមួយ វេលាដែលកុដុម្ពីរកំពុងដើរមើលស្រូវក្នុងស្រែស្រាប់តែកូនប្រុសច្បងត្រូវពស់វែកស្រងែចឹកចំបាតដៃ ហើយប្រកាច់ក្អួតឈាមស្លាប់បាត់ទៅ។ ឪពុកបានលើកត្រកងបីសពកូនប្រុសទៅដាក់

លើទីទួលម្ខាងស្រែ ហើយដើរកាច់អុសមកដាក់គរលើខ្មោចកូនរង់ចាំប្រពន្ធមកដល់នឹងបូជាសពកូន។ លុះថ្ងៃបន្តិចប្រពន្ធមកដល់ ប្តីបានប្រាប់ប្រពន្ធថា ឯងហ្នើយ! កូនប្រុសរបស់យើងវាដើរលូករន្ធក្តាមស្រែត្រូវពស់វែកស្រងែចឹកចំដៃស្លាប់បាត់ទៅហើយ។ ប្រពន្ធឥតបានយំស្រែកអ្វីឡើយក៏តបនឹងប្តីថា សពនោះលោកបងទុកនៅឯណា? ប្តីឆ្លើយថា បងផ្តេកលើគំនរអុសនៅលើទួលម្ខាងស្រែឯណោះ។ ប្រពន្ធក៏ដើរទៅមើលដោយស្ងាត់ស្ងៀម។ លុះវេលាថ្ងៃត្រង់ជាក់ នាងទាសីម្នាក់ក៏បានទូលបាយ កណ្តៀតក្អមទឹកមកជូនម្ចាស់ខ្លួននៅឯវាលស្រែ ពេលមកដល់ក៏ស្រែកប្រាប់លោកម្ចាស់អញ្ជើញពិសារបាយ។ លោកម្ចាស់ប្រាប់ថា អើហ៍នាង! លោកម្ចាស់តូចរបស់ឯង វេលាព្រឹកមិញត្រូវអាសិរពិសវាចឹកប្រហារបាត់ទៅហើយ! អញបានលើកសពអ្នកប្រុសតូចឯងដាក់នៅលើគំនរអុសជាជើងថ្កររួចស្រេចបាច់ហើយ! នាងបម្រើសួរថា តើអុសគ្រប់គ្រាន់ដែរទេលោកម្ចាស់? បើមិនទាន់គ្រប់ ខ្ញុំម្ចាស់នឹងកាច់ថែម! ហើយបូជាថ្មើរណាទៅ? លោកម្ចាស់តបថា អុសគ្រប់ល្មមនឹងឆេះសុសហើយ ចាំអញដាក់ពីភ្លែរ និងបរិភោគអាហារ រួចវេលាថ្ងៃជ្រេរបន្តិចយើងនឹងបូជាអ្នកប្រុសតូចរបស់ឯង។ នាងទាសីក៏រៀបចំ

អាហារជូនលោកប្រុសលោកស្រី លុះវេលាថ្ងៃជ្រេរពួកគេក៏រៀបចំភ្លើងបូជាលោកម្ចាស់តូចទាំងអស់គ្នាដោយឥតសម្រក់ទឹកភ្នែក សូម្បីតែមួយដំណក់។ អ្នកស្រុកអ្នកស្រែបានឃើញព្រឹត្តិការណ៍នេះហើយនាំគ្នាងឿងឆ្ងល់គ្រប់ៗគ្នាថា មាតាបិតានោះជារុក្ខជាតិទេឬ បានជាមិនចេះអាឡោះអាល័យបុត្រសោះយ៉ាងដូច្នេះ? នាងម្នាក់ទ្រាំមិនបានក៏ឈ្លួចសួរនាងទាសីថា តើម្ចាស់ឯងគ្មានបេះដូងទេឬ? ដែលកូនប្រុសច្បងកំពុងពេញស្រលាញ់ត្រូវស្លាប់ទាំងស្រស់ ហើយបែរជានាំប្តីប្រពន្ធដុតសពធ្វើព្រងើយយ៉ាងនេះ? ហើយឯងជាមនុស្សខ្លះឬទេ ដែលមិនចេះស្រលាញ់ស្រណោះចៅហ្វាយតូចដែលធ្លាប់បីពរតាំងពីតូចដូចជា មាតាយ៉ាងនេះឯងមិនយំខ្លះទេឬអី? នាងទាសីតបថា យំហ្អី? តើយំបានការអី បើលោកម្ចាស់តូចនៅក្នុងភ្នក់ភ្លើងឥតទាំងក្តៅអីផងហ្នឹង! តើយំនាំឱ្យមនុស្សស្លាប់រស់ឡើងមកវិញបានឬ? លោកម្ចាស់តូចត្រូវលោកម្ចាស់ធំយកឈើរុកទំលាយពោះ បុកបំបែកទ្រូងប្រមៀលលើភ្លើងឥតមានការឈឺចាប់អ្វីទាំងអស់ ហើយមកឈឺចាប់អីយើងដែលត្រូវស្រែកយំដូចជាកូនក្មេងឥតដឹងអ្វីនោះ? ជាធម្មតា លោកម្ចាស់របស់យើងតែងប្រទានឱវាទឱ្យពួកយើងប្រារព្ធធ្វើកម្មដ្ឋាន មរណានុស្សតិសព្វទិនទិវារាត្រី ពួក

យើងបានហាត់ស្លាប់ទាំងកំពុងរស់ ហើយត្រៀមលក្ខណៈតាមផ្លូវចិត្តរួចជាស្រេច និងព្រមទទួលយកហេតុការណ៍នោះបានគ្រប់ពេលឥតមានរង្គៀសចិត្តអ្វីឡើយ សេចក្តីស្លាប់គឺជាមរតករបស់យើងគ្រប់គ្នា ការដែលត្រឹមត្រូវគឺត្រូវរួតរះបំពេញសេចក្តីល្អឱ្យបានហើយជាស្រេច កុំរង់ចាំដល់ថ្ងៃស្អែក ព្រោះថ្ងៃស្អែកគ្មានអ្នកណាដឹងថាមានអ្វីកើតឡើងខ្លះចំពោះយើងគ្រប់គ្នានោះទេ។ ការយំស្រណោះអ្នកដែលបានចែកឋានទៅហើយ គឺដូចជាកូនក្មេងយំទាក្តាយព្រះច័ន្ទ តើអំពើរនោះសមចំពោះយើងឬទេ? ការចេះថែទាំ ពេលវេលានៅពេលកំពុងមានការរស់នៅជួបជុំឯនោះទេទើបជាការត្រឹមត្រូវ កុំចាំដល់ស្លាប់ទើបស្តាយក្រោយថា មិនបានធ្វើអំពើរល្អដល់គ្នានិងគ្នា ពេលរស់នៅត្រូវចេះអត់អធ្យាស្រ័យដល់គ្នា ត្រូវចេះចែករំលែកសេចក្តីស្រលាញ់ ចេះរួមសុខរួមទុក្ខជាមួយគ្នា កុំសំងំសុខយករួចខ្លួនតែឯង ត្រូវចេះធ្វើបុណ្យដាក់ទាន ព្រោះគ្មានអ្នកណាយកអីបានពីលោកនេះទៅទេ។ នាងទាសីពន្យល់អ្នកស្តាប់ប្រកបដោយគតិបណ្ឌិត ហើយសរុបសេចក្តីដោយពុទ្ធគាថាថា ធម៌រមែងគ្រប់គ្រងរក្សាអ្នកប្រព្រឹត្តិធម៌ដូច្នេះឯង។ តើញាតិញោមអាចធ្វើចិត្តយ៉ាងនេះបានទេ បើគ្មានកម្មដ្ឋានជាបង្អែកសម្រាប់ជីវិតឱ្យបានរឹងមាំទេ

នោះ? កុំសោយសុខដោយឥសតិ ព្រោះសុខនោះវាមិនទៀងទេ្បីយ អាត្មាក៏ជាអ្នកធ្លាប់សិក្សារៀនសូត្រវិជ្ជាផ្លូវលោកខ្លះដែរ តាមពិតគឺជាវិជ្ជាក្នុងពុទ្ធសាសនា ព្រះលោកបានស្រាវជ្រាវរំពឹងរាវរកដោយសព្វញ្ញុតញ្ញាណឃើញអស់ឥតសេសសល់អ្វីទេ្បីយ ប៉ុន្តែធម៌ខ្លះព្រះលោកទ្រង់មិនពន្យល់ ព្រោះមិនមែនជាធម៌ចាកចេញទុក្ខ ហើយអាចនាំឱ្យមនុស្សវង្វេងរាយមាយបាន។ កំណកំណើតជីវិត ព្រះលោកសម្តែងគឺចាប់តាំងអំពីរូបធាតុដ៏តូចល្អិតដែលជាមេជីវិតស្ថិតក្នុងសុក្កៈរបស់បិតា ទៅផ្សំផ្គុំនឹងមេជីវិតរបស់មាតាក្នុងដៃស្បូន ហើយចាប់ផ្តើមពីធាតុបរមាណូដ៏តូចល្អិតទាំងពីរ សម្ព័ន្ធកូវ៉ាឡង់របស់ធាតុគីមីក៏ចាប់តោង ផ្តើមចាប់ភ្ជាប់ចងក្រងគ្នា ហើយបង្កើតបានជាគំនររូបដែលមានសមុដ្ឋានអំពីកម្មដែលបុគ្គលបានសាងហើយពីអតិតជាតិ ព្រះលោកឱ្យឈ្មោះថា កម្មជរូប អំពីឧតុហៅថា ឧតុជរូប អំពីអាហារមាតាហៅថាអាហារជរូប កងគំនររូបនេះជាអាស្រ័យនៃបញ្ចវិញ្ញាណហើយធ្វើឱ្យបញ្ចវិញ្ញាណចម្រើនឡើង ចក្ខុវិញ្ញាណ សោតវិញ្ញាណ ជីវ្ហាវិញ្ញាណ និងកាយវិញ្ញាណ។ ប៉ុន្តែព្រមពេលនៃការកើតឡើងនៃកងរូប និងកងវិញ្ញាណទាំងនេះ គឺមនោវិញ្ញាណឬចិត្តរបស់សត្វបានមកចាប់បដិសន្ធិក្នុងផ្ទៃម្តាយ រួចជាស្រេចហើយដែរ

ព្រោះក្នុងបដិច្ចសមុប្បាទធម៌ ពន្យល់បកស្រាយថា៖ អវិជ្ជាជាបច្ច័យដល់សង្ខារដោយការមិនដឹង ចតុរារិយសច្ចៈ គឺមិនដឹងហេតុរបស់ទុក្ខ មិនដឹងថាជាទុក្ខ មិនដឹងទីរលត់ទុក្ខ និងមិនដឹងកិច្ចបដិបត្តិដើម្បីរំលត់ទុក្ខ ទើបត្រូវតាក់តែងកម្មឱ្យមានវិបាកជាប់ក្នុងភពគឺអភិសង្ខារដែលមានបុញ្ញាភិសង្ខារតាក់តែងឱ្យជាប់ក្នុងកាមភបមានមនុស្ស ទេព្តា និងរូបព្រហ្ម អបុញ្ញាភិសង្ខារតាក់តែងឱ្យធ្លាក់ក្នុងអបាយភូមិ៤មាន **នរក ប្រេត តិរិច្ឆាន និងអសុរកាយ** ជាប់ក្នុងអនេញ្ជាភិសង្ខារ បានដល់អរូបព្រហ្ម ឬអរូបភព។ សង្ខារជាបច្ច័យដល់វិញ្ញាណ៖ វេលារៀបស្លាប់ដួងវិញ្ញាណទី១ គឺពួកបញ្ចវិញ្ញាណត្រូវរលត់មុន ហើយវាបានប្រគល់អារម្មណ៍ធំតាមទ្វាណាមួយ ដែលសន្សំច្រើនជាងគេទៅឱ្យមនោទ្វារដែលជាដួងវិញ្ញាណទី២ ហើយដួងវិញ្ញាណទី២ បានតោងយកអារម្មណ៍នោះទៅធ្វើបដិសន្ធិ អាស្រ័យតាមកម្លាំងកម្មដែលខ្លួនបានសន្សំមកនោះ។ បើសិនអារម្មណ៍នោះកើតក្នុងមនោទ្វារ វាគឺជាអារម្មណ៍ដែលផ្តល់ដោយកម្លាំងពីអតិតជាតិ ហេតុនេះហើយបានជាយាយតាខ្លះជាតិនេះគាត់រក្សាសីល តាំងពីក្មេងតែវេលារៀបស្លាប់បែជាពិបាក ព្រោះអកុសលវិបាកវាផុសឡើងមកបាន ដោយសារបយោគៈដែលជាការ

ប្រព្រឹត្តិរឿយៗរបស់យើងមិនខ្ជាប់ខ្ជួនក្នុងកុសលធម៌ ឯអារម្មណ៍ដែលកើតឡើងតាមបញ្ចទ្វារ គឺជាអារម្មណ៍ដែលយើងបានសន្សំក្នុងបច្ចុប្បន្ជាតិនេះឯង ព្រោះហេតុនេះជីវិតគឺចប់ហើយត្រឹមអំពើល្អ ធ្វើអាក្រក់គឺជាការបើកអបាយភូមិឱ្យខ្លួនឯង។ ជាក់ស្តែងវេលាសត្វរៀបស្លាប់គឺវិញ្ញាណដែលកើតឡើងតាមផ្លូវភ្នែកត្រចៀក ច្រមុះ អណ្តាត កាយ ត្រូវរលត់មុន ភ្នែកនៅបើកត្រចៀកនៅចំហរតែមើលលែងស្គាល់កូនចៅប្តីប្រពន្ធ ស្តាប់លែងលឺឬលឺខ្លះតែគាំងថ្កាមនិយាយលែងរួចតែចិត្តឬមនោទ្វារនៅតែប្រព្រឹត្តិទៅមិនទាន់រលត់ បើអ្នកគ្មានធម៌រមែងភិតភ័យតក់ស្លុតរន្ធត់ញាប់ញ័រ ឯអ្នកធ្លាប់បានសិក្សារៀនសូត្រព្រះធម៌រមែងបានព្រះធម៌ជាទីពឹងគឺកំណត់វេទនា ឬតោងយកអារម្មណ៍កម្មដ្ឋានជាបង្អែកណាមួយដែលខ្លួនធ្លាប់ហ្វឹកហាត់ ចម្រើនបានស្ទាត់ជំនាញមកហើយរមែងបិទអបាយភូមិបាន។ វេលាដែលមនោវិញ្ញាណបានត្រូវរលត់ថាមពលចិត្តដែលជាថាមពលអគ្គីសនីរបស់ខួរក្បាលត្រូវផ្សាយចេញ ហើយផ្អែកលើអាកាសលោកជាលោកវិថីនាំទៅតាមចេតនាកម្ម ទៅរកទីកំណើតជាថ្មីតាមកម្មនិយាម ដែលខ្លួនបានសន្សំទុកជានិស្ស័យសាងជាសំណាងវាសនាក្នុងភពថ្មីទៀត។ ថាមពលចិត្ត ឬថាមពលអគ្គីសនី

របស់ខួរក្បាលនេះឯងដែលព្រះលោកឱ្យឈ្មោះថា វិញ្ញាណ សាសនាព្រាហ្មណ៍ហៅថា ព្រលឹង ឬអាត្មន ខ្លះហៅថា ភូត ឬចេតភូត ពេលណាដែលវាសំងំជ្រកក្នុងគុហាគឺមហាភូតរូប៤លែងបានតទៅទៀត ហើយ វាក៏ចាកចេញរកលំនៅថ្មី ហេតុនេះហើយបានជាមនុស្សចាស់ខ្លះដែលកំពុងដេកឈឺធ្ងន់នៅឡើយ ស្រាប់តែមានកូនក្មួយសុបិន្តឃើញគាត់ទៅសុំនៅជាមួយ ឯរូបគាត់ក៏ត្រូវធ្វើមរណកាលតាមក្រោយទៅ។ មរណកាលបែបនេះគឺមិនសូវលែងគេទេ ព្រោះចេតភូតបានរកទីតាំងនៅបានហើយ ចំណែកឯបុគ្គលែលត្រូវស្លាប់ទាន់ហន់ភ្លាមៗចេតភូតមិនទាន់រកកន្លែងនៅបានទើបចេះតែបង្ហាញខ្លួនឱ្យគេឃើញជារឿយៗ ហើយដែលអ្នកស្រុកនិយមហៅថាខ្មោចលងនេះឯង។ ថាមពលចិត្ត ឬថាមពលអគ្គីសនីនេះ មិនត្រូវបានរលាយចូលទៅក្នុងធម្មជាតិដែលជាថាមពលបរិសុទ្ធនៃសកលចក្រវាឡ វិទ្យសាស្ត្រហៅថា កូស្មិចអឺណែជី (Cosmic Energy) នោះទេ ព្រោះវាប្រកបដោយថាមពលមិនបរិសុទ្ធខ្មៅក្រខ្វក់ ប្រកបដោយចេតនា និងតណ្ហា ហេតុនេះវាត្រូវតែនៅវិលវល់ឱ្យបានជាកំណើតក្នុងភពរួចតាំងនៅក្នុងទុក្ខជាបន្តទៀត ព្រោះត្រូវភាពមិនទៀងបៀតបៀនរឿយៗ។ បុគ្គលណាមានវិជ្ជាបានដឹងរឿងរ៉ាវនេះ

ជាក់ប្រាកដ ហើយជិនឆ្អន់នឿយណាយ និងកំណើតថ្មីដែលមានតែទុក្ខ រមែងខំរក្សាចិត្តឱ្យប្រាស់ចាកមន្ទិលសៅហ្មង ធ្វើចិត្តឱ្យបរិសុទ្ធផូរផង់ រលត់អវិជ្ជា តណ្ហា ចេតនា ដែលជាគ្រាប់ពូជក្នុងអស់ហើយ ពេលនោះ ថាមពលចិត្ត ឬថាមពលអគ្គីសនីរបស់ខួរក្បាលដែលផ្សាយចេញពេលស្លាប់រមែងឆក់ស្រូបចូលទៅក្នុងថាមពលនៃចក្រវាឡ ហើយលែងត្រឡប់មកកើតទៀត នេះឯងជាវិធីយាងចូលបរមនិព្វាននោះ។ សង្ឃដីកាមិនទាន់បានបញ្ចប់ស្រួលបួលផង ស្រាប់តែមុំមានអារម្មណ៍ថាក្នុងពោះត្រូវបុកដោលចេញពីក្នុងមក ធ្វើឱ្យនាងចង់រកកលក្អួតចង្អោរព្រោះការបញ្ចូលចិត្តស្រាប់តាមក្រសែធម៌ ធ្វើឱ្យនាងខ្ពើមឆ្អើមជីវិតលោកិយរបស់នាង ដែលត្រូវរស់ទ្រាប់ក្រោមកម្រាស់ទ្រូងរបស់មនុស្សសុនខច្រើនប្រភេទឥតរើសមុខព្រោះតែប្រាក់ នាងសម្រួលស្ថានភាព រំងាប់បដិកូលគួរខ្ពើមនោះចោលចេញ ដោយកំណត់ដឹងតាមខ្យល់ដង្ហើមជាបន្តទៀត ដើម្បីស្តាប់ព្រះធម៌។ លោកតាសង្ឃទេពបានលើកកែវទឹកក្រែបផ្សើមបំពង់កន្តិច ក៏ជាប់មានសង្ឃដីការបន្ត៖ តាមពិតទៅរូបកាយរបស់មនុស្សបើតាមទ្រឹស្តីអគ្គីសនី គឺគ្រាន់តែជាដុំមេដែកមួយដែលមានចលនាអាស្រ័យកំលាំងវាយោធាតុកើតឡើង ដោយសារតែមានចិត្តជា

សមុដ្ឋានហៅថា ចិត្តជ្ជវាយោធាតុ នាំឱ្យកាយកម្រើកបានជាឥរិយាបថធំតូច ដូចជាអាយ៉ងដែលគេកន្ត្រាក់ខ្សែឱ្យមានចលនាដូច្នេះដែរ កាលណាចិត្តរលត់ កាយវិការផ្សេងៗក៏រលត់ព្រោះលែងមានការផ្សាយទៅនៃវាយោធាតុ ការអស់វាយោធាតុក្នុងរូបកាយនាំឱ្យបែកធាតុផ្សេងៗ ហើយបានជាតិអង់ស៊ីមរំលាយជាតិសាច់របស់រូបកាយ បែកចេញមករំលាយឱ្យហើមរលួយព្រមនឹងល្បឿងរបស់ពួកបាក់តេរីផង កាយនេះក៏ត្រូវប្រគល់ឱ្យធម្មជាតិវិញជាធម្មតា។ តើត្រង់ណាទៅយើង? ត្រង់ណាជារបស់យើង? អត្តភាពបុគ្គលគ្រប់រូបគ្រានត្រឹមតែជាខន្ធ៥ មិនលើសមិនខ្វះ ស្តេចមន្ត្រីសេដ្ឋី អ្នកមានអ្នកក្រ ប្រណីតថោកទាប មានត្រឹមខន្ធ៥ដូចៗគ្នា តើយើងត្រូវមកចង់បានអីឱ្យលើសនេះទៀត? ក្នុងរូបក្ខ័ន្ធ តើមានអំណាចយើងនៅក្នុងនោះទេ? បើមានម្លេះយើងអាចឃាត់ឃាំង កុំឱ្យរូបចាស់ កុំឱ្យឈឺ កុំឱ្យស្លាប់បានហើយ ឯនាមក្ខ័ន្ធផ្សេងទៀតក៏ដូចគ្នា ចង់វាកើតក៏កើតឡើង ព្រោះមានហេតុបច្ច័យនាំឱ្យកើត រលត់ទៅក៏ព្រោះមានហេតុបច្ច័យនាំឱ្យរលត់វាមិនឋិតក្រោមអំណាចរបស់យើង គឺបង្គាប់បញ្ជាមិនបានឡើយនេះហៅថា អនត្តា។ និយាយពីដុំរូបកាយដែលធម្មជាតិបានតាក់តែងឡើងជារបស់ធម្មជាតិសុទ្ធៗ តែពេលដែលវិញ្ញាណ

កើតឡើងទទួលដឹងឮក៏ចាប់ប្រកាន់មាំទៅតែម្តងថា អ្វីៗជារបស់ខ្លួន ដែលតាមពិតជារបស់ធម្មជាតិសោះ តែចិត្តដ៏អាស្រូវរបស់យើងចង់លួចយករបស់គេមកប្រចុបប្រចែងតុបតែងធ្វើជារបស់ខ្លួន ដល់គេត្រូវយករបស់គេទៅវិញតាំងភិតភ័យតក្តមា ខំស្វែងរកវិធីបិទបាំងការពារហួងហែងទុក តើជាហានៈទេ? បើក្នុងកាយនោះវាមានធម្មជាតិដែលបំផ្លាញគ្នាស្រាប់គ្នាពីក្នុងនោះមកហើយហ្នឹង! បើត្រូវជាពួនសំងំនៅក្រហែងថ្មដាណាក៏ចៀសស្លាប់មិនរួច នៅតែក្រវិលចូលក្នុងភវចក្រកើតចាស់ ឈឺ ស្លាប់កើត កើតស្លាប់ វិលទៅជាប់តែយ៉ាងនេះ។ អរិយបុគ្គលសង្កេតឃើញថា នៅលើតំណរសង្សារវដ្តនេះបើយើងមានការប្រកាន់មិនព្រមវិលទៅមុខតាមចរន្តធម្មជាតិទេ នោះនឹងមានទុក្ខធំជាមិនខាន ហេតុនោះនៅលើចំនុចណាមួយនៃវង្វិលដុំនេះ គឺមានតែលះការប្រកាន់ចោលចេញ ហើយទុកឱ្យធម្មជាតិជាអ្នកចាត់ចែងទាំងអស់ទៅចុះ ធ្វើឱ្យជីវិតយើងលែងកង្វល់ហើយផុតក្តីទុក្ខអំពុល ព្រោះមានការអស់កង្វល់នេះជាទីពឹង។ ច្បាប់អន្តរកម្មក្នុងធម្មជាតិបានថ្ពិនភ្នែកយើងដោយតាក់តែងឱ្យកើតជាទឹក គឺតាមពិតអាតូម អ៊ីដ្រូសែនពីរចាប់អាតូមអុកស៊ីហ្សែនមួយសោះ សូដ្យូម ភ្លើងជាធាតុក្តៅដែលបានពីចំហេះពួកផូស្វ័រ

កាបូន អ៊ីដ្រូសែន បង្កុំអ៊ីដ្រុកស៊ីល ជាមួយអុកស៊ីហ្សែនអប់អ៊ុន ដល់ធាតុផ្សេងៗទៀតកុំឱ្យបែកធ្លាយ វាយោធាតុដែលជាចរាចរណ៍របស់ពពួកឧស្ម័នផ្សេងៗ បូកផ្សំឱ្យបានជាសាច់ឈាមរាងកាយសត្វឡើង ហើយមានចំហាយអគ្គីសនីរត់ពាសពេញសព្វសព៌ាង្គកាយ។ ហេតុនេះ រាងកាយរបស់មនុស្សម្នាក់ៗ សុទ្ធតែមានថាមពលអគ្គីសនីផ្សាយចេញ និងស្រូបចូលមកវិញជាធម្មតា ការផ្សាយចេញ និងស្រូបចូលនេះ សុទ្ធតែមានផ្នែកល្អ និងអាក្រក់ដូចគ្នា។ ការផ្សាយចេញផ្នែកល្អ ថាមពលចិត្តរបស់បុគ្គលខ្លះសំបូរទៅដោយមេត្តាករុណា ការផ្សាយចេញទៅធ្វើឱ្យអ្នកដទៃមានការចាប់ចិត្ត ទឹកមុខមានអំណោយទានគួរឱ្យ គោរពស្រលាញ់ដូចជាព្រះពុទ្ធ ដែលចិត្តរបស់ព្រះអង្គអស់អាសវៈ មានតែមហាករុណាថាមពលផ្សាយចេញដ៏អស្ចារ្យ អាចគ្របសង្កត់ទឹកចិត្តដែលមិនល្អឱ្យស្ងប់លែងមានប្រតិកម្មតបតបាន ដូចជាពេលអង្គុលីមារបានចូលជិតព្រះអង្គ ប្រៃជាទន់ជង្គង់រកប្រព្រឹត្តិអំពើរអាក្រក់មិនកើត ព្រោះត្រូវអំណាចថាមពលចិត្តរបស់ព្រះអង្គ ផ្សាយចេញទៅរំងាប់ចិត្តដែលរំជួលញាប់ញ័រនោះឱ្យស្ងប់ស្ងាត់បាន ក៏ដូចជាពេលដែលព្រះអង្គផ្សាយមេត្តាចិត្តទៅកាន់ដំរីនាឡាគីរីដូច្នោះដែរ។ ថាមពលចិត្តស្ងប់គឺ

អាចផ្សាយចូលទៅក្នុងសកលចក្រវាឡបានយ៉ាងទូលំទូលាយ ព្រោះហេតុនេះ ទើបព្រះឱ្យយើងធ្វើបុណ្យជាមួយអ្នកដែលមានចិត្តស្ងប់ ទើបបានផលបុណ្យច្រើន ព្រោះវេលាលោកផ្សាយមេត្តាដើម្បីឧទ្ទិសបុណ្យ គឺពពួកញាតិដែលបានចែកឋានទៅ អាចអនុមោទនាបានយ៉ាងពេញទំហឹង ទោះជាវិញ្ញាណពពួកញាតិទាំងនោះតាំងនៅលោកធាតុឆ្ងាយយ៉ាងណាក៏ដោយ។ គេអាចសំគាល់ឃើញពេលដែលញាតិរបស់យើងដែលរស់នៅឆ្ងាយពីយើងមានទុក្ខកង្វល់ដូចជា ឈឺធ្ងន់ជាដើម ធ្វើឱ្យយើងទទួលទានដំណេកមិនលក់ពេញមួយយប់ក៏មាន។ គេអាចផ្សាយឧទ្ទិសផលបុណ្យដល់ពពួកញាតិ ដែលមានជំងឺជាទំងន់ឱ្យធូរស្រាលបាន ឬផ្សាយថាមពលតាមបាតដៃឱ្យមនុស្សម្នាក់ដេកលក់បានយ៉ាងស្រួល។ ការផ្សាយចេញផ្នែកមិនល្អដូចជាផ្សាយចិត្តចងពៀរ ការដាក់ប្រទេចផ្តាសារចំពោះមនុស្សម្នាក់ បើយើងមិនបានធ្វើខុសដោយចេតនាទេនោះ ថាមពលចិត្តអាក្រក់មិនអាចបំផ្លាញយើងបានឡើយ ប៉ុន្តែបើយើងមានចេតនាអាក្រក់ពិតមែននោះ បណ្តាសារអ្នកដទៃប្រាកដជាអាចបំផ្លាញយើងបានជាក់ជាមិនខាន។ ការស្រូបចូលដែលល្អ ចិត្តអ្នកខ្លះស្រូបចិត្តអ្នកដទៃឱ្យគេអាណិតស្រលាញ់គោរពរាប់អាន។ ថាមពល

ចិត្តបរិសុទ្ធ គឺអាចស្រូបថាមពលបរិសុទ្ធនៃសកលចក្រវាឡបានច្រើនជាងគេ ធញ្ញវើឱ្យកើតមានសភាវៈទ្រទ្រង់ចម្រើនឡើងក្នុងរាងកាយរបស់គេ វាបានជួសជុលព្យាបាលចរន្តភ្លើងដែលគាំងនាំឱ្យខ្វិនពិការផ្នែកណាមួយនៃរាងកាយឱ្យបានធូរស្បើយឡើងវិញ ជួសជុលការស្ទះចរន្តឈាមឱ្យមានការស្រោចស្រពឈាមឱ្យប្រសើរឡើងវិញ ព្រោះហេតុនេះទើបអ្នកចម្រើន សមថវិបស្សនាច្រើនតែមានអាយុវែង ហើយមានសុខភាពល្អពេលស្លាប់ក៏ស្រួល មិនលំបាកដូចអ្នកមានចិត្តជាប់ជំពាក់ក្នុងលោកនេះទេដែលពេលស្លាប់ត្រូវនៅអណ្តឹតអណ្តកយូរក្រជាច់ខ្យល់ ត្រូវនៅឱ្យពេទ្យគេចាក់ដោត គេរុកឆ្កៀលដោយទុយោផ្សេងៗពេញមាត់ច្រមុះនិងទ្វាធំតូច។ ថាមពលស្រូបចូលមិនល្អ អ្នកខ្លះដែលមានចិត្តអាក្រក់មិនទាន់បានធ្វើអ្វីគេផង ត្រូវគេស្អប់មុនបាត់ទៅហើយ គេមិនចង់រាប់រក គេចង់តែធ្វើទុក្ខបុកម្នេញជាដើម។ ព្រះពុទ្ធលោកឃើញហើយដឹងសព្វឥតចន្លោះ ទើបលោកបង្កើតវិជ្ជា៨ប្រការឡើងប៉ុន្តែត្រូវមានវិបស្សនាញាណដើម្បីបន្សុទ្ធចិត្តខ្មៅអាក្រក់ឱ្យថ្លាស្អាតអស់សិន ទើបបានកើតមនោយិទ្ធិ ភ្នែកទិព្វ ត្រចៀកទិព្វ តាមក្រោយហើយអាចឃើញការចម្រើនឡើងនៃកប្ប និងការវិនាសទៅនៃកប្បគួរឱ្យនឿយណាយឆ្ងាយចាកសង្សារវដ្ត

ដែលមានតែទុក្ខពុំគួរនែបនិត្យតទៅទៀត។ ការឃើញច្បាស់ ដឹងច្បាស់ដោយខ្លួនឯងយ៉ាងនេះចិត្តក៏បានប្រាស់ចាកអកុសលធម៌ លែងប្រលាកប្រទ្ឆសអំពីលាមកតទៅទៀត ប្រៀបដូចជាសុបិន្តនិម្មិតរបស់ព្រះពុទ្ធដែលឃើញព្រះអង្គនិមន្តចង្រ្កមឈរលើលាមក ប៉ុន្តែមិនបានប្រលាក់ព្រះបាទរបស់ព្រះអង្គឡើយយ៉ាងដូច្នេះឯង។ ហេតុនេះ ព្រះពុទ្ធសាសនាជាសាសនាដែលប្រកបនាទីប្រដៅចិត្ត ព្រោះធម៌ទាំងឡាយមានចិត្តជាធំ ធ្វើបានសម្រេចក៏ព្រោះចិត្ត ព្រោះធម៌ទាំងឡាយមានចិត្តជាធំ មិនបានសម្រេចក៏ព្រោះចិត្ត។ យើងឃើញហើយថាសិស្សសាលាដែលមានវ័យស្របាលគ្នា កំពស់កំពរប៉ុនគ្នា ខួរក្បាលមួយត្រឡោកដូចគ្នា ចុះហេតុអីក៏មានសិស្សពូកែធ្វើកិច្ចការបានល្អជាងគ្នា? នេះមិនមកពីអំណាចចិត្តដែលជាការតាំងចិត្តដ៏ល្អរបស់គេ ឆ្លងតាមរយៈការអប់រំតាំងពីអតីតជាតិមកខ្លះទេឬ? ហាមពលចិត្តដែលយើងបានហ្វឹកហាត់អប់រំដោយបញ្ញាបានល្អ ហើយរមែងនាំមកនូវសេចក្តីសុខ គឺសុខឆ្ងាយចាកទុក្ខ សុខព្រោះអស់ការប្រកាន់ក្នុងភពវាផ្ទុយពីសុខក្នុងលោកដែលបានមកដោយសារទុក្ខ គេមានទុក្ខខ្លាំងណាស់ទើបបានទទួលក្តីសុខរហូតដល់ថ្នាក់បង្កពៀរទៀតផងក៏មាន។ ដើម្បីទទួលបានក្តីសុខពិតគឺគេ

លែងប្រកាន់តាំងពីទីដេកទីជ្រកអាស្រ័យ លែងប្រកាន់ក្នុងក្លិនក្នុងរស ក្នុងសម្ផស្ស ការពាល់ត្រូវកាយដោយត្រជាក់ក្តៅរឹងទន់ជាដើមទៅ។

១-**តាមសម្មតិសច្ចៈ សម្មតិមរណៈ** គឺសេចក្តីស្លាប់ដោយសន្មត់ថា មានសត្វបុគ្គលជាអ្នកស្លាប់ ព្រោះគេលែងរកឃើញបុគ្គលនោះនៅលើផែនដីនេះតទៅទៀត ហើយកាលប់គាត់បានរំលត់ខន្ធពីលោកនេះទៅហើយ។ ក្នុងនេះព្រះលោកចែកជា៖ **កមរណាកាល**- គឺជាសេចក្តីស្លាប់ដោយអស់អាយុ និងអស់បុណ្យស្លាប់តាមកាលអាយុក្ខ័យរបស់គាត់ដោយ ជរា ព្យាធិមរណៈ។

ខ-អមរណាកាល គឺជាសេចក្តីស្លាប់មិនតាមកាលដោយអស់បុណ្យ ព្រោះត្រូវឧបឃាតកម្ម ឬអកុសលកម្មឯណានិមួយដែលខ្លួនកាត់ផ្តាច់សង្ខារសត្វឱ្យឃ្លាតចេញទៅ ដូចជាស្លាដោយទាន់ហន់ស្លាប់ទាំងក្មេង ដោយជំងឺដំកាត់ជាដើម ឧទាហណ៍៖ យើងសង្កេតឃើញថា ពេលរដូវគ្រុនឈាមរាត្បាត ក្មេងឈឺដំណាលគ្នាមានកម្រិតធ្ងន់ធ្ងរហូរឈាមដូចគ្នា ប៉ុន្តែហេតុអីក៏មានក្មេងខ្លះស្លាប់ ខ្លះរស់ តើនេះមិនអាស្រ័យលើកម្មរបស់គេបានសាងមកទេឬ? បើយើងមិនដឹងក៏ស្មានថា គឺមកពីការធ្វេសប្រហែសនាំឱ្យមានកំហុសនេះកំហុសនោះកើតឡើង ហើយឈឺចាប់ក្នុង

ចិត្តខ្លួនឯង តែតាមពិតគឺតុលាការកម្មសោះជាអ្នកមមកផ្តាច់ផ្តិលអាយុជីវិតសត្វនោះ។

គ-ខណិកមរណៈ ជាសេចក្តីស្លាប់ជាខណៈៗ តាមពិតជីវិតសត្វលោកគឺជាតំណនៃសង្ខារធម៌សុទ្ធៗ យើងស្លាប់រាល់តែដង្ហើមតែដោយសេចក្តីស្លាប់នេះវាកើតឡើងលឿនរហ័សពេក ធ្វើឱ្យបញ្ញាយើងមិនអាចកំណត់បានព្រោះត្រូវជាប់ដោយការប្រកាន់មាំ យើងកើតមកជាកូនង៉ា ហើយរូបកូនង៉ានោះត្រូវស្លាប់បាត់អស់ទៅ ហើយវាបានប្តូរមកជារូបកុមារាកុមារី ហើយរូបកុមារាកុមារីទាំងនោះក៏ស្លាប់បាត់អស់ទៀតដូរជាយុវជនយុវនារី បន្ទាប់មករូបយុវជនយុវនារីនោះក៏ត្រូវស្លាប់បាត់អស់ទៀត រូបកំលោះក្រមុំក៏ស្លាប់បាត់អស់ទៀតយប់ថ្ងៃផ្លាស់ប្តូរវេនគ្នាជាប់យ៉ាងរន្ថែន ចំណែកឯរូបយើងកំពុងតែស្លាប់ញាប់ស្មេរគ្រប់ដង្ហើមចេញចូល ចិត្តកើតរលត់តាមបញ្ចទ្វា១៧ខណៈរូបរលត់មួយ គឺកោសិកាមេមួយត្រូវបានបំបែកទៅជាពីរ ចេញជាកោសិការថ្មីដែលមានសភាពចាស់ទ្រុឌទ្រោមទៅជាបណ្តើរៗ ព្រោះត្រូវសឹករចរិលក្នុងផ្នែក ឪអិនអេរបស់វា។ ឱយើងហ្អើយយើង! តើមានយើងត្រង់ណាទៅញោម? យ៉ាង

ម៉ែចក៏ប្រកាន់មាំខ្លាំងម្លេះកាប់សម្លាប់ហុតឈាមគ្នាខ្លាំងម្លេះ អញខ្លាំងម្លេះ?

ឃ- សមុច្ឆេទមរណៈ ជាសេចក្តីស្លាប់ដែលលែងកើតឡើងទៀត ជាការស្លាប់របស់អ្នកអស់អវិជ្ជានិងតណ្ហា។

២- តាមបរមត្ថសច្ចៈ សេចក្តីស្លាប់ដោយបរមត្ថៈ តាមពិត គឺអត់មានសត្វបុគ្គលណាជាអ្នកស្លាប់សោះ គឺគ្រាន់តែជាការបែកធ្លាយនៃខន្ធទាំងឡាយ៥តែប៉ុណ្ណោះ បើនៅតែមានចេតនាកម្មប្រកបដោយលោភៈ ទោសៈមោហៈ នោះជវនចិត្តនៅតែអន្ទោលទៅកើតទៀតអាស្រ័យអំណាចកម្មដែលខ្លួនបានធ្វើ បានសាងសន្សំដោយខ្លួនឯង។ បំណកស្រាយនេះ គឺនៅចន្លោះទិដ្ឋិខុសពីប្រការដែលជាសង្ខេបពីទិដ្ឋិទាំង៦២ មុនព្រះពុទ្ធបានត្រាស់ដឹងឡើងក្នុងលោក។

ក- សស្សតទិដ្ឋិ ក្រុមលទ្ធិខ្លះគេយល់ថាអាត្មនឬព្រលឹង គឺទៀតទាត់ឥតប្រែប្រួល ស្លាប់ពីឆ្កែត្រូវទៅកើតជាឆ្កែបន្តទៀត ស្លាប់ពីមនុស្សត្រូវទៅកើតជាមនុស្សបន្តទៀត ស្លាប់ពីទេវតាត្រូវទៅកើតជាទេវតាបន្តទៀត មនុស្សមិនអាចស្លាប់ទៅកើតជាឆ្កែបានជាដាច់ខាត។ លទ្ធិនេះត្រូវបានព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់បដិសេធ ព្រោះខុសពីច្បាប់ធម្មជាតិ

ដែលតាមពិតការកើតស្លាប់ សុទ្ធតែអាស្រ័យកម្មដែលខ្លួនបាសាងឡើងទាំងអស់ ហើយត្រូវបិតក្រោមអនិច្ចតាធម៌នៃសកលចក្រវាឡ។

ខ- ឧច្ឆេទទិដ្ឋិ ក្រុមលទ្ធិខ្លះយល់ថា ស្លាប់ទៅសូន្យលែងមានអ្វីកើតទៀតហើយ រូបកាយដែលស្លាប់គឺក្លាយជាត្រីអាំងសុទ្ធៗ លែងមានបាតុភូតអ្វី ឬចរន្តអ្វីកើតឡើងនាំឱ្យមានការបន្តនូវនិរន្តរភាពស្អីទៀតទេ គឺចប់តែត្រឹមហ្នឹងឯង។ ទិដ្ឋិនេះក៏ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់បដិសេធព្រោះខុសពីសច្ចៈធម៌ក្នុងច្បាប់ធម្មជាតិជាបរានុម័ត ក្នុងធម្មជាតិគឺពុំមានធម្មធាតុណាមួយ ត្រូវរលត់បាត់សូន្យឈឹងទាំងស្រុងចេញពីធម្មជាតិបាននោះឡើយ។ ដែកសុទ្ធដែលបានលត់ជាកាំបិតហើយ ពេលកើតច្រេះចាប់ក៏ក្លាយជាដែកអុកស៊ីត ពុកហិលរិចរិលបាត់រូបរាងជាកាំបិតពីដើមអស់ទៅ ដែកអ៊ុកស៊ីតត្រូវទទួលរងនូវអំពើរពីធាតុផ្សេងទៀតក្លាយជាដែកអ៊ីដ្រុកស៊ីត ក្លាយជាអំបិលដែ ឬរ៉ែដែកចូលក្នុងសំបកផែនដីវិញដូចដើម ហើយវិលចេញជារូបធាតុផ្សេងៗទៀតជាធម្មតាតសាបសូន្យឡើយ នេះជានិយាមរបស់ធម្មជាតិ។ ជីវិតសត្វលោកក៏ដូចគ្នា គឺបើនៅតែមានលោភៈ ទោសៈ មោហៈ នោះនៅតែកើតទៀតជាធម្មតា កូនង៉ាដែលកើតចេញមកនេះថាជាសង្ខារធម៌ថ្មីស្រឡាងក៏មិនមែន

ជាសង្ខារធម៌ចាស់សុទ្ធសាធក៏មិនមែន ព្រោះមានហេតុបច្ច័យនាំឱ្យមានអត្ថិភាព។ គ្រាប់ពោតនេះថាជាគ្រាប់ពោតចាស់ក៏មិនមែន ថាជាគ្រាប់ពោតថ្មីក៏មិនមែន ព្រោះត្រូវឯក្រោមឥទ្ធិពលជីវជាតិដី និងអាកាសធាតុដែលសុទ្ធតែជាបច្ច័យតាក់តែងបានដល់កម្មនេះឯង។ ការយល់ថាសតហ្វលោកទៀត នាំឱ្យមនុស្សលែងខ្វាយខ្វល់និងបំពេញកុសលធម៌ ហ៊ានធ្វើបាបធម៌ តតខ្លាចរអា ការយល់ថាស្លាប់សូន្យក៏នាំឱ្យមនុស្សលែងចេះធ្វើបុណ្យ ដណ្តើមតែកាមគ្នាបរិភោគ ពួយឱ្យអស់ចិត្តយឺតឱ្យអស់ចង់ ព្រោះអាងតែគ្មាននរកសួគ៌ជាងង្វាន់ ឬជាការពិន័យអ្វីទាំងអស់។ ខន្ធ៥មិនមានយើង មិនមែនជារបស់យើងឡើយការបែកធ្លាយនៃខន្ធ៥មានយើងជាអ្នកបែកធ្លាយឯណា ក្នុងធម្មជាតិមិនមែនអ្វីទទេរ បើធម៌មួយរលត់ជាបច្ច័យដល់ធម៌មួយកើតឡើង ឬធម៌មួយកើតឡើងជាបច្ច័យដល់ធម៌រលត់។ មិនមានអ្វីចាស់មិនមានអ្វីថ្មី មិនមានអ្វីកើតមិនមានអ្វីស្លាប់ គឺធាតុដីទឹកភ្លើងខ្យល់ ដដែលឺ ដែលមិនមានចាស់មិនមានថ្មី មិនមានកើតមិនមានស្លាប់ មិនមែនប្រុសមិនមែនស្រី គឺត្រឹមតែធាតុដី ទឹក ភ្លើង ខ្យល់ប្រជុំគ្នា។ កើតទៀតខ្លះក៏មិនមែន មិនកើតទៀតខ្លះក៏មិនមែន គឺបើយើងអស់អវិជ្ជានិងតណ្ហា អស់លោភៈ ទោសៈ មោហៈ

ហើយបញ្ចខន្ធនេះ នឹងត្រូវរលត់អស់ទាំងស្រុង ព្រោះថាមពលបរិសុទ្ធ របស់ចិត្តត្រូវរលាយចូលក្នុងថាមពលសកលចក្រវាឡអស់ លែងត្រឡប់មានកំណើតទៀតហើយមហាភូតរូប៤ ត្រូវប្រគល់ឱ្យផែនដីវិញ នេះឯងកើតទៀតខ្លះក៏មិនមែន។ នាមធម៌លែងកើតទៀតមែន ប៉ុន្តែរូបធម៌ដែលផ្សំផ្គុំពីធាតុ៤ ដី ទឹក ភ្លើង ខ្យល់ នោះ ពេលដែលប្រគល់ឱ្យធម្មជាតិវិញហើយក៏ត្រូវធម្មជាតិរៀបចំតាក់តែងឱ្យកើត បានជារូបរបស់វិញ្ញាណផ្សេងទៀត ធម្មតាធាតុ៤គ្រាន់តែប្រជុំកើតរួចបែកធ្លាយ បែកធ្លាយរួចប្រជុំកើត មិនបានរលត់សូន្យឈឹងក្នុងធម្មជាតិឡើយនេះឯងមិនកើតទៀតខ្លះក៏មិនមែននោះ។ ចុះវិញ្ញាណជាបច្ច័យដល់នាមរូបនោះលោកតាតើដូចម្តេច? (ពូហេងលូកមាត់សួរកាត់ថេរដីកា)។ ចម្រើនពរ! អាត្មាចូលចិត្តណាស់ដែលពេលសម្តែងធម៌ ហើយមានការសួរនាំដូច្នេះ ព្រោះអាត្មានិយាយតែឯងយូរទៅមិនដឹងថាញាតិញោមយល់ឬមិនយល់យ៉ាងណាទេ។ ពេលនិមន្តបិណ្ឌតាមភូមិក៏អញ្ជើង អាត្មាតែងប្រទានឱវាទបរិស័ទដែលគេប្រគេចង្ហាន់ឱ្យរឿយៗ ហើយតែងតែដោះស្រាយបញ្ហាជូនញាតិញោមជាប់មិនដាច់ដែរ ព្រោះការគោរពទាំងមិនយល់ គឺជាការគោរពឥតប្រយោជន៍ហើយនាំឱ្យសាសនាវិនាសឆាប់ទៅវិញទេ។

វិញ្ញាណជាបច្ច័យដល់នាមរូប (១) វិញ្ញាណជាបច្ច័យដល់នាមដោយសារតែការតាក់តែងកម្ម ព្រោះមានចេតនាប៉ងប្រាថ្នាឱ្យមានកំណើតតែនាមធម៌ ទើបមានការបដិសន្ធិជាចតុវោការភពដែលមានតែនាមធម៌ អត់រូបធម៌ដូចច្នេះទៅ។ (២) វិញ្ញាណជាបច្ច័យដល់រូបធម៌ យោគាវចរខ្លះបំពេញតបធម៌ព្រោះយល់ថាទុក្ខទាំងឡាយដឹងបាន ព្រោះតែមានចិត្តជាអ្នកដឹង ហេតុនេះមានចេតនាប៉ងប្រាថ្នាឱ្យបានទៅកើតទីដែលមានតែរូបអត់មានចិត្តឬនាមធម៌ ទើបបានបដិសន្ធិនៅឯកវោការភពដែលមានអសញ្ញីភពជាដើម។ យោគាវចរជាអ្នកបំពេញការព្យាយាមខ្លះយល់ថា ព្រោះតែមានរូបទើបមានទុក្ខ ទើបបំពេញតបធម៌ឱ្យបានទៅកើតនៅចតុវោការភព ដូចដែលបានអធិប្បាយរួចមកហើយ។

៣- វិញ្ញាណជាបច្ច័យដល់នាមនិងរូប បានដល់ពួកបញ្ចវោការភពដូចជាពួកយើងដែលមានខន្ធ៥នេះឯង ព្រោះហេតុនេះបានជាអាត្មាអធិប្បាយថា វិញ្ញាណគឺចិត្ត ឬមនោវិញ្ញាណនេះចុះចាប់បដិសន្ធិព្រមពេលដំណាលគ្នានឹងការកកើតរូបធម៌នេះដែរ។ គឺវិញ្ញាណដែលផ្សាយចេញពីបុគ្គលម្នាក់ដែលបានបែកធ្លាយខន្ធ ហើយមានរលកធាតុអាកាស ឬអាកាសលោកជាវិថី ផ្សាយទៅសណ្ឋិតលើស៊ុតដែលកំពុង

តែមានការផ្សំផ្គុំបង្កកំណើតពីមេជីវិតញីឈ្មោល នេះដូចជាបាតុភូតការ
ផ្សាយវិទ្យុ ឬក៏ការប្រើទូរសព្ទដូច្នេះដែរ បើគ្មានវិទ្យុក៏គ្មានការទទួលសំ
លេង បើគ្មានតួរទូរសព្ទសម្រាប់ទទួលក៏គ្មានការសម្រេចជាការសន្ទនា
ដែរ បាតុភូតកំណកំណើតជីវិតសត្វក៏ដូចគ្នា។ ទាំងអស់នេះសុទ្ធតែជា
ធម្មជាតិទេ ព្រះលោកប្រមើលមើលឃើញដោយទិព្វញាណ ហើយទ្រង់
ខំពន្យល់ប្រាប់យើងគ្រប់គ្នា កុំឯងធ្វើច្រឡើសបើសអត់ជឿថា មានទេវ
តាមានព្រហ្មអីនោះ តោងតែត្រូវដឹងឱ្យច្បាស់ថា ធម៌ទាំងឡាយជាគូនឹង
គ្នា បើមានកើតត្រូវមានស្លាប់ បើមានកើតត្រូវមានមិនកើត បើទីនេះមាន
ទៅនោះក៏មានបើទីនេះគ្មានទីនោះក៏គ្មាន។ ព្រះធម៌ក្នុងសាសនានេះ
សុទ្ធតែពិសោធបានដោយខ្លួនឯង មិនផុតវិស័យមនុស្សធ្វើមិនបាននោះ
ឡើយ។ បើទីនេះមានគឺក្នុងប្រព័ន្ធ ព្រះអាទិត្យ មានជីវិតរស់នៅលើភព
ផែនដីចុះហេតុដូចម្តេចក៏ក្នុងប្រព័ន្ធគ្រួសារផ្កាយ ឬព្រះអាទិត្យផ្សេងទៀត
ជាអនន្តនោះ វាមិនមានជីវិតរស់នៅដែរបើទីនេះមានជីវិតរស់នៅបាន ?
ទៅនោះក៏ត្រូវតែមានជីវិតរស់នៅបានដូចគ្នា។ យប់មួយអាត្មាបានឮវិទ្យុ
សំលេងសហរដ្ឋអាមេរិកដែលផ្សាយជាភាសាខ្មែរ បណ្ឌិតសាស្ត្រាចារ្យ
ភូមិវិទ្យា មាស ចន មានប្រសាសន៍ថា នេះក្រុមហ៊ុនណាហ្សាផ្នែក

អវកាសរបស់សហរដ្ឋអាមេរិកបានទៅដល់ភពនេះភពនោះ តែអត់មានឃើញទេវតាព្រហ្មអីរស់នៅដូចជា ព្រះពុទ្ធសាសនាបាននិយាយនោះទេ។ អាត្មាគិតសព្វៗទៅគួរករុណាដល់គាត់ដែលចំណាស់ហ្នឹងទៅហើយមិនអាចយល់សច្ចៈធម៌ ជីវិតមនុស្សមិនអភ័ព្វទេ មិនអាចគិតយល់ពីការពិតបាន។ ក្រុមហ៊ុនណាហ្សាយកភ្នែកសាច់ទៅប្រឹងរកមើលអមនុស្ស ធ្វើម៉េចរកឃើញមនុស្សសព្វថ្ងៃប្រឹងមានអំណួតថា បញ្ញាគេធ្វើឱ្យដៃករាប់តោនហោះបាននេះក៏សំរេចបានពីចិត្ត ប៉ុន្តែមនុស្សជាន់ដើមគេហ្វឹកហាត់ឱ្យកាយមានរិទ្ធអាចហោះហើរបាន ឱ្យមានភ្នែកទិព្វ ត្រចៀកទិព្វ មានញ្ញាណទិព្វជាដើម នេះក៏សំរេចបានពីចិត្តដែលប្រឹងហ្វឹកហាត់ស្រាវជ្រាវរកដូចគ្នា ប៉ុន្តែតាមចិត្តលោកគឺមិនបាននាំលោកឱ្យទៅរកក្តីវិនាសក្នុងថ្ងៃណាមួយជាមិនខាន។ ពួកតារាវិទូបានសន្និដ្ឋានថាហេតុដែលភពនៅជិតព្រះអាទិត្យឆ្ងាយជាផែនដីក៏គ្មាន ជីវិតរស់នៅបានដែរនោះ ព្រោះត្រជាក់ពេក ប៉ុន្តែនេះយានស្រាវជ្រាវរបស់ណាហ្សាបានបង្ហាញភស្តុតាងថា បានរកឃើញស្លាកស្នាមមានជីវិតរស់នៅលើភពព្រហស្បតិ៍ តើហេតុអ្វីក៏ភពនោះនៅសល់តែផេះដូច្នេះទៅវិញ? មិនគឺដោយសារលោភៈ ទោសៈ មោហៈ របស់ពួកសត្វអស់នោះចម្រើន

ហើយនាំគ្នាបំផ្លិតបំផ្លាញគ្នាទៅវិញទៅមកទេឬ? រឿងនៅលើផែនដីក៏ដូចគ្នាគង់នឹងមានសភាពយ៉ាងនោះអញ្ចឹងដែរណាញោមហ្អើយ តើគួរនៅឆេះក្នុងភ្លើងជាមួយគេទេញោម? តើអ្វីទៅគឺជាការស្វែងរកដ៏ឧត្តមនោះញោម? គឺការស្វែងរកព្រះនិព្វាននេះឯងទើបជាការដោះស្រាយបញ្ហាទុក្ខបានដល់រឹសគល់នៃបញ្ហាពិតប្រាកដ ហេតុនៃការស្វែងរកនោះគឺត្រូវប្រើសតិស្វែងរកក្នុងខន្ធ៥ រកឱ្យឃើញថានៅត្រង់ណាទៅជាយើង ត្រង់ណាទៅជារបស់យើង កាលបើឈ្លេចឈ្លីរកមើលទៅឃើញថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ វាអត់ទាំងមានខ្លួនឯងផង តើមានយើងមកពីណា ក៏អស់អាល័យក្នុងខន្ធ៥ ការអស់ប្រកាន់ក្នុងខន្ធ៥នេះឯងគឺជាព្រះនិព្វាន។ វិញ្ញាណកើតឡើងព្រោះមានហេតុបច្ច័យនាំឱ្យកើតតែមិនដឹងកំណើតខ្លួនឯង ស្រាប់តែមកឈ្លក់វង្វេងនឹងផស្សៈដែលគ្រាន់តែជាការប៉ះខ្ទប់រវាងអារម្មណ៍មកលើវិញ្ញាណខ្លួនឯង វេទនាក៏កើតឡើងតាមទ្វារសោយអារម្មណ៍ជាសុខ ជាទុក្ខ តណ្ហាក៏កើតឡើងចាប់ប្រកាន់មាំហើយតាក់តែងកម្មជាហូរហែរ ដល់តែបានជួបព្រះធម៌ទើបចេះប្រើសតិពិនិត្យឆែកឆេររកឃើញបុព្វហេតុអញ និងផលរបស់អញ។ ឱ! អស្ចារ្យណាស់ញោម តើមានបុគ្គលណាសូម្បីតែម្នាក់ក្នុងលោកយើងនេះ

ដែលអាចពោលអរិសច្ចៈ៤ ពោលអំពីទុក្ខ ហេតុរបស់ទុក្ខ ការរលត់ទុក្ខ និងវិធិលះហេតុរបស់ទុក្ខឱ្យបានដល់អមតៈសុខដូចជាព្រះសម្មាសម្ពុទ្ធ ជាម្ចាស់នៃយើងនេះទៅញោម។ ការសម្តែងធម្មទេសនា ល្មមត្រូវបញ្ចប់សមគួរដល់កាលវេលា ឯវំ។ សាធុ សាធុ សាធុ

ថ្ងៃរសៀលជ្រៀលជ្រេបន្តិចហើយ ព្រះសូរិយោយាងយាសបន្ទាបខ្លួនប៉ប្រះមាត់ព្រៃ បានបញ្ចេញរស្មីពណ៌មាសរំលេចលំអរផ្ទៃធម្មជាតិគួរឱ្យគយគន់។ សំលេងបំពង់ទឹកត្នោតប៉ូកៗតាមដើមត្នោត ដែលកសិករកំពុងរូតរះផ្លាស់ប្តូរបំពង់ និងដាក់ទឹកត្នោតចុះដើម្បីចាក់ដាក់ខ្ទះរំងាស់ធ្វើជាស្ករ ប្រគុំបន្ទរជាមួយសំលេងមេគោស្រែកយំហៅកូនឱ្យចូលក្រោលហាក់បីដូចជាអង្រួនបេះដូងមុំឱ្យកាន់តែឈឺចុកចាប់ពឹតផ្សារ ព្រោះត្រូវបណ្តាសារធម្មជាតិដ៏សែនឃោរឃៅ។ ម៉ែ! លើលោកនេះ បើទោះជាខ្ញុំត្រូវខំស្វះស្វែងទៅរកម៉ែនៅទីណាក៏ពុំអាចរកឃើញម៉ែបានឡើយ អំណឹះពីថ្ងៃនេះតទៅមុខកូនលែងបានឮសម្លេងម៉ែទៀតហើយ ជីវិតគឺជាស្នាមអនុស្សាវរីយ៍ ប៉ុន្តែស្នាមនេះគឺវាជិតដាមយ៉ាងជ្រៅក្នុងក្រអៅបេះដូងកូនមិនអាចលុបបានឡើយ។ បើទោះជារូបកូនត្រូវដីគ្របមុខ ក៏វិញ្ញាណកូននៅតែចងចាំឧបការៈគុណរបស់ម៉ែ ដែលមានមកលើកូនជាប់ជានិច្ចមិន

អាចបំភ្លេចបាន កូនស៊ូលក់អស់ទាំងកិត្តិយសដើម្បីរកប្រាក់មកព្យាបាលជំងឺម៉ែ តែធម្មជាតិឥតមេត្តានៅតែមកផ្តាច់ផ្តិលជីវិតម៉ែពីទ្រូងកូនទៅបាត់។ បើម៉ែអាចបង្ហាញខ្លួនឱ្យកូនឃើញបាន ទោះជាយប់អាធ្រាត្រងងឹតយ៉ាងណាក៏កូននឹងស្ទុះទៅអោបម៉ែ មិនព្រមលែងឱ្យម៉ែចាកចេញពីរង្វង់ដៃរបស់កូនបានឡើយ។ នាងគិតបណ្តើរ ឯស្បែរាត្រីកាលក៏ចាប់ផ្តើមទំលាក់គ្របដណ្តប់លើផែនពសុធាជាបណ្តើរៗដែរ ទីបំផុតវាំងននជីវិតត្រូវបានបិទបាំង ដោយភាពងងឹងអន្ធកាលនៃរាត្រីរនោចៗ។ មាណវីកំសត់នាងរាវរកដៃកកេះ យកមកកេះច្រឹកៗបែកផ្ការភ្លើងព្រាតៗមួយស្របក់ ទើបពន្លឺកូនចង្កៀងប្រេងកាតនោះបានរះឡើង ស្រាប់តែលេចចេញរង្វង់មុខធ្លោឡើងនៅមាត់ទ្វារផ្ទះ។ អើហ៍មុំ! គឺតាណា អញ្ជនឹកអាណិតឯងកុំឱ្យយប់នេះស្រងេះស្រងោចពេក តាបានហៅក្មួយពេទ្យហេង អាផេង នាងស៊ុម ចៅដេត ចៅណែត និងអ្នកភូមិខ្លះទៀតឱ្យមកប្រជុំគ្នាស្តាប់ព្រះធម៌ដែលមានតាជាអ្នកសម្របសម្រួល ហើយតាក៏បាននិមន្តព្រះសង្ឃដែលទេសនាពីថ្ងៃមិញនោះ ឱ្យបានលោកមកគង់ជាមួយក្នុងអង្គធម្មសាកច្ឆានេះដែរណាចៅ ឯងជួយរៀបចំទឹកតែខ្លះទៅព្រោះបន្តិចទៀតភ្ញៀវមកជួបជុំគ្នាហើយ។ មុំលើកដៃសំពះក្រាបបង្គំឆ្ពោះ

រូបថតអ្នកម្តាយ ដែលតាំងនៅពីក្រោយកញ្ចប់ធាតុដាក់លើតុក្បែរជញ្ជាំង រួចនាងចូលទៅមើលចង្ក្រានរៀបចំដាក់ទឹកក្តៅឆុងតែ មួយស្របក់ក្រោយមក ភ្ញៀវក៏បានមកជួបជុំឯព្រះសង្ឃបាននិមន្តគង់លើធម្មាសនៈរួចជាស្រេច កិច្ចនមស្ការចំពោះព្រះរតនៈត្រ័យក៏បានចាប់ផ្តើមឡើងដោយសំលេងសូរសព្ទភាសាបាលីពិរោះក្រអួនក្រអៅ ពុះជ្រែកផ្ទៃធម្មជាតិនារាត្រីកាលគួរឱ្យជក់ចិត្ត សូម្បីតែសត្វខ្លះដែលស្តាប់ពុំយល់ថាមានន័យដូចម្តេច ហេតុតែនិស្ស័យធ្លាប់សន្សំពីអតីតមកក៏ធ្វើឱ្យចិត្តបង្អោនចុះទៅស្តាប់ដោយក្តីគោរពស្រលាញ់អស់ពីដួងចិត្ត។ លុះកិច្ចនមស្ការបានបញ្ចប់ហើយ លោកតាសនគ្រូហែមបន្តិចក៏ពោលថាៈ ក្នុងជំនឿសាសនានាក៏ដោយក៏មានអង្គ៣ក្នុងនោះដែរគឺ (១) ក្រឹត្យវិន័យ (២) ពិធីសាសនា និង (៣) បញ្ញា ក្នុងនោះដូចៗគ្នាទាំងអស់ដែរប្លែងត្រង់ថា តើអង្គទាំង៣នេះមានប្រជាប្រិយភាពអាចទាក់ទាញចិត្តមនុស្សឱ្យគោរពជឿតាមបានច្រើនជាគ្នាប៉ុណ្ណាៗតែប៉ុណ្ណោះ។ ត្រង់នេះខ្ញុំឆ្ងល់ថា បើព្រះពុទ្ធសាសនានេះមានភាពប្រកាដប្រជានិងមានសុក្រិត្យភាពជាងគេ ចុះហេតុដូចម្តេចក៏បានជាមានពុទ្ធបរិស័ទគោរពរាប់អានតិចជាងគេម្លេះ? សូមអង្គធម្មសាកច្ឆាជួយដោះស្រាយផងមកមើល? សូម

និមន្តលោកម្ចាស់មុនគេទាន។ ព្រះអរិយសង្ឃជាមហាសង្ឃអង្គនោះ ទទួលភារៈ ដោយទឹកព្រះភ័ក្រស្រស់ភ្លឺថ្លាក្នុងសភាពជាមនុស្សស្តើងកិលេស ដូចជាពន្លឺដុំមាសដែលកប់ក្នុងគំនរស្លឹកឈើហើយត្រូវចាំងចំពន្លឺភ្លើង ព្រះអង្គចាប់បន្លឺសម្លេងៈ បញ្ហានេះគឺជាប់ទាក់ទងទៅនឹងពុទ្ធបរិស័ទទាំងអស់គ្នា បើយើងចង់ថែរក្សាមហាសម្បត្តិវប្បធម៌បញ្ញាដ៏គ្មានពីរលើលោកនេះដើម្បីបានជាប្រយោជន៍ដល់ជនច្រើនទៅថ្ងៃមុខទៀត វាមិនមែនជាបញ្ហារបស់បារាំង អង់គ្លេស អាមេរិកកាំងអីពីណាមោហ៍ទេ វាគឺជារឿងរបស់យើងទាំងអស់គ្នាដែលត្រូវនាំគ្នាជួយថែរក្សា ប៉ុន្តែក៏មិនត្រូវដល់ថ្នាក់ហួងហែងឈ្លោះប្រកែកចោទដាក់គ្នាអ្វីពេកនោះដែរ ព្រោះសាសនានេះគឺជាសាសនាដែលនឹងវិនាសទៅទេ។ ហេតុនេះទាន់ព្រះធម៌នៅគង់វង់ជាធរមានហើយបរិសុទ្ធល្អដូចដើមនៅឡើយ យើងត្រូវតែខិតខំសិក្សារៀនសូត្រហ្វឹកហាត់បដិបត្តិឱ្យបានរួចចាកទុក្ខ កូនចៅជំនាន់ក្រោយណាដែលមានឧប្បនិស្ស័យអាចស្គាល់យល់បាន ក៏បដិបត្តិបន្តទៅ។ ព្រះធម៌ធ្វើឱ្យសត្វពិបាកទទួកយកបានភ្លាមៗ ព្រោះព្រះលោកប្រដៅប្រញ្ជាស់នឹងតណ្ហារបស់សត្វលោក សត្វកំពុងតែឈ្លក់វង្វេងនឹងរូប ងប់ងល់ភ្លើតភ្លើនត្រេកត្រអាលនឹងរូប មានៈប្រកាន់

ហួងហែងក្នុងរូបថាមានខ្លឹមសារ អ្វីៗជារបស់ខ្លួន ស្រាប់តែព្រះលោកពន្យល់ថា រូបចជារបស់ឥតសារៈ របស់ស្អុយរលួយស្មោកគ្រោកអាក្រក់ក្រខ្វក់គួរខ្ពើមរអើម រូបមិនមែនជារបស់យើងឡើយ ភ្នែកឃើញរូបហើយកុំស្អប់កុំស្រលាញ់រូបនោះ ព្រោះភ្នែកឯងក៏មិនមែនជារបស់យើងដែរ របស់ណាមិនមែនជារបស់យើងគួរលះការប្រកាន់ក្នុងរបស់នោះថា ជារបស់ខ្លួនឱ្យហើយ វាដូចជាសម្រាមដែលត្រូវគេកើបយកទៅចោលហើយយើងឥតតាមប្រកាន់ថា សំរាមដែលត្រូវគេកើបយកទៅចោលនោះជារបស់យើងទៀតឡើយ។ ត្រចៀកបានឮសំលេងហើយកុំស្អប់កុំស្រលាញ់ កុំជាប់ជំពាក់ក្នុងសំលេងនោះ ព្រោះសូម្បីត្រចៀកឯងនេះក៏មិនែមជារបស់យើងឡើយ សូម្បីតែក្លិនផដ្ឋព្វៈនិងធម្មារម្មណ៍ក៏ត្រូវពិចារណាតាមទំនង ដូចគ្នានេះដែរ នេះហៅថាយោនិសោមនសិការដើម្បីច្រានចោលសភសញ្ញាតាមសេចក្តីពិត សត្វលោកគ្រាន់តែបានឮប៉ុណ្ណោះក៏ក្រាញមិនចង់ស្តាប់ដែរ ព្រោះគ្នាកំពុងតែវក់វីក្នុងក្តីប្រកាន់។ ទាល់តែរូបនោះវាឱ្យទោស រូបស្អាតក៏វិនាស រូបអាក្រក់ក៏វិនាស សុទ្ធតែជាសំបុករោគជង្រុកតណ្ហា ហើយត្រូវព្រោត់ប្រាស់និរាសជាហូរហែរទើបមើលឃើញពុទ្ធដីការថាត្រឹមត្រូវពិតប្រាកដមែន។ សត្វលកកំពុងតែ

សប្បាយនឹងបានស្រាប់តែព្រះលោកពន្យល់ថា ការបាននោះនាំឱ្យមានទុក្ខតាមពិតគ្មានអ្នកណាបានអ្វីទាំងអស់ពីលោកនេះ គឺសុទ្ធតែអស់ទៅសូន្យទៅដូចៗគ្នា ធ្វើឱ្យសត្វលោកស្រងាកចិត្តស្តាប់មិនបាន ព្រោះវាមិនឃើញអស់ គេកំពុងតែបានព្រះលោកពន្យលថាឱ្យលះវាដូចជាសត្វសុនខដែលកំពុងតែពាំសាច់ ស្រាប់តែត្រូវគេបង្ខំឱ្យទំលាក់ចោលទៅងាយអីទំលាក់ចោលបាន ទាល់តែត្រូវសុនខដទៃព្រួតគ្នាខាំហែកដណ្តើមដាច់សាច់ហូរឈាមស្ទើរស្លាប់ស្ទើររស់ ទើបបានឃើញទោសរបស់ដុំសាច់នោះ។ សត្វលោកកំពុងតែសប្បាយហិចហៃលក្នុងស្ទឹងតណ្ហាសត្វណាមិនទាន់លង់ជិតស្លាប់ទេ គឺមិនព្រមតោងសំណាត់ឈើដែលព្រះលោកបោះឱ្យតោងឡើងមកនោះឡើយ។ សត្វណាដែលត្រូវតណ្ហាធ្វើទុក្ខបុកម្នេញឱ្យរងទុក្ខស្ទើរស្លាប់ស្ទើររស់បានព្រមតោងឡើង សត្វខ្លះវង្វែងបន់ស្រន់ បួងសួងឱ្យទេវតាអាទិទេពជួយដោយមិនព្រមវាឡើងដោយខ្លួនឯងឡើងមកឡើយ។ ដើម្បីចេញចាកទុក្ខបានពិតប្រាកដ ក្នុងព្រះសាសនានេះខាងនិកាយថេរវាទ ដែលនិយមប្រព្រឹត្តិបដិបត្តិតាមពុទ្ធឱវាទ គឺមានក្រិត្យវិន័យតឹងតែងបន្តិច។ ប៉ុន្តែមិនមែនមានន័យថាមនុស្សមិនអាចធ្វើតាមបាននោះឡើយ គ្រាន់តែថាបថុជ្ជនជាជនក្រាស់

ដោយកាមធ្លាប់បៅជញ្ជក់ នៃបនិត្យនិងកាមនោះឡើងញៀនញ៉ាំមអត់មិនបានទៅហើយ ទៅឱ្យផ្តាច់ភ្លាមៗមិនបានឡើយ ទើបអ្នកសម្តែងធម៌ខ្លះដែលខ្លាចបាត់លាភសក្ការៈ ខ្លាចអ្នកស្តាប់ធម៌គេអាក់អន់ចិត្ត និងសម្តីពិតព្រោះពាក្យពិតរែងស្លែង តម្រូវឱ្យអ្នកសម្តែងធម៌ត្រូវតែយល់មុខយកចិត្តយកថ្លើម និយាយលើកជើងបញ្ឆោរបញ្ឆើចបញ្ឆើរអ្នកស្តាប់លែងហ៊ាននិយាយពីធម៌វិន័យទេឬ? ពេលធ្វើបុណ្យទានម្តងៗ ការសម្តែងធម៌នាំឱ្យកើតបញ្ញាគឺមិនសូវនឹកនាដល់ទេ ប្រឹងតែពីខំយកមុខ។ ម្ចាស់បុណ្យចង្អុលឱ្យយាយតា ជើងឈ្នួល ឱ្យនាំគ្នាស្តាប់ធម៌ទៅ ឯខ្លួនឯងនៅប្រឹងចាំឆ្លេឆ្លាទទួលភ្ញៀវ ព្រោះខ្លាចគេអាក់អនចិត្ត ឯភ្ញៀវនោះទៀតសោតមិនមែនមកស្វែងរកបុណ្យទេ គឺមករករឿងចាំអន់ចិត្តជាមួយម្ចាស់បុណ្យពេលណាគេមិនបានគោរពរាក់ទាក់ដាក់ខ្លួន ម្នាក់ៗនាំយកតែការមានះប្រកាន់ដាក់គ្នា។ ទីណាឱ្យតែមានពិធីហើយ គឺអត់បញ្ញាចូលរួមទេ។ ថ្ងៃមុនផ្ទះចិនម្នាក់ ជីដូនគាត់ស្លាប់ចៅម្នាក់និមន្តអាត្មាទៅវាក់អើនឹងចិនសែពីរបីនាក់ ម្នាក់ថាអញ្ជេះបានត្រូវ ម្នាក់ថាធ្វើអញ្ចឹងខុសទេចៅម្នាក់អុជទៀនស ស្រាប់តែម្តាយធំគំហកថាត្រូវដុតទៀនក្រហមវិញប្រយ័ត្នរកស៊ីដាក់មិនឡើង។ អាត្មាមើលសព្វៗទៅ ម្នាក់ៗមិនមែន

មកធ្វើបុណ្យជូនជីដូនទេ គឺមកប្រជែងយកចិត្តខ្មោចឱ្យទៅបម្រើការរកស៊ីឱ្យខ្លួនទៀត អាត្មាឃើញតែអវិជ្ជានិងតណ្ហាវាចេញមុខឱ្យច្បាស់ក្រៃឡែត ប្រើជីដូនតាំងពីនៅរស់រហូតដល់ស្តាប់ហើយនៅអន្ទងហៅឱ្យមកបម្រើចាំថែទាំផ្ទះ ជួយហៅម៉ូយឱ្យទិញឥវ៉ាន់ខ្លួនទៀត នេះបានចំជាឥតមានមេត្តាមែន សូម្បីតែខ្មោចក៏ប្រើមិនលើកលែង។ មួយឱ្យរៀបចំអញ្ចេះ មួយស្រាប់តែមកប្រើលោកឱ្យជួយរៀបចំបាយសី ជួយរៀបថូផ្កា រួចប្រើឱ្យជួយហែរខ្មោចទៀត។ គេនាំគ្នាវក់វីតែនិងពិធី មិនដឹងស្អីជាស្អីទេគេដុតផ្ទះក្រដាស ឡានក្រដាស ហើយប្រើឱ្យលោកជួយសូត្រធម៌បញ្ជូនផេះក្រដាសនោះផ្ទៀឱ្យខ្មោចយាយ ចង់មិនចង់ក្មេងជំនាន់ក្រោយវាច្រឡំថាហ្នឹងជាពិធីក្នុងព្រះពុទ្ធសាសនាទៀត។ ទាក់ទងនឹងការផ្សាយព្រះពុទ្ធសាសនានេះដែរ យើងគួររៀបចំតាមសាលារៀនឱ្យក្មេងៗបានសិក្សារៀនសូត្រព្រះធម៌ឱ្យបានបានជ្រៅជ្រះ ដឹកនាំឱ្យចេះគោរពធម៌វិន័យជាដើម។ តាមរមនីយដ្ឋាននានាគួរមានចារិកពុទ្ធប្រវត្តិ ឬពុទ្ធភាសិតល្អៗឱ្យក្មេងបានឃើញ កុំដាក់តែរូបអាសអាភាសពន្យាកំណើតស្រោមអនាម័យពេក ដូចដឹកនាំក្មេងឱ្យខូចខុសពីជំនាន់ដើមដែលមិនងាយបានដឹងរឿអាសអាភាសអីដូចសព្វថ្ងៃនេះទេ។ អាត្មាកាលអាយុ

២០វស្សាហើយ អត់ដឹងថាកូនកើតតាមណាផង។ យើងត្រូវនាំគ្នារៀន ធម៌បដិបត្តិធម៌ ទើបព្រះធម៌នៅគង់វង្សបានព្រោះជម្រៅក្នុងព្រះពុទ្ធ សាសនាគឺជ្រៅដោយអត្ថធម្មនិរុត្តិ និងបដិភាណៈឬអត្ថៈ ធម្មទេសនា និងបដិវេធដែលមិនងាយយល់បានឡើយ។ ម្យ៉ាងទៀតដោយសារតែ ព្រះសាសនានេះចាប់ផ្តើមឡើងគឺប្រដៅចិត្តខ្លួនឯង តិះដៀលឱ្យបាត់ អំនួតឱ្យកើតវិរាគៈ នឿយណាយស្ងាត់ចាកកាម ទើបអ្នកចេះដឹងធំៗក្នុង ព្រះពុទ្ធសាសនាលោកច្រើនតែចូលព្រៃបាត់ៗ មិនបានមកត្រេកអរ និង លាភយសខ្លាចបាត់បង់ឋានៈតួនាទីក្នុងលោកនេះទេ នេះក៏ជាហេតុនាំ ឱ្យសាសនាព្រះពុទ្ធផ្សាយយឺតជាងគេដែរ។ អរិយបុគ្គលលោកច្រើន សំងំកៀនជញ្ជាំង មិនបានមកចេញមុខទាមទារសញ្ញាបត្រវាយតម្លៃ កិលេសអីនោះទេ ដូចជាព្រះមលិន្ទបានទូលសួរព្រះនាគសេនថា ព្រះ អង្គគឺជាព្រះអរហន្តឬ? ព្រះនាគសេនមានថេរដីកាតបថា ព្រះអរហន្ត ក្នុងព្រះពុទ្ធសាសនានេះតែងមានក្នុងលោក ព្រោះឱ្យតែបានបដិបត្តិតាម ធម៌វិន័យ គឺប្រាកដជាអស់អាសវៈបាន។ ព្រះអង្គមិនបានអួតអាងថា ខ្លួនព្រះអង្គគឺជាព្រះអរហន្តនោះឡើយ ខុសពីសាសនាដទៃដែលហ៊ាន ដាក់គ្រាប់បែកសំលាប់គ្នាដើម្បីដណ្តើមឋានៈតួនាទីក្នុងលោក។ ក្នុងព្រះ

ពុទ្ធសាសនានេះមិនបានបង្ខិតបង្ខំឱ្យអ្នកណាម្នាក់ ទទួលជឿដោយងងឹតងងុលឡើយ ដូចកាលណោះក្នុងព្រះរាជគ្រឹះ មានមេសាសនាធំៗជាច្រើនចូលមកផ្សាយសាសនា ហើយសុទ្ធតែអួតអាងថាសាសនាខ្លួនមានភាពល្អបរិសុទ្ធប្រសើរលើសគេតែរៀងៗខ្លួន។ ពេលនោះមានព្រាហ្មណ៍ម្នាក់ចូលក្រាបសួរព្រះពុទ្ធថា បើសាសនាទាំងអស់នោះមានសុទ្ធតែល្អទាំងអស់យ៉ាងនេះ តើឱ្យខ្ញុំព្រះអង្គទទួលជឿមួយណាទៅព្រះអង្គ? ព្រះបរមគ្រូត្រាស់តបថា ធម៌ វិន័យណាដែលប្រព្រឹត្តិទៅមិនដើម្បីបៀតបៀនខ្លួនឯង និងបៀតបៀនអ្នកដទៃទេ ចូរអ្នកចងចាំធម្មវិន័យនោះ ហើយបដិបត្តិតាមចុះ។ តើអ្នកមិនដឹងទេឬ ថាសេចក្តីលោភៈ ទោសៈ មោហៈ គឺជាទោស ជាហេតុដែលនាំឱ្យវិនាសតែប៉ុណ្ណោះឯង។ ព្រាហ្មណ៍បានស្តាប់ពុទ្ធដិការរបស់ព្រះអង្គ ដែលច្បាស់ដូចជាគេបើកឡើងរបស់ដែលផ្កាប់ ឬដូចជាគេដឹកដៃចេញពីទីងងឹតទៅកាន់ទីភ្លឺ ហើយមានចិត្តស៊ប់សួនក្នុងព្រះពុទ្ធសាសនាឥតរង្គើឡើយ។ ភារកិច្ចរបស់អគ្គបុគ្គលក្នុងលោកដូចជា ព្រះបរមគ្រូនេះព្រះអង្គមានមហាករុណាទិគុណអនន្តគុណ ព្រះអង្គប្រោសសត្វតាមឧបនិស្ស័យដែលគួរនឹងទូន្មានបាន នេះប្រៀបឧបមាដូចជាមានបឹងឈូកមួយដែលពោរ

ពេញទៅដោយផលផលមានសេត្តប្បលរត្តប្បលមីដេរដាស់ មានផ្លែទុំចាស់ខ្ចីគួរដល់នូវការបរិភោគយ៉ាងក្រៃលែង ប៉ុន្តែមហន្តរាយដែលមានក្នុងបឹងឈូកដ៏អាថ៌កំបាំងនោះ គឺឥតមានសត្វលោកណាមួយបានដឹងឡើយ រយពាន់ឆ្នាំកន្លងមកហើយដែលជីវិតសត្វលោកត្រូវបានបំផ្លាញក្នុងទីនោះ។ ស្រាប់តែព្រះពុទ្ធបានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គឈ្វេងយល់ពីគ្រោះកាចក្នុងបឹងឈូកនោះទាំងអស់ ព្រះអង្គក៏គង់នៅមាត់កំពង់ទឹក ពេលឃើញមនុស្សម្នាមកដល់ហើយ ចង់ស្ទុះទៅប្រមូលផលក្នុងបឹង ព្រះអង្គទ្រង់ត្រាស់ឃាត់ថា នែ៎ម្នាលអ្នកដ៏មានអាយុ អ្នកមានបានពិចារណាខ្លះទេថា ហេតុអីក៏បឹងឈូកនេះសំបូរផលានុផលច្រើនម្លេះ ចូរអ្នកយកដុំដីចោលទៅក្នុងទឹកបឹងនោះសាកមើល។ មនុស្សនោះក៏ចោលដុំដីតាម ស្រាប់តែមានសត្វក្រពើរធំៗស្ទុះព្រូងើបឡើងដេញត្របាក់ព្រោងព្រាត ហើយព្រះពុទ្ធទ្រង់ត្រាស់ថា ឥឡូវនេះចប់ភារៈថតគតដែលជាអ្នកសង្គ្រោះសត្វលោកហើយ ហេតុនេះអ្នកសម្រេចចិត្តចុះបឹងឬមិនចុះគឺស្រេចតែចិត្តអ្នកទេ ព្រោះបញ្ញាតថាគតបានផ្តល់ដល់អ្នកហើយ។ អស្ចារ្យណាស់ព្រះធម៌ក្នុងព្រះពុទ្ធសាសនា គឺពិតជាឥតមានការបង្ខិតបង្ខំឱ្យបុគ្គលណាម្នាក់ ទទួលធ្វើតាមដោយងងឹតងងល់

នោះទេ្បីយ គឺគ្រាន់តែពន្យល់ប្រាប់ហេតុផលតែប៉ុណ្ណោះ ឯការពិសោធន៍យ៉ាងណាៗ បានផលឬមិនបានផល គឺអាស្រ័យលើយើងជាអ្នកប្រព្រឹត្តិបដិបត្តតាមបានដល់ទីជម្រៅ ឬមិនបានដល់តែប៉ុណ្ណោះ។ បឹងឈូកនោះគឺជាអន្លង់ភព សត្វសាហាវគឺជាកិលេសវដ្ដៈ ជលផលគឺកាមគុណ៥ តណ្ហាប្រាថ្នាក្នុងកាមគុណ៥ គឺឈ្មោះថាជាការលិចចុះក្នុងភព រមែងត្រូវជាតិ ជា ព្យាធិ មរណៈ បៀតបៀនរឿយៗឥតស្រាកស្រាន្ត។ ផែនការផ្សាយសាសនា គឺជាកិច្ចការបដិបត្តិដ៏ធំមហិមាដើម្បីបើកភ្នែកពិភពលោកឱ្យបានឃើញធម្មៈតាមសេចក្តីពិត ឃើញដំណើរធម្មជាតិដែលមានហេតុបច្ច័យប្រជុំឱ្យធម្មធាតុមួយកើតទេ្បីង ហើយតាំងនៅរួចរលត់ទៅ រលត់ហើយកើត កើតហើយរលត់។ បានជាចរន្តនៃបម្រែបម្រួលមួយហូរទៅមុខជាប់ជានិច្ច ដែលមិនអនុញ្ញាតឱ្យសត្វណាមួយនៅប្រកាន់ហួងហែង ចង់ឱ្យទៅជាយ៉ាងដទៃក្រៅក្រិតក្រមនេះបានជាដាច់ខាត។ ហេតុដែលសព្វថ្ងៃមនុស្សជាច្រើនស្តាប់ធម៌យល់មិនបានព្រោះជាមនុស្សកៀកនឹងចុងកប្បណាស់ទៅហើយ តណ្ហាសត្វកាន់តែក្រាស់ទេ្បីង ព្រោះសុទ្ធតែជាសត្វដែលមិនបានហ្វឹកហាត់ដុសខាត់សំអាតកិលេសចិត្តតាំងពីអតិតកាល ព្រោះហេតុនេះ វិញ្ញាណដែលចុះ

ចាប់បដិសន្ធិគឺសុទ្ធតែជាវិញ្ញាណចងពៀរតាមស៊ីចាសច់ហុតឈាមគ្នា ធ្វើឱ្យលោកនេះទាំងមូលធ្លាក់ចូលក្នុង ក្តីវិបត្តិកស្តារលែងរួច។ ពូហែងឃើញពាក្យលោកសម្តែងចេញរាងរង្វើល ក៏លូកមាត់ចូលសួរភ្លែត៖ ក្រៅពីពៀរវេរាដែលកូនខ្លះតាមមកកើតនឹងម្តាយដើម្បីសងសឹក តើមានហេតុបច្ច័យអ្វីខ្លះទៀតដែរឬទេ ដែលធ្វើឱ្យមនុស្សសព្វថ្ងៃប្រែជាកាចៗមិនសូវមានខន្តី និងមេត្តាករុណា? មនុស្សខ្សត់បញ្ញាត្រាស់ដឹងធម៌តាមសេចក្តីពិត មានតែបញ្ញាកាប់ចាក់ជិះជាន់ កៀបសង្កត់គ្នា បញ្ញាប្រល័យលោក។ មហាសង្ឃស្ងាត់មួយស្របក់ទើបពោលបន្ត៖ ធម្មៈ គឺជាធម្មជាតិ អ្វីៗលើលោកយើងនេះគឺសុទ្ធតែជាធម្មជាតិដែលមិនគួរប្រកាន់ មិនគួរចង់តាមចិត្តរបស់ខ្លួនពេកទេ ព្រោះការចង់នោះឯងគឺជាទុក្ខ អាក្រក់ល្អគឺសុទ្ធតែមកពីចិត្តយើងគិតទាំងអស់ ចិត្តដែលមិនស្ងប់គឺជាចិត្តដែលងាយកើតទោសៈ ចិត្តមិនស្ងប់ព្រោះចិត្តមិនស្គាល់ធម្មៈ ចិត្តមិនស្គាល់ធម្មៈគឺជាចិត្តដែលងាយប្រតិកម្មទៅនឹងព្រឹត្តិការណ៍ខាងក្រៅ។ អាក្រក់ក៏ធម្មជាតិ ល្អក៏ធម្មជាតិ ស្អប់ស្រលាញ់ សរសើរនិន្ទា សុខទុក្ខ បានលាភបាត់លាភ បានយសបាត់យស ជួបព្រាត់ ប្រណីតថៅកែទាប រូបធាតុខាងក្នុង រូបធាតុខាងក្រៅ អ្វីៗទាំងអស់សុទ្ធតែជាធម្មៈ គឺធម្មជាតិ

បរិសុទ្ធស្អាតទាំងអស់ ប៉ុន្តែចិត្តយើងទេដែលធ្វើឱ្យធម្មជាតិទាំងនោះ ល្អក់កករដោយខ្លួនឯង។ ព្រឹត្តិការណ៍ខាងក្រៅតែងកើតមានឡើងជាធម្មតា ប៉ុន្តែយើងបានចាប់យករឿងអស់នោះមកប្រកាន់ថាជារបស់ខ្លួន ហើយចេះតែចង់ឱ្យវាទៅជាអញ្ចេះ ទៅជាអញ្ចោះតាមក្តីលង់ខ្លៅដ៏លីលារបស់យើង លុះចង់មិនបានតាមប្រាថ្នាក៏តាំងកើតការថ្នាំងថ្នាក់ចិត្ត ខ្លះមួរម៉ៅក្តៅក្រហាយ ខ្លះទោសៈហឹង្សាខ្លះអញ្ចឹងទៅ។ កុំពេលបានជួបយើងចង់កុំឱ្យព្រាត់ ពេលបានព្រាត់យើងចង់ឱ្យជួបពេលបាននិន្ទាយើងចង់បានសរសើរ ពេលបាត់យសយើងចង់បានយស ចេះតែចង់នោះមិនចេះស្ងប់ចិត្តទើបប្រែជាកាចសាហាវឥតមេត្តា ករុណា ព្រោះរស់នៅឥតសតិគ្រប់គ្រងចិត្ត។ ការរំខានចិត្តដែលភាសាបរទេសហៅថា ស្ត្រេស នោះវាគឺជាប្រតិកម្មចិត្តរបស់យើងទៅនឹងហេតុការណ៍ខាងក្រៅ ហើយសាងអារម្មណ៍ខុសឱ្យខ្លួនឯង នាំឱ្យអារម្មណ៍ច្របូកច្របល់ ព្រោះបើដុសខាត់តាក់តែងឱ្យកើតថ្នាំងថ្នាក់ នាំឱ្យកើតអារម្មណ៍ទើសទាស់ទៅក៏ទាំងដេកក្តៅក្រហាយចិត្តប្រទូស្តអារម្មណ៍ទៅ បើសាងបានអារម្មណ៍គួរជាទីត្រេកត្រអាល គួរប្រាថ្នាទៅក៏តាំងជាប់ជំពាក់ក្នុងអារម្មណ៍នោះទៅ នេះហៅថាចិត្តប្រព្រឹត្តិទៅដោយឥតសតិគ្រប់គ្រង បើមានសតិគេគប្បី

ព្យាយាមលះអកុសលវិតក្កៈឱ្យក្លាយទៅជាកុសលវិតក្កៈ នេះគឺជាសេចក្តីព្យាយាមត្រូវអង្គមគ្គគឺ **សម្មាវាយាមៈ** នេះឯង។ បុព្វហេតុនាំឱ្យមានការរំខានចិត្តដូចជា ការរស់នៅមានភាពមិនចុះសម្រុងនឹងគ្នារវាងប្តីប្រពន្ធ កូនចៅ ញាតិមិត្តជិតខាង គ្រួសារមានប្តីឬប្រពន្ធព្រាត់ប្រាស់ទៅទាំងស្លាប់ឬរស់ ប្តីប្រពន្ធលែងលះគ្នា ប្តីប្រពន្ធរៀបការហើយត្រូវរស់នៅបែកគ្នា មានសមាជិកគ្រួសារស្លាប់ ពពួកជនដែលមានជំងឺប្រចាំកាយ ស្ថានភាពជីវិតដែលជួបប្រទះការបាត់បង់ការងារ ពេលចូលនិវត្តន៍ ពេលមានផ្ទៃពោះ ព្រោះពិបាក ទីសទាស់ធ្វើអីមិនបានដូចកាលនៅទំនេរពោះ ហើយជីវសាស្ត្ររបស់ស្ត្រីនោះ តែងបង្កនាំឱ្យមានចិត្តរហ័សខឹង ឆេវឆាវច្រើន មានញាតមិត្តស្លាប់ ត្រូវផ្លាស់ប្តូរកន្លែងធ្វើការងារ កន្លែងសិក្សា មានការផ្លាស់ប្តូរលំនៅដ្ឋាន មានកូនប្រស្រីទៅរស់នៅឆ្ងាយពីផ្ទះ។ ជីវិតបុគ្គលម្នាក់ដែលជួបការរំខានចិត្តរឿយៗ ហើយមិនចេះថែរក្សាចិត្តឱ្យបានល្អទេ ក៏អាចទទួលឥទ្ធិពលបញ្ហានោះឱ្យក្លាយទៅជា ប្រែប្រួលចរិតឥរិយាបថបាន ដូចជាសត្វសុនខដែលនៅក្នុងចំណងឬឃ្លុំមាត់ តែងតែកាចសាហាវជាងសុនខដោះលែងឱ្យមានសេរីភាពជាធម្មតា។ ចិត្តមាននាមរូបជាបទដ្ឋាននេះ មានន័យសេចក្តីថា កាលបើចិត្តស្ងប់កាយក៏

ស្ងប់ ចិត្តបស្សទ្ធិ កាយបស្សទ្ធិ ចិត្តរំជួយញាប់ញ័រ កាយជ្រួលច្របល់ ចិត្តឈឺនាំឱ្យកាយឈឺ ឬកាយឈឺនាំឱ្យចិត្តឈឺតាមដែរ ព្រោះហេតុនេះ នៅពេលដែលចិត្តមានការរំខាន បាតុភូតជីវសាស្ត្រដែលកើតឡើងលើរាងកាយ គឺមានការរំញោចទៅលើបសាទរូបធំ ដែលភាសាបរទេសគេហៅថាម៉ែចលោកពេទ្យ? ពូហេងរវល់តែស្តាប់យ៉ាងជក់ចិត្តចំហរមាត់ដល់លោកតាសួរបន្ទាន់ពេកក៏ស្រាប់តែឆ្លើយបង្ហោសយករួចខ្លួនថា៖ ពួកវាក៏ហៅអញ្ចឹងដែរហ្នឹងលោកតា អូហ៎សុំទោសគេហៅថា ប្រព័ន្ធសុំប៉ាទិចលោកតា។ អង្គធម្មសាកច្ឆាប្រែជាញញឹមគ្រប់ៗគ្នា លោកតាសង្ឃទេពមានថេរដីកាបន្តទៀត៖ កាយយើងស៊ីដុំអាហារ ឯចិត្តវាស៊ីអារម្មណ៍ ដល់តែម្ចាស់វាសាងអារម្មណ៍មិនល្អឱ្យចិត្តស៊ី ចិត្តនោះកើតរោគនាំឱ្យវិនាសខ្លួនឯងទៅរកអត់អំពើ។ ហើយចុះបាតុភូតភាពលេចឡើងលើរាងកាយនេះតើវាយ៉ាងម៉េចដែរពេទ្យ? ពូហេងលើកនេះគាត់មានការផ្ងង់អារម្មណ៍បានល្អជាងមុន ទើបអធិប្បាយ៖ កូណាគុណាម្ចាស់! ពេលចិត្តមានស្ត្រេសវាភ្ជោចលើប្រព័ន្ធសុំប៉ាទិចឱ្យធ្វើការខ្លាំងខុសធម្មតា នាំឱ្យយើងតានតឹងក្នុងចិត្តដេកមិនលក់ ពិបាកផ្តុំអារម្មណ៍ មានគំនិតរាយមាយ ចេញរឿងមួយចូលរឿងមួយ ក្តៅក្នុងក្បាល

ក្រហាយភ្នែក មួរម៉ៅឆេវឆាវខឹងច្រើន តឹងទ្រូងរោយកញ្ឆឹងក តឹងណែន សាច់ដុំថ្ពាម ឈឺក្បាល ត្រជាក់ចុងដៃ បែកញើស្អិតត្រជាក់ស្រែងលើ ថ្ងាសលើកញ្ឆឹងក អស់កម្លាំង ហើយពេលខ្លះអស់កម្លាំងមែនទែនស្ទើរ តែផុតដង្ហើមម្តងៗ បេះដូងដើរញាប់ បុកទ្រូងខ្លាំងរហូតលើសសម្ពាធ ឈាមផងក៏មាន។ នេះព្រោះតែក្នុងរាងកាយមានការបញ្ចេញជាតិអាដ្រេ ណាលីន និងគ័រទីស៊ុលក្នុងក្រពេញលើតម្រងនោមច្រើនពេក ជាហេតុ ធ្វើឱ្យរូបធាតុជីវៈគីមីក្នុងរាងកាយមានការប្រែប្រួលយ៉ាងច្រើន ក្នុងឈាម មានជាតិស្ករលើសឬខ្វះ ជាតិខ្លាញ់កើនឡើង ជាតិកាល់ស្យូមនិងម៉ាញេ ស្យូមចុះក្នុងឈាម ជាតិលីតចូមចុះក្នុងឈាម ដែលធ្វើឱ្យរឹតតែបាត់ លំនឹងអារម្មណ៍កាន់តែខ្លាំងឡើង។ ពេលដែលបសាទរូបធំកើនការងារ ខ្លាំង បសាទរូបតូចឬប៉ារ៉ាសុំប៉ាទិចក៏ខំបង្កើតការងាររបស់ខ្លួនទប់ទល់ តបវិញដែរ ជាហេតុធ្វើឱ្យពេលខ្លះត្រូវសម្ពាធឈាមធ្វើទុក្ខខ្លាំងចង់គាំង បេះដូង តឹងណែនថប់ក្នុងទ្រូងពិបាករកដង្ហើមរលាកក្រពះពោះវៀនរាក អាចម៍ ទល់នោម ចេញរមាស់ ខ្មៅមុខ ជាំស្បែក ចុករោយដៃជើង ឈឺ ចាប់លើរាងកាយមិនដឹងមូលហេតុ ចុកខ្នងចង្កេះ។ ផលវិបាកកាន់តែ ធ្ងន់ធ្ងរទៅគឺនាំឱ្យកើតការបង្ករោគផ្សេងៗ ងាយកើតមហារីក ទឹកនោម

ផ្អែម ឈឺសន្លាក់រហូតលេចឡើង។ នូវបាតុភាពតាមផ្លូវចិត្តឱ្យចេះតែភ័យ ភ័យដោយអត់មូលហេតុច្បាស់លាស់។ បើសិនជាស្ត្រេសនៅតែបន្តទៀត យើងគ្មានមធ្យោបាយថយចេញពីវា ហើយក៏មិនអាចរំលត់វាដោយឧបាយនៃបញ្ញាទេ ពេលនោះយើងនឹងធ្លាក់ខ្លួនមានជំងឺផ្លូវចិត្តធំៗជាច្រើនទៀត ដូចជាជំងឺធ្លាក់ទឹកចិត្ត ជំងឺវិកលចរិតជាដើម។ ហ៊ឺ! សត្វលោកហ្អើយសត្វលោក ព្រោះតែការគិតខុសក្នុង **ទិដ្ឋិ មានៈ តណ្ហា ឧបាទាន** ត្រូវច្រានជីវិតខ្លួនឯងឱ្យធ្លាក់នរកទាំងរស់យ៉ាងនេះហ្ន៎? ល្អហើយចាំឆ្លងប្រធានបទនេះរួច យើងនឹងពិភាក្សាគ្នាថា តើត្រូវមានឧបាយយ៉ាងណា ដើម្បីដោះទុក្ខនេះបានតាមគន្លងព្រះពុទ្ធសាសនាណាក្មួយ (លោកតាសនលូកមាត់ពោលកាត់) ព្រោះហេតុនេះ អាត្មាភាពយល់ថាការធ្លាក់ស្រុតចុះនៃសីលធម៌សង្គម ព្រោះតែការរស់នៅមិនយល់ធម៌ រៀននិងបង្រៀនបដិបត្តិធម៌គឺជាភារកិច្ចស្នូលប្រចាំជីវិតយើងគ្រប់គ្នាដែលជាបុព្វការីជន។ មើលចុះសៀវភៅប្រលោមលោកអាសអាភាសកើនគរដូចភ្នំ ចំណែកសៀវភៅធម៌បែរជាមិនសូវសំបូរទៅវិញគួរឱ្យសង្វេគណាស់។ តើនៅមានហេតុបច្ច័យណាផ្សេងទៀតទេដែលនាំឱ្យមនុស្សសព្វថ្ងៃប្រែជាកាចសាហាវពុំសូវមានខន្តី មេត្តា ករុណា

ដល់គ្នានឹងគ្នានោះ? ពូហេងយកដៃលើកប៉ាន់តែចាក់ដាក់កែវហើយ ក្រេបផ្សើមបំពង់កបន្តិច រួចលើកដៃប្រណម្យចំពោះមហាសង្ឃហើយ ពេលថា៖ ខ្ញុំព្រះករុណាសូមឱកាសពីអង្គធម្មសាកច្ឆាដើម្បីបានចូលរួមមតិដូចតទៅ កត្តាសេដ្ឋកិច្ចនយោបាយក្នុងសង្គម នឹងក្នុងពិភពលោកក៏មានចំណែកនាំឱ្យមនុស្សកើតស្ត្រេសដែរ ព្រោះទីណាមានភាពក្រីក្រទីនោះ គឺជាប្រភពនៃបញ្ហាហើយរលកនយោបាយក៏តែងតែបោកបក់នៅទៅនោះ ព្រោះជាទីនាំឱ្យបានផលចំណេញដល់ពួកមហាអំណាចធំៗ។ សត្វលោកដែលរស់នៅមិនដឹងធម្មៈ មិនដឹងអនិច្ចំ ទុក្ខំ អនត្តា តែងតែរស់ក្នុងជីវភាពរឹតរវាជានិច្ច សព្វថ្ងៃកំណើនគ្រឿងបរិក្ខារដើម្បីបម្រើតាមតណ្ហាមនុស្សកើនច្រើនណាស់ ឆាងចក្រវថយន្ត ទោចក្រយានយន្ត ផ្សែងរ៉ាំពុលបរិស្ថានធ្វើឱ្យខ្យល់ពុលកើនឡើងក្នុងអាកាសធាតុ ឯខ្យល់បរិសុទ្ធកាន់តែតិចទៅៗ ធ្វើឱ្យពុលដល់ខួរក្បាលសរសៃប្រសាទមនុស្សដេកមិនលក់មួរម៉ៅ មានចិត្តរើរាយគិតចង់តែបំផ្លាញនេះបំផ្លាញនោះដើម្បីកែអផ្សុក។ គ្រាន់តែការដេក ការអង្គុយ ការជ្រកអាស្រ័យ គេនាំគ្នាបំផ្លាញដើមឈើដែលមានអាយុរាប់រយឆ្នាំយកមកធ្វើគ្រឿងតុ ទូ គ្រែនិងអចលនវត្ថុជាគ្រឿងលំអរផ្សេងៗ អត់ដឹងថាធ្វើនោះគឺជាការបំផ្លាញខ្យល់

ដង្ហើមខ្លួនឯងអីទេ ទីបំផុតដោយសារខ្យល់ពុលកើនឡើងខ្លាំង ធ្វើឱ្យ
កើតវិកលចរិតគ្រប់ៗគ្នា ទាំងពេទ្យទាំងប្រជាជនមិនដឹងអ្នកណា
ព្យាបាលអ្នកណា ឆ្កួតកាប់សម្លាប់ បាញ់ ចាក់ អាកររហុតឈាមគ្នា ពុះ
ទ្រូងរូងយកថ្លើមបារពោះវៀនគ្នាស៊ីទាំងរស់ដោយមិនដឹងខ្លួន តំណាក់
កាលនោះឯព្រះលោកហៅថា ឆ្កួតអរិយវិន័យ។ តើមានអ្នកណាម្នាក់
ដែលអាចជៀសផុតពីការបំពុលនេះទេ? ចិត្តអត់ធម៌ជាបច្ច័យឱ្យកើតការ
បំពុល ការបំពុលជាបច្ច័យឱ្យចិត្តអត់ធម៌ វាកើតបានជាវដ្ដៈមួយវិលឆ្ពោះ
ទៅកាន់ក្ដីវិនាសនៃលោកទាំងមូល។ អាហារសុទ្ធតែគ្រឿងបំពុលគ្រឿង
ញៀន ឱសថសុទ្ធតែក្លែងក្លាយ ការព្យាបាលសុទ្ធតែប្រើល្បិច។ ខែមុន
ក្មួយប្រុសខ្ញុំដួលម៉ូតូនាំចូលពេទ្យ និយាយផ្តេសផ្តាសការតែមួយភ្លែត
លក់អស់ស្រែភ្លឺ តើត្រូវពឹងអីរាល់ថ្ងៃហ្នឹង? បើមិនពឹងធម៌ធ្វើម៉េចបើ
លោកសន្និវាសគឺជាលោកដែលនឹងវិនាសទៅតែអញ្ចឹងហ្នឹង? ម្សៅស៊ុប
ប៊ីចេង ស៊ីទៅវាឱ្យរលួយសាច់ខ្លួនក្បាល លើសឈាម ងាប់មួយចំហៀង
ខ្លួន ឈឺក្បាល ដេកមិនលក់ ចុកចាប់ដៃជើង ប្រែចរិតទៅជាកាចឆេវឆាវ
ពិបាកគ្រប់គ្រងអារម្មណ៍ ឱកើតជំងឺឆ្កួតទ្បប់សោះ ស្រាប់តែយកមក
ផ្សាយថាលើកកម្ពស់សុខភាព ធ្វើឱ្យប្តីលែងដើរចោលផ្ទះ អើហ៎! លែង

ដើររួចមែនហ្នឹងបើវាងាប់មួយចំហៀងខ្លួនទៅហើយនោះ។ ប៊ីចេងសញ្ញា ខ្លះទ្រវែកប្រើយូរទៅក្លាយជាសញ្ញាក្បាលទ្រវែកសោះ។ ដំណោះស្រាយ បញ្ហានេះ គឺមានតែនាំគ្នាស្រលាញ់ធម្មជាតិឡើងវិញ កុំដូចរូបត្លុកក្មេងៗ កាន់តែកូនឈើហើយស្រែកថាដាំៗៗ ស្រាប់តែចាស់ៗលីពូថៅទៅតាម ពីក្រោយកាប់ៗៗ។ ល្មមកាត់បន្ថយភាពស្រណុកសុខស្រួលខ្លះ បន្ថយ ការសប្បាយភ្លើតភ្លើនក្រែងលោបានអាយុវែងទាំងអស់គ្នា ត្រូវតែរក ហេតុនាំឱ្យកើតបញ្ញាវិសុទ្ធិដែលជាការកំណត់ដឹងធម្មៈតាមសេចក្តីពិត នេះឯង សូមអនុមោទនា.....។ សាធុ សាធុ សាធុ មុំឆ្លៀតឱកាសនេះក៏ ចាប់ផ្តើមមួយសំណួរនឹងគេដែរ៖ ខ្ញុំសូមលើកចំងល់មួយជូនអង្គធម្ម សាកច្ឆាជួយដោះស្រាយ តើហេតុអីក៏មនុស្សអាក្រក់ចេះតែរស់នៅមាន ក្តីសុខម្លេះ? ឯមនុស្សល្អម្តេចក៏ចេះតែវិនាសដុនដាបទៅយ៉ាងនេះ? តា សនគ្រហែមបន្តិចដើម្បីបញ្ជាក់ថា គាត់នឹងទទួលភារៈកិច្ចនេះក្នុងការ ឆ្លើយ៖ មិនមែនធ្វើបុណ្យបានបាប ធ្វើបាបបានលុយទេណាមុំ អ្នកណា ពោលយ៉ាងនេះគឺបានបង្ហើបចិត្តឱ្យមិច្ឆាទិដ្ឋិតោងហើយ ទោសរបស់ មិច្ឆាទិដ្ឋិគឺជ្រៅជាងអនន្តរយកម្ម៥យ៉ាងទៅទៀតណា កុំពោលពាក្យ នោះនាំតែធ្វើចិត្តឱ្យសៅហ្មង កម្មមិនមានក្នុងផល ផលមិនមានក្នុងកម្ម

ទាំងពីរយ៉ាងសូន្យចាកគ្នានិងគ្នា តែពាលពេលកម្មមិនទាន់ឱ្យផលរមែង សំគាល់អំពើបាបថាមានរសផ្អែមដូចទឹកឃ្មុំ លោកនេះគឺគ្មាអ្វីទៀងទាត់ឡើយ កុំបានសម្លាប់គេហើយធ្វើក្រអឺតថាគេមិនដឹង តែកម្មថាដឹង។ បុគ្គលមានខ្លួនអ្នកដឹងដោយខ្លួនឯង កុកអាចភ្លេចជុងតែជុងមិនដែលភ្លេចកុកឡើយ រឿងកម្មនេះក៏ដូចគ្នា ចិត្តវាសន្សំវិបាកនឹងឱ្យផលខ្លួនឯងឱត្រូវបានគេសម្លាប់វិញជាមិនខាន។ បាបបុណ្យក្នុងលោក អ្នកណាធ្វើអ្នកហ្នឹងទទួល នេះជាពុទ្ធដីកាពេលព្រះអង្គត្រូវពួកនិគ្រន្តតិរ្ថីយ៍ចោទថាព្រះអង្គបានរំលោភហើយមួលកសម្លាប់នាងសុន្ទរីរួចកាយកប់ក្បែរបង្ហួចលុះក្រោយមកពួកឧត្បាតទាំងនោះត្រូវព្រះបាទបសេនទិកោសល ចាប់កប់រាស់ក្បាលកោសអស់ស្បែកក្បាល សល់តែលលាដ៏សស្គុសដូចផ្សិតពងលលកដុះតាមព្រះរបោះអញ្ចឹង។ មនុស្សអាក្រក់មានអំណាចធ្វើបាបគេឯង បើទោះជាច្បាប់មនុស្សមិនអាចធ្វើអ្វីបាន ក៏គេចមិនផុតពីច្បាប់ធម្មជាតិដែរ។ មនុស្សសាងអំពើបាបរមែង សៅហ្មងដល់ចិត្តខ្លួនឯង ហេតុនេះនៅពេលរៀបស្លាប់ ចិត្តដែលសៅហ្មងនោះរមែងនាំទៅកើតក្នុងអបាយភូមិជាមិនខាន ព្រោះគេស្លាប់ប្រកបដោយវិប្បដិសារីយ៍ ហើយត្រូវគេស្អប់គេប្រទេសផ្តាសាតកូនតចៅ ជាប់ឈ្មោះអាស្រូវក្នុង

ប្រវត្តិសាស្ត្រដ៏វែងឆ្ងាយ ព្រោះហេតុនេះ ជីវិតគឺជៀសពីអំពើល្អមិនបានឡើយ។ សូមអនុមោទនា! សាធុៗៗ ពូផេងអៀៗក៏សួរមួយសំណួរនឹងគេ៖ តើគេនាំគ្នារៀនធម៌ដើម្បីអ្វីហ្ន៎? មីងស៊ុមហួសចិត្តពោលកាត់ អូយ! ខ្ញុំកោតតែឯងចេះសួរទៅកើត បើឯងមិននិយាយក៏គ្មានអ្នកណាគេថាឯងគដែរ រៀនធម៌គឺដើម្បីចេះធម៌ហ្នឹងហើយ។ មហាសង្ឃឯក់ព្រះសីលៈហើយពោលដោយក្តីសួតស្ងប់ សំនួរនេះជ្រៅមិនងាយដោះស្រាយឡើយ តែអាត្មាព្យាយាមបកស្រាយបន្តិចលមើល ដើម្បីលួងលោមចំងល់របស់បណ្ឌិតឯង។ រៀនធម៌ គឺដើម្បីឱ្យចិត្តចេះរស់ជាមួយធម្មៈ រស់ដោយចុះសម្រុងជាមួយធម្មជាតិ ដើម្បីរស់ឱ្យបានសេចក្តីសុខ ឱ្យស្លាប់ស្រួល កុំឱ្យសេចក្តីស្លាប់មានវិប្បដិសារីយ៍នាំឱ្យធ្លាក់នរក នឹងឱ្យបានដល់ទីបំផុតគឺការមិនត្រលប់មកកើតទៀត។ តើរៀនធម៌ដូចម្តេចដើម្បីឱ្យបានសេចក្តីសុខ? គឺរៀនហើយត្រូវបដិបត្តិធ្វើតាមធម៌ បើមិនបដិបត្តិតាមទេនោះនឹងរកប្រយោជន៍មិនឃើញឡើយ ។ ដូចសព្វថ្ងៃនេះព្រះធម៌ ៨៤០០០ ព្រះលោកសង្គ្រោះឱ្យមូលចូលប្រជុំចុះទៅក្នុងកិច្ចបដិបត្តិត្រឹមតែ ៣យ៉ាងគឺ *សីល សមាធិ បញ្ញា* បញ្ញាបានដល់វិបស្សនានេះឯង។ កិច្ចបដិបត្តិ៣យ៉ាងនេះ នឹងចែករំលែកឱ្យដាច់ពីគ្នាដោយបដិបត្តិយកតែ

ម្យ៉ាងៗជាច់តែឯងនោះគឺមិនត្រូវទំនងតាមធម៌ ហើយមិនអាចចេញចាកទុក្ខបានទាំងស្រុងនោះឡើយ។ ព្រះពុទ្ធឃោសចារ្យបានពន្យល់ថា បុគ្គលដែលរក្សាសីលបានបរិសុទ្ធល្អហើយ តែចូលមិនដល់សមាធិ ឈ្មោះថា មិនបានគោរពនូវសីលរបស់ខ្លួន ហើយបុគ្គលដែលបានសមាធិរឹងមាំល្អហើយចូលមិនដល់វិបស្សនាឈ្មោះថា មិនបានគោរពនូវសមាធិរបស់ខ្លួននោះឡើយ បញ្ញាដែលអប់រំដោយសមាធិរមែងបានបុណ្យច្រើនបានអានិសង្សច្រើន ព្រោះធម៌ទាំងបីយ៉ាងនេះតែងតែដុសខាត់ឱ្យកំលាំងដល់គ្នានិងគ្នា ជួយទ្រទ្រង់គ្នាទៅវិញទៅមកឱ្យចម្រើនឡើង ហើយអាចប្រហារកិលេសបានជាស្ថាពរ ធម៌ណាលេចចេញតែឯងគឺជាធម៌ភ្លាវហើយ។ ប៉ុន្តែដោយសារតែទិដ្ឋិធ្វើឱ្យពុទ្ធបរិស័ទខ្លះបដិបត្តិតែសីល ខ្លះបដិបត្តិតែសមាធិ ខ្លះបដិបត្តិតែវិបស្សនា ព្រោងព្រាតដូចគោបែកហ្វូងគួរឱ្យអាសូរ ហើយស្រែកដាក់គ្នាថាផ្លូវឯងដើរគឺខុសទេ នាំឱ្យឃឹតយូរក្នុងវដ្តៈណាស់ ផ្លូវគ្នាឯណោះទើបធ្វើឱ្យសំសារវដ្តនៅខើចខ្លី ខ្លះថាបើទោះជាស្អែកត្រូវស្លាប់ក៏យើងនៅតែរក្សាសីលជាច់ខាតមិនធ្វើសមាធិ ព្រោះអង្គសីលដែលពួកឯងរក្សាគឺមិនបរិសុទ្ធល្អហ្មត់ហ្មងឡើយ។ ថាអីថាចោះឱ្យតែបានធ្វើ ធ្វើអីធ្វើចោះឱ្យតែបានអស់

អស់អីអស់ចោះឱ្យតែអស់កិលេស បើថាហើយ ធ្វើហើយ តែមិនអស់កិលេសថានោះធ្វើនោះគឺខុសទេ។ កិលេសគឺធម្មជាតិនាំចិត្តឱ្យសៅហ្មង ឱ្យល្អក់កករ ឱ្យក្តៅក្រហាយស្តាយក្រោយ ឱ្យអន្ទះសារឆ្លេឆ្លាលីលា ហេតុនេះបើបដិបត្តិធម៌មិនត្រូវទំនងតាមធម៌ទេ កិលេសមិនស្លាប់ងាយឡើយ បើវាមិនស្លាប់អស់ហើយគឺយើងនៅតែមានទុក្ខដដែលទេ អញ្ចឹងហើយបានជាអ្នករៀនធម៌ខ្លះចេញតែពីស្តាប់ធម៌ អាចកាន់កាំបិតដេញកាប់គ្នាបាននោះ។ បហានវិន័យ៥យ៉ាងដើម្បីប្រយុទ្ធជាមួយកិលេសគឺ៖

១- ***តទង្គបហាន*** លះកិលេសដោយវិបស្សនា ដោយការត្រិះរិះពិចារណាដោះទុក្ខចេញអំពីចិត្ត បញ្ញាចេះដោះទុក្ខចេញពីចិត្តទើបជាបញ្ញាដ៏ឧត្តម ធញ្ញវើឱ្យចិត្តរួចចាកទុក្ខស្គាល់រសនិព្វានជាខណៈៗដោះចេញចិត្តពីនរក ចិត្តអានិសង្សគឺមានទេវលោកជាសុគតិ។

២- ***វិក្ខម្ភនបហាន*** លះកិលេសដោយសមថកម្មដ្ឋាន គឺសមាធិជាន់សង្កត់សង្កិនញាំញីកិលេសឱ្យអស់ដៃអស់ជើង ដាច់ស្ងិតរញ្ជួយហើយត្រូវវិបស្សនាជាអ្នកជួយផ្តាច់រឹសគល់។

៣- ***សមុច្ឆេទ្ទបហាន*** កិលេសត្រូវលះដោយអរិយមគ្គ។

៤- ***បដិបស្សទ្ធិបហាន*** កិលេសត្រូវលះដោយអរិយផល។

៥- ***និស្សរណៈបហាន*** បានដល់ព្រះនិព្វានគឺលះអស់កម្មជាអកុសលនិងកុសល លះសីល សមាធិ វិបស្សនា លះទាំងខន្ធបញ្ចកៈនេះទៅទៀតផងដើម្បីឆ្លងដល់ត្រើយបរមសុខ។ ហេតុនេះកិលេសបើលះមិនត្រូវទំនងទេ វាមិនស្លាប់ងាយៗឡើយ សទ្ធាកអណ្តើកដែលលឹបលៗ ទុក្ខពាល់ត្រូវរឿយៗទីបំផុតក៏យល់ឃើញថា រៀនធម៌អស់ប្រយោន៍ព្រោះមិនអាចកែទំលាប់ចាស់បាន។ មិនមែនខ្លួន មិនមែនខ្លួន ស្រាប់តែចុកពោះកើតឡើងមានខ្លួនជាអ្នកចុកដដែល តើនេះព្រោះហេតុអ្វី? ព្រោះមានតែវិបស្សនាគ្មានសមាធិ សមាធិមានអំណាចរំងាប់វេទនាបានតែយើងមិនបានហាត់ធ្វើ រវល់តែខ្លាចសក្កាយទិដ្ឋិចាប់យក រវល់តែនាំគ្នាចាប់កំហុសធម៌ នាំគ្នាគុំគួននឹងសមាធិ មិនហ៊ាននិយាយពាក្យសមាធិឱ្យបានច្បាស់ទេ ខ្លាចវិបស្សនូបក្កិលេសវាបានចិត្ត។ សម្តែងធម៌ព្រះមិនសម្តែងតាមធំឱ្យបានត្រឹមត្រូវ ទៅសម្តែងតាមទិដ្ឋិរបស់ខ្លួនទៅវិញដូចធម៌ព្រះជាធម៌របស់ខ្លួន ហើយពោលថាខ្លាចធម៌ព្រះវិនាសត្រូវនាំគ្នាគោរពឱ្យបានម៉ត់ចត់ នាំគ្នាលះទិដ្ឋិក្នុងទិដ្ឋិ។ រៀនធម៌តំបូងឡើយគឺរៀនសម្រាប់ប្រដៅខ្លួនឯង ប្រដៅឱ្យកិលេសវាស្លូតបូតរៀនធម៌ មិនមែនដើម្បី

ទៅអ្នកអាងបង្ខិតបង្ខំប្រដៅអ្នកដទៃឱ្យជាងខ្លួនឯងឡើយ កុំរវល់តែចង់ឱ្យគេស្ងើចសរសើរ ចង់ឱ្យគេធ្វើតាមខ្លួន។ ការជាប់ក្នុងពួកគណៈ ការមានះប្រកាន់អីជាដើម នេះរឹតតែធ្វើឱ្យវិនាសសាសនាទេ ព្យាយាមចាប់កំហុសខ្លួនឯងនឹងបានជាសន្តបុគ្គល ព្យាយាមចាប់កំហុសអ្នកដទៃគឺបំផ្លាញខ្លួនឯង។ រៀនធម៌ប្រដៅខ្លួនឯងឱ្យច្រើនជាងរៀនប្រដៅឱ្យអ្នកដទៃ ព្រោះការប្រដៅអ្នកដទៃដែលយើងគ្មានចិត្តបរវិជ្ជា ជួនកាលអាចមានគ្រោះថ្នាក់ដល់ខ្លួនឯងក៏សឹងតែមាន។ ចង់ជួយអ្នកដទៃត្រូវជួយខ្លួនឯងជាមុនសិន ជួយខ្លួនឯងឱ្យរួចពីនឹមកិលេសសិនទើបអាចជួយអ្នកដទៃដោយការមិនជាប់ជំពាក់បាន បើការជួយអ្នកដទៃវាមានភាពងាយស្រួលម្លេះ សមមិនមានគេលើកគ្នាទៅជេរច្រាស់ឆ្មេះដាក់ព្រះពុទ្ធនោះឡើយ អ្នកចេះធម៌ក៏ងាប់ អ្នកមិនចេះធម៌ក៏ងាប់ ងាប់ដូចតែគ្នាហេតុនេះមិនគួរចាំបាច់អីដល់ថ្នាក់ធ្វើខ្លួនឱ្យលំបាកពេកនោះឡើយ ព្រោះទំរាំគេយល់ធម៌ យើងអាចមានភាពយឺតយ៉ាវខ្លួនឯងក៏មានមនុស្សសុទ្ធតែស្លាប់ទេ តែស្លាប់មានទីពឹង ស្លាប់គេមិនតិះដៀល ទើបបណ្ឌិតលោកសរសើរ។ កុំស្ទាបអង្អែលទិដ្ឋិដទៃទាំងលះទិដ្ឋិខ្លួនឯងទៀតផង ព្រោះទីណាមានទិដ្ឋិខុសគ្នានេះឯង គឺជាមូលហេតុនៃសង្គ្រាមសាសនាទៅថ្ងៃ

មុខ ហើយបើព្រះពុទ្ធសាសនានេះចូលរួមទិដ្ឋិនឹងគេនោះឈ្មោះថា ជាសាសនាចេញចាកទុក្ខមិនបានដូចតែគ្នាទេ អ្នកលះទិដ្ឋិបាន គឺបានទៅដល់គោលដៅសន្តិភាពមុនគេបង្អស់រៀនធម៌ គឺរៀនលះទិដ្ឋិខ្លះឯងនេះ ហើយដើម្បីក្លាយជាអ្នកចេះស្តាប់យោបល់អ្នកដទៃ អនុញ្ញាតឱ្យគេបញ្ចេញមតិយោបល់ដោយសន្តិភាព មិនហួងហែងមតិខ្លួនឯង។ លោកនេះគ្មានអ្វីពិតគ្មានអ្វីក្លែងក្លាយឡើយ លោកនេះសូន្យទទេ សូន្យចាកសត្វបុគ្គល សូនចាកតួរខ្លួន បើទិដ្ឋិកើតក្នុងខ្លួនតើនៅមានទិដ្ឋិនេះមកពីណា? អ្វីៗត្រឹមតែជាធម្មជាតិតែប៉ុណ្ណោះ។ ការព្រមរស់ជាមួយអនិច្ច ទុក្ខ អនត្តា គឺជាជោគជ័យរបស់ពុទ្ធបរិស័ទលើសមរភូមិកិលេស ពុទ្ធមរតកមានតម្លៃលើសមរតកក្នុងលោក តែមនុស្សភាគច្រើនទទួលយកមិនបាន ឯអ្នកទទួលយកបានហើយប៉ុន្តែខ្លះមិនអាចថែក្សារឬប្រើប្រាស់វាឱ្យបានត្រឹមត្រូវទៅទៀត។ ការស្វែងរកសន្តិភាពតាមផ្លូវចិត្ត គឺមិនមែនជាការងាយឡើយបើគ្មានមហាបុរសជួយដឹងនាំត្រង់ផ្លូវទេនោះ ហេតុនេះ ការប្រមាថចំពោះមាគ៌ាស្វែងរកសន្តិភាពនេះឈ្មោះថាជាការប្រមាថដល់តម្លៃជីវិតខ្លួនឯង ហើយជៀសមិនផុតពីភាពកំឡៅអវិជ្ជាគ្របសង្កត់គ្មានថ្ងៃបានរំដោះឱ្យរួចផុតឡើយ។ តើសេចក្តីមិនគួររបស់អ្នកសិក្សា

ទាំងឡាយនោះតើដូចម្តេច? សិក្សាវិជ្ជានេះហើយមិនគួរនឹងយកទៅប្រមាថវិជ្ជាដទៃថាអន់ថយ យឺតយ៉ាវមិនល្អដូចជាចេះផ្នែកគន្ថធុរៈហើយបែរជាទៅតិះដៀលផ្នែកវិបស្សនាធុរៈថា ជាអ្នកប្រព្រឹត្តធូររលុង ឬចេះវិបស្សនាធុរៈហើយទៅតិះដៀលផ្នែកគន្ថធុរៈថា ជាពួករកធម៌បិទភ្នែកធ្វើម៉េចឃើញធម៌ ឬដៀលថា ជាមនុស្សអត់បញ្ញាព្រោះរវល់តែជាប់ជំពាក់ក្នុងក្តីស្ងប់ ដំអក់ឱ្យវដ្តៈយឺតយូរ។ អ្នកចេះវិទ្យាសាស្ត្របែរជាតិះដៀលអ្នករៀនធម៌ថា រៀនវិជ្ជាមិនទាន់សម័យនិយម មិនចេះអភិវឌ្ឍន៍ខ្លួនឯង ធ្វើឱ្យខ្លួនឯងទន់ខ្សោយ ម្ល៉ៃអង្គុយសណ្តំចិត្តខ្លួនឯងឱ្យដេកលក់ ឱ្យរលត់មហិច្ឆតាដែលជាគោលដៅចំបងរបស់មនុស្ស រស់នៅក្នុងភាពស្រមើស្រម៉ៃជាមួយនឹងជីវភាពអាទិទេព ដែលគ្រាន់តែជារឿងព្រេងនិទានតៗគ្នាគ្មានការពិត។ ឯអ្នកចេះធម៌បែរជាតិះដៀលអ្នកវិទ្យាសាស្ត្រថា សាងតែអំពើបាបអំពើឥតប្រយោជន៍ បង្កើតតែគំនរសម្រាម គំនរថ្មលើផែនដីឱ្យសង្កត់មនុស្សស្លាប់វាល់លាន បំពុលមនុស្សដោយសម្ភារៈអូសទាញលោកឱ្យធ្លាក់ក្នុងក្តីវិនាសជាដើម ព្រោះវិទ្យាសាស្ត្រខ្លះក៏ត្រឹមត្រូវរបស់គេដែរ ក្នុងន័យមនុស្សធម៌នោះ។ អ្នកសិក្សាទាំងឡាយមិនត្រូវយកចំណេះទៅសាងបាបធម៌ អ្នកសិក្សាទាំងឡាយគួរយកចំណេះនោះ

ទៅធ្វើឱ្យអស់នូវអាសវៈផង កុំគ្រាន់តែធ្វើជាគ្រឿងប្រដាប់សម្រាប់ជួយឱ្យអាសវៈកំរើកឡើង ត្រូវចម្រើនគុណធម៌ដល់ខ្លួនឯងនិងអ្នកដទៃផង មិនគួរសិក្សាហើយបោះបង់ចោល ការចេះដឹងនោះឱ្យបាត់បង់ទៅដោយឥតប្រយោជន៍នោះឡើយ អត្ថន័យការសិក្សាគួរតែជាសន្តិភាពនិងអភិវឌ្ឍន៍ សូមអនុមោទនា! សាធុ សាធុ សាធុ ។ ណាពិរោះសាច់ធម៌ណារាត្រីកាលកាន់តែយប់យន់ទៅ ខ្យល់ត្រជាក់បានបក់ជាត់ត្រសៀកៗមកបបោសអង្អែលកាយា ឱ្យពួកសត្វស្រែកឃ្លានគុណធម៌ទាំងអស់នេះវង្វែងក្នុងទុព្វមន្តធម្មជាតិ។ មាត់គកទាំងឡាយជាសត្វសភាវគតិតែងធ្វើត្រាប់ បិតារបស់ខ្លួនក៏ទទះស្លាបរងាវញាប់តៗគ្នាយ៉ាងរន្ថើនដើម្បីបំពេញនាទីជានាឡិកាធម្មជាតិ ឯសត្វរាត្រីចរប្រឹងប្រែងរូតរះបញ្ចប់ភារកិច្ចកុំឱ្យពួកសត្វទិវាចរ បានមកឃើញគំនិតច្នៃប្រឌិតដ៏រស់រវើកក្នុងទីងងឹតរបស់ខ្លួនព្រោះវាជាទេពកោសល្យប្រចាំត្រកូល។ ក្មេងៗក្បែរអង្គធម្មសាកច្ឆាខ្លះខ្ជិលគិតច្រើនពីបញ្ហាទុក្ខ ចាំថ្ងៃណាថ្ងៃហ្នឹងទៅក៏លង់លក់កើយភ្លៅម្តាយ ប្រុសដេតនិងស្រីណែតចេះតែស្ងាប ហើយពត់ខ្លួនដើម្បីឱ្យសរសៃសរសូងវាប្រឹងសុះស្ងារឡើងកុំឱ្យស្ពឹកស្រពន់ លោកតាសនយល់សភាពមិនសូវអំណោយផល ព្រោះខ្លាចអស់អ្នកស្តាប់ធម៌

គាត់ប្រញាប់តាំងសំណួរខ្លីមៗភ្លាម៖ តេជគុណម្ចាស់ តើធុរៈត្រូវបំពេញក្នុងសាសនាព្រះជិនស្រីមានប៉ុន្មានយ៉ាងទៅទាន សូមប្រោសប្រទានដល់សត្វដែលល្ងង់ខ្លៅផងគុណម្ចាស់? មហាសង្ឃឈ្លោកព្រះភ័ក្ត្របន្តិច ប៉ុន្តែក្រសែព្រះនេត្រនៅឆ្ងៀងមើលម្ចាស់សំណួរសឹងមុតធ្លុះព្រោះកោតសរសើរនឹងបញ្ញាវាងវៃ ដែលចោទសួរចំមធ្យោបាយដោះស្រាយ ប្រស្នាជីវិតរបស់សត្វលោក៖ ចម្រើនពរញោម! ព្រះសទ្ធម្មបីដែលត្រូវតែវិលចូលគ្នាទាំងបី ឆ្លុងជាខ្សែពួរជីវិតជាមគ្គវិថីសម្រាប់សត្វឆ្លងទៅកាន់ទីបំផុតនៃទុក្ខ ហើយសត្វចាប់តោងពួរណាមួយក៏ត្រូវតែតោងឱ្យបានគ្រប់ទាំងបីនោះគឺ៖

១- ***ព្រះបរិយត្តិសទ្ធម្ម***

២- ***ព្រះបដិបត្តិសទ្ធម្ម***

៣- ***ព្រះបដិវេធសទ្ធម្ម***

ព្រះបរិយត្តិជាត្រីវិស័យ ព្រះបដិបត្តជាពិសោធន៍ ព្រះបដិវេធគឺជាជោគជ័យនៃពិសោធន៍ និងជាចម្លើយរបស់ប្រាថ្នាទុក្ខ។ ការសិក្សាណាក៏មានទ្រឹស្តី ហើយត្រូវមានការពិសោធន៍ឃើញថាត្រឹមត្រូវតាមទ្រឹស្តី

នោះពិតប្រាកដហើយ គេរមែងអស់សេចក្តីសង្ស័យដែលជាអន្ទាក់ដ៏មាំ ក្នុងការបណ្តុះកុសលធម៌ ជាគុណវិសេសក្នុងព្រះពុទ្ធសាសនានេះ។ នោះហើយ គឺជាជោគជ័យដែលមិនត្រលប់ជាចាញ់វិញនៅលើវិថីជីវិតរបស់គេ គេបានទៅដល់ទីបំផុតនៃលោកទាំង៣ ***កាមលោក រូបលោក អរូបលោក*** បច្ចវេក្ខណាញាណបានកើតឡើង គេពិចារណាថាគេបានអស់កិច្ច ក្នុងព្រពុទ្ធសាសនានេះហើយ សោឡសកិច្ចគេបានបំពេញហើយអវិជ្ជាសវៈគេបានកំចាត់ចេញអស់ហើយ កិច្ចដទៃគឺពុំមានទៀតឡើយ គេនៅត្រឹមតែសោយផលចិត្តដើម្បីរងចាំថ្ងៃចុងក្រោយនៅលើផែនដីនេះបានមកដល់តែប៉ុណ្ណោះ។ តើធុរៈដែលត្រូវបំពេញនោះមានប៉ុន្មានយ៉ាង? មានត្រឹមតែពីរយ៉ាងប៉ុណ្ណោះណាញោម គឺ***គន្ថធុរៈ*** និង ***វិបស្សនាធុរៈ*** ។ គន្ថធុរៈបានដល់សមថកម្មដ្ឋានដែលជាទីហ្វឹកហាត់ឱ្យចិត្តស្ងប់រហូតឱ្យក្លាយកិលេសបានជាសមុច្ឆេទ្ធ នៅពេលដែលកិច្ចបដិបត្តិរបស់គេចូលឱ្យបានដល់និរោធសមាបត្តិ ឬសញ្ញាវេទយិតនិរោធ ហើយពិចារណាសង្ខារធម៌ក្នុងត្រៃលក្ខណ៍កិច្ច បដិបត្តិបែបនេះហៅថាសមថយានិកបុគ្គល ព្រោះគេពឹងសមថសុទ្ធៗជាខាងដើមដើម្បីពុះបំបែកកិលេសឱ្យល្អិតម៉ត់។ ចំណែកឯវិបស្សនាធុរៈ បានដល់វិបស្សនា

កម្មដ្ឋាន គឺជាការហ្វឹកហាត់ឱ្យចិត្តស្ងប់ដែរ ហើយធ្វើឱ្យក្សីយកិលេស បានដូចគ្នា គេប្រើសតិធ្វើឱ្យកិលេសរឹងខះស្ងួតអស់ដោយបញ្ញាដ៏ប្រពៃ កិច្ចបដិបត្តិបែបនេះហៅថា វិបស្សនាយានិកបុគ្គល ព្រោះគេពឹងទៅលើ វិបស្សនាតែម្យ៉ាង នឹងខណិកសមាធិដើម្បីដុតកំទ្បោចកិលេសឱ្យឆេះ វិនាសអស់។ ចុះហេតុអ្វីក៏ព្រះលោកចាំបាច់បំបែកកិច្ចបដិបត្តិនេះឱ្យបែក ជាពីរញ្ជោម? **ពូហោងតបៈ** ដើម្បីតម្រូវតាមអធ្យាស្រ័យឧប្បនិស្ស័យសត្វ ព្រះអង្គ។ ត្រូវហើយញ្ជោម (ព្រះអង្គញញឹមតប) ប៉ុន្តែបើព្រះយោគាវចរ អង្គណាលោកបង្អោនចិត្តទៅយកសមាបត្តិណាមួយ ព្រោះលោកដឹងថា លោកនៅខ្វះសមាបត្តិនោះ លោកក៏អាចបដិបត្តិយកតាមការប្រាថ្នា ដើម្បីឱ្យចិត្តបានធឹករសបីតិរបស់ព្រះកម្មដ្ឋានប្លែកៗគ្នា។ ការពោលអំពី កិច្ចបដិបត្តិព្រះធម៌ក្នុងរយៈពេលដ៏ខ្លីបែបនេះ អាត្មាភាពមិនអាច អធិប្បាយឱ្យបានអស់ល្អិតល្អន់បានទេ អាត្មាសូមលើកយកតែគោលៗ ព្រះកម្មដ្ឋានមកសម្តែង ហើយចាំសម្តែងលំអិតក្នុងកម្មដ្ឋានណាមួយ ដែលមនុស្សភាគច្រើនអាចបដិបត្តិតាមបានមិនលំបាកតែប៉ុណ្ណោះ។

ក្នុងសមថកម្មដ្ឋានដែលយើងនិយមហៅថាសមាធិនោះមានកម្មដ្ឋាន ៤០ ដែលគួរដល់នូវការហ្វឹកហាត់ឱ្យត្រូវតាមអធ្យាស្រ័យរបស់សត្វគឺ ***កិ***

សណា១០ អសុភ១០ អនុស្សតិ១០ អរូបឈាន៤ ព្រហ្មវិហារធម៌៤ ចតុធាតុវដ្ឋាន១ និង អាហារបដិកូលដ្ឋាន១ គំរប់ជា៤០។ ក្នុងវិបស្សនាកម្មដ្ឋានមានភូមិជាអារម្មណ៍៧៣ នេះតាមវិបស្សនានាជំនាន់ពុទ្ធកាល ឯវិបស្សនាបច្ចុប្បន្នកាលគេនិយមបដិបត្តិតាមមហាសតិប្បដ្ឋាន៤ដែលកុលបុត្រខ្លះលោកហៅថា ***សតិប្បដ្ឋានវិបស្សនា ឬសតិប្បដ្ឋានភាវនា*** ។ អារម្មណ៍៧៣នោះមានដូចជា ***ខន្ធ៥ ធាតុ១៨ អាតាយន:១២ សច្ច:៤ ឥន្ទ្រីយ៍២២ បដិច្ចសមុប្បាទ១២*** ។ អារម្មណ៍ទាំង៧៣នេះ យោគាវចរត្រូវអប់រំចម្រើនឱ្យឃើញត្រឹមតែជារូបធម៌ នាមធម៌ ក្នុងត្រៃលក្ខណ៍តែប៉ុណ្ណោះ ព្រោះអត្តភាពនេះមានត្រឹមតែរូបធម៌នាម នាមធម៌ មិនមានអ្វីឱ្យលើសនេះឡើយ ឯការអប់រំចម្រើនតាមវិសុទ្ធិ៧ គឺត្រូវដុសខាត់រូបធម៌ជាមុនទើបកើតនាមធម៌តាមក្រោយ នេះជាការពន្យល់របស់ព្រះពុទ្ធឃោសចារ្យ។ ដោយសារតែការអធិប្បាយពន្យល់របស់ព្រះពុទ្ធបរមគ្រូ គឺតម្រូវតាមអធ្យាស្រ័យសត្វធ្វើឱ្យយើងមើលឃើញថាកិច្ចបដិបត្តិហាក់ដូចជាខុសគ្នា តាមពិតគឺមិនមានអ្វីខុសគ្នានោះឡើយ ប៉ុន្តែរយៈពេលត្រាស់ដឹងធម៌របស់សត្វលោកគឺមិនដូចគ្នា ព្រោះអាស្រ័យលើឧប្បនិស្ស័យដែលបានសន្សំទុកមក ព្រះពុទ្ធបានបែងចែកបុគ្គលជា៤ពួក៖

១- ***ឧគ្ឃដិតញ្ញាបុគ្គល*** ពួកលោកបានស្តាប់ធម៌តែកន្លះគាថាក៏បានត្រាស់ដឹង។

២- ***វិបចិតញ្ញាបុគ្គល*** លោកស្តាប់ដោយពិស្តារទើបត្រាស់ដឹងធម៌បាន។

៣- ***វេនេយ្យសត្វ*** ស្តាប់ពិស្តារហើយត្រូវហ្វឹកហាត់បដិបត្តិច្រើនជាតិទៀតត្រាស់ដឹងធម៌បាន។

៤- ***បទបរមបុគ្គល*** ពួកនេះមិនចេះស្តាប់ធម៌ឡើយ។

ហេតុនេះការត្រាស់ដឹងធម៌ គឺអាស្រ័យលើបុគ្គលមានឥន្ទ្រីយ៍ចាស់ក្លា ឬទន់ខ្លីនិងកិលេសក្លៀវក្លាឬមិនក្លៀវក្លានេះឯង។ តទៅនេះអាត្មាភាពនឹងសម្តែងអំពីកិច្ចបដិបត្តិព្រះធម៌ដូចតទៅ៖

១- ***ពេលវេលា*** កាលដែលត្រូវអប់រំចម្រើន គឺវេលាដែលស្ងាត់ដូចជាពេលយប់រៀបសំរាន្ត ឬពេលទៀបភ្លឺ ពេលថ្ងៃក៏បានឱ្យតែស្ងប់ស្ងាត់ចាកសំលេងអ៊ូអរ។

២- ***ទីកន្លែង*** ចូលកាន់ព្រៃស្ងាត់ ផ្ទះស្ងាត់ ឬបន្ទប់ស្ងាត់ចាកសំលេងអ៊ូអរដែលនាំឱ្យរំខានកិច្ចបដិបត្តិ។

៣- ***ក្នុងពេលចម្រើន*** គឺអាចធ្វើបានទាំងអស់ ដេក ដើរ ឈរ អង្គុយ ប៉ុន្តែឥរិយាបថអង្គុយ គឺល្អជាងគេ ព្រោះមិនរាយមាយនិងនាំឱ្យងោកងុយ។

អង្គុយពែនភ្នែនតាំងកាយឱ្យត្រង់ ជើងស្តាំដាក់លើជើងឆ្វេង ដៃស្តាំដាក់លើដៃឆ្វេង មេដៃទល់មេដៃ ឥរិយាបថបែបនេះគឺសម្រួលកាយឱ្យស្ងប់ដើម្បីជួយឱ្យចិត្តឆាប់ស្ងប់ដែរ ហើយរក្សារបត់ឈាមរត់ឱ្យប្រព្រឹត្តទៅស្មើល្អ និង អណ្តាតទល់ក្រអូបលើរបស់មាត់ ឥរិយាបថនេះគឺត្រូវបដិបត្តិទាំងសមថនិងវិបស្សនា អធ្យាស្រ័យអ្នកខ្លះអង្គុយក្នុងទីស្ងាត់នាំឱ្យរាយមាយ ខ្លះអង្គុយក្នុងទីវាលនាំឱ្យរាយមាយ ខ្លះនៅក្នុងផ្ទះរាយមាយត្រូវទៅរកទីអារាមឆ្ងាយ ខ្លះទៅឆ្ងាយក្នុងព្រៃនាំឱ្យរាយមាយវិញ។ ត្រូវលះកាត់ក្តីកង្វល់ទាំងអស់ចោលចេញកង្វល់ នឹងផ្ទះសំបែងកូនចៅទ្រព្យសម្បត្តិជំងឺដំកាត់ ត្រូវកាត់លះចោលមួយរយៈសិន។ តើត្រូវរើសកម្មដ្ឋានណាមួយយកមកចម្រើន? កម្មដ្ឋានទាំងអស់សុទ្ធតែត្រូវអប់រំចម្រើនតាមចរិតអធ្យាស្រ័យ ហើយអ្នកឱ្យកម្មដ្ឋានគឺត្រូវមានចិត្តបរវិជ្ជា គឺវិជ្ជាអាចដឹងចិត្តអធ្យាស្រ័យអ្នកដទៃ ហើយសូម្បីតែព្រះពុទ្ធបរមគ្រូព្រះអង្គមានអាសវក្ខយវិជ្ជាអាចដឹងការពោលពាក្យ ដឹងឧបាយនាំឱ្យ

សត្វអស់អាសវៈផង នៅតែមនុស្សខ្លះមិនអាចទទួលការប្រៀនប្រដៅពីព្រះអង្គបាន ត្រូវទទួលកម្មដ្ឋានអំពីព្រះសាវ័កវិញ។ ចរិត៦យ៉ាងគឺជាជំងឺធ្ងន់របស់សត្វគឺជាបុព្វហេតុអបាយភូមិ ឯព្រះកម្មដ្ឋានគឺជាឱសថសម្រាប់ព្យាបាលជំងឺ ព្រះសម្មាសម្ពុទ្ធគឺជាម្ចាស់ថ្នាំ និងជាវេជ្ជបណ្ឌិតតែម្ចាស់ថ្នាំបរិនិព្វានចោលយើងហើយ យើងមានតែត្រូវផ្សំឱសថនោះខ្លួនឯងតែប៉ុណ្ណោះ រំពឹងតាមការមើលចរិតចរិយាអីនោះវាក៏មិនត្រឹមត្រូវទាំងស្រុងដែរ។ កម្មដ្ឋានណាដែលយើងហ្វឹកហាត់អប់រំចម្រើនអស់ពេលប្រមាណជាងមួយខែហើយនៅតែរកមិនឃើញចិត្តស្ងប់ទៀត គួរតែប្តូរកម្មដ្ឋាននោះចេញ។ តើត្រូវខំស្វែងរកចិត្តស្ងប់នោះយកមកធ្វើអ្វី? ចិត្តស្ងប់នោះមានប្រយោជន៍អីទៅលោកតា? (មីងស៊ុមសួរ) ចម្រើនពរញ្ជោម! ចិត្តស្ងប់គឺជាសមាចិត្ត ជាជោគជ័យរបស់សតិ និងវីរយៈលើមោហៈអវិជ្ជា អានិសង្សរបស់ចិត្តស្ងប់គឺសុខៈ និងឯកគ្គតាចិត្តស្ងប់គឺជាសុខភាពចិត្តដ៏អស្ចារ្យ ហើយកាលបើមានចិត្តស្ងប់នាំឱ្យកាយក៏ស្ងប់ កាយស្ងប់នាំឱ្យជាជំងឺកាត់ទាំងអស់ ជាជំងឺបេះដូង តម្រងនោម ក្រពះថ្លើម សួតដែលឈឺរ៉ាំរ៉ៃ បើទុកជាមិនបានជាដាច់ទាំងស្រុង ក៏អាចជួយសម្រួលកុំឱ្យជំងឺអស់នោះវាធ្ងន់ធ្ងរលឿនពេកដែរ ព្រោះរាងកាយមានជំងឺ

គឺយើងត្រូវព្រួញមួយហើយដល់តែចិត្តគិតព្រួយភ័យបារម្ភច្រើន គឺរឹតតែជំរុញឱ្យសភាពជំងឺកាន់តែធ្លាក់ធ្ងន់ធ្ងរទៅ គឺយើងត្រូវព្រួញមួយថែមទៀតអត់ប្រយោជន៍។ សរុបមក ព្រះកម្មដ្ឋានដែលយើងគួរជ្រើសរើសយកមកអប់រំចម្រើន គឺបើតាមយោបល់អាត្មាគួររើសយកព្រះកម្មដ្ឋានអានាបានុស្សតិ ព្រោះបច្ចុប្បន្ននេះមនុស្សភាគច្រើនគឺច្រើនមានមោហៈចរិត ដោយសារតែបញ្ហាសេដ្ឋកិច្ចនយោបាយវាវឹកវរខ្លាំងពេកនាំឱ្យមនុស្សគិតច្រើនវង្វេងស្មារតីរាយមាយ ហេតុនេះព្រះកម្មដ្ឋានអានាបាគឺជាការហ្វឹកហាត់ឱ្យកើតសតិដ៏ខ្លាំងខ្លា និងជាការសម្រាកចិត្តដ៏អស្ចារ្យរកព្រះកម្មដ្ឋានណាប្រដូចគ្មាន។ មនុស្សយើងគ្រប់គ្នាចេះសម្រាកតែកាយ ប៉ុន្តែចិត្តគឺមិនចេះសម្រាកឡើយ មានតែកម្មដ្ឋាននេះតែមួយគត់ដែលអាចឱ្យយើងចេះសម្រាកចិត្តបាន។ សមដូចព្រះពុទ្ធដីកាបានពោលទុកក្នុងគម្ពីរ សុត្តន្តបិដកមជ្ឈិមនិកាយ លេខ២៦ ទំព័រ៣៥៩ បានសម្តែងថា៖ អានាបានុស្សតិដែលបុគ្គលបានចម្រើនបានធ្វើរឿយៗ ហើយរមែងញុំាងសតិប្បដ្ឋាន៤ឱ្យពេញបរិបូរណ៌បាន សតិប្បដ្ឋាន៤ ដែលបុគ្គលបានចម្រើន បានធ្វើឱ្យរឿយៗហើយរមែងញុំាងឱ្យពោជ្ឈង្គៈ៧ឱ្យពេញបរិបូរណ៌បាន ពោជ្ឈង្គៈ៧ ដែលបុគ្គលបានចម្រើនបានធ្វើឱ្យ

រឿយៗហើយរមែងញុំាងវិជ្ជានិងវិមុត្តិឱ្យពេញបរិបូរណ៍បាន ព្រោះហេតុនេះអានាបានុស្សតិ គឺជាហេតុជិតនៃព្រះនិព្វាន។ លោកតាសនលើកដៃប្រណម្យរួចទូលសួរ៖ អញ្ជឹងព្រះកម្មដ្ឋានអានាបានេះ ពេលកំពុងបដិបត្តិតើអាចកើតមានសតិប្បដ្ឋានទាំង៤ មានដូចជា ***កាយ វេទនា ចិត្ត ធម៌*** កើតឡើងគ្រប់ទាំង៤ ឬទេគុណម្ចាស់? ព្រះភិក្ខុសង្ឃជ្រួញចិញ្ចើមជញ្ជឹងគិតមួយស្របក់ទើបពោលតប៖ គឺមានកើតឡើងពេញលេញគ្រប់គ្រាន់ល្អណាស់តាមពុទ្ធដីកាក្នុងកាយានុបស្សនាសតិប្បដ្ឋាន គឺយើងកំណត់ដឹងខ្យល់ដង្ហើម ដើម្បីឱ្យកើតសតិគ្រាន់តែប៉ុណ្ណឹង ហេតុម្តេចក៏នាំឱ្យកើតសតិបាន? ព្រោះពេលដែលកំពុងតែតាមដឹងខ្យល់ស្រាប់តែចិត្តប្រែជារង្វេងរាយមាយទៅតោងអារម្មណ៍ផ្សេងៗ យើងត្រូវព្យាយាមរលឹកដឹងទាន់ ហើយឈប់គិតដេញតាមអារម្មណ៍រាយមាយនេះយកសតិមកតាមកំណត់ដឹងខ្យល់ចេញចូលវិញ ធ្វើតែយ៉ាងនេះដោយមិនអង្គុយចង់ឱ្យបានឃើញនេះឃើញនោះ មិនអង្គុយគិតពីរឿងខ្លួនឯង គិតពីរឿងអ្នកដទៃ មិនអង្គុយបួងសួង មិនអង្គុយប្រាថ្នា មិនអង្គុយមួរម៉ៅធុញទ្រាន់ ប៉ុន្តែគឺអង្គុយដោយមានការតាំងចិត្តប្តូរផ្តាច់ក្នុងការបដិបត្តិធម៌ដើម្បីចេញចាកទុក្ខតែប៉ុណ្ណោះ។ ក្នុងវេទនានុបស្សនា

សតិប្បដ្ឋាន យើងអាចកំណត់ដឹងនូវវេទនាក្នុងវេទនា គឺសុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា កំណត់ដឹងនូវភាពមិនទៀង **អនិច្ចំ ទុក្ខំ អនត្តា** តាមផស្សៈជាសុខ ផស្សៈជាទុក្ខរហូតបានឈានផស្សៈទៀតផង។ ពិនិត្យឃើញវេទនាកើតរលត់មិនទៀងជាទុក្ខ មិនបិតក្រោមការបង្គាប់បញ្ជារបស់យើងឡើយ ព្រោះពេលវេលាកើតក៏កើតឡើងយើងមិនបានបង្កើតវាទេ ហើយពេលវារលត់ទៅក៏មិនបានលា គឺវារលត់ទៅដោយឯកឯងមិនបិតនៅក្រោមអំណាចអ្វីឡើយ។ វេទនាទាំងអស់ គឺសុទ្ធតែមិនមែនជារបស់យើងឡើយ ប៉ុន្តែការប្រកាន់ហួងហែងរបស់យើងគឺចង់បានតែសុខវេទនា ហើយបដិសេធទុក្ខវេទនាមិនចង់ឱ្យជួប ប៉ុន្តែមិនមែនជាហានៈឡើយ។ ចិត្តានុបស្សនាសតិប្បដ្ឋាន គឺយើងកំណត់ដឹងចិត្តដោយបញ្ញា និងសតិឱ្យឃើញតំណចិត្តដែលកើតរលត់តជាប់គ្នាមិនដាច់ជាហូរហែរមិនអាចបង្គាប់បញ្ជាបាន ***រាគៈ ទោសៈ មោហៈ*** កើតឡើងក្នុងចិត្តក៏ដឹង ការដែលត្រឹមតែមានសតិដឹងនេះឈ្មោះថាបានកំទេចញ៉ាំញីជាន់ឈ្លីរកិលេសដោយបញ្ញា ព្រោះការត្រឹមតែដឹងនេះកើតឡើងធ្វើឱ្យថាមពលចិត្តដែលបានកើតឡើង បម្រុងនឹងប្រព្រឹត្តិខុសតាមកាយវាចានោះត្រូវចុះខ្សោយកំលាំងដោយស្វ័យប្រវត្តិ ដូចជាកំលាំងទឹកក្នុង

ប្រឡាយបើយើងមិនកាយបង្ហូរឱ្យបែកខ្ទែកទេ គឺទឹកក្នុងប្រឡាយនោះ ហូរទៅមានសន្ទុះខ្លាំងណាស់។ ពេលខ្លះបថុជ្ជនមានសតិរលឹកដឹងទាន់ហើយ ប៉ុន្តែបែរជាត្រូវរលត់ទៅទាំងសតិព្រោះតែចេះមិនឈ្នះចង់ ចង់ខ្លាំងពេកទប់មិនបានក៏ទៅទាំងសតិតែម្តងទៅ។ ប៉ុណ្ណឹងក៏នៅគ្រាន់បើដែរ ព្រោះថ្ងៃណាមួយគង់នឹងមានឆន្ទៈប្តូរទំលាប់មិនល្អរបស់ចិត្តនេះជាមិនខាន។ ធម្មានុបស្សនាសតិប្បដ្ឋាន យើងអាចកំណត់យកកម្មដ្ឋានអានាបាមកបដិបត្តិជាសកល កិច្ចបដិបត្តិក្នុងកម្មដ្ឋានអានាបាមាន៤ តំណាក់កាលគឺ៖

១- ***រាប់ខ្យល់***

២- ***ដឹងខ្យល់***

៣- ***តាមដឹងខ្យល់***

៤- ***រក្សានិមិត***

រាប់ខ្យល់ កាលបើអ្នកបដិបត្តិធម៌មានចិត្តរាយមាយខ្លាំងពេក ព្រះលោកឱ្យរាប់ខ្យល់ គឺខ្យល់ចូលមួយ ចេញមួយ ត្រូវរាប់ថាមួយខ្យល់ចូល មួយខ្យល់ចេញ មួយទៀតត្រូវរាប់ថា ពីរ បី បួន រាប់មិនត្រូវឱ្យលើសពី១០តែ

មិនតិចជាង៥ ព្រោះបើរាប់លើសពី១០នាំឱ្យចិត្តរាយមាយ រាប់តិចជាង ៥នាំឱ្យចិត្តចង្អៀត។ ឧទាហរណ៍៖ រាប់បានត្រឹម៩ ឬ៨ ត្រលប់មករាប់ពី មួយ ពីរ បី វិញទីតាំងដើម្បីពិនិយ្យឱ្យដឹងថាខ្យល់ចូលចេញមាន៣ កន្លែងគឺ ត្រង់រន្ធច្រមុះឬរឹមបបូរមាត់ ត្រង់ទ្រូង និងត្រង់ពោះ។ បើខ្យល់ ចូលហើយត្រង់រន្ធច្រមុះ ផស្សៈកើតត្រង់ទីដែលខ្យល់ប៉ះ ខ្យល់ចូលនាំ ឱ្យទ្រូងប៉ោងពោះប៉ោង ខ្យល់ចេញនាំឱ្យទ្រូងផងពោះផង កំណត់សតិ ដឹងត្រឹមតែចូលចេញ ចូលចេញ តែយ៉ាងនេះ ផ្ងង់ចិត្តស្មារតីដឹងខ្យល់ ចូលដឹងថាចូល ចេញដឹងថាចេញប៉ុណ្ណោះ គឺជាតំណាក់កាលទី២ **ដឹងខ្យល់**។ **តាមដឹងខ្យល់** យកសតិតាមពិនិត្យតាមដឹងលក្ខណៈរបស់ខ្យល់ ដង្ហើម ពេលចិត្តទៅតាមតោងអារម្មណ៍រាយមាយត្រូវមានស្មារតីរលឹក ដឹងទាន់ ហើយបង្វែរសតិមកតាមដឹងខ្យល់ដង្ហើមវិញ ពេលរាយមាយ កើតឡើងទៀតត្រូវធ្វើដូច្នេះ បន្តទៀតតាមកៀបចងចិត្តកុំឱ្យរាយមាយ ចងក្រៀកចិត្តឱ្យជាប់នឹងបង្គោល គឺការដឹងខ្យល់ចេញចូលតែម្យ៉ាង។ ហ្វឹកហាត់រាងថ្នឹកបន្តិចចិត្តរាងស្ងប់អាចឱ្យយើងដឹង ប្រភេទខ្យល់ដង្ហើម ដែលកំពុងដកមាន៤ប្រភេទ ***ខ្យល់វែង ខ្យល់ខ្លី ខ្យល់ត្រគាតត្រគាត វែងខ្លះខ្លីខ្លះ*** និងខ្យល់ល្អិតស្ទើរតែរលត់ ប៉ុន្តែតាមពិត គឺមិនមែនរលត់ទេ មកពី

សតិយើងមិនទាន់រឹងមាំចាស់ក្លា ទើបកំណត់ខ្យល់នោះមិនបាន ព្រោះចិត្តស្ងប់ខ្លាំងពេក។ យន្តការរបស់វាគឺពេលណាអារម្មណ៍រាយមាយខ្លាំង ខួរក្បាលត្រូវការ អុកស៊ីហ្សែន សកម្មភាពដង្ហើមត្រូវផ្លាស់ប្តូរពីសកម្មមកអកម្មវិញ គឺប្តូរពីខ្យល់ដកខ្លាំងមកល្អិតស្ទើរតែរលត់ គឺប្តូរពីបាតុភូតសកម្មមកអកម្ម ចំហរឱ្យកូនថង់សួតធ្វើបាតុភូតបណ្តូរឧស្ម័ន ជាមួយបរិយាកាសយ៉ាងល្អិត។ ពេលដឹងថាខ្យល់ដង្ហើមប្រព្រឹត្តទៅយ៉ាងល្អិតដូច្នេះអ្នកបដិបត្តិមិនត្រូវភិតភ័យអ្វីឡើយ ព្រោះគ្រាន់តែដឹងថាខ្យល់ល្អិត ហើយការដឹងនេះ គឺចិត្តចាប់ប្តូរពីភវង្គចិត្តស្ងប់ខ្លាំងមករកសភាពធម្មតាវិញ ឯខ្យល់ដង្ហើមក៏ចាប់មានជាប្រក្រតីធម្មតាឡើយវិញហើយ។ ការដែលបានដល់ដំណាក់កាលនេះ គឺចិត្តចាប់ផ្តើមស្ងប់ចុះយ៉ាងជ្រៅ ហើយនិមិត្តកម្មដ្ឋានក៏អាចកើតមានឡើង។ **រក្សានិមិ្តតទុក** ខណៈពេលដែលចិត្តស្ងប់ខ្លាំងសតិក៏ប្រែជារឹងមាំ ចាស់ក្លាឡើងៗ រហូតអាចពិនិត្យឃើញសភាពប្រែប្រួលលើរាងកាយ ដូចជាផស្សៈតំបូងជាទុក្ខ ការចុកពោយច្រពន់អស់លែងដឹងការឈឺចាប់អ្វីមកផស្សៈជាសុខ ភ្នែនលែងទីសទាស់ គឺសុខស្ងប់យ៉ាងស្រួលព្រោះចិត្តស្ងប់កាយស្ងប់ ហើយការពែនភ្នែន នោះក៏សុសម្រួលឱ្យកាយស្ងប់ជួយឱ្យចិត្តស្ងប់ដែរ។ បើធាតុដី

ចម្រើនឡើងខ្លាំង អ្នកបដិបត្តិមានអារម្មណ៍ថារាងកាយគឺប្រៃជារឹងមាំដូចជាថ្មមានកម្លាំងក្រៃណា បើធាតុទឹកចម្រើនឡើងខ្លាំង អ្នកបដិបត្តិឃើញរាងកាយមានសភាពដូចប៉េងប៉ោងច្រកទឹក បើធាតុខ្យល់ចម្រើនឡើងខ្លាំង គឺមានអារម្មណ៍ថាកាយដូចជាស្រាលហើយអណ្តែតឡើងឬបាត់ឡែងដឹងរាងកាយអ្វីទាំងអស់ ដឹងតែម្តុំច្រមុះដែលខ្យល់កំពុងតែចេញចូលយ៉ាងនេះជាដើម។ ត្រូវដឹងថានិមិ្តតកើតឡើងរបស់អ្នកបដិបត្តិធម៌ទាំងអស់គឺមិនដូចគ្នាទេ គេមិនអាចពោលថានិមិ្តតរបស់នរណាម្នាក់កើតឡើងខុសនោះឡើយ ព្រោះវាគ្រាន់តែជាការប្រែប្រួលសភាពលើរាងកាយ និងការរីកចម្រើនឡើងនៃសតិស្មារតីតែប៉ុណ្ណោះ។ យោគាវចរ ខ្លះពេលដែលចិត្តសូប់ចុះយ៉ាងជ្រៅហើយ ស្រាប់តែបានឃើញសួនឧទ្យានសភាពខុសពីឋានមនុស្សលោក គឺស្អាតស្រស់ថ្លាមែនទែននេះក៏គ្រាន់តែជាមាយារបស់ចិត្ត ជាកម្លាំងផ្លាតត្រលប់អំពីរូបភាពដែលសញ្ញារបស់ខ្លួន ធ្លាប់បានឃើញពីមុនមកតែប៉ុណ្ណោះ។ ឃើញអ្វីក៏ដោយ ដឹងអ្វីដោយត្រឹមតែរក្សាទុកក្នុងចិត្ត មិនចាំបាច់ត្រេកអរឬប្រាថ្នាចង់បានអ្វីឡើយ ហើយក៏មិនចាំបាច់សង្ស័យពីនេះពីនោះ សង្ស័យថាខ្លួនបានសម្រេចធម៌ដល់ថ្នាក់ណាហើយ នេះឬព្រះនិព្វាន? នោះឬទេវលោក

ព្រហ្មលោក? ជាការអត់ប្រយោជន៍ទៅវិញទេ ព្រោះនាំឱ្យរាយមាយ រលត់សតិ ត្រូវខំបន្តកំណត់ដឹងខ្យល់ឱ្យចិត្តស្ងប់ធ្លាក់ចុះយ៉ាងជ្រៅក្នុងភវង្គឱ្យបានកាន់តែថ្នឹកញឹកញាប់ឡើងៗ រហូតដល់កិលេសកើតឡើងមិនបានអស់ដៃអស់ជើងស្លាប់អស់ទៅ ត្រង់នេះទេទើបជាគោលដៅពិតដែលយើងត្រូវប្រឹងទៅឱ្យបាន ឯការដឹងក្រៅពីនេះអាចជាការបំផ្លាញកម្មដ្ឋានផងក៏មាន ដូចជាការត្រេកអរហើយសំគាល់ថាអញជាង្គកបានធម៌មានតែអញទេបានឃើញធម៌យ៉ាងនេះជាដើម។ ពេលចិត្តស្ងប់ចុះយ៉ាងជ្រៅនេះឧបធិកិលេស ឬវិបស្សនូបក្កិលេសដប់កើតឡើង ដូចជាប្រភពនាំឱ្យកើត **លោភៈ ទោសៈ មោហៈ** ទៅវិញទេ ត្រូវលះវាចោលចេញមិនត្រូវប្រកាន់យកឡើយ ព្រោះនេះមិនមែនជាមគ្គផលដើម្បីឱ្យបានរួចចាកទុក្ខទេ ប៉ុន្តែបើយោគាវចរមិនបានជួបធម៌នេះទេ ក៏ហាក ដូចជាការបំពេញព្យាយាមរបស់ខ្លួននៅមិនទាន់បានត្រឹមត្រូវដែរ ប៉ុន្តែក៏មាននិស្ស័យរបស់យោគាវចរខ្លះ មានតែនិម្មិតស្ងប់ឈឹងទៅតែម្តងក៏មាន គឺមិនបានឃើញអ្វីនឹងគេឡើយ។ ឃើញក្តីមិនឃើញក្តី គឺកុំឱ្យមានក្តីប្រាថ្នាដែលជាលោភៈដ៏ល្អិតមិនត្រូវទោមនស្ស ព្រោះមិនបានឃើញអ្វីដែលនាំឱ្យកើតទោសៈ ដ៏ល្អិតកើតឡើងចំពោះកិច្ចបដិបត្តិទៅវិញទេ។ ការមិន

ប្រាថ្នាអ្វីទាំងអស់ហើយធ្វើតែតាមការពន្យល់របស់ព្រះនោះ គឺជាមូលដ្ឋានគ្រិះនៃភាពជោគជ័យនៅលើសមរភូមិកិលេស ពីព្រោះតែសត្វទាំងអស់ត្រូវរារាំងដោយទំនប់គឺអវិជ្ជា ត្រូវជាប់ដោយខ្សែគឺតណ្ហា ជាធម្មជាតិនាំសត្វបានទទួលកុសលវិបាកគឺដូចជាបានត្រូវឆ្នោតជីវិត ពេលបានទទួលអកុសលវិបាកគឺដូចជាខុសឆ្នោតជីវិត កម្មណាដែលបុគ្គលបានសាង ព្រោះតែហេតុ **លោភៈ ទោសៈ មោហៈ** កម្មនោះគឺជាដែនកើតនៃអត្តភាពជាប់មិនដាច់ ហើយត្រូវទទួលផលកម្មពីអតីតដោយជៀសពុំរួច។ ការអស់ទៅនៃអវិជ្ជាគឺជាការចម្រើនឡើងនៃបញ្ញា ជាហេតុនាំឱ្យរលត់ទៅនៃតណ្ហាសូម្បីតែការប្រាថ្នាក្នុងកុសល ទៅពោលដល់ថ្វីអកុសលដែលជាបាបធម៌គួរខ្ពើមនោះ។ ការរលត់ទៅនៃតណ្ហាទើបគ្មានជាតិកំណើតតទៅទៀត កម្មណាដែលមាន **អលោភៈ អទោសៈ អមោហៈ** ជាបុព្វហេតុ កម្មនោះឈ្មោះថាជាកម្មមានរឹសគល់ផ្តាច់ផ្តិល ហើយដូចជាគ្មោតកំបុតចុងដែលតែងតែធ្វើឱ្យវិនាស មិនមានពូជដុះតទៅទៀតបានដូចជាកម្មមិនមានកំណើតក្នុងភពថ្មី។ កម្មទាំងឡាយណាក្នុងកម្មដ្ឋាន គឺជាកម្មដែលមានទិសដៅផ្តាច់ផ្តិលតណ្ហានេះឯង ហេតុនេះតើយើងត្រូវនៅចង់បានអីពីកម្មនេះទៅទៀត សេចក្តីសុខពិតព្រះ

និព្វានគឺត្រូវលះចោលទាំងអស់ ទាំងសីល សមាធិ បញ្ញា ទាំងខន្ធបញ្ចកៈនេះទៀតផងទើបបានទៅដល់ទីសុខពិត ហើយបើមិនប្រាថ្នាឱ្យកើតទៀតផង តើត្រូវមកចង់ឈ្នះចង់ចាញ់អីជាមួយអ្នកណាទៀត ចង់បានអ្វីទៀត ព្រះលោកជាម្ចាស់ធម៌ ជាព្រះរាជាមួយអង្គដែលត្រូវឡើងគ្រប់គ្រងរាជ្យសម្បត្តិ និងក្លាយជាស្តេចចក្រពត្តិ តើលោកមានបានយកអ្វីពីលោកនេះទៅបានទេ? ព្រះរាជាទាំងឡាយពីបូរាណកាលរៀងមក តើមានអ្នកណាដែលបានអីក្រៅពីត្រលប់ទៅរកធាតុដើម ដី ទឹក ភ្លើង ខ្យល់ ជារបស់ធម្មជាតិវិញនោះ កុំធ្វើតែអំពើឥតប្រយោជន៍នាំឱ្យក្លាយជាកញ្ជះធម្មជាតិ មាគ៌ាត្រាស់ដឹងកើតមានស្រេចហើយ គប្បីត្រូវរួតរះបំពេញដើម្បីកាត់ផ្តាច់កាំច្រ៉ាក់នៃអវិជ្ជា ដែលជារឹសគល់ក្នុងបដិច្ចសមុប្បាទ ហើយបដិច្ចសមុប្បាទនេះ គឺជាច្បាប់ព្រះពុទ្ធបកស្រាយពីដំណើរដ៏អាថ៌កំបាំងរបស់ធម្មជាតិ វាជាទ្រឹស្តីដែលផ្អែកលើរូបធម៌នាមធម៌រួមជាមួយអនត្តាធម៌ ព្រោះតែហេតុនិងបច្ច័យប្រព្រឹត្តទៅហើយទាំងបានបំភ្លឺអរិយសច្ចៈទី២ គឺទុក្ខសច្ចៈដែលអវិជ្ជាចម្រើនគឺជាការចម្រើនឡើងនៃទុក្ខ និងអរិយសច្ចៈទី៣ ទុក្ខនិរោធអរិយសច្ចៈ គឺរលត់អវិជ្ជានិងតណ្ហាទើបទុក្ខរលត់ ហេតុនេះបដិច្ចសមុប្បាទក៏វិលចូលក្នុងអរិយសច្ចៈ

៤ ហើយអរិយសច្ចៈ៤ គឺជាជីវិតរស់នៅប្រចាំថ្ងៃនេះឯង មិនមែនជារបស់អាទិទេព ឥន្ទព្រហ្មយមយក្សឯណាទេ គឺជារបស់ខ្យល់ដង្ហើមដែលកំពុងប្រព្រឹត្តិទៅក្នុងជីវិតបច្ចុប្បន្ន ព្រោះយើងគ្មានអំណាចកែប្រែអតីតកាល តែអាចគ្រប់គ្រងជីវិតបច្ចុប្បន្នឱ្យរស់ក្នុងការគិតគប្បីយល់ត្រូវ បានអាចលះហេតុរបស់ទុក្ខចោលចេញបាន។ ព្រះធម៌៨៤០០០ គឺវិលចូលតែមួយជាចក្កៈធម៌ ឆ្ពោះទៅកាន់ព្រះនិព្វានជាទីរលត់ទៅនៃទុក្ខតែម្យ៉ាង ពុំមានបែងចែកឱ្យបែកខ្ញែកទៅជាយ៉ាងដទៃឡើយ។ ពោលបានត្រឹមនេះត្រូវអាក់ខានអស់មួយស្រេបក់ ព្រោះតែកែវទឹកតែកំពុងតែត្រូវលោកបឺតក្អឹកៗហើយជូតមាត់ទើបពោលបន្ត៖ កម្មដ្ឋានអានាបាអាចយកធ្វើជាបាតគ្រប់កម្មដ្ឋានទាំងអស់ ព្រោះជាកម្មដ្ឋានសម្រាកចិត្តជាវិហារធម៌ដែលញុំាងចិត្តឱ្យបានផឹករសបីតិនៃចិត្តស្ងប់ យើងអាចចម្រើនវិបស្សនាតាមអារម្មណ៍ត្រៃលក្ខណ៍ដោយពិចារណាអំពី អនិច្ចំ អ្វីៗមិនទៀង ទុក្ខំ អ្វីៗគឺជាទុក្ខ និងអនត្តា មិនមានអ្វីជារបស់ខ្លួនមិនមានសារៈ រួចពិនិត្យខ្យល់ដើមបដិបត្តិឆ្លាស់គ្នាជារយៈៗ គឺបើពិចារណាច្រើនយូរទៅនាំឱ្យហត់នឿយ ត្រូវនាំចិត្តមកជ្រកក្រោមសមាធិអានាបាសិន បើជ្រកយូរទៅនាំឱ្យភាពងោកងុយកើតឡើង ត្រូវលើកចិត្តឡើងកាន់វិបស្សនាវិញ

បដិបត្តិឆ្លាស់ចុះឡើង កុំឱ្យកិលេសវាមានឱកាសងើបឡើងឱ្យចិត្តគោងនាំខូចប្រយោជន៍។ សម័យណាដែលចិត្តសូប់ចុះយ៉ាងជ្រៅថ្នឹកមែនទែនហើយ រហូតដល់អារម្មណ៍លែងពាល់ត្រូវមនោទ្វារបាន ពេលនោះចិត្តកើតតាមបញ្ចទ្វារក៏រលត់អស់សល់តែចិត្តប្រព្រឹត្តិទៅក្នុងមនោទ្វារ ដើម្បីឱ្យសមថវិថី ឬវិបស្សនាវិថីប្រព្រឹត្តិទៅទោះជាមានសំលេង ក្លិន កើតឡើងនៅខាងក្រៅយ៉ាងណាក៏យោគាវចរនោះមិនបានដឹងឡើយ យ៉ាងនេះហៅថា ចូលផលសមាបត្តិ។ ចុះអ្នកបដិបត្តិធម៌ ហេតុអ្វីក៏គេមានការអត់ធន់ ចំពោះការឈឺចាប់ដែលកើតឡើងតាមផ្លូវកាយ ផ្លូវចិត្តបានល្អជាងមនុស្សធម្មតាម្តេះ? (ពួកផងសួរកាត់ពុទ្ធដីកាលោក) សំនួររបស់ញោមគឺល្អណាស់ ព្រោះតែគេបានហ្វឹកហាត់អប់រំចម្រើនឱ្យចិត្តកើតឧបេក្ខា ចំពោះគ្រប់សភាវៈធម៌ទាំងឡាយដែលបានកើតឡើងចំពោះគេបានយ៉ាងស្ទាត់ជំនាញ ហើយម្យ៉ាងទៀតការហ្វឹកហាត់ពិនិត្យវេទនាយូរទៅធ្វើឱ្យទុក្ខវេទនា កើតឡើងមិនសូវខ្លាំងលើរាងកាយពេកទេ ដែលនាំឱ្យសេចក្តីស្លាប់របស់ពួកគេ គឺមិនសូវមានការឈឺចាប់ខ្លាំងពេកឡើយ ហើយអាចដឹងពេលវេលារៀបស្លាប់ទៀតផង។ ប្រភពថាមពលដែលបានផ្តល់កំណើតចិត្ត ចេះតែបង្កើតកូនចិត្តច្រើនប្រភេទ ចិត្តមួយរលត់

ជាបច្ច័យឱ្យចិត្តមួយកើត ចិត្តមួយកើតជាបច្ច័យឱ្យចិត្តមួយរលត់ចេះតែយ៉ាងនេះពេញៗមួយថ្ងៃមួយយប់ ចិត្តជាច្រើនប្រភេទនោះបានត្រូវផ្លាស់ប្តូរទៅជាវេទនានិងសញ្ញា នៅពេលណាដែលយើងគ្រាន់តែកំណត់សតិដឹងជាឧបេក្ខា កុំតាមត្រិះរិះជាមួយចិត្តដែលកើតឡើងមកនោះឈ្មោះថាមិនបានសាងអារម្មណ៍ឱ្យចិត្តក្នុងមនោទ្វារសោយ លុះយូរទៅប្រភពថាមពលដែលផ្តល់កំណើត ចិត្តក៏អស់ថាមពលបញ្ចេញកូនចិត្តតទៅទៀត នាំឱ្យវេទនានិងសញ្ញាត្រូវរលត់អស់ទាំងក្នុងមនោទ្វារ នេះឯងជាតំណាក់កាលព្រះនិព្វានកើតឡើងក្នុងចិត្ត ឬហៅថានិរោធសមាបត្តិនេះមានតែព្រះអរហន្ត និងអានាគាមីបុគ្គលប៉ុណ្ណោះទើបអាច ប្រព្រឹត្តិទៅបាន ព្រោះចិត្តលោកស្ងប់ដល់កំពូលអាចបិទមេតាប៉ូលីសកោសិកា ឬឱ្យត្រឹមតែបាតុភូតសំណាយប្រព្រឹត្តិទៅតែប៉ុណ្ណោះ ការចេញពីសមបត្តិនេះមកវិញ គឺដោយសារអំណាចការឧទ្ទិសដ្ឋានចិត្តយ៉ាងយូរបំផុតត្រឹម ៧ថ្ងៃ។ ការហ្វឹកហាត់បានដល់ខណៈនេះគឺបានរួចផុតចាកទុក្ខទាំងស្រុង ព្រោះចិត្តលែងមានប្រតិកម្មទៅនឹងគ្រប់ព្រឹត្តិការណ៍ រឿងរ៉ាវអ្វីៗទាំងអស់ទៀតហើយ សូម្បីតែសេចក្តីស្លាប់របស់ខ្លួនក៏លែងភ្ញាក់ផ្អើល ចិត្តនៅរក្សាជាឧបេក្ខារៀងរហូតព្រោះបានលុបលាងវិប្បដិសារីយ៍

ចំពោះផែនដីនេះរួចអស់ហើយ លោកលែងជាប់បំណុលផែនដីតទៅទៀតជារៀងរហូត។ កុំឱ្យពិបាកចងចាំ អាត្មាសូមពោលសង្ខេបឡើងវិញ ប្រភពផ្តល់ថាមពលចិត្តនាំឱ្យមានកំណើតកូនចិត្តតៗគ្នា ប្រភពផ្តល់ថាមពលចិត្តនាំឱ្យមានកំណើតកូនចិត្តតៗគ្នា នាំឱ្យកើតវេទនានិងសញ្ញាលើរាងកាយ នឹងក្នុងចិត្តមកដល់ត្រង់នេះមានលក្ខខណ្ឌពីរយ៉ាងកើតឡើងគឺ៖

១- ***ចិត្តភ្លាត់សតិ ឬ រលត់សតិ ឬចិត្តដែលមិនមានការអប់រំ*** ចិត្តនោះបានចូលរួមចាំនូវអារម្មណ៍ សោយនូវរសអារម្មណ៍ ចូលរួមត្រិះរិះនាំឱ្យកើតស្អប់ ស្រលាញ់ ហើយប្រតិកម្មដោយកើតការរំជួលចិត្ត ញាប់ញ័រតក់ស្លុតចំពោះរូបសម្លេង ក្លិនរស ជោដ្ឋព្វៈ និងធម្មារម្មណ៍ ចិត្តត្រូវរងទុក្ខទោសព្រោះតែការត្រិះរិះរបស់ខ្លួនឯងអត់អំពើ ហើយរលកចិត្តក៏ចេះតែកើតឡើងផ្ទួនៗកាន់តែខ្លាំងឡើងជាប់មិនដាច់ ធ្វើឱ្យកាន់តែគិតកាន់តែខឹង កាន់តែគិតកាន់តែចង់បាន គិតថានឹងធ្វើអកុសលញយៗថ្ងៃណាមួយកូនចិត្តទាំងនោះនឹងជំរុញឱ្យប្រព្រឹត្តិទាល់តែបាន។

២- ***ចិត្តប្រកបដោយសតិ*** ពិនិត្យដោយឧបេក្ខាចំពោះគ្រប់សភាវៈធម៌ទាំងអស់កើតឡើងក្នុងចិត្តនាំឱ្យរលត់ ឬថមថយថាមពល ចិត្ត

រាយមាយនាំឱ្យរលត់វេទនា និងសញ្ញាអស់នេះឯងជាពុទ្ធដីកាដែលបានទូន្មានថា ភិក្ខុក្នុងសាសនានេះគប្បីបញ្ជូនចិត្តទៅកាន់ព្រះនិព្វានឱ្យបានរឿយៗនេះ។ សាធុ សាធុ សាធុ ពិរោះណាស់រសអម្រឹតនៃព្រះធម៌ធ្វើឱ្យអ្នកស្តាប់រួចផុតចាកទុក្ខបានពិតៗ ស្តាប់យល់មួយខណៈ លះអកុសលបានមួយខណៈ មគ្គចិត្តប្តូរជាផលចិត្ត កើតផលមិនរងចាំកាលមែន លោកតាសនជញ្ជក់មាត់ ព្រមទាំងគ្រវីក្បាលអស្ចារ្យក្នុងចិត្តខ្លាំងពេកចំពោះពុទ្ធញ្ញាណ ដែលក្រៃណាលើសបញ្ញាក្នុងលោករកពីរគ្មាន។ ចំណែកមីងស៊ុម បីតិកើតឡើងខ្លាំងពេករហូតធ្លាក់ទឹកភ្នែកគាត់ទាញជាយសំពត់ផ្តិតយកទឹកភ្នែកដែលធ្លាក់ ដើម្បីបញ្ចប់ក្តីឆោតល្ងង់របស់ខ្លួន ស្តាយពេលវេលាអស់ជាងកន្លះសតវត្សដែលត្រូវរស់នៅចាញ់បោកចិត្ត ចាញ់បោកក្តីកំណាញ់ ក្តីលោភលន់ កំហឹង និងក្តីវង្វេងដែលប្រកាន់ថាខ្លួនទៀង ខ្លួនសុខ ខ្លួនមានខ្លឹមសារ ខ្លួនប្រសើរលើសគេ ប៉ុន្តែនេះភ្ញាក់ខ្លួនដូចរន្ទះបាញ់ចំបន្ទុលក្បាល ព្រោះដឹងច្បាស់ថាជីវិតនេះគឺជៀសពីក្តីវិនាសពុំផុត ហើយជាជីវិតហោងស៊ប់ទៀតផង ព្រោះគ្មានសីល សមាធិ បញ្ញា ជាគ្រឿងបិទបាំង រារាំងអបាយភូមិ។ កាន់តែគិតគឺកាន់តែសង្វេគចំពោះជីវិត ដែលត្រូវរស់នៅមានតែការប្រជែង អស់ពី

ប្រជែងក្រៅផ្ទះត្រូវមកប្រជែងជាមួយប្តី ប្រពន្ធ កូនចៅ ឆ្វេងទាស់ ស្តាំទាស់ មុខទាស់ក្រោយទាស់ លីទាស់ ឃើញទាស់ ទាស់ទាល់តែទៅបាត់បានឈប់ទាស់ ប៉ុន្តែត្រូវទៅទាស់ជាមួយញាតិថ្មីៗទៀត ឱ! មីលង់អញនេះ។ (ពូផេងលបអួលដើមកដើម្បីតបស្នងវិប្បដិសារី) ឱ! អញនេះពេញជាលាភធំក្នុងយប់នេះ នេះមិនទាន់ហួសពេលទាន់កូនប្រពន្ធនៅរស់ជួបជុំ តាមពិតអញជាអ្នកស្លាប់សោះ រស់ចាញ់បោកតែកិលេសឱ្យវាប្រើទាំងយប់ទាំងថ្ងៃដូចឆ្កែអង្កែរស៊ី រស់មានជីវិតតែឥតតម្លៃទាល់តែសោះ គឺកិលេសតណ្ហានេះឯងជាអ្នកធ្វើឱ្យអញថោកទាប គិតទៅមនុស្សណាក៏ដោយ ឱ្យតែអស់កិលេសគឺនឹងបានជាព្រះអហរន្តរួចចាកទុក្ខបានតែទាំងអស់គ្នា ប៉ុន្តែមោហៈអវិជ្ជាវាបិទបាំងលោភៈបាំងអនិច្ចំទោសៈបាំងទុក្ខំ មោហៈបាំងមគ្គផលនិព្វានអស់។ ឱ! ម៉ែវាជាទីស្រលាញ់របស់បង បងមិនដែលចេះមើលឃើញអំពើល្អរបស់អូនទាល់តែសោះ ណាថៃទាំកូន ណាថៃទាំប្តី និងញាតិខាងប្តី ម៉្លេៗត្រាក់ៗពីលិចទៅកើត ពីកើតទៅលិចវិលតែជុំវិញចង្រ្កាន ឯបងអាងតែខ្លួនជាអ្នកធ្វើការរកលុយចង់គំហកៗ ចង់សំលុតៗ ដាក់ប្រពន្ធកូនដូចសត្វធាតុ អូនហ្អើយយើងមិនដឹងត្រូវព្រាត់ប្រាស់គ្នានៅពេលណាទេ? ជួបគ្នា

ក៏ជានិស្ស័យព្រាន់គ្នាក៏ជានិស្ស័យ ប៉ុន្តែបងមិនត្រូវសាងវិប្បដិសារីឱ្យខ្លួនឯងចំពោះគ្រួសារសោះ។ សូមវត្ថុសក្តិសិទ្ធិជួយជាសាក្សី ខ្ញុំសូមតាំងសច្ចៈវាចាឧទ្ធិសដ្ឋានក្នុងចិត្ត សូមពពួកសត្វដ៏ជាសត្វទេព និងទេពនិករអមរទេព្តាទាំងក្នុងឆកាមាទាំង៦ជាន់ សូមជួយដឹងលឺថាចាប់តាំងអំពីពេលនេះតទៅ ខ្ញុំព្រះអង្គនឹងស្រលាញ់ប្រពន្ធកូន ហើយសូមរក្សានូវនិច្ចសីលដើម្បីតបស្នងសងគុណចំពោះជាតិនិងសាសនា ព្រមទាំងព្រះមហាវីរក្សត្រ ដែលលោកមានទសពិធរាជធម៌ចំពោះផែនដីមហានគរនេះ អំណឹះតទៅបើខ្ញុំធ្វើខុសការបួងសួងនេះសូមឱ្យទេវតាបរាមុខហើយយមរាជសូមដកហូតខ្ញុំពីផែនដីនេះទៅ កុំឱ្យរស់នាំតែធ្ងន់ផែនដីទុកឱ្យក្មេងជំនាន់ក្រោយគេបានរស់នៅសប្បាយផង។ ពូផេងលួចសម្លឹងមុខប្រពន្ធដោយក្តីករុណាជាពន់ពេក ចំណែកឯដេត និងណែតក៏បានលួចធ្វើការប្តេជ្ញាចិត្តតែរៀងៗខ្លួនដែរ។ ពុក ម៉ែ! កូនពិតជាបានធ្វើខុសដោយអចេតនាក្នុងពេលកន្លងមកខ្លះមែន តែអំណឹះពីពេលនេះតទៅ កូននឹងតស៊ូរក្សាសតិស្មារតីដើរតាមគន្លងការប្រៀនប្រដៅរបស់លោកទាំងពីរ ដើម្បីកសាងខ្លួនឱ្យក្លាយទៅជាកូនខ្មែរអ្នកពូជមានអំបូរមានអរិយធម៌រុងរឿងលើផែនដីនេះ។ កូនតស៊ូរស់ក្បែរម៉ែ ពុក មិនជិន

ឆ្អន់នឹងការទូន្មានប្រៀនប្រដៅ កូនព្យាយាមបំពេញភាពខ្វះខាតក្នុងសុជីវធម៌ និងគុណធម៌ ហើយស្រលាញ់ជាតិនិងមាតុភូមិដ៏កំសត់របស់យើង។ អ្ហែមៗ! (តាសនគ្រហែមព្រោះឃើញមានភាពស្ងប់ស្ងាត់ប្រព្រឹត្តទៅយូរពេក គាត់ខ្លាចគេនាំគ្នាគិតខុសប្រាសចាកគន្លងធម៌) ហេតុម្តេចក៏ជីវិតសត្វលោកត្រូវរស់នៅក្នុងសភាពខ្វះកន្លះជានិច្ចដូច្នេះ? ពូហែងលើកដៃសំពះរួចពោលៈ ព្រោះសត្វលោកចេះតែស្វែងរកនូវសំលេង ក្លិន រស ជោដ្ឋព្វៈ និធម្មារម្មណ៍ ដែលជារបស់ខាងក្រៅមកធ្វើជាទីតាំងនៃតំរេកត្រេកត្រអាល ស្វែងរកការបានពីខាងក្រៅមិនចេះស្វែងរកពីខាងក្នុងមកទំនុកបំរុងទើបចេះតែខ្វះកន្លះជានិច្ច។ សត្វខ្លះរកផ្ទះពិតរបស់ជីវិតមិនឃើញ ប្រឹងតុបតែងថែរក្សាតែផ្ទះខាងក្រៅដែលជាផ្ទះមិនពិត មិនចេះប្រឹងប្រែងតុបតែង ថែរក្សាចិត្តដែលជាផ្ទះពិតរបស់ខ្លួននោះឡើយ។ រឿងមិនគួរខឹងក៏ខឹងបានរហូតដល់ទៅចងពៀរវេរានឹងគ្នា របស់មិនគួរស្រលាញ់ឆ្អេះឆ្អាបស្អុយគគ្រុក តែបែរជាស្រលាញ់ស៊ូស្លាប់មិនលែង។ តើមានអ្នកណាបានអីអំពីក្នុងលោកនេះទៅ ក្រៅតែពីការដឹងអារម្មណ៍របស់វិញ្ញាណ ហើយសោយទៅជាការប្រកាន់មាំទៅតែម្តងថាមានខ្លួនអ្វីៗជារបស់ខ្លួន ថាខ្លួនជាអ្នកបាននេះបាននោះ ថាមានខ្លួនប្រសើរ

លើសគេ តែតាមពិតគឺចាញ់បោកសក្កាយទិដ្ឋិវាចេញមុខបាំងបញ្ឆោសោះ ប៉ុន្តែវាត្រូវបានបំបែកទៅវិញដោយវិបស្សនាញ្ញាណ។ ការបំពេញកុសលក៏ដូចគ្នា គ្រាន់តែនឹកថាចង់បំពេញកុសលភ្លាមត្រូវលោភៈចាប់យកភ្លែតថា អញធ្វើគឺដើម្បីឱ្យអញបាន នេះមិនមែនជាខ្លឹមសារពិតរបស់បុណ្យទានក្នុងព្រះពុទ្ធសាសនាឡើយ ធ្វើបុណ្យចង់ល្បីគឺធ្វើដោយមិនចង់ល្បី ហើយបើរឹតតែពិតណាស់ទៅទៀត គឺធ្វើដោយមិនចង់បានអ្វីទាំងអស់ ចង់ឱ្យតែអ្នកដទៃបានសុខតែប៉ុណ្ណោះ មិនចង់ឱ្យវាអញ្ចេះ វាអញ្ចុះ គឺប្រគល់ទៅឱ្យតុលាការកម្មទាំងអស់។ ចេះធម៌មិនមែនមិនងាប់ មិនវិនាសឯណា តែគឺដើម្បីត្រៀមខ្លួនទទួលគ្រប់សភាវៈដែលកើតឡើងជាប្រក្រតី ក្នុងជីវិតប្រចាំថ្ងៃ មិនឱ្យកើតប្រតិកម្មចិត្ត បើចេះធម៌ហើយបែរជាទទួលយកការវាយប្រហារពីធម្មជាតិ មិនបាននោះមិនឈ្មោះថាចេះធម៌ឡើយ ចាញ់បថុជ្ជនដែលគេមានការតាំងចិត្តមោះមុតទៅទៀត។ រឿងដែលថាស្លាប់ហើយត្រូវទៅណា នៅឯណា មានជីវភាពដូចម្តេច? នោះជារឿងដែលត្រូវកើតឡើងតាមក្រោយ ព្រោះវាជាវិបាករបស់បច្ចុប្បន្នភាពទេ ចង់ថ្ងៃមុខជួបវិបាកយ៉ាងណាៗ គឺអ្នករៀនធម៌ត្រូវមានស្មារតី មានសតិកំណត់ដឹងក្នុងគ្រប់លក្ខខណ្ឌទាំងអស់ នេះឯងជាភាព

រឹងមាំតាមផ្លូវចិត្តរបស់អ្នករៀនធម៌។ ការរៀនធម៌នេះបើមិនបានត្រិះរិះ ប្រកបដោយបញ្ញាទេ ធម៌ទាំងនេះអាចបង្ករឱ្យកើតទុក្ខដូចជាការចាប់ពស់ពិសត្រង់កន្ទុយផងក៏មាន។ សូមអនុមោទនា! សាធុ ៗ ៗ តើអ្វីជាអ្នកធ្វើឱ្យតណ្ហាកើតឡើងតាមទ្វារ? ហើយអ្វីជាអ្នកធ្វើឱ្យភវចក្ក ដែលជាកង់វដ្តៈចាប់ផ្តើមរំកិលនិងវិលទៅមុខ? (ពូហោងលើសំណួរជូនអង្គធម្មសាកច្ឆា)។ មហាទេពយល់ថា នេះជានាទីរបស់ខ្លួនទើបមានថេរៈដីការ ៖ ចម្រើនពរ! ពេលដែលអារម្មណ៍ប៉ះខ្ទប់នឹងវិញ្ញាណនាំឱ្យផស្សៈកើតឡើង ព្រោះផស្សៈក៏មាននាទីជាអ្នកភ្ជាប់អារម្មណ៍ទៅនឹងវិញ្ញាណដែរ វេទនាជាការសោយនូវអារម្មណ៍ឡើង ហើយសញ្ញាជាការចាំនូវអារម្មណ៍ក៏កើតឡើង តណ្ហាពុះកញ្ជ្រោល ជំរុញអភិសង្ខារការតាក់តែងកម្មឱ្យមានវិបាកក៏កើតឡើង កង់វដ្តៈចាប់ផ្តើមវិល និងរំកិលទៅមុខតាមគន្លងកិលេសវដ្តៈដែលនាំឱ្យមានកម្មវដ្តៈនិងវិបាកវដ្តៈ ហើយការប្រជុំនៃរូបធម៌នាមធម៌ក៏កើតឡើយតាមនិស្ស័យអនត្តា។ ព្រោះហេតុនេះគឺផស្សៈនេះឯងជាបច្ច័យឱ្យកើតតណ្ហាតាមទ្វារ ហើយអភិសង្ខារជាអ្នកធ្វើឱ្យកង់វដ្តៈវិលទៅមុខ។ សូមអនុមោទនា! សាធុ សាធុ សាធុ ករុណាគុណម្ចាស់ខ្ញុំព្រះអង្គស្តាប់ទៅយល់ចូលចិត្តណាស់ហើយ ប៉ុន្តែខ្ញុំព្រះករុណាសូម

សាកសួរសំណួរបន្តទៀត៖ ដើម្បីឱ្យសន្តិភាពក្នុងលោកនេះកើតឡើងប្រាកដ តើព្រះពុទ្ធសានាមានការពន្យល់ដូចម្តេចដែរគុណម្ចាស់? (ពូហោងទូលសួរចំពោះព្រះភិក្ខុសង្ឃ)។ ព្រះអង្គទទួលសំនួរដោយតុណ្ហីភាព៖ សំខាន់ណាស់ញោម រឿងនេះមានគេទូលសួរព្រះពុទ្ធបរមគ្រូ តាំងពីកាលព្រះអង្គទ្រង់គង់ជាធរមាននៅឡើយម្លេះ។ មនុស្ស គឺមានចិត្ត ចិត្តចុះក្នុងអត្ថបទថាវិចិត្រគឺវិចិត្រនូវលោកមានខន្ធលោកនេះជាដើម ព្រោះតែមានចិត្តធ្វើឱ្យមនុស្សមានការយល់ឃើញខុសៗគ្នា ត្រឹមតែការយល់ឃើញតែឯងក៏មិនថា តែមនុស្សនៅទៅបង្ខិតបង្ខំគេឯងឱ្យនាំគ្នាយល់ឃើញតាមខ្លួនឯងទៀត អ្នកណាមិនព្រមយល់ឃើញឱ្យដូចខ្លួនក៏កំណត់ថា អ្នកនោះជាបច្ចាមិត្តរបស់ខ្លួន មិនបានរក្សាឧបេក្ខាចិត្តចំពោះទស្សនៈដទៃនោះឡើយ។ នៅក្នុងសល្លេខសូត្រទី៨ បិដកខ្មែរលេខ២០ ពេលនោះព្រះជិនស្រីទ្រង់គង់ក្នុងវត្តជេតពន ជាអារាមរបស់អានាថបិណ្ឌិកសេដ្ឋី ព្រះមហាចុន្ទទូលសួរព្រះអង្គថា ឥទ្ធ្យវនេះទិដ្ឋិកើតឡើងច្រើនប្រការ ពួកអត្តវាទប្រកាន់សក្កាយទិដ្ឋិ៨យ៉ាង ដូចជា ខ្លួននេះក្តីលោកនេះក្តីជារបស់ទៀង ម្ខាងៗសុទ្ធតែប្រកាន់ថាទិដ្ឋិរបស់សាស្តាខ្លួនសុទ្ធតែល្អបរិសុទ្ធត្រឹមត្រូវ តើគួរលះទិដ្ឋិនោះបានដូចម្តេចព្រះអង្គ?

ព្រះលោកជាអ្នកដែលបានជាទីពឹងនៃលោកទ្រង់ត្រាស់តបថា ទិដ្ឋិទាំងឡាយកើតក្នុងបញ្ចក្ខន្ធ សំងំនៅក្នុងបញ្ចខន្ធកើតឡើងផុលផុសក្នុងបញ្ចខន្ធ បុគ្គលកាលបើបានឃើញច្បាស់ក្នុងបញ្ចខន្ធតាមសេចក្តីពិតថា ខន្ធទាំងឡាយ៥នេះគឺមិនមែណអញ មិនមែនរបស់អញ រមែងលះបង់ទិដ្ឋិទាំងនោះបាន។ បើខន្ធ៥នេះវាមិនមានខ្លួនវាផង ទៅប្រកាន់យកអីទិដ្ឋិអស់ទាំងនោះ ជនទាំងឡាយជាអ្នកប្រកាន់មាំក្នុងសេចក្តីយល់ឃើញរបស់ខ្លួន ពួកយើងនឹងមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកមិនប្រកាន់មាំ និងជាអ្នកដែលគេឱ្យលះបង់លទ្ធបានដោយងាយ។ បើទុកជាចង់ឱ្យលះព្រះពុទ្ធសាសនា ក៏នៅតែជាប់ក្រោមការប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ព្រោះឱវាទរបស់ព្រះអង្គ គឺប្រើសន្តិភាពសេរីភាព និងមេត្តា ករុណាក្តៅបលើការប្រៀនប្រដៅទាំងអស់ក្នុងលោក។ ការប្រកាន់មាំគឺជាទុក្ខ លះការប្រកាន់មាំគឺជាសុខ ហេតុនេះបើលះព្រះពុទ្ធសាសនា ហើយប្រកាន់ក្នុងសាសនាដទៃ គឺនៅតែមានជាប់ឈ្មោះថាមានទុក្ខតែដដែលហ្នឹង ព្រោះនៅជាប់ក្នុងទិដ្ឋិចេញមិនរួច។ អ្នកលិចក្នុងភក់ គឺកាមគុណមិនដែលជួយស្រង់អ្នកលិចក្នុងភក់ដូចគ្នាបានយ៉ាងណា អ្នកមិនដែលបានប្រដៅចិត្តខ្លួនឯង នឹងចេះប្រដៅចិត្ត

អ្នកដទៃបានដូចម្តេច? អ្នកមិនទាន់រំលត់កិលេសខ្លួនឯង នឹងចេះប្រាប់របៀបរំលត់កិលេសអ្នកដទៃម្តេចបាន? អរិយសាវកបិតក្នុងសម្មាទិដ្ឋិ ព្រោះស្គាល់អាហារបច្ច័យ ស្គាល់ការកើតឡើងនៃអាហារ៤ និងការរលត់ទៅនៃអាហារ៤ ហើយទិសដៅនៃកិច្ចបដិបត្តិគឺឆ្ពោះទៅកាន់ការរំលត់អាហារបច្ច័យ ស្គាល់ការកើតឡើងនៃអាហារ៤ និងការរលត់ទៅនៃអាហារ៤ ហើយទិសដៅនៃកិច្ចបដិបត្តិគឺឆ្ពោះទៅកាន់ការរំលត់អាហារនេះឯង។ តើផ្តាច់អាហារដូចម្តេច? ធម៌តែមួយក្នុងលោកគឺអាហារ ធម៌ជាតិទាំងឡាយគង់រង់រីកចម្រើនបានព្រោះអាហារ។ ការរីករាយត្រេកត្រអាលនឹងរូប សំលេង ក្លិន រស ការប៉ះពាល់សម្ផស្សនាំឱ្យត្រេកត្រអាលភ្លើតភ្លើនគឺជាអាហាររបស់រាគៈ ទោសៈ មោហៈ ការផ្តាច់អាហាររបស់រាគៈ ទោសៈ មោហៈ គឺសំរួមមិនរីករាយត្រេកអរក្នុងរូបសំលេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍។ ការសំរួមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តគឺជាអាហាររបស់សតិសម្បជញ្ញៈ ការចម្រើនសតិជាអាហាររបស់សុច្ចរិត៣ ការចម្រើនសុច្ចរិត៣ជាហាររបស់សតិប្បដ្ឋាន៤ នាំឱ្យមានលំអរ១០ប្រការនៃឈានកើតឡើងគឺសេចក្តីបរិសុទ្ធខាងដើម៤ សតិកំណត់ដឹងជាកណ្តាលក្នុងឧបេក្ខា៤ និងសេចក្តីរីករាយខាងចុង២ នេះ

ជាជីវិតរស់នៅប្រក្រតីប្រចាំថ្ងៃរបស់ព្រះអរិយៈ។ មុំស្តាប់បណ្តើរ ពិចារណាបណ្តើរក៏មានចិត្តកើតការត្រិះរិះថា៖ ឱហ្ន៎! ព្រះធម៌នេះសល្អ បរិសុទ្ធដូចជាសង្ខដែលដុសខាត់រលើងយ៉ាងម៉ត់ចត់ប្រាកដប្រជា បើយ៉ាងនេះជីវិតជាឃរាវាស នឹងមិនអាចបានឃើញធម៌នេះបានច្បាស់ប្រាកដឡើយ គឺមានតែបព្វជិតប៉ុណ្ណោះទើបអាចសម្រេចបាន បើទោះជាត្រូវបួសតាមផ្លូវចិត្ត ហើយកាយរស់នៅក្នុងជីវិតឃរាវាសក៏គង់ជៀសមិនផុតពីការរុកគួន ដោយអារម្មណ៍ក្នុងលោក ហេតុនេះអាត្មាអញបើចង់រួចផុតពីរណ្តៅអបាយភូមិ គឺមានតែទៅនៅវត្តតែប៉ុណ្ណោះ។ កំពុងតែស្តុងចិត្ត ស្រាប់តែលោកតាសនក្អកគ្រហែមបន្តិចហើយពោលៈ ណ្តើយ! យប់កាន់តែជ្រៅហើយ ការសន្ទនានេះសមគួរដល់កាលវេលាត្រឹមនេះសិនចុះ កុំឱ្យរំខានលោកយូរពេក តែខ្ញុំព្រះករុណាសូមពិតពុទ្ធដីកាឱ្យហើយផង គឺស្អែកសុំនិមន្តព្រះអង្គមកទទួលភត្តាហារក្នុងវេលាថ្ងៃម្តងទៀតជាកិច្ចបង្ហើយបុណ្យ សូមគុណម្ចាស់មេត្តាអនុគ្រោះផង។ ព្រះសង្ឃញញឹមបន្តិចហើយបានបន្លឺថា៖ ពរៗ មិនអីទេញោម អញ្ចឹងអាត្មាសុំចម្រើនពរត្រឹមនេះសិនចុះ។ ព្រះអង្គឈោងចាប់ចង់យាមហើយដោះភ្នែនចាកធម្មាសនៈនិមន្តចាកចេញទៅ ដោយមានពូហែងចុះ

តាមជូនពីក្រោយលោកទៅវត្តវិញ។ លោកតាសន ពូផេង មីងស៊ុម ក៏លាតាក្រោយដោយអនុញ្ញាតឱ្យក្មេងៗពីរបីនាក់នៅសម្រាកកំដរមុំ កុំឱ្យនាងមានការភ័យខ្លាច។ បើទោះជាអាល័យម្តាយប៉ុណ្ណា ក៏មិនឈ្នះក្តីហត់នឿយពេញមួយថ្ងៃដែរ ជំនោររាត្រីកាលបក់ចូលតាមប្រហោងជញ្ជាំងនិងតាមបង្អួច រុញស្បែមុនឱ្យប៉ោងឡើងប៉ះផ្ទៃមុខ នាងត្រដុសស្រាលៗ ហាក់ដូចជាជួយលួងលោមបបោសអង្អែលនាងឱ្យគេងលង់លក់បានស្កប់ស្កល់ ឱ្យបានធូរស្បើយល្ហើយចាកទុក្ខព្រួយបានមួយគ្រាដែរ។ ការគេងលក់ គឺជាការជួសជុលកាយដែលខូចខាតគ្រាំគ្រា និងជួសជុលចិត្តគំនិតដែលខ្ទេចខ្ទាំ ទើបព្រឹកស្អែកឡើងមុំបានក្រោកចាកនិទ្រាហាក់ដូចជាបានធូរស្បើយកាយចិត្តបានបន្តិច។ ព្រះទិនករបររាជ្យរថដោយអាជានេយ្យលើអាកាសវេហាស៍មានល្បឿនលឿន ដូចជាគ្រាប់ព្រួញដែលបាញ់ចេញពីដងកៅទណ្ឌធ្វើពីលោហៈធាតិដ៏រឹងមាំ ព្រមជាមួយសម្លេងខ្ទៀវខ្ទារបស់បក្សាបក្សីលើចុងព្រឹក្សា ឯក្រោមផ្ទះមុំលឺតែសំលេងកាំបិតនិងជ្រុញ អង្រែនិងត្បាល់បុកគ្រឿង មិនយូរប៉ុន្មានភត្តាហារនាវេលាថ្ងៃត្រង់ក៏បានរៀបចំរួចជាស្រេច។ ព្រះសង្ឃពីរអង្គបាននិមន្តដល់ លោកតាសនធ្វើបដិសណ្ឋារៈរួចក៏និមន្តវេរបង្សុកូលអាហារ

និងទេយ្យវត្ថុទានដែលរៀបជាលំដាប់បច្ច័យ៤បានចប់ស្រេចបាច់ រេលា ដែលព្រះសង្ឃនិមន្តលាត្រលប់ទៅវត្តវិញ ស្រាប់តែមុំស្ទុះមកលុតជង្គង់ ក្រាបក្បាល ថ្វាយបង្គំចំពីមុខលោកតាឪ នាងងើបមុខសូមលោកតា មេត្តាអនុគ្រោះ ស្រោចស្រង់សត្វដែលកំព្រាអាងរដូចរូបខ្ញុំព្រះករុណាផង ខ្ញុំព្រះអង្គបានសម្រេចចិត្តហើយថា នឹងលាចាកភូមិដ្ឋានដើម្បីបានទៅ រស់នៅបម្រើសង្ឃវត្ត ប្រយោជន៍បានសិក្សារៀនសូត្រព្រះធម៌ ស្តាប់ ធម៌ និងចម្រើនធម៌ ដើម្បីធ្វើវដ្តៈនេះឱ្យខើចខ្លី សូមលោកតាករុណាដល់ ខ្ញុំព្រះអង្គផង។ ស្តាប់លឺវាចាគួរឱ្យអាសូរនេះចប់ លោកតាទ្រឹងមួយ ស្របក់ទើបមានថេរដីកា៖ ចៅស្រីប្រាកដជាជាប់អាល័យពីលោកនេះ មែនឬ? និស្ស័យកម្មបច្ចុប្បន្នពិតជាត្រូវបានរំងាប់ចិត្តដោយការមិនបាន គិតពិចារណាឱ្យបានច្បាស់លាស់នោះទេ ចៅអាចរៀនសូត្រស្តាប់ធម៌ នៅក្រៅវត្តបានជាធម្មតា ព្រោះដូនជីបួសនៅក្មេងច្រើនតែចំណាយពាក្យ ញាតិថាបួសគេចស្នេហា បួសព្រោះត្រូវប្រុសបោះបង់ចោលជាដើម។ រឿងនេះពេលខ្លះអាចជាការធ្វើបាបចិត្តខ្លួនឯងផងក៏មាន មុំបានពោល កាត់សង្ឃដីកា៖ ខ្ញុំកូណាបានពិនិត្យច្បាស់លាស់អស់ហើយ ព្រោះ ឃើញគំនរទុក្ខច្បាស់ ពាល់ត្រូវដោយចិត្តចាក់ធ្លុះដោយបញ្ញា មិនមែន

ជាការធ្វើលេងទេ សូមលោកតាមេត្តាអនុគ្រោះផង។ លោកតាពិនិត្យ
មើលទឹកមុខស្ងួតស្ងប់របស់នាងដោយយកចិត្តទុកដាក់ រួចពោលថា៖
ណ្ហើយ! អញ្ចឹង ចាំអាត្មានាំនាងទៅផ្ទើនឹងដូចជីខន្តី ឱ្យរៀនធម៌វិន័យនឹង
គេចុះ។ មុំត្រេកអរណាស់ នាងបានផ្តាំផ្ញើទុកដាក់កិច្ចការទាំងអស់នឹង
មីងស៊ុមយ៉ាងសំងាត់រួចមកហើយ មិនមានអ្វីត្រូវអាល័យទៀតឡើយ
នាងទាញបង្វែចដែលបានរៀបចំរួចជាស្រេច ហើយចេញដំណើរយ៉ាង
ស្រគត់ស្រគំ តាមក្រោយលោកដូចជាដូនជីមានវស្សាមួយរយដូច្នោះដែ
រ។ ពេលចូលដល់ក្នុងវត្ត លោកតានិមន្តបង្ហួសទៅកុដិដូនជីខន្តី ហើយ
គង់ចំមុខកុដិ ដូចជីបានឃើញទាន់ក៏ស្ទុះម្ដីម្នាមកអង្គុយប្រណម្យអង្គលី
ហើយពោល៖ គុណម្ចាស់មានកិច្ចការអ្វីឬព្រះអង្គ? លោកតាញញឹម
បន្តិចក៏ពោល៖ អាត្មាសុំផ្ញើចៅស្រីម្នាក់នេះ នាងឈ្មោះមុំជាក្មេងកំព្រា
ឱ្យបាននៅជាមួយយាយបានរៀនធម៌វិន័យ សូមយាយជួយណែនាំផ
ង។ លោកយាយញញឹមបន្តិច ព្រមទាំងចោលកន្ទុយភ្នែកមើលមុំហើយ
ពោល៖ កូណាគុណម្ចាស់! លោកតាក៏និមន្តទៅកុដិលោកវិញទៅ។
លោកយាយបានហៅមុំឱ្យចូលក្នុងអាស្រម ព្រមទាំងបានចង្អុលប្រាប់ទី
កន្លែងផ្សេងៗនិងកិច្ចការទាំងឡាយដែលគួរ ឬមិនគួរចំពោះនាងចប់

សព្វគ្រប់ លោកយាយក៏បានរៀបចំទីកន្លែងសម្រាកនាវេលាថ្ងៃ ក្រោយពីបានដឹងថាមុំបានស្រស់ស្រូបអាហាររួចហើយ។

វេលាគួរដល់ការសំណេះសំណាល ដើម្បីឱ្យបានស្គាល់ចិត្តថ្លើមគ្នាបានមកដល់ លោកយាយក្រោយពីបានស្តាប់រឿងរ៉ាវរបស់មុំចប់សព្វគ្រប់ គាត់បានអារកាត់ឱ្យនាងប្រឹងប្រែងរៀនធម៌និងស្តាប់ធម៌កុំបីមានការធ្វេសប្រហែសឡើយ។ មុំបានទទួលយកទុកក្នុងចិត្តដោយក្តីគោរពជាទីបំផុត លុះពេលព្រលប់មកដល់ លោកយាយនិងមុំបាននាំគ្នាសូត្របទនមស្ការចំពោះព្រះរតនត្រ័យដោយក្តីគោរព។ លុះសូត្រចប់មុំនាងមានអារម្មណ៍កក់ក្តៅជាខ្លាំង ហាក់បីដូចជាបានជួបម្តាយម្នាក់ទៀត នាងចេះតែលួចគយគន់រាងរៅ និងឥរិយាបទរបស់ស្ត្រីចំណាស់ម្នាក់នេះដោយការស្ញើចសរសើរអស់ពីពោះចំពោះគុណធម៌ និងភាពស្មោះត្រង់ឥតលាក់លៀមយ៉ាងសាមញ្ញរបស់គាត់។ ដោយអត់ទ្រាំមិនបាន មុំក៏ភ្លាយមាត់សួរលោកយាយ៖ ខ្ញុំសុំទោសផងលោកយាយបើមិនយល់ទាស់ទេ សូមលោកយាយមេត្តានិទានពីប្រវត្តិលោកយាយឱ្យចៅដឹងផង។ លោកយាយងាកមកញញឹមដាក់បន្តិច រួចគាត់បែរទៅរៀបចំដំណេក ហើយទំរេតខ្នងយឺតៗសំរាន្តហើយយកដៃគងថ្ងាសសំលឹង

មើលដំបូលខ្ទមភ្លឺៗ ហាក់ដូចជាមិនចង់រើគាស់កកាយគំនរឿងរ៉ាវចាស់ៗនោះឱ្យកក្រើកឡើងមកវិញឡើយ។ គាត់បន្ទរដង្ហើមធំមួយយ៉ាងវែង រួចពោលថា៖ អតីតកាលវាកន្លងហួសអស់ទៅហើយ ឱ្យវារលត់ផុតអស់ទៅចុះ មិនគួររំលឹកឡើងវិញទេ ព្រោះវាគ្មាននាំឱ្យយើងបានសម្រេចមគ្គផងឡើយ ការធ្វើជីវិតឱ្យជាប់ចំណងអតីតកាលដែលជិតដាមដោយស្នាមអនុស្សាវរីយ៍ជូរចត់នោះ ចានាំឱ្យរំជួលចិត្តឥតប្រយោជន៍ទេ ជីវិតយាយសព្វថ្ងៃ គឺព្រះលោកស្រង់យកឡើងមកអំពីសេចក្តីស្លាប់ដែលជាសេចក្តីស្លាប់ឥតធម៌ ស្លាប់ស្មើតែដូចសត្វតិរិច្ឆានដូច្នេះឯង មិនគួររំលឹកឡើងវិញឡើយ។ សំដីនេះនាំឱ្យម៉ុំរឹងរឹតតែមានចំងល់ទ្វេឡើង នាងរំកិលខ្លួនទៅក្បែរលោកយាយ ហើយពោលលួងលោម៖ ជំរៅសមុទ្ទជ្រៅរាក់ខុសៗគ្នា ជំរៅទុក្ខរបស់សត្វលោកក៏មិនខុសពីជំរៅសមុទ្ទនោះដែរ ភាពខុសគ្នានេះ គឺអាស្រ័យលើបញ្ញាស្មារតីនឹងការប្រកាន់រៀងៗខ្លួនតែប៉ុណ្ណោះ។ ជីវិតមនុស្សគ្រប់រូបកើតឡើងមកបានគឺដោយសារតែ **រាគៈ ទោសៈ មោហៈ និងទិដ្ឋិ មានៈ តណ្ហា ឧបាទាន** ការប្រកាន់មាំតាំងពីអតីតជាតិមកម្លេះ ទើបបានជាមនុស្សចេះតែជួបរលកបញ្ហា និងការទាស់ចិត្តដែលជាហេតុនៃទំនាស់ បើអស់អកុសលចិត្តអស់នេះហើយ

ម្លេះសមសត្វលោកមិនមានទុក្ខសោកកើតឡើងឡើយ។ ម្នាក់ៗបើមានវាសនាគឺទាល់តែបានជួបធម៌ទើបបានចេះដឹងខុសត្រូវល្អអាក្រក់ ចេះដឹងគុណទោសរបស់ចិត្ត ដឹងថាចិត្តអាក្រក់របស់ខ្លួនគឺបានត្រឹមតែបំផ្លាញជីវិតខ្លួនឯង ទើបបានចេះនាំគ្នាខំលះជំរះចិត្តមិនល្អនោះចោលចេញដើម្បីឱ្យបានដល់ទីបំផុតទុក្ខ រឿងអាក្រក់ល្អពីអតីតកាលបើយើងកុំតែជំពាក់ចិត្តលើវាតើមានអ្វីត្រូវឈឺចាប់ ពេលខ្លះវាអាចជាប្រយោជន៍តាមជួយរំលឹក កុំឱ្យយើងប្រព្រឹត្តិខុសនៅបច្ចុប្បន្នកាលនេះទៀតផង។ ស្តាប់មុំនិយាយដូចសមហេតុផល លោកយាយក៏ចាប់បង្ហូរវាចាៈ របប ប៉ុល ពត បានរលត់ផុតទៅ មនុស្សក្រោយពីស្រងល់លែងចង់មាន ចង់បានអស់មួយស្របក់ ស្រាប់តែសេចក្តីលោភលន់នេះឆាបឆេះកើតឡើងមកវិញ កើតម្តងនេះគឺមានកំលាំងខ្លាំងក្លាជាទីបំផុត គេនាំគ្នាចូលព្រៃកាប់ឈើលក់សម្លាប់សត្វព្រៃ ជួបអីឱ្យតែមានប្រយោជន៍អាចរកលុយបានគឺគេស្រវាស្រទេញអោបក្រសោបយកទាំងអស់ ទីបំផុតវាបានក្លាយជាការបំផ្លិចបំផ្លាញដ៏ធ្ងន់ធ្ងរសម្រាប់ប្រទេសជាតិ។ អ្នកតូចបំផ្លាញតាមរបៀបអ្នកតូច អ្នកធំបំផ្លាញតាមរបៀបអ្នកធំ ចំណែកខេត្តបាត់ដំបងមិនសូវមានព្រៃកាប់នឹងគេ តែបែរជាមានមនុស្សមកសឹងពីគ្រប់

ខេត្តសំរុកចូលតំបន់បរប៉ៃលិន រុករកត្បូងធម្មជាតិរបស់ខ្មែរដែលមានតម្លៃបំផុតក្នុងលោកដូចជា ត្បូងកណ្តៀងពណ៌ខៀវ និងត្បូងទន្ទឹមពណ៌ក្រហម ត្បូងពេជ្រពណ៌សជាដើម។ ក្នុងសណ្តោរុករកត្បូង ដោយសារតែលុយ បងប្អូនបង្កើតវាយសំពងក្បាល សម្លាប់គ្នានឹងត្បូងចបក៏មានចាប់ភ្លើយក្បាលអារកគ្នាក៏មាន ល្បិចពាលសុីពាលកើតទាំងយប់ថ្ងៃឥតស្រាកស្រាន្ត។ ឃើញការមានបានក្រឡាប់ចាក់សឹងជឿមិនបានយ៉ាងនេះ ចឹកស្រែងអាងខ្លួនចេះភាសាយួនអាចប្រើការបាន ឃើញឱកាសល្អក៏លបសហការជាមួយកងទ័ពយួនឱ្យវាយយកដីត្បូងពេជ្រ គាត់ជាអ្នកជំហរម្ហូបអាហារថ្លៃឈ្នួលកម្មករ និងឧបករណ៍សម្រាប់ជីករុករកត្បូងពឹងកងទ័ពយួនជាបង្អែក ប្រាក់ដើមប្រើប្រាស់កាន់តែមានចំនួនច្រើនឡើងៗ អស់លុយខ្លួនឯងហើយត្រូវទៅខ្ចីបុលបងប្អូនញាតិមិត្តអស់រាប់ពាន់តំឡឹងមាសទៀត។ ទីបំផុតគ្រាប់ត្បូងដែលប្រមូលបានរាប់គីឡូត្រូវសម្រេចនាំយកទៅលក់នៅស្រុកថៃ ដឹកនាំដោយមេបញ្ជាការយួន។ មួយថ្ងៃ ពីរថ្ងៃ មួយអាទិត្យ កន្លះខែបាត់ដំណឹងសូន្យឈឹងលែងឃើញស្រមោលយួននោះត្រឡប់មកវិញ ចឹកស្រែងអស់សង្ឃឹមរលីង ដំណឹងនេះបានលេចលឺមកដល់ខេត្ត ម្ចាស់បំណុលទាំងអស់បាននាំគ្នាសំរុក

ចូលរឹបអូសយកឥវ៉ាន់ក្នុងផ្ទះអស់ខ្ទេចខ្ទី សូម្បីតែតុកៅអីតូចមួយមិនសល់ ម្ចាស់លុយធំយកច្រើនទាំងផ្ទះ ដីប៉ុន្មានកន្លែងក៏អស់តមានសេសល់។ ចឹកស្រែងធ្លាក់ខ្លួនដើរធឹកស្រាយវង្វែងឡប់សតិស្មារតីអស់ឯនាងប្រពន្ធទប់ទល់នឹងការធ្លាក់ខ្លួនយ៉ាងគំហុកបែបនេះមិនបាន ទីបំផុតក៏ជ្រើសរើសយកផ្លូវរួចខ្លួនមួយ គឺទៅដេកទទឹងផ្លូវរថភ្លើង ដើម្បីឱ្យរថភ្លើងជាន់ដាច់ជាកំណាត់ៗ ដើម្បីបញ្ចប់ទុក្ខ។ កំពុងតែដេកបង្ហូរទឹកភ្នែកភាវនាធម៌ ស្រាប់តែមានព្រះសង្ឃចាស់មួយអង្គទៅគង់ក្បែរមានពុទ្ធដីកាយ៉ាងស្រទន់ថា៖ មានការអីទោញោមបានជាសម្រេចចិត្តយ៉ាងដូចឆ្នេះ? បើជីវិតនេះត្រូវកំទេចចោលដដែលទេ ហេតុនេះសូមឱ្យអាត្មាបិណ្ឌបាតមកចុះ សូមញោមដាក់ចិត្តថាដូចជាបានស្លាប់បាត់ពីលោកនេះទៅហើយ អំពីពេលដែលអាត្មាបិណ្ឌបាតហើយញោមត្រូវរក្សាចិត្តជាមនុស្សថ្មីដែលលែងចាំរឿងរ៉ាវអតីតកាលទាំងអស់ សូម្បីតែជួបអ្នកណាម្នាក់ក៏មិនត្រូវតក់ស្លុតភ័យខ្លាច ហើយចូរមានស្មារតីរក្សាភាពស្ងៀមស្ងាត់ឱ្យបានជានិច្ច បើមានការរំខានខ្លាំងចូរឱ្យគេមកជួបអាត្មាចុះ កុំបារម្ភឡើយ។ បើទោះជាលោកខំពោលពាក្យយ៉ាងណាក៏នាងនៅសំងំស្ងៀកស្ងឹង ព្រោះចិត្តនាងបានស្លាប់បាត់ទៅហើយ នាងគ្មានកំលាំងកំរើក

ដៃជើង សូម្បីតែការនិយាយស្តីក៏នឹងរកពាក្យអ្វីមកនិយាយបានផង ជីវិតដែលធ្លាប់ថ្កុំថ្កើង ការរីករាយក្នុងការជួបជុំកូនចៅ មុខមាត់ដែលធ្លាប់គេគោរពរាប់អាន ឥឡូវនេះតែមួយប៉ព្រិចភ្នែកត្រូវវិនាសទៅជាផេះអស់។ ការក្លាយខ្លួនជាអ្នកសុំទានមិនជាការអ្វីទេ ប៉ុន្តែការប្រមាថមាក់ងាយដោយពាក្យសំដីនេះគឺស៊ូស្លាប់ល្អជាង។ លោកតាអង្គនោះប្រឹងពោលបន្តៈ សេចក្តីស្លាប់ចំពោះមនុស្សម្នាក់គ្មានអ្នកណាមានពីរដងឡើយ ចង់ស្លាប់ណាស់ក៏គង់តែនឹងស្លាប់ មិនចង់ស្លាប់សោះក៏គង់នឹងស្លាប់ ព្រោះកើតជាពូជអ្នកស្លាប់មិនមានអ្នកណាម្នាក់ជៀសរួចឡើយ សំខាន់នៅត្រង់ថា សេចក្តីស្លាប់នោះតើវាពិតជាអាចបញ្ចប់បញ្ហាបានពិតទេ? អ្នកចង់ស្លាប់ កាលបើបានស្លាប់តាមប្រាថ្នាហាក់ដូចជាវាបានរួចខ្លួន ប៉ុន្តែតើមានបានគិតដល់អ្នកនៅរស់ទេ? ចំពោះអ្នកដែលគេស្រលាញ់យើង តើគេរងទុក្ខឈឺចាប់ខ្លោចផ្សាប៉ុណ្ណាទៅ? គ្រួសារដែលមានប្រវត្តិសម្លាប់ខ្លួន តើសមរម្យចំពោះអ្នកដទៃទេ? ស្រាប់តែចិត្តនាងនោះនឹកឃើញដល់កូនតូចៗដែលមិនទាន់មានគ្រួសារ នឹកដល់កេរ្តិ៍ឈ្មោះកូនចៅ សេចក្តីអាល័យបានអង្រួនបេះដូងនាង ធ្វើឱ្យនាងបើកភ្នែកសំលឹងលោកនេះសាជាថ្មីម្តងទៀត នាងបានបន្លឺវាចាយ៉ាងក្រៀមក្រំថាៈ តើឱ្យ

ខ្ញុំកូណាធ្វើអ្វីកើត ខ្ញុំកូណាវិនាសអស់ហើយ វិនាសអ្វីខ្លះទៅញោម? តើមានអ្នកណាអាចស្លាប់យកទ្រព្យទៅតាមបានឬ ទើបញោមត្រូវវិនាសតែឯង? (លោកសួរផ្ទាន់) បាត់បង់ទ្រព្យសម្បត្តិមិនស្មើបាត់បង់កិត្តិយស បាត់បង់កិត្តិយសមិនស្មើបាត់បង់ការតស៊ូ បាត់បង់ការតស៊ូឈ្មោះថាជាការបាត់បង់នូវអ្វីៗទាំងអស់។ តស៊ូស្វែងរកទ្រព្យមិនស្មើនឹងការតស៊ូស្វែងរកកិត្តិយស ការតស៊ូទាំងពីរសូម្បីលំបាកដល់ម្តឹងក៏ឈ្មោះថាជាការតស៊ូស្វែងរកខ្លួនឯង ស្វែងរកច្រកចេញពីចំណងជីវិត ខ្វះអីអំពើល្ងង់ខ្លៅដែលដែលមនុស្សដាក់ទោសខ្លួនឯង មួយថ្ងៃៗមិនមែនញោមមិនដឹងឯណា អ្នកចងក អ្នកលោតទឹកសម្លាប់ខ្លួនពីលើស្ពានខ្ពស់ៗ អ្នកចាក់សាំងដុតខ្លួន លេបថ្នាំសម្លាប់ខ្លួនអីជាដើម តើពពួកជនគេបានពោលថាម៉េចខ្លះ? បើយកទៅពេទ្យត្រូវពួកពេទ្យគេជេរថា បើវាចង់ងាប់ហើយ ម៉េចមិនឱ្យវាងាប់ទៅ យកមកនាំរំខានគេឯងខានដេកពួនអស់ ខំជួយឱ្យវារស់ក៏វាគ្មានអរគុណអីឯងដែរ ជួយវានាំតែមានបាបដល់ខ្លួនទៀត ព្រោះបានប្រឆាំងនឹងការចង់ងាប់របស់វា។ បើស្លាប់តាមចិញ្ចើមថ្នល់ ឬតាមទឹក គេមានតែស្តោះទឹកមាត់ខ្ពើមឆ្អើមតែប៉ុណ្ណោះ សភាវៈល្អអាក្រក់ គឺមិនមែននៅខាងក្រៅទេ គឺនៅក្នុងចិត្តយើងជាអ្នកគិត ដែល

ចេះតែគិតឱ្យឃើញថាមានល្អអាក្រក់មានប្រណីតឧត្តុងឧត្តម មានថោកទាបទៅតាមការយល់ឃើញផ្ទាល់ខ្លួន ហេតុនេះសុខទុក្ខ ទើសទាស់នឿយណាយ ជិនឆ្អន់ថ្នាំងថ្នាក់គាប់មិនគាប់នឹងរបស់ខាងក្រៅ គឺសុទ្ធតែមកពីចិត្តយើងជាអ្នកគិតទាំងអស់មិនមែនបិតនៅក្នុងរឿងខាងក្រៅទាំងស្រុងទេ? តែខ្ញុំកូណាត្រូវជំពាក់គេ សូម្បីតែជីវិតក៏សងពុំរួច មិនមែនថាខ្ញុំកូណាចង់ស្លាប់ព្រោះទាស់ចិត្តអ្វីនោះឡើយ។ (នាងនោះតប) ។ អើហ៎! មានយ៉ាងណាក៏គង់នឹងស្លាប់ ក្រយ៉ាងណាក៏គង់នឹងស្លាប់ ជីវិតចប់ត្រឹមតែស្លាប់ កុំតែញោមតាំងចិត្តថាមិនសងគេ បើញោមនៅតែតាំងចិត្តសងនោះញោមគ្មានអ្វីខុសឡើយ ប៉ុន្តែឥឡូវនេះញោមនៅសល់តែជីវិតមួយ ហេតុនេះបើអ្នកណាគេនៅចង់បានទៀត ក៏ឱ្យគេមកយកទៅចុះ កុំតែញោមនាំយកជីវិតនេះទៅដោយខ្លួនឯងនោះ គឺខុសហើយទុក្ខឱ្យកម្មនិយាមមកយកដោយខ្លួនឯងចុះ នេះវាត្រឹមត្រូវជាង ជីវិតលំបាកគឺមកតែពីយើងគិតឱ្យលំបាកទេ ក្នុងលោកនេះគ្មានអ្វីដែលយើងមិនអាចដោះស្រាយបានឡើយ ព្រះលោកត្រាស់ថា លោកនេះទុក្ខមានពិត ហេតុនាំឱ្យកើតទុក្ខមានពិត ទុក្ខទាំងអស់ឬបញ្ហាទាំងអស់សុទ្ធតែអាចដោះស្រាយបាន មានវិធីដោះស្រាយបញ្ហាទុក្ខយ៉ាងពិតប្រាកដ។

ញោមគួរតែបានស្រាវជ្រាវពីបញ្ហានេះសាកលមើលម្តងចុះ សូមញោម លើកលែងទោសឱ្យខ្លួនឯងម្តងសិន ដើម្បីអាចសម្រេចកិច្ចការនោះបាន ជឿសំដីអាត្មាម្តងទៅ ព្រះលោកមិនដែលធ្វើឱ្យសត្វលោកណាខកចិត្ត ចំពោះការប្រៀនប្រដៅរបស់ព្រះអង្គម្តងណាឡើយ ឱ្យតែយើងបានដាក់ចិត្តទំលាក់មានះ ហើយព្រមស្តាប់តាមការពន្យល់នោះឱ្យបានត្រឹមត្រូវ នោះនិព្វានជាទីស្ងប់រំងាប់ នឹងប្រាកដមានឡើងដល់យើងជាមិនខាន។ សូមញោមទុកផ្លូវរស់ឱ្យខ្លួនឯងផង ទុករយៈពេលឱ្យជីវិតស្វែងរកការពិត បានមួយរយៈខ្លី ហើយសឹមសម្លាប់វាវិញក៏មិនជាយឺតពេលអីប៉ុន្មានដែរ ចាំពេលនោះទុកឱ្យអាត្មាជាអ្នកធ្វើបុណ្យចំលងបាបកម្មនេះឱ្យក៏បានដែរ មកចូរក្រោកឡើងហើយមានសតិស្មារតីឡើងវិញ សេចក្តីស្លាប់មិនបាច់ចង់ទេព្រោះវាគង់តែមកដល់ជាមិនខានមិនបាច់ទន្ទឹមរងចាំវាឡើយ សូម្បីតែព្រះលោកមានរិទ្ធិចេស្តាបារមីដល់ម្ល៉ោះគង់កន្លងការវិនាសនេះមិនបាន ចុះទំរាំជនថយថោកដូចជាពួកយើងតើអាចកន្លងក្តីវិនាសនេះម្តេចបាន? មក! បើញោមព្រួយពីអាហារ កុំបារម្ភឡើយ បាយសល់ពីបាតលោកគង់សមល្មមនឹងអាចសម្រន់ក្តីស្រេកឃ្លានបានទេ ហើយតើចាំបាច់ត្រូវព្រួយពីអ្វីទៀត បើយើងជាអ្នកប្តេជ្ញាថានឹងស្លាប់សោះហ្នឹង?

ស្ត្រីនោះបានចុះចាញ់ចំពោះថាមពលចិត្តមេត្តារបស់លោក នាងក្រោកបោសគូថហើយយកជាយអាវជូតផ្តិតទឹកភ្នែកចេញពីរង្វង់កែវភ្នែក ដោយកាយវិការមួយៗគួរឱ្យអាសូរ។ ពួកគេដើរចេញពីទីពិឃាតបានប្រមាណ១០ម៉ែត្រ ក្បាលរថភ្លើងក៏បានមកដល់ហើយរថយ៉ាងលឿនហួសផុតទៅ នាងបែរមើលកន្លែងដេកហើយនឹងក្នុងចិត្តថា បើកុំតែមានលោកម្ល៉េះរូបនេះត្រូវក្លាយជារូបបីកំណាត់លាចាកលោកនេះបាត់ទៅហើយ។ កំពុងគិតបណ្តើរដើរបណ្តើរ លោកតាក៏ប្រទានឱវាទបន្តទៀតៈ មាតាបិតាគ្រប់រូបខំបង្កើតបុត្រគឺដោយក្តីអាណិតស្រលាញ់សុទ្ធសាធ ហើយចង់ឱ្យកូនបានរស់មានសេចក្តីសុខ មានភាពថ្លៃថ្នូរ បើស្លាប់ក៏ស្លាប់តាមបែបជាមនុស្ស កុំស្លាប់ដូចជាសត្វធាតុ អំណឹះពីថ្ងៃនេះទៅសូមញោមប្រឹងប្រែងពិនិត្យអង្កេតមើលដំណើរធម្មជាតិតើដូចម្តេច ពិនិត្យរាវរកសេចក្តីពិតក្នុងខ្លួនឯងឱ្យបានឃើញជាក់ច្បាស់ប្រាកដ កុំរស់ផ្តោតចិត្តទៅកាន់រឿងរ៉ាវខាងក្រៅខ្លួនឱ្យសោះ ទាន់ផែនដីមិនទាន់ក្លាយជាភ្នក់ភ្លើង ហើយទាន់ព្រះធម៌ដែលជាការប្រៀនប្រដៅរបស់ព្រះពុទ្ធនៅគង់វង់បរិសុទ្ធដូចដើម ចូរខំរំដោះជីវិតឱ្យបានរួចផុតចាកទុក្ខដោយខ្លួនឯង ឥឡូវដល់វត្តហើយអាត្មាសូមដាក់នាមថ្មីឱ្យញោមហៅថា ញោមខ

ន្តីទៅចុះ។ នោះអាស្រមចូរញោមបោសសំអាតហើយស្នាក់នៅ បន្តិច ទៀតអាត្មាឱ្យក្មេងយកសំពត់សខ្លះមកឱ្យប្រើប្រាស់។ មុំភ្ញាក់ព្រើត តាម ពិតប្រវត្តិលោកយាយខន្តីក៏មិនមែនជារឿងសាមញ្ញប៉ុន្មានដែរ នាងដក ដង្ហើមធំយូរហើយបន្តសួរថា៖ តើជីវិតលោកយាយក្នុងវត្តអារាមនេះមាន សុខទុក្ខម្តេចដែរ? លោកយាយឆ្លើយតបដោយស្ងួតស្ងប់៖ ទីណាមាន មនុស្ស ទីនោះមានទិដ្ឋិ ការយល់ឃើញរបស់មនុស្សគឺមិនអាចដូចគ្នា អាចមានត្រឹមតែការយល់ស្រប ទីណាមានព្រះទីនោះមានមារ ហេតុនេះ កុំឃើញកន្លែងស្ងប់ស្ងាត់ថាគ្មានបញ្ហាឱ្យសោះ ព្រះធម៌បើមិនបានចូល ឱ្យដល់ការពិតទេ នោះមនុស្សគឺនៅតែជាមនុស្សដែលខ្លះត្រូវរហេម រហាមតាមផ្លូវចិត្ត ខ្លះបិសាចយក្សមារពេញក្នុងខ្លួនជាធម្មតា ប៉ុន្តែទាំង អស់នេះ គឺសុទ្ធតែជាធម៌ដែលយើងត្រូវខំហាត់រៀនពីវាឱ្យបានសព្វគ្រប់ យាយៗស្លៀកពាក់សសុទ្ធមិនមែនចិត្តគាត់ក៏សល្អបរិសុទ្ធ ម៉ត់ហ្មងទាំង អស់ដែរនោះទេ ពួកសទាំងនោះក៏មានចែកបក្សពួកដែរទៅតាមគុណ ភាពសាច់ក្រណាត់ ក្រណាត់សល្អខ្លះ គឺមកនៅវត្តព្រោះតែទើសទាស់ ជាមួយកូនមិនអាចនៅផ្ទះបាន ហេតុនេះមកវត្តគឺត្រឹមតែមកនៅសន្សំ រឿងជាមួយគេឯង មកអង្គុយវាយតម្លៃរិះគន់បន្ទាបបន្ថោកគេឯងគ្រប់គ្នា

សខ្លះទៀតគឺធ្វើដូចជាសំរួមល្អមិននិយាយរកអ្នកក្រទេ ប៉ុន្តែឱ្យតែឃើញគេមានគឺរាក់ទាក់ ផ្អែមរលួយដល់ឆ្អឹង នេះពួកយាយសគឺនៅមានច្រើនប្រភេទទៀតណាស់ ឯតាៗក៏ដូចគ្នា ម៉្លេៗកាច់កុងគ្នាតែរឿងតាមលោកដើរសូត្រមន្ត បើឃើញអ្នកក្រមកនិមន្តលោក ធ្វើដើរហួសដូចជាមើលមិនឃើញ បើឃើញអ្នកមានមកស្រែកសួររាក់ទាក់ដូចធ្លាប់ស្គាល់ដប់ជាតិមកហើយអញ្ចឹង។ ប៉ុន្តែមុំហ្អា! មកនៅវត្តចូរឯងកុំមើលគេ ចូរយកភ្នែកមើលតែធម៌ សិក្សាពីជីវិតសត្វអស់នោះឱ្យបានត្រឹមតែជាសភាវៈធម្មជាតិ ចូរមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹកយើងមកនៅវត្តរក្សាសីល មិនមែនមកប្រារព្ធចំពោះបុគ្គលអស់នោះទេឡើយ គឺប្រារព្ធចំពោះព្រះរតនត្រ័យទេ អ្នកនៅត្រែកអរនឹងរូប នឹងសំលេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ នៅរីករាយភ្លើតភ្លើននឹងបញ្ចកាមគុណ មានន័យថាគឺគេពេញចិត្តនឹងវដ្ត បើគេពេញចិត្តហើយឱ្យគេចុះ ព្រោះនេះជាសិទ្ធិរបស់គេទេ លោកនេះគឺជាកម្មសិទ្ធិរបស់មនុស្សគ្រប់រូប សត្វលោករមែងប្រព្រឹត្តិទៅតាមកម្មរៀងៗខ្លួន ដូច្នេះឯង។ ចំពោះលោកសង្ឃវិញ លោកកំលោះៗអស់នោះក៏ជាមនុស្សដែរ ទាំងជាមនុស្សកំលោះពេញកំលាំងទៀត ហេតុនេះតើមានខុសអីពីកំលោះតាមភូមិ លើកលែងតែ

លោកខ្លះដែលលោកបួសសដោយសទ្ធា **សីលៈ សុតៈ ហិរឧត្តប្បៈ ចាគៈ និងបញ្ញា** លោកប្រគេននេះទើបជាមនុស្សដែលខំហ្វឹកហាត់ដុសខាត់ សំអាតចិត្តគួរដល់នូវការគោរពបូជា។ នៅថ្ងៃទី២ ខែមីនា ឆ្នាំ ២០១២ យាយបានស្តាប់វិទ្យុអាស៊ីសេរីគេផ្សាយថា មានក្មេងស្រីនៅកំពុងធំបានលបទៅធ្វើការនៅស្រុកថៃមានចំនួន៤នាក់ ពេលដែលតំរួតថៃតាមឆែកឆេររកមើលសំបុត្រស្នាម រកលិខិតស្នាក់នៅជាអន្តោប្រវេសន៍ ពួកនាងបាត់រត់គេចខ្លួនទៅបាងកកស្រាប់តែបានជួបលោកសង្ឃខ្មែរ ពួកនាងត្រេកអរដូចបានកើតជាថ្មី ព្រោះបានលោកនាំយកទៅពួនសំងំស្នាក់នៅក្នុងកុដិលោក ដោយលោកឱ្យសម្រាកបែកគ្នា លុះវេលាកណ្តាលអាធ្រាត្រលោកនោះបានចាប់រំលោភនាងក្មេងម្នាក់ដោយគំរាមសម្លាប់បើនាងប្រាប់គេ រហូតពួកនាងបានលួចរត់ត្រឡប់មកស្រុកវិញ។ មើលចោះ! ហេតុនេះឯងកុំឃើញមនុស្សនៅក្នុងស្បង់នោះថាជាទេវតាឱ្យសោះ ព្រោះក្នុងស្បង់នោះគឺជារាងកាយរបស់មនុស្សសុទ្ធសាធ មានសាច់មានឈាមនិងឆ្អឹងមានរាគៈដូចគេឯងជាធម្មតាទេ ពេលយប់តណ្តាខ្វាក់មិនអាចមើលឃើញអ្វីឡើយ។ ហេតុនេះចូរកុំនិយាយស្និទ្ធស្នាលនឹងលោកណាឱ្យសោះ ថ្វីត្បិតតែព្រះពុទ្ធលោកបានហាម

លោកកំលោះអស់នោះថា ចូរកុំនិយាយប្រាស្រ័យទាក់ទងនឹងមាតុគ្រាម បើនិយាយត្រូវចាត់ទុក្ខនាងជាម្តាយ ជាបងស្រី ជាប្អូនស្រី មិនត្រូវស្និតស្នាលជាដាច់ខាតយ៉ាងនេះក៏ដោយ ប៉ុន្តែធម្មជាតិរបស់រាគៈនេះ គឺវាជាប់ស្អិតណាស់មនុស្សអាចមិនធ្វើអាក្រក់ដូចជាលួច សម្លាប់ កុហកអីបាន តែត្រង់ហ្នឹងមួយវាបែរជាយល់ថាអំពើល្អ ជាសេចក្តីសុខទៅវិញ ព្រោះធម្មជាតិរបស់រាងកាយមនុស្សវាជាគំនរអាតូមដែលមានធាតុញី ឈ្មោល ជាហេតុអគ្គិសនីសុទ្ធសាធ វាតែងតែស្រូបទាញចូលគ្នារវាងធាតុញីនិងឈ្មោល តោងស្អិតជាប់គ្នាដោយមិនដឹងខ្លួន ដែលយើងត្រូវមានសតិកំណត់ដឹងឱ្យបានច្បាស់ប្រាកដ។ សង្គមលោកសង្ឃនេះវារឹតតែត្រូវប៉ាន់ទៅទៀត ចំពោះមនុស្សប្រុសស្រលាញ់ភេទដូចគ្នា គឺចំម៉ាច់តែម្តងដែលលោកនៅសំងំប្រព្រឹត្តិអំពើអានាចារធ្វើបាបនេនៗ ប៉ុន្តែមុំអើយ នាងកុំមើលអំពើចោកទាបរបស់មនុស្សក្បាលខ្មៅអី ចូរមើលព្រះធម៌ មើលត្រឹមតែស្បង់លោកដែលជាទង់ព្រះអរហន្ត សូម្បីព្រះសម្មាសម្ពុទ្ធ ព្រះអរិយសាវ័កក៏លោកធ្លាប់បានគ្រងដណ្តប់កាយ ហើយការប្រៀនប្រដៅរបស់លោកសុទ្ធតែជាស្ពានចំលងសត្វឱ្យផុតនរកអវចីប្រេតតិរច្ឆាន និងអសុរកាយបាន ហេតុនេះកុំទៅទើសទាស់អីជាមួយ

មនុស្សអស់នោះ កម្មអ្នកណាធ្វើអ្នកហ្នឹងទទួលទេ ដូចជាលោកខិលខូច ដែលមកស្នាក់នៅវត្តស្រះចកនៅឆ្នាំ២០០៨ លួចតាំងកាមេរ៉ាចាំថតរូបភាពគេផ្លាស់សំពត់ក្នុងបន្ទប់ទឹក ត្រូវប៉ូលិសវ៉ៃខ្នោះដៃនាំចូលគុកព្រៃសបាត់ទៅ។ មនុស្សទាំងអស់ឱ្យតែនៅជាអន្ធបថុជ្ជនគឺនៅតែមានកំហុសជាធម្មតា ថ្វីត្បិតតែមានរាងកាយជាមនុស្សតែចិត្តដូចជាប្រេតនរកតិរច្ឆានជាធម្មតាទេ ព្រោះមនុស្សព្រះលោកចែកជា៥ប្រភេទគឺ **មនុស្សនរក (នារយិកោ) មនុស្សប្រេត (សបេតោ) មនុស្សតិរិច្ឆានោ មនុស្សមនុស្សោ (មនុស្សធម្មតា) និង មនុស្សទេវោ** ជាមនុស្សមានសីលមានទានជាដើម។ មនុស្សទាំងអស់ឱ្យតែមានការកសាងខ្លួនទៅអនាគតជាតិ គឺគង់តែបានសម្រេចមគ្គផលជាធម្មតាទេ សូម្បីភិក្ខុទេវទត្តក៏គង់នឹងបានសម្រេចជាព្រះបច្ចេកពុទ្ធមួយអង្គនៅកប្បខាងមុខនឹងគេដែរ។ អើហ៍មុំយប់ជ្រៅណាស់ហើយ លួមសម្រាកទៅ ទុកកំលាំងរៀនធម៌និងបោសសំអាតវត្តក្នុងថ្ងៃស្អែកទៀត គ្មានអ្វីធ្វើបុណ្យនឹងគេ ថែទាំចិត្តឱ្យល្អនេះព្រះលោកហៅថាគឺ ជាកំពូលបុណ្យដ៏ធំធេងណាស់ក្នុងព្រះពុទ្ធសាសនាហើយ។ យើងបោសសំអាតវត្ត ថែទាំផ្កាសម្រាប់ជាទីឋានមនោរម្យគួរជាទីជ្រះថ្លាដល់ពពួកជនច្រើន ឱ្យគេបានសប្បាយរីករាយ

ពេលមកស្លាប់ធម៌លោកឪសម្តែងបានដោះទុក្ខចេញពីចិត្ត ឱ្យចិត្តរស់នៅបានស្គាល់សេចក្តីសុខពិតនោះបុណ្យយើងគឺធំណាស់ទៅហើយ។ សំលេងលោកយាយរង្វើយទៅៗរហូតលែងលឺទាំងស្រុង មុំនៅបើកភ្នែកភ្លឺៗសំលឹងដំបូលខ្ទមស្លឹក ដែលអាចមើលឃើញព្រាលៗ ដោយសារចំណាំងពន្លឺចង្កៀងពីមុខអាសនៈព្រះពុទ្ធរូប។ នាងនៅបន្តនឹកគិតត្រិះរិះតទៅទៀត ហឺ! មនុស្សគួរស្ងើចសរសើរបំផុតគឺពូកែដឹងចិត្តអ្នកដទៃ តែបែរជាអន់បំផុតព្រោះមិនដឹងចិត្តខ្លួនឯង សំណាងល្អណាស់ដែលមានព្រះធម៌ជាការសិក្សាពីចិត្តខ្លួនឯង ការស្គាល់ខ្លួនឯងគឺដើម្បីលើកស្ទួយដល់សន្តិសុខ។ មនុស្សគួរធ្វើតាមនូវអ្វីដែលខ្លួនបានប្រដៅគេ ហើយប្រាប់គេនូវអ្វីដែលខ្លួនធ្វើបានសម្រេច មិនគួរកប់ទុក ឬស្លាប់យកទៅតាមនូវពិសោធន៍ជីវិតដែលខ្លួនបានឆ្លងកាត់នោះឡើយ ម្រឹគអាងដើរ បក្សាអាងហើរ មច្ឆាអាងហែល សត្វលោកដើម្បីរស់បានសុខ គឺពឹងអាងទៅលើជំនាញរៀងៗខ្លួន គឺជំនាញនោះហើយដែលមិនគួរឱ្យក្លាយជាប្រភពនេះជំលោះ ប្រភពនៃការប្រមាថមាក់ងាយគ្នា គួរបានជាការចែករំលែកសុខទុក្ខក្នុងនាមជាមនុស្សដូចគ្នា រស់ក្នុងតម្លៃនៃជីវិតដែលមានសមធម៌គ្រប់ជាតិសាសន៍ព្រោះជីវិតដែលមានសោកនាដកម្មពិតប្រាកដ

គឺជាជីវិតដែលស្លាប់បាត់នូវអំពើល្អ **ជាមនុស្សស្លាប់ទាំងរស់** មានផ្លូវតែមួយគត់ដែលមនុស្សជាតិអាចរស់នៅគង់វង់បានលើផែនដីនេះគឺ ការដើរតាមគំនិតព្រះពុទ្ធសាសនា។ ត្របកភ្នែកមុំទន់ឡើងៗ ក៏គ្របគ្រាប់ភ្នែកឱ្យសម្រាក ឱ្យឈប់បានមើលឃើញអ្វីៗក្នុងលោកមួយរយៈដើម្បីបន្តយចរន្តគំនិតកុំឱ្យពុះពោរពេក។ ទុកចោលខ្នមសីលធម៌ឱ្យឈរយោងអាត្មានៅក្បែរទីធ្លារបងវត្តនៅក្រោមដំបូលមេឃដែលជះពន្លឺព្រិចៗ ដូចជាគេបានកំទេចពេជ្រឱ្យភ្លឺព្រោងព្រាត គួរឱ្យគយគន់ទេសភាពនារាត្រីកាល។

រូបំអនិច្ចំ	រូបំទុក្ខំ	រូបំអនត្តា
ព្រោះរូបមិនទៀង		ត្រូវសូន្យសង្ខារ
ពាក្យនេះថ្លៃថ្លា		ព្រោះជាពាក្យពិត
រូបណាមិនទៀង		សុខតែងតែល្អៀង
មិនមានសុខពិត		ទើបរូបជាទុក្ខ
មិនមានប្រឌិត		រូបមានទុក្ខពិត

សត្វគប្បីដឹង។

ពាក្យថាអនត្តា មិនមានរូបណា
ជារបស់ខ្លួន ព្រោះហេតុបច្ច័យ
ទុកដូចជាក្បួន រូបមិនមានខ្លួន
នៅក្រៅអំណាច។
បើនេះជាច្បាប់ ដែលកើតមានស្រាប់
សម្រាប់អត្តា ជនណាបានឃើញ
នឹងសុខកាយា លុះគ្រាមរណា
សង្ខារផុតទុក្ខ។

រាយនាមពុទ្ធបរិស័ទចូលរួមបច្ច័យសម្រាប់បោះពុម្ពសៀវភៅ

១- Chheam Phally	៣៥ ដុល្លារ
២- Theang Sokuntheavy	២០,០០០រៀល
៣- ឧបាសិកា **ឈឹម ឈីឆែ** និងស្វាមី ព្រមទាំងបុត្រនិងចៅ	១០,0000 រៀល
៤- វ៉ន់ ឡៃស្រេង	១០ ដុល្លារ
៥- ពុទ្ធបរិស័ទទូទៅ	២០,000 រៀល
៦- Maly Meta	១00,000 រៀល
៧- Leng Leap	១00 ដុល្លារ

ភ្នំពេញ ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែស្រាពណ៌ ឆ្នាំកុរ ឯកសក ព.ស ២៥៦៣

ភ្នំពេញ ថ្ងៃព្រហស្បតិ៍ ទី ១៥ ខែ សីហា ឆ្នាំ ២០១៩

និពន្ធដោយ វេជ្ជបណ្ឌិត ថោង នីដាមុនី

ចែកជូនជាធម្មទាន



ទំនាក់ទំនងតាមរយៈ:

សុះ កុសល ០១០ ៣៣ ៥៨ ៥៤

Facebook.com/សាលាធម្មសភាចំការត្របែក

Youtube.com/សាលាធម្មសភា ចំការត្របែក

https://chamkatrorbek.blogspot.com/

គណៈគ្រប់គ្រងសាលា